# យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះ

# នៃព្រះរាជាណាចក្រកម្ពុជា



ក្រសួងបរិស្ថាន

និងគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចំរុះ

Biodiversity the life of Cambodia

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# យុទ្ធសាស្ត្រ
# និងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះ

"ដើម្បីប្រើប្រាស់ ការពារ និងគ្រប់គ្រងជីវៈចំរុះ
សំរាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា"

រាជរដ្ឋាភិបាលកម្ពុជា

ខែ មេសា ឆ្នាំ ២០០២

ក្រសួងបរិស្ថាន / អង្គការ FAO/UNDP/GEF

គំរោង CMB/98/G33



Cambodia NBSAP Add-On Project
Contact : (855-23) 217 560
Email : cambio_coor@bigpond.com.kh
Website : www.biodiversity-kh.org

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

លេខ: ៧០៥ . សជណ . ខរ

*រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ ២០០២*

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជំរាបជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**កម្មវត្ថុ** : ករណីសំណើសុំការអនុញ្ញាតិសំរេចលើឯកសារយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះសំរាប់ព្រះរាជាណាចក្រកម្ពុជា ។

**យោង** : -លិខិតលេខ ២៣៤ ប.ស្ថ ស.ណ ចុះថ្ងៃទី ០៦ ខែ មិនា ឆ្នាំ ២០០២ របស់ក្រសួងបរិស្ថាន

-របាយការណ៍អង្គប្រជុំរបស់ក្រុមសង្កេតការណ៍ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ចុះថ្ងៃទី ១៨-មេសា-២០០២

-ចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១៧-០៥-២០០២

តបតាមកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជំរាបជូនឯកឧត្តមរដ្ឋមន្ត្រីជ្រាបថា : រាជរដ្ឋាភិបាលបានឯកភាពជាគោលការណ៍ លើឯកសារយុទ្ធសាស្ត្រ និង ផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះសំរាប់ព្រះរាជាណាចក្រកម្ពុជាតាមសំណើហើយ ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ ។ សូមឯកឧត្តមមេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**ជ.ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

រដ្ឋលេខាធិការ

**ស៊ុំ ម៉ានិត**

**ចម្លងជូន**

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
-ក្រសួងផែនការ
-គណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចំរុះ
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ឯកសារ-កាលប្បវត្តិ

សម្តេច **ហ៊ុន សែន**

*នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា*

# សារលិខិត

## របស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល កម្ពុជា គាំទ្រយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិ ស្តីពីជីវៈចំរុះ

ជាលើកទីមួយហើយ ក្នុងអំឡុងពេលជាច្រើនទសវត្សចុងក្រោយនេះ ដែលប្រជាជនកម្ពុជាអាចមានឱកាសដ៏ល្អប្រសើរបំផុត ក្នុងការទទួលបាននូវសន្តិភាពពេញលេញ ស្ថេរភាពនយោបាយ និងសន្តិសុខនៅទូទាំងប្រទេស ។ បច្ចុប្បន្នប្រទេសកម្ពុជា បានរួបរួមឯកភាពគ្នាជាថ្មី ក្នុងនាមជារដ្ឋឯករាជ្យមួយនៅក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល ដែលបានបង្កើតឡើង តាមការបោះឆ្នោតជាលក្ខណៈប្រជាធិបតេយ្យ ដោយពុំមានក្រុមឧទ្ទាម ឬក្រុមបំបែកខ្លួនទៀតឡើយ ។ យើងបានលុបបំបាត់ទាំងស្រុងនូវជំលោះផ្ទៃក្នុង ហើយយើងកំពុងរស់នៅក្នុងសន្តិភាព និងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជិតខាងនៅភូមិភាគអាស៊ីអាគ្នេយ៍ ។ អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ កំពុងតែត្រូវបាន អនុវត្ត ។ ការស្រុះស្រួលគ្នា និងការផ្សះផ្សារជាតិបាននាំឱ្យមានការបង្កើតជាមាគ៌ាឆ្ពោះទៅរកការស្តារនិង ការរីកចំរើនលូតលាស់ដោយនិរន្តរភាព ។

សហស្សវត្សថ្មីបានចូលមកដល់ ក្នុងនោះសហគមន៍អន្តរជាតិបានចាត់ទុកជាសត្សវត្សដើមនៃការការពារ និងអភិរក្សបរិស្ថាន ។ យើងបានត្រៀមខ្លួនរួចជាស្រេច ដើម្បីស្តារឡើងវិញនូវជោគវាសនាអនាគតរបស់យើង ក្នុងឋានៈជាប្រជាជាតិខ្មែរ និងជាព្រះរាជាណាចក្រមួយដោយឈរយ៉ាងរឹងមាំជាមួយបណ្តាប្រជាជាតិនានាលើពិភពលោក ។ បច្ចុប្បន្នយើងបានត្រៀមជាស្រេចដើម្បីធ្វើសហប្រតិបត្តិការ និងរួមចំណែកក្នុងការកសាងភពផែនដីមួយដែលប្រកបទៅដោយសុខសន្តិភាព និងភាពរុងរឿង ។

ទោះជាយ៉ាងណាក៏ដោយក៏កិច្ចការអាទិភាពសំរាប់ប្រទេសយើង ពុំទាន់បានសំរេចនៅឡើយ នោះគឺត្រូវយកជ័យជំនះលើសង្គ្រាមមួយផ្សេងទៀត ពោលគឺសង្គ្រាមប្រឆាំងនឹងភាពក្រីក្រ និងកិច្ចការពារធនធានធម្មជាតិ ។ យើងនឹងឈ្នះសង្គ្រាមនេះសំរាប់កូនចៅជំនាន់ក្រោយ តាមរយៈការថែរក្សាយ៉ាងមធ្យ័តនូវលំនៅដ្ឋាន និងធនធានធម្មជាតិរបស់យើង រួមទាំងស្រែចំការ ព្រៃឈើ បឹងនិងស្ទឹង ទន្លេនានារបស់យើង ព្រៃភ្នំក្រំថ្ម និងដីធ្លី កេរ្តិ៍ដំណែលប្រវត្តិសាស្ត្រ និងវប្បធម៌ ព្រមទាំងបរិស្ថានទាំងមូលរបស់យើង ។ យើងនឹងឈ្នះសង្គ្រាមនេះបាន ប្រសិនបើយើងចេះរួមសាមគ្គីបំពេញភារកិច្ចជាមួយគ្នា រវាងរដ្ឋាភិបាលនិងប្រជាជន រវាងស្ថាប័នសាធារណៈនិងឯកជន រវាងបុរសនិងស្ត្រី រវាងអ្នកមាននិងអ្នកក្រ ។ យើងនឹងឈ្នះសង្គ្រាមនេះតាមរយៈ សាមគ្គីភាពជាមួយសង្គមទាំងមូល ដែលយើងក៏ជាចំណែកនៅក្នុងនោះដែរ ពោលគឺឃុំ-សង្កាត់ ស្រុក ខេត្ត ប្រទេសកម្ពុជាទាំងមូល ប្រជាជាតិអាស៊ាន សហគមន៍អន្តរជាតិ និងពិភពផែនដីទាំងមូល ។ យើងនឹងឈ្នះសង្គ្រាមនេះ តាមរយៈការយោគយល់ស្តាប់គ្នាទៅវិញទៅមក ដើម្បីអាចជួយគ្នា និង

ចែករំលែកជាមួយគ្នាឱ្យបានល្អប្រសើរ ។ យើង នឹងឈ្នះសង្គ្រាមនេះ ដោយសារយើងបានប្តេជ្ញាចិត្តធានាឱ្យបានថា នៅក្នុងដំណើររៀង១ខ្លួនរបស់យើង នឹងពុំមានជនកម្ពុជាណាម្នាក់ក្លាយជាអ្នកចាញ់នោះឡើយ ។ យើងនឹងឈ្នះសង្គ្រាមនេះតាមរយៈការបំពេញការងារ និងការប្តេជ្ញាចិត្ត ។ យើងនឹងឈ្នះសង្គ្រាមនេះតាមរយៈស្ថេរភាពនៃម៉ាក្រូសេដ្ឋកិច្ច ដោយច្បាមជាប់វិស័យអាទិភាពសំខាន់១ ។

យុទ្ធសាស្ត្រនិងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះគឺជាសមិទ្ធផលមួយ ដែលដាក់ឱ្យអនុវត្តដើម្បីយកជ័យជំនះមិនត្រឹមតែលើសង្គ្រាមប្រឆាំងនឹងភាពក្រីក្រតែមួយនោះទេ ប៉ុន្តែនឹងយកជ័យជំនះក្នុងការធានានូវភាពសំបូរបែបនៃជីវៈចំរុះរបស់ប្រទេសយើង តំបន់ និងពិភពលោក ។

សាររបស់ខ្ញុំទៅកាន់ជនរួមជាតិគឺ ដើម្បីកាត់បន្ថយភាពក្រីក្រ តាមការធានានិរន្តរភាពនៃធនធានធម្មជាតិ និងជីវៈចំរុះ ។ ភាពក្រីក្រមិនមែនជាឫសគល់តែមួយនៃការបំផ្លិចបំផ្លាញជីវៈចំរុះប៉ុណ្ណោះទេ ប៉ុន្តែនិន្នាការនៃការរីកចំរើនសេដ្ឋកិច្ចក៏ជាឫសគល់នៃការបំផ្លិចបំផ្លាញជីវៈចំរុះផងដែរ ។ ដូច្នេះការអភិវឌ្ឍន៍សេដ្ឋកិច្ចដ៏ឆ្លាតវៃត្រូវតែធ្វើសមាហរណកម្មជាមួយកម្មវិធីកាត់បន្ថយ ភាពក្រីក្រ ដើម្បីធានានូវកិច្ចការពារ ការអភិរក្សនៃជីវៈចំរុះ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០២

សែន

# សាររបស់ឯកឧត្តម បណ្ឌិតម៉ុកម៉ារ៉េត
# រដ្ឋមន្ត្រីនៃក្រសួងបរិស្ថាន

អស់រយៈពេលជិត ៨ ឆ្នាំហើយបន្ទាប់ពីព្រះរាជាណាចក្រកម្ពុជាបានចូលជាសមាជិកនៃអនុសញ្ញាអន្តរជាតិស្តីពីជីវៈចំរុះ (CBD) ។ ឥឡូវនេះគឺជាលើកទី២ហើយដែលប្រទេសយើងបានឆ្លើយតបទៅនឹងអនុសញ្ញាអន្តរជាតិនេះ ដោយបានបំពេញកាតព្វកិច្ចដែលចែងក្នុងមាត្រាទី៦នៃ CBD ក្នុងការបញ្ចប់របាយការណ៍ជាតិស្តីពីជីវៈចំរុះ និងយុទ្ធសាស្ត្រនិងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះត្រូវបានរៀបរៀងឡើងនៅដើមឆ្នាំ២000 នឹងបញ្ចប់នៅដើមឆ្នាំ ២00២នេះ ។

១៧ប្រធានបទ និង៩៨ផែនការសកម្មភាពអាទិភាពនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះ នឹងត្រូវយកមកអនុវត្តបន្ទាប់ពីរាជរដ្ឋាភិបាលបានអនុម័ត។ ៩៨ផែនការសកម្មភាពអាទិភាពទាំងនេះ នឹងជះឥទ្ធិពលយ៉ាងខ្លាំងដល់ការអភិវឌ្ឍន៍ប្រទេសជាតិជាពិសេសដល់ការរួមចំណែកកាត់បន្ថយភាពក្រីក្រ រក្សាគុណភាពបរិស្ថាននិងប្រព័ន្ធអេកូឡូស៊ីធម្មជាតិនិងស្ថេរភាពនៃកំនើនលូតលាស់នៃសេដ្ឋកិច្ចជាតិ ។ ពីព្រោះយុទ្ធសាស្ត្រនិងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះមិនមែនមានតែ២ស្ថាប័នជាអ្នកអនុវត្ត "ក្រសួងបរិស្ថាន និងក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ" ប៉ុណ្ណោះទេ ប៉ុន្តែមាន១៨ស្ថាប័នពាក់ព័ន្ធដទៃទៀតនិងអង្គការក្រៅរដ្ឋាភិបាលនឹងចូលរួមអនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះនេះ។ ដូច្នេះយើងទាំងអស់គ្នាត្រូវរួមដៃគ្នាដើម្បីការពារបរិស្ថាន ជីវៈចំរុះអោយគង់វង្ស និងធានាបាននូវការអភិវឌ្ឍន៍ដោយចីរភាព។

ចេញពី៩៨ផែនការសកម្មភាពអាទិភាពនៃយុទ្ធសាស្ត្រនិងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះ ក្រសួងបរិស្ថាននិងក្រសួងពាក់ព័ន្ធនឹងបង្កើតជាកម្មវិធី និងគំរោងនានាដែលទាក់ទងដល់ការការពារជីវៈចំរុះ និងការអភិវឌ្ឍន៍ដោយចីរភាពដើម្បីរួមចំណែកធ្វើអោយការអនុវត្តន៍ យុទ្ធសាស្ត្រនិងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះ នេះទទួលបានដោយជោគជ័យ។ លើសពីនេះទៅទៀត ជោគជ័យនេះគឺជាជោគជ័យលើការរួមចំណែកកាត់បន្ថយភាពក្រីក្រ និងធានាបាននូវស្ថេរភាពមាក្រូសេដ្ឋកិច្ចរបស់ប្រទេសជាតិ ។

ដូច្នេះសាររបស់ខ្ញុំទៅកាន់ជនរួមជាតិ និងអ្នកស្នេហាបរិស្ថានទាំងអស់គឺ គន្លឹះនៃកិច្ចការពារជីវៈចំរុះមានមូលដ្ឋាននៅលើការចូលរួមរបស់មហាជនគ្រប់ស្រទាប់ការលើកស្ទួយភាពជាម្ចាស់លើធនធានជីវសាស្ត្រដែលមានទិសដៅឆ្ពោះទៅរកការកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយជីវភាពរបស់ពួកគេមានធនធានមនុស្សគ្រប់គ្រាន់ដើម្បីការពារជីវៈចំរុះ និងមានការគាំទ្រពីឆន្ទះនយោបាយ និងការបេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ពិតៗក្នុងការការពារបរិស្ថានជារូបភាពរួម។

រាជធានីភ្នំពេញថ្ងៃទី២៨ ខែមេសា ឆ្នាំ ២00២

ហត្ថលេខា

ម៉ុក_ម៉ារ៉េត

បណ្ឌិត.ជីវវិទ្យា

## សេចក្តីថ្លែងអំណរគុណ

ក្នុងនាមខ្ញុំបាទជាអ្នកសំរបសំរួលគំរោងយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះ ដែលបន្តពីគំរោងជំរុញសមត្ថភាពផ្នែកជីវៈចំរុះនៅកម្ពុជាផ្តល់ថវិកាដោយអង្គការកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងអង្គការមូលនិធិបរិស្ថានពិភពលោក សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាលនិងផ្នែកឯកជនដែលបានផ្តល់វិភាគទានក្នុងការចងក្រងឯកសារយុទ្ធសាស្ត្រនិងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះ ។ ការរៀបចំចងក្រងយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះ គឺដើម្បីឆ្លើយតបទៅនឹងមាត្រាទី៦នៃអនុសញ្ញាអន្តរជាតិស្តីពីជីវៈចំរុះដែលព្រះរាជាណាចក្រកម្ពុជាបានក្លាយជាភាគីចុះកិច្ចសន្យារួចមកហើយ ។

សូមសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេច ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្តល់នូវភាពដឹកនាំដ៏ច្បាស់លាស់ និងការនាំមុខគោលនយោបាយដើម្បីធ្វើអោយប្រាកដនូវភាពរីកចំរើនរបស់ជាតិដែលបញ្ចូលនិរន្តរភាពបរិស្ថានទៅក្នុងកម្មវិធីអភិវឌ្ឍន៍ជាតិដើម្បីការពារនិងអភិរក្សជីវៈចំរុះ កាត់បន្ថយភាពក្រីក្រ លើកស្ទួយជីវភាព និងធានានូវលទ្ធភាពប្រើប្រាស់ធនធាន និងសមធម៌ ។

សូមថ្លែងអំណរគុណដល់ **ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត** រដ្ឋមន្ត្រីក្រសួងបរិស្ថានដែលបានដឹកនាំក្នុងការគាំទ្រលើកស្ទួយសមាហរណកម្មនៃបញ្ហាបរិស្ថានទៅក្នុងកម្មវិធីនិងគោលនយោបាយធំៗ ។ សូមថ្លែងអំណរគុណដល់ឯកឧត្តមក្នុងនាមជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចំរុះ ដែលបានជួយគាំទ្រយ៉ាងពេញទំហឹងដល់ដំណើរការគំរោងជាពិសេសបានជួយដឹកនាំសំរបសំរួលសេចក្តីសំរេចថ្នាក់នយោបាយដល់គំរោងធ្វើឱ្យយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះលេចចេញជារូបរាង ។

សូមថ្លែងអំណរគុណដល់ **ឯកឧត្តម ម៉ៅ សំអឿន** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាអនុប្រធានគណៈកម្មាធិការគ្រប់គ្រងជីវៈចំរុះដែលបានជួយសំរួល ផ្តល់មតិ គាំទ្រកិច្ចសំរបសំរួលអន្តរក្រសួងរហូតធ្វើឱ្យគំរោងទទួលបានជោគជ័យ ។

សូមថ្លែងអំណរគុណដល់អ្នកអង្គម្ចាស់ ឯកឧត្តម អស់លោក លោកស្រីជាសមាជិក សមាជិកានៃគណៈកម្មាធិការជាតិគ្រប់គ្រងជីវៈចំរុះដែលបានចូលរួមប្រជុំពិភាក្សា ផ្តល់មតិយ៉ាងសកម្ម ដល់ការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះ និងផ្តល់ជាវេទិការសំរាប់កិច្ចសហប្រតិបត្តិដ៏ការប្រសើរ ក្នុងចំណោមក្រសួងពាក់ព័ន្ធ ក្នុងកិច្ចការពារធនធានធម្មជាតិ និងជីវៈចំរុះ ។

សូមថ្លែងអំណរគុណដល់ស្ថាប័នពាក់ព័ន្ធ ដែលបានផ្តល់នូវមន្ត្រីជំនាញដល់គំរោង និងបានធ្វើសហប្រតិបត្តិការដល់ការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះរហូតទទួលបានជោគជ័យ ។

សូមថ្លែងអំណរគុណដល់ **ឯកឧត្តម ខៀវ មុត** អគ្គនាយកបច្ចេកទេសនៃក្រសួងបរិស្ថានជាមន្ត្រីបង្គោល របស់អង្គការមូលនិធិបរិស្ថានពិភពលោក និងជាសមាជិកនៃផ្នែកធ្វើផែនការជីវៈចំរុះ ដែលបានផ្តល់នូវយោបល់ល្អៗ និងជួយសំរួលក្នុងដំណើរការរៀបចំយុទ្ធសាស្ត្រនិងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះ ។

សូមថ្លែងអំណរគុណដល់ លោក Jady Smith លោកស្រី Linda Collette លោក Jacques Prescott លោកឡាយ ឃីម លោកទិន ពន្លក និង លោកស្រី Tine Feldman និងសិក្ខាកាមនៃសិក្ខាសាលាជីវៈចំរុះជាតិ ដែលបានផ្តល់មតិយោបល់ក្នុងការចងក្រងយុទ្ធសាស្ត្រនិងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះ ។

សូមថ្លែងអំណរគុណដល់អង្គការកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងអង្គការមូលនិធិបរិស្ថានពិភពលោកក្នុងការផ្តួចផ្តើមគំរោង ផ្តល់កម្មវិធី និងឧបត្ថម្ភហិរញ្ញវត្ថុ ដើម្បីបញ្ចប់ការរៀបចំចងក្រងនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះ ។សូមថ្លែងអំណរគុណដល់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិដែលបានខិតខំក្នុងការគ្រប់គ្រងគំរោង និងបានសំរេចជាផ្លែផ្កានូវសេចក្តីព្រាងយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះសំរាប់ធ្វើការកែសំរួលជាបន្តបន្ទាប់ ។

ជាទីបញ្ចប់ សូមថ្លែងអំណរគុណដល់បុគ្គលិកគំរោងដែលបានផ្តល់វិភាគទានដ៏មានតម្លៃក្នុងការរៀបចំចងក្រងយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះ

១-លោក អ៊ុង សំអឿន មកពីក្រសួងបរិស្ថាន ជាជំនួយការគំរោង

២-លោក អ៊ុយ ជីង មកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាជំនួយការគំរោង

៣-លោក ពេជ សំអាង មកពីក្រសួងអភិវឌ្ឍន៍ជនបទ ជាមន្ត្រីសមភាគី

៤-លោក ឆាង ភូរិន្ទ មកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមន្ត្រីសមភាគី

៥-លោក កែវ វាសនា មកពីក្រសួងបរិស្ថាន ជាមន្ត្រីសមភាគី

៦-លោកស្រី ពេជ ម៉ាលី មកពីក្រសួងធនធានទឹក និងឧតុនិយម ជាមន្ត្រីសមភាគី

៧-លោក ចាន់ ស៊ីថា មកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមន្ត្រីសមភាគី

៨-លោក គិមចន្ទាឫទ្ធិ មកពីក្រសួងផែនការ ជាមន្ត្រីសមភាគី

៩-កញ្ញា ចាន់ សូម៉ាលី មកពីក្រសួងបរិស្ថាន ជាមន្ត្រីសមភាគី

១០-កញ្ញា ម៉ម សុធារី មកពីក្រសួងបរិស្ថាន ជាមន្ត្រីសមភាគី

១១-លោក សុខ ម៉េង ជំនួយការរដ្ឋបាល

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០២

អ៊ុ ពិសី អ្នកសំរបសំរួលគំរោង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

❖❖❖❖❖

# យុទ្ធសាស្ត្រ និង ផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះ

## កិច្ចប្រឹងប្រែងរបស់ជាតិដើម្បីការអភិរក្ស និងប្រើប្រាស់ធនធានជីវសាស្ត្រដោយនិរន្តរភាព

ព្រះមហាក្សត្រ និងរាជរដ្ឋាភិបាលតែងមានព្រះទ័យ និងយកចិត្តទុកដាក់ជាពិសេស លើកិច្ចការពារធនធានធម្មជាតិក្នុងព្រះរាជាណាចក្រកម្ពុជា ដោយទ្រង់ឈ្វេងយល់ និងយល់យ៉ាងច្បាស់ពីសារៈសំខាន់នៃប្រព័ន្ធអេកូឡូស៊ីធំៗនៅក្នុងប្រទេស សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមប្រកបដោយចីរភាព តាមរយៈគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។ មកទល់បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងឥតសំចៃក្នុងកិច្ចការពារបរិស្ថាន និងជំរុញការប្រើប្រាស់ធនធានជីវសាស្ត្រ ប្រកបដោយនិរន្តរភាព ដូចជា : ការរៀបចំក្របខ័ណ្ឌច្បាប់និងគោលនយោបាយ ការបង្កើតនិងពង្រឹងស្ថាប័ន ការរៀបចំនិងអនុវត្តន៏ផែនការ ការកសាងសមត្ថភាពបច្ចេកទេស ការអនុវត្តន៏វិធានការជាក់ស្តែងមួយចំនួនសំដៅលុបបំបាត់សកម្មភាពបំផ្លិចបំផ្លាញធនធានធម្មជាតិ ។ល។ បណ្តាវិធានការទាំងនោះរួមមាន ការបង្កើតតំបន់ការពារធម្មជាតិចំនួន ២៣ កន្លែង នៅឆ្នាំ ១៩៩៣ ស្មើនឹងប្រមាណ ១៨% នៃផ្ទៃប្រទេស ការបង្កើតរដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិស្ថាននៅឆ្នាំ ១៩៩៣ ការដាក់ចូលជាធរមាននៅឆ្នាំ ១៩៩៦ នូវច្បាប់ស្តីពី "កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ" ដែលនាំឱ្យមានការបង្កើតជាក្រសួងបរិស្ថាន និងការអនុម័តផែនការបរិស្ថានជាតិនៅក្នុងឆ្នាំ ១៩៩៨ ។ល។ រាជរដ្ឋាភិបាលក៏បានចូលរួមយ៉ាងសកម្មជាមួយសហគមន៍អន្តរជាតិក្នុងវិស័យការពារបរិស្ថាន និងជីវៈចំរុះ ។ មកទល់បច្ចុប្បន្ន កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិមួយចំនួន ពាក់ព័ន្ធនឹងវិស័យបរិស្ថាន ដែលរួមមាន : អនុសញ្ញាស្តីពីជីវៈចំរុះ (Convention on Biological Diversity) អនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ (Convention on Climate Change) អនុសញ្ញាស្តីពីតំបន់ដីសើមមានសារៈសំខាន់ជាអន្តរជាតិ ឬហៅថាអនុសញ្ញារ៉ាមសារ (Ramsar Convention) អនុសញ្ញាស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិនូវប្រភេទកំពុងរងគ្រោះថ្នាក់ (Convention on International Trade in Endangered Species: CITES) អនុសញ្ញាស្តីពីកិច្ចការពារបេតិកភណ្ឌពិភពលោក (World Heritage Convention) អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីច្បាប់សមុទ្រ (United Nations Convention on the Law of the Seas) អនុសញ្ញាស្តីពីការទប់ស្កាត់ការបំពុលសមុទ្រដោយនាវា (Convention on the Prevention of Marine Pollution from Ships) កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការ សំរាប់ការអភិវឌ្ឍន៏ដោយចីរភាពក្នុងអាងទន្លេមេគ្គ ។ល។

មកទល់បច្ចុប្បន្ននេះ គេនៅពុំទាន់យល់ដឹងអំពីសក្តានុពល និងវិសាលភាពនៃជីវៈចំរុះក្នុងប្រទេសកម្ពុជាឱ្យបានពេញលេញនៅឡើយទេ ប៉ុន្តែដោយសារទីតាំងដ៏អំណោយផលនៃប្រទេសកម្ពុជា គេរំពឹងថា កម្ពុជាមានជីវៈចំរុះសំបូរបែប និងអា[illegible]ជា តំបន់ដែលមានជីវៈចំរុះសំខាន់ៗ ។ បើប្រៀបធៀបនឹងបណ្តាប្រទេសជិតខាង ប្រទេសកម្ពុជាមានដង់ស៊ីតេ[illegible] នៅមានតំបន់ធំទូលាយ ដែលស្ថិតក្នុងសភាពដើមបែបធម្មជាតិនៅឡើយ ។ ធនធានធម្មជាតិគឺជាមូ[illegible]

សេដ្ឋកិច្ចនៃប្រទេសកម្ពុជា ។ អាស្រ័យហេតុនេះ ការផ្តល់អាទិភាពខ្ពស់ទៅលើការគ្រប់គ្រងធនធានទាំងនេះដោយចីរភាព គឺជាប្រការសំខាន់ ជាអាយុជីវិតរបស់ប្រទេសជាតិ ។

ពាក់ព័ន្ធនឹងកាតព្វកិច្ចដែលមានចែងក្នុងអនុសញ្ញាស្តីពីជីវៈចំរុះ រាជរដ្ឋាភិបាលកម្ពុជាកំពុងតែចាត់វិធានការយ៉ាងជាក់លាក់ ដើម្បីអនុវត្តកម្មវិធីអភិរក្ស និងបង្កើនការយល់ដឹងក្នុងចំណោមសាធារណជន ក៏ដូចជាស្ថាប័នពាក់ព័ន្ធនានា សំដៅធានានូវការប្រើប្រាស់ និងការអភិរក្សធនធានជីវៈចំរុះ ប្រកបដោយគតិបណ្ឌិត ។ ក្រោយពេលអនុសញ្ញាស្តីពីជីវៈចំរុះបានទទួលសច្ចាប័ន ក្រសួងបរិស្ថានត្រូវបានតែងតាំងជាស្ថាប័ននាំមុខ ដែលមានភារៈទទួលខុសត្រូវក្នុងការកសាងយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះជាតិ ដើម្បីកំនត់បណ្តាវិធានការចាំបាច់ សំរាប់បំពេញកាតព្វកិច្ច ដែលមានចែងក្នុងអនុសញ្ញានេះ និងដើម្បីពង្រឹងការសំរបសំរួលរាល់ការងារអនុវត្តន៍ភារកិច្ចនៅថ្នាក់ជាតិ ក្នុងគោលបំណងអភិរក្សជីវៈចំរុះ និងការប្រើប្រាស់ធនធានជីវសាស្ត្រដោយនិរន្តរភាព ។

ភារកិច្ចទទួលខុសត្រូវចំបងក្នុងការអភិរក្សជីវៈចំរុះ និងកិច្ចធានានូវការប្រើប្រាស់ធនធានជីវសាស្ត្រដោយនិរន្តរភាព ត្រូវបានចែករំលែករវាងក្រសួងបរិស្ថាន និងបណ្តាក្រសួងពាក់ព័ន្ធនានា ដែលរួមមាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់. ក្រសួងអភិវឌ្ឍន៍ជនបទ. និងក្រសួងធនធានទឹក និងឧតុនិយម ។ ដោយសារក្រសួងទាំងអស់នេះ និងស្ថាប័នពាក់ព័ន្ធដទៃទៀត បានដើរតួនាទីយ៉ាងសំខាន់ នៅក្នុងដំណើរការអនុវត្តមាត្រានានានៃអនុសញ្ញាជីវៈចំរុះ រាជរដ្ឋាភិបាលបានសំរេចបង្កើតនូវ គណៈកម្មាធិការអន្តរក្រសួងដឹកនាំការងារជីវៈចំរុះ ដែលមានតំណាងមកពីក្រសួងទាំងនេះ សំរាប់រៀបចំកសាងយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះជាតិ ។

បណ្តាអាជ្ញាធរថ្នាក់ខេត្ត-ក្រុង ផ្នែកឯកជន សហគមន៍មូលដ្ឋាន សហគមន៍ជនជាតិភាគតិច អង្គការអភិរក្សអន្តរជាតិ សាកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវ ព្រមទាំងក្រុមផ្សេងៗទៀត បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអភិរក្សជីវៈចំរុះ និងជំរុញឱ្យមានការប្រើប្រាស់ធនធានជីវសាស្ត្រដោយនិរន្តរភាព ។ ភាគីពាក់ព័ន្ធជាច្រើនបានចូលរួមពិភាក្សា និងផ្តល់យោបល់ ក្នុងដំណើរការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះជាតិនេះ ។

យុទ្ធសាស្ត្រនេះទទួលស្គាល់យ៉ាងច្បាស់ថា រាជរដ្ឋាភិបាលមិនអាចបំពេញការងារតែឯកឯង ដើម្បីធានាការអភិរក្សជីវៈចំរុះ និងការប្រើប្រាស់ធនធានជីវសាស្ត្រប្រកបដោយនិរន្តរភាពបានឡើយ ។ ការអនុវត្តន៍យុទ្ធសាស្ត្រនេះអាចទទួលបាននូវជោគជ័យ លុះត្រាតែមានការចូលរួមគាំទ្រយ៉ាងទូលំទូលាយពីសំណាក់ប្រជាជនកម្ពុជាទាំងអស់ ហើយចាំបាច់ត្រូវឱ្យពួកគេយល់យ៉ាងច្បាស់ថា ប្រទេសកម្ពុជាមានតួនាទីស្នូលក្នុងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសនានា ជាពិសេសប្រទេសជិតខាង ដើម្បីអនុវត្តអនុសញ្ញាជីវៈចំរុះនេះ ឱ្យបានជោគជ័យ ។

ការអភិរក្សជីវៈចំរុះ និងការប្រើប្រាស់ធនធានជីវសាស្ត្រប្រកបដោយនិរន្តរភាព គឺជាកត្តាដ៏សំខាន់ ក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកកំពស់គុណភាពជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ។ គោលដៅទាំងអស់នេះគឺជាការឆ្លើយតបនឹងពុទ្ធឱវាទ និងជំនឿក្នុងព្រះពុទ្ធសាសនា ពាក់ព័ន្ធនឹងកាតព្វកិច្ចរបស់មនុស្ស ក្នុងការរក្សាតុល្យភាពនៃទំនាក់ទំនងនានាជាមួយនឹងកត្តាផ្សេងៗទៀត ដែលមាននៅក្នុងធម្មជាតិ ។

## យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះ

យុទ្ធសាស្ត្រនិងផែនការសកម្មភាពជីវៈចំរុះជាតិ គឺជាការឆ្លើយតបនឹងមាត្រាក្នុងរដ្ឋធម្មនុញ្ញ និងបណ្តាច្បាប់ដែលមានបច្ចុប្បន្ន ពាក់ព័ន្ធនឹងការទទួលខុសត្រូវចំពោះជីវៈចំរុះនៅក្នុងប្រទេសកម្ពុជា ។ យុទ្ធសាស្ត្រ និងផែនការនេះក៏បានបញ្ជាក់ច្បាស់ផងដែរ អំពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការអន្តរស្ថាប័ន ដើម្បីកសាងគោលនយោបាយ លក្ខខណ្ឌនៃការគ្រប់គ្រង និងការស្រាវជ្រាវនានា ដែលចាំបាច់ សំរាប់ឈានទៅគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី ។ ដោយសហការជាមួយភាគីពាក់ព័ន្ធនានា និងសាធារណជនទាំងមូល បណ្តាស្ថាប័នរដ្ឋាភិបាល ទាំងនៅថ្នាក់កណ្តាល និងថ្នាក់ខេត្ត ក៏ដូចជាស្ថាបន័ជំនាញទាំងឡាយ ត្រូវចូលរួមអនុវត្តទិសដៅជាយុទ្ធសាស្ត្រ ដែលមានចែងនៅក្នុងឯកសារនេះ ដោយអនុលោមតាមគោលនយោបាយ ផែនការ អាទិភាព និងសមត្ថភាពរបស់ខ្លួន ។

# សេចក្ដីសង្ខេប

## ការអនុវត្តន៍អនុសញ្ញាជីវៈចំរុះ

ជីវៈចំរុះទ្រទ្រង់សង្គមមនុស្ស ទាំងខាងផ្នែកអេកូឡូស៊ី សេដ្ឋកិច្ច វប្បធម៌ និងខាងស្មារតី ។ ក៏ប៉ុន្តែ កំណើនចំនួនប្រជាជន និងល្បឿននៃការប្រើប្រាស់ធនធានធម្មជាតិហួសហេតុ បានជះឥទ្ធិពលអវិជ្ជមាន ធ្វើឱ្យប្រព័ន្ធអេកូឡូស៊ីរងការរេចរឹល ហើយភាពសំបូរបែបនៃប្រភេទ និងសេនេទិច ត្រូវបានថយចុះ ក្នុងអត្រាគួរឱ្យបារម្ភ ។ បច្ចុប្បន្ន ការបាត់បង់ជីវៈចំរុះនៅក្នុងពិភពលោក ត្រូវបានគេទទួលស្គាល់ថា ជាបញ្ហាបរិស្ថានដ៏ធ្ងន់ធ្ងរ ដែលមនុស្សលោកកំពុងជួបប្រទះ ។

ការយល់ដឹងពីហេតុប៉ះពាល់នៃការបាត់បង់ជីវៈចំរុះនៅទូទាំងពិភពលោក បានញុំាងឱ្យប្រជាជាតិនានាលើពិភពលោក ចរចាគ្នា ដើម្បីបង្កើតឡើងនូវអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្ដីពីជីវៈចំរុះ ។ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា បានចូលរួមយ៉ាងសកម្ម នៅក្នុងកិច្ចចរចានេះ ហើយព្រះរាជាណាចក្រកម្ពុជាបានផ្ដល់សច្ចាប័ន និងចូលជាសមាជិកនៃអនុសញ្ញានេះ ចាប់តាំងពីឆ្នាំ ១៩៩៥ មក ។

គោលបំណងទាំងបីនៃអនុសញ្ញាជីវៈចំរុះគឺ :

- *អភិរក្សជីវៈចំរុះ*
- *ប្រើប្រាស់ធនធានជីវសាស្ត្រដោយនិរន្តរភាព និង*
- *បែងចែកផលប្រយោជន៍បានពីការប្រើប្រាស់ធនធានសេនេទិច ប្រកបដោយសមធម៌ និងយុត្តិធម៌ ។*

គោលបំណងទាំងអស់នេះ ឆ្លុះបញ្ចាំងអំពីមូលដ្ឋានគ្រឹះទាំងបី នៃការអភិវឌ្ឍន៍ប្រកបដោយចីរភាព (ស្ថានភាពគង់វង្សនៃប្រព័ន្ធអេកូឡូស៊ី ចីរភាពសេដ្ឋកិច្ច និងសមធម៌សង្គម) និងបង្ហាញពីលក្ខណៈសម្បត្តិ និងវិសាលភាពនៃអនុសញ្ញានេះ ។ ក្នុងនាមជាបរិធានច្បាប់ក្របខ័ណ្ឌពិភពលោក អនុសញ្ញានេះកំណត់នូវដំណាក់កាលនីមួយៗ សំរាប់បណ្ដាប្រទេសជាសមាជិក ដើម្បីធ្វើការវាយតំលៃកិច្ចខិតខំប្រឹងប្រែងនៅពេលបច្ចុប្បន្ន ក្នុងការអភិរក្សជីវៈចំរុះ និងវាយតំលៃការប្រើប្រាស់ប្រកបដោយនិរន្តរភាព នូវធនធានជីវសាស្ត្រ និងដើម្បីកំណត់វិធី សំរាប់ចាត់វិធានការបំពេញចំនុចខ្វះខាតនានា និងវិធីប្រើប្រាស់កាលានុវត្តភាព ដែលមាននាពេលបច្ចុប្បន្ន ។

កាតព្វកិច្ចមួយ ក្នុងចំណោមកាតព្វកិច្ចសំខាន់ៗជាច្រើន សំរាប់បណ្ដាប្រទេសដែលបានចូលជាសមាជិកអនុសញ្ញានេះ គឺការរៀបចំយុទ្ធសាស្ត្រជាតិ ។ ការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះជាតិ គឺជាការឆ្លើយតបនឹងកាតព្វកិច្ចខាងលើ ហើយយុទ្ធសាស្ត្រ និងផែនការសកម្មភាពនេះ ត្រូវបានកសាងឡើង ជាមគ្គុទ្ទេសក៍សំរាប់អនុវត្តអនុសញ្ញាជីវៈចំរុះ នៅក្នុងប្រទេសកម្ពុជា ។ រាល់សេចក្ដីណែនាំជាយុទ្ធសាស្ត្រដែលមានចែងនៅក្នុងឯកសារនេះ មានការពាក់ព័ន្ធនៅក្នុងក្របខ័ណ្ឌថ្នាក់ជាតិ ប៉ុន្តែចំនុចមួយចំនួននៅក្នុងឯកសារនេះ អាចពុំមានការពាក់ព័ន្ធ សំរាប់តំបន់មួយចំនួននៅក្នុងប្រទេសនេះ ឬសំរាប់ស្ថាប័នជំនាញមួយចំនួន ។

យុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះជាតិ ត្រូវបានរៀបចំឡើង ស្របទៅនឹងមាត្រាក្នុងរដ្ឋធម្មនុញ្ញ និងបណ្ដាច្បាប់ដែលមានបច្ចុប្បន្ន ពាក់ព័ន្ធនឹងការទទួលខុសត្រូវចំពោះជីវៈចំរុះនៅក្នុងប្រទេសកម្ពុជា ។ យុទ្ធសាស្ត្រ និងផែនការនេះ ក៏បានបញ្ជាក់ច្បាស់ផងដែរ អំពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការអន្តរស្ថាប័ន ដើម្បីរៀបចំគោលនយោបាយ បច្ចេកទេសសាស្ត្រ សំរាប់ការគ្រប់គ្រង និងការស្រាវជ្រាវនានា ដែលចាំបាច់ សំរាប់ឈានទៅគ្រប់គ្រងធនធានធម្មជាតិ ប្រកបដោយនិរន្តរភាព ។

## ចំណុចសំខាន់ៗនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះជាតិ

**ទស្សនៈរួម** នៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះជាតិ សំរាប់ប្រទេសកម្ពុជា គឺ :

*" វិបុលភាពសេដ្ឋកិច្ចប្រកបដោយសមធម៌ និងការលើកកំពស់គុណភាពនៃជីវភាពរស់នៅ តាមរយៈការប្រើប្រាស់ កិច្ចការពារ និងគ្រប់គ្រងធនធានជីវសាស្ត្រដោយនិរន្តរភាព "*

យុទ្ធសាស្ត្រនេះថ្លែងអំពីក្របខ័ណ្ឌណែនាំសំរាប់អនុវត្តសកម្មភាពនៅគ្រប់លំដាប់ថ្នាក់ ដែលនឹងជួយពង្រឹងសមត្ថភាពជាតិក្នុងការធានាបាននូវផលិតភាព ភាពសំបូរបែប និងភាពគង់វង្សនៃប្រព័ន្ធធម្មជាតិ ក៏ដូចជាក្នុងការកាត់បន្ថយភាពក្រីក្រ និងការលើកកំពស់គុណភាពនៃជីវភាពរស់នៅរបស់ជនកម្ពុជាគ្រប់រូប ។ យុទ្ធសាស្ត្រនេះជំរុញឱ្យមានការអភិរក្សជីវៈចំរុះ និងការប្រើប្រាស់ធនធានជីវសាស្ត្រដោយនិរន្តរភាព និងពិពណ៌នាអំពីវិធីសាស្ត្រសំរាប់ប្រទេសកម្ពុជា ដើម្បីរួមចំណែកក្នុងការអនុវត្តន៍អនុសញ្ញានេះ ជាមួយសហគមន៍អន្តរជាតិ ។

## ការថ្លែងនូវបេសកកម្ម

*ប្រើប្រាស់ ការពារ និងគ្រប់គ្រងជីវៈចំរុះ សំរាប់ការអភិវឌ្ឍន៍ដោយចីរភាពនៅកម្ពុជា ។*

## គោលដៅចំបង

- ថែទាំជីវៈចំរុះ និងផលិតភាពនៃប្រព័ន្ធអេកូឡូស៊ី តាមរយៈកិច្ចការពារប្រភេទនានានៃសារពាង្គកាយមានជីវិត ទាំងនៅក្នុងបរិស្ថានធម្មជាតិ និងបរិស្ថានសិប្បនិម្មិត ជាពិសេស ព្រៃឈើ ប្រព័ន្ធអេកូឡូស៊ីនៃមជ្ឈដ្ឋានទឹក តំបន់ដីសើម និងដីកសិកម្ម ។
- គ្រប់គ្រងសកម្មភាពមនុស្ស និងប្រើប្រាស់ធនធានជីវសាស្ត្រ តាមវិធីដែលអាចរក្សាការពារសំរាប់រយៈពេលវែង នូវធនធានធម្មជាតិ ដែលមានសារៈប្រយោជន៍ចាំបាច់សំរាប់ជីវិតមនុស្ស និងការអភិវឌ្ឍន៍ ។
- ធានាថា ផលប្រយោជន៍បានពីការប្រើប្រាស់ដោយនិរន្តរភាពនូវធនធានជីវសាស្ត្រ នឹងរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកំពស់គុណភាពនៃការរស់នៅសំរាប់ជនកម្ពុជាគ្រប់រូប ។

## គោលបំណងជាយុទ្ធសាស្ត្រ

គោលបំណងជាយុទ្ធសាស្ត្រដែលបានកំណត់ក្នុងផ្នែកនីមួយៗ ឆ្លុះបញ្ចាំងនូវចេតនារបស់រាជរដ្ឋាភិបាល ក្នុងការបំពេញសកម្មភាពតាមវិស័យនីមួយៗ ។ គោលបំណងទាំងអស់នេះមានភាពជាក់លាក់ និងអាចផ្ទៀងផ្ទាត់បាន ដែលនឹងជួយតំរង់ទិសក្រសួងស្ថាប័ននានា ក្នុងពេលអនុវត្តដំណាក់កាលនីមួយៗនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពនេះ ។ ក្រសួងនានានឹងចងក្រងឯកសារ ត្រូវរៀបចំធ្វើសេចក្តីរាយការណ៍ជាទៀងទាត់ ទៅតាមសន្ទស្សន៍បង្ហាញ ដែលមានភ្ជាប់ជាមួយទៅតាមគោលបំណង

## សកម្មភាពជាអាទិភាព

សកម្មភាពជាអាទិភាព ដែលអនុមត័ដោយរាជរដ្ឋាភិបាល អាចចែកជាបីក្រុមធំៗ : (១) បណ្តាសកម្មភាពបង្កើនការយល់ដឹង និងកសាងសមត្ថភាពមន្ត្រីរាជរដ្ឋាភិបាល ក៏ដូចជាសហគមន៍មូលដ្ឋាន សំរាប់អភិរក្សជីវៈចំរុះ និងប្រើប្រាស់ធនធានដោយនិរន្តរភាព. (២) បណ្តាសកម្មភាពជំរុញឱ្យមានការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍. និង (៣) បណ្តាសកម្មភាពសំដៅបញ្ជាក់ឱ្យច្បាស់នូវដែនសិទ្ធិអំណាចរបស់ស្ថាប័ន កាត់បន្ថយភាពត្រួតគ្នានៃការទទួលខុសត្រូវ និងជំរុញការងារសំរបសំរួល ព្រមទាំងកិច្ចសហប្រតិបត្តិការអន្តរក្រសួង ក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ដោយចីរភាព ។

## យន្តការសំរាប់អនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះ

- ចងក្រងរបាយការណ៍ជាតិប្រចាំឆ្នាំ ស្តីពីគោលនយោបាយ សកម្មភាព និងផែនការអំពីការអនុវត្តន៍យុទ្ធសាស្ត្រនេះ ។
- សំរបសំរួលការអនុវត្តន៍យុទ្ធសាស្ត្រ ទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ តាមរយៈគណៈកម្មាធិការអន្តរក្រសួងដឹកនាំការងារជីវៈចំរុះ និងលេខាធិការដ្ឋានជាតិសំរាប់កិច្ចការជីវៈចំរុះ ។
- ចាត់វិធានការដែលអនុញ្ញាត និងលើកទឹកចិត្តឱ្យមានការចូលរួមពីសំណាក់អង្គការមិនមែនរដ្ឋាភិបាល ក្នុងការអនុវត្តន៍យុទ្ធសាស្ត្រនេះ ។
- រាយការណ៍ជាប្រចាំអំពីសន្ទស្សន៍នៃការអនុវត្តគោលបំណងយុទ្ធសាស្ត្រនីមួយៗ ។
- រាយការណ៍អំពីស្ថានភាពនៃជីវៈចំរុះក្នុងប្រទេស ។ និង
- ពិនិត្យ និងកែសំរួលឡើងវិញនូវយុទ្ធសាស្ត្រនេះ ក្រោយពីបានអនុវត្តជំហានដំបូងដែលមានរយៈពេល ២ ឆ្នាំ នៃយុទ្ធសាស្ត្រនេះ ។

ជោគជ័យនៃការអនុវត្តន៍យុទ្ធសាស្ត្រនេះ អាស្រ័យទៅនឹងកំរិតនៃការទទួលយកនូវចក្ខុវិស័យ និងគោលការណ៍នានារបស់យុទ្ធសាស្ត្រ និងការរួមចំណែកសំរេចគោលដៅនៃយុទ្ធសាស្ត្រនេះ ពីសំណាក់ប្រជាជនគ្រប់ស្រទាប់ក្នុងសង្គម ។ ប្រការសំខាន់គឺថា ការអភិរក្សជីវៈចំរុះ និងការប្រើប្រាស់ធនធានជីវសាស្ត្រដោយនិរន្តរភាព ទាមទារឱ្យមានការគាំទ្រ និងការចូលរួមពីប្រជាជនគ្រប់រូប សហគមន៍មូលដ្ឋាន អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ក្រុមអភិរក្ស ស្ថាប័នពាណិជ្ជកម្ម វិស័យឧស្សាហកម្ម ស្ថាប័នអប់រំ និងស្ថាប័នស្រាវជ្រាវ ។ បណ្តាសកម្មភាពដែលមានចែងនៅក្នុងផែនការសកម្មភាពនេះ នឹងអនុវត្តតាមរយៈប្រព័ន្ធវិមជ្ឈការ ឬវិសហមជ្ឈការ ដោយស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ននានា ឬអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ ។

ដើម្បីតាមដាន និងវាយតំលៃដំណើរការរីកចំរើនតាមរយៈរបាយការណ៍ ចាំបាច់ត្រូវកំនត់គោលដៅសំរាប់សន្ទស្សន៍មួយចំនួននៅក្នុងផែនការនេះ ។ គេអាចប្រើប្រាស់តារាងម៉ាទ្រិចស្តីពីសកម្មភាព និងសន្ទស្សន៍ដែលមានចែងក្នុងឯកសារយុទ្ធសាស្ត្រ និងផែនការសកម្មភាពនេះ (ឧបសម្ព័ន្ធ ១) សំរាប់តាមដាន និងវាយតំលៃប្រសិទ្ធភាពនៃការអនុវត្តន៍យុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះ តាមរយៈសន្ទស្សន៍សំរាប់ប្រធានបទពាក់ព័ន្ធនឹងសកម្មភាពនីមួយៗ ។

## ការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះជាតិ

យុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះជាតិត្រូវបានរៀបចំឡើង ដោយមានការជួបប្រជុំជាមួយស្ថាប័នពាក់ព័ន្ធ និងសិក្ខាសាលាស្ដីពីជីៈចំរុះថ្នាក់ជាតិចំនួនពីរ និងថ្នាក់ខេត្តចំនួនបី ។ សិក្ខាសាលាបានលើកឡើងនូវចំនុចជាគន្លឹះសំរាប់ជីវៈចំរុះនៅក្នុងប្រទេសកម្ពុជា ដែលមានអធិប្បាយនៅក្នុងប្រធានបទនីមួយ១ ។ ស្ថាប័នជំនាញនីមួយ១បានផ្ដល់ពតិមាន និងយោបល់ចំពោះប្រធានបទពាក់ព័ន្ធ ជាពិសេសបានបង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលចំពោះសកម្មភាពជាអាទិភាព ពាក់ព័ន្ធនឹងប្រធានបទទាំងនេះ ។

## ទំនាក់ទំនងរវាងបណ្ដាប្រធានបទដែលមានចែងក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះ

ប្រធានបទនីមួយ១ ដែលមាននៅក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពនេះ បានបង្ហាញពីវិធីសាស្ត្ររបស់ស្ថាប័ននីមួយ១ ក្នុងការគ្រប់គ្រងជីវៈចំរុះ ។ ដោយសារជីវៈចំរុះគឺជាបញ្ហាអន្តរស្ថាប័ន ដូច្នេះនៅក្នុងប្រធានបទទាំងនោះ មានចំនុចត្រួតគ្នាជាច្រើន ប៉ុន្តែចំនុចត្រួតគ្នានេះអាចចាត់ទុកថាជាការបំពេញឱ្យគ្នាទៅវិញទៅមក តែមិនមែនជាការធ្វើជាន់គ្នាដដែល១ទេ ។ នេះគឺជាផែនការដំបូងបំផុត ប៉ុន្តែយើងសង្ឃឹមថា នៅពេលអនាគត ផែនការនេះនឹងត្រូវកែសំរួលឡើងវិញ ដោយមានការពិចារណាបានប្រសើរជាងនេះ អំពីទំនាក់ទំនងអន្តរស្ថាប័ន រវាងប្រធានបទនានា ។

យុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះជាតិ មានគោលបំណងជាយុទ្ធសាស្ត្រ និងសកម្មភាពជាអាទិភាពជាច្រើន ដែលមានបង្ហាញជូននៅក្នុងប្រធានបទនីមួយៗ និងដែលមានការពាក់ព័ន្ធជាមួយស្ថាប័នភាគច្រើនក្នុងសង្គម ។ ប្រធានបទទាំងនោះរួមមាន :

១. កិច្ចការពារធនធានធម្មជាតិ (តំបន់ការពារធម្មជាតិ ប្រភេទកំពុងប្រឈមគ្រោះថ្នាក់ និងការអភិរក្សក្រៅតំបន់)
២. ធនធានសត្វព្រៃ
៣. ជលផលទឹកសាប និងវារីវប្បកម្ម
៤. ធនធានតំបន់ឆ្នេរ និងសមុទ្រ
៥. ធនធានព្រៃឈើ និងរុក្ខជាតិព្រៃ
៦. កសិកម្ម និងផលិតកម្មសត្វ
៧. ធនធានថាមពល
៨. ធនធានរ៉ែ
៩. ឧស្សាហកម្ម បច្ចេកវិទ្យា និងសេវាកម្ម (ផលិតកម្ម ជីវបច្ចេកវិទ្យា និងជីវសុវត្ថិភាព ទេសចរណ៍)
១០. សន្តិសុខបរិស្ថាន
១១. ការធ្វើផែនការប្រើប្រាស់ដីធ្លី
១២. ធនធានទឹក
១៣. ការប្រែប្រួលអាកាសធាតុ និងជីវៈចំរុះ
១៤. ការចូលរួមរបស់សហគមន៍
១៥. ការយល់ដឹង ការអប់រំ ការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍន៍
១៦. រចនាសម្ព័ន្ធច្បាប់ និងស្ថាប័ន
១៧. គុណភាពនៃការរស់នៅ និងការកាត់បន្ថយភាពក្រីក្រ ។

# អក្សរកាត់ប្រើក្នុងឯកសារនេះ

| | |
|---|---|
| ក្រ | ក្រសួង |
| បស្ថ | ក្រសួងបរិស្ថាន |
| កសក | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| អជប | ក្រសួងអភិវឌ្ឍន៍ជនបទ |
| ផក | ក្រសួងផែនការ |
| ធទឧ | ក្រសួងធនធានទឹក និងឧតុនិយម |
| អយក | ក្រសួងអប់រំ យុវជន និងកីឡា |
| ឧរថ | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| ពជក | ក្រសួងពាណិជ្ជកម្ម |
| សកដជ | ក្រសួងសាធារណៈការ និងដឹកជញ្ជូន |
| កនអយ | ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន |
| រជនស | ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ |
| ទច | ក្រសួងទេសចរណ៍ |
| វវស | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| កអសក | ក្រុមប្រឹក្សាអភិវឌ្ឍន៍សង្គមកិច្ច |
| ធកស | ក្រសួងធម្មការ និងសាសនា |
| សខភ | ក្រសួងសុខាភិបាល |
| សហ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| គចអកអបស្ថ | គណៈកម្មាធិការចំរុះអន្តរក្រសួងស្តីពីការអប់រំបរិស្ថាន |
| សភភព | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| គជគម | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| មហផ | ក្រសួងមហាផ្ទៃ |

# មា តិ កា

ទំព័រ

**សេចក្តីសង្ខេប** .................... iv

ការអនុវត្តន៍អនុសញ្ញាជីវៈចំរុះ .................... iv

ចំណុចសំខាន់ៗនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះជាតិ .................... v

ការថ្លែងនូវបេសកកម្ម .................... v

គោលដៅចំបង .................... v

គោលបំណងជាយុទ្ធសាស្ត្រ .................... v

សកម្មភាពជាអាទិភាព .................... vi

យន្តការសំរាប់អនុវត្តយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះ .................... vi

ការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះជាតិ .................... vii

ទំនាក់ទំនងរវាងបណ្តាប្រធានបទដែលមានចែងក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះ .................... vii

**អក្សរកាត់ប្រើក្នុងឯកសារនេះ** .................... ix

**មាតិកា** .................... x

**បុព្វកថា** .................... 1

អនុសញ្ញាជីវៈចំរុះ .................... 1

កិច្ចខិតប្រឹងប្រែងបច្ចុប្បន្នសំរាប់ការអភិវឌ្ឍន៍ដោយចីរភាព និងការអភិរក្សជីវៈចំរុះក្នុងប្រទេសកម្ពុជា .................... 2

តួនាទី និងសារៈសំខាន់នៃជីវៈចំរុះ .................... 2

**ការពិពណ៌នាពីជីវៈចំរុះនៅប្រទេសកម្ពុជា** .................... 4

ប្រវត្តិដើម .................... 4

ការប្រើប្រាស់ជីវៈចំរុះ .................... 5

ស្ថានភាពជីវៈចំរុះ .................... 5

ការគំរាមគំហែងចំពោះជីវៈចំរុះ .................... 9

សន្និដ្ឋាន ....................

**យុទ្ធសាស្ត្រ** .................... 11

ទស្សនៈវិស័យនៃជីវៈចំរុះ ....................

ការថ្លែងនូវបេសកកម្ម ........ 11

គោលដៅចំបង ........ 11

គោលការណ៍គ្រឹះ ........ 11

ការអង្កេតតាមដាន និងការវាយតំលៃនៅក្នុងការអនុវត្តន៍យុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះជាតិ ........ 12

ការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះជាតិ ........ 13

ទំនាក់ទំនងរវាងបណ្ដាប្រធានបទដែលមានចែងក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះ ........ 14

**ប្រធានបទទី ១ : កិច្ចការពារធនធានធម្មជាតិ** ........ 15

១.១ តំបន់ការពារធម្មជាតិ ........ 15

១.២ ប្រភេទកំពុងប្រឈមគ្រោះថ្នាក់ ........ 22

១.៣ ការអភិរក្សក្រៅតំបន់ ........ 25

**ប្រធានបទទី ២ : ធនធានសត្វព្រៃ** ........ 28

**ប្រធានបទទី ៣ : ជលផលទឹកសាប និងវារីវប្បកម្ម** ........ 30

**ប្រធានបទទី ៤ : ធនធានតំបន់ឆ្នេរ និងសមុទ្រ** ........ 35

**ប្រធានបទទី ៥ : ធនធានព្រៃឈើ និងរុក្ខជាតិព្រៃ** ........ 39

**ប្រធានបទទី ៦ : កសិកម្ម និងផលិតកម្មសត្វ** ........ 43

**ប្រធានបទទី ៧ : ធនធានថាមពល** ........ 48

**ប្រធានបទទី ៨ : ធនធានរ៉ែ** ........ 50

**ប្រធានបទទី ៩ : ឧស្សាហកម្ម បច្ចេកវិទ្យា និងសេវាកម្ម** ........ 52

៩.១ កម្មន្តសាល ........ 52

៩.២ ជីវបច្ចេកវិទ្យា និងជីវសុវត្ថិភាព ........ 53

៩.៣ វិស័យទេសចរណ៍ ........ 56

**ប្រធានបទទី ១០ : សន្តិសុខបរិស្ថាន** ........ 59

**ប្រធានបទទី ១១ : ការធ្វើផែនការប្រើប្រាស់ដីធ្លី** ........ 62

**ប្រធានបទទី ១២ : ធនធានទឹក** ........ 65

**ប្រធានបទទី ១៣ : ការប្រែប្រួលអាកាសធាតុ និងជីវៈចំរុះ** ........ 68

**ប្រធានបទទី ១៤ : ការចូលរួមរបស់សហគមន៍** ........ 71

ប្រធានបទទី ១៥ : ការសំរបសំរួល និងការអភិវឌ្ឍន៍ការយល់ដឹង ការអប់រំ និងការស្រាវជ្រាវ ..... 74

ប្រធានបទទី ១៦ : ច្បាប់ និងគោលនយោបាយស្ថាប័ន ..... 78

ប្រធានបទទី ១៧ : គុណភាពនៃការរស់នៅ និងការកាត់បន្ថយភាពក្រីក្រ ..... 82

## បុព្វកថា

## អនុសញ្ញាជីវៈចំរុះ

ពាក្យថាជីវៈចំរុះសំដៅលើសារពាង្គកាយរស់នានាពីគ្រប់ប្រភព ដែលក្នុងនោះរួមទាំង ប្រព័ន្ធអេកូឡូស៊ីដីគោក សមុទ្រ និងប្រព័ន្ធអេកូឡូស៊ីនៃមជ្ឈដ្ឋានទឹកផ្សេងទៀត និងអន្តរកម្មអេកូឡូស៊ី ។ ដូច្នេះជីវៈចំរុះរួមមាននានាភាពក្នុងប្រភេទ រវាងប្រភេទ និងនៃប្រព័ន្ធអេកូឡូស៊ី ។ ដោយសារតែសកម្មភាពមនុស្ស ជីវៈចំរុះបានបាត់បង់ ក្នុងអត្រាខ្ពស់ជាងកំរិតនៃការបាត់បង់ដោយធម្មជាតិ ។ ការថយចុះយ៉ាងរហ័សនៃភាពសំបូរបែបរបៀបនេះ ជាការគំរាមកំហែងចំពោះផលប្រយោជន៍ខាងផ្នែកអេកូឡូស៊ី សេដ្ឋកិច្ច ស្មារតី ការកំសាន្ត និងវប្បធម៌ ដែលយើងទទួលបានពីធនធានមានជីវិតនៅលើផែនដីនេះ ។

ដោយទទួលស្គាល់នូវការគំរាមកំហែងទាំងនេះ ទើបសហគមន៍អន្តរជាតិធ្វើការការចរចា ហើយសំរេចបានដោយជោគជ័យ នៅក្នុងការបង្កើតអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីជីវៈចំរុះ ដែលបានបើកឱ្យអ្នកដឹកនាំពីបណ្តាប្រទេសនានាលើពិភពលោកចុះហត្ថលេខា នៅឯសន្និសីទសហប្រជាជាតិស្តីពីបរិស្ថាន និងការអភិវឌ្ឍន៍ ដែលបានប្រព្រឹត្តទៅ នៅទីក្រុងរីយ៉ូដឺសានេរ៉ូ (Rio de Janeiro) ប្រទេសប្រេស៊ីល កាលពីខែ មិថុនា ឆ្នាំ ១៩៩២ ។ ព្រះរាជាណាចក្រកម្ពុជា បានចូលរួមយ៉ាងសកម្ម ក្នុងការកិច្ចចរចា ដែលឈានទៅការផ្តល់សច្ចាប័ន និងចូលជាសមាជិកអនុសញ្ញានេះ នៅឆ្នាំ ១៩៩៥ ។

អនុសញ្ញានេះត្រូវបានបង្កើតឡើង ជាការឆ្លើយតបទៅនឹងទស្សនៈវិជ្ជានៃបណ្តាបុព្វាធិការីនានា ដូចជា *ការថែរក្សាភពផែនដី : យុទ្ធសាស្ត្រសំរាប់ជីវភាពរស់នៅដោយនិរន្តរភាព* (Caring for the Earth, A Strategy for Sustainable Living) ដែលបានបោះពុម្ពផ្សាយនៅឆ្នាំ ១៩៩១. *អនាគតរួមរបស់យើង* ឬ *របាយការណ៍ Bruntland* (Our Common Future, the Brundtland Report) ដែលបានបោះពុម្ពផ្សាយនៅឆ្នាំ ១៩៨៧ និង *យុទ្ធសាស្ត្រអភិរក្សពិភពលោក* (the World Conservation Strategy) ដែលបានបោះពុម្ពផ្សាយនៅឆ្នាំ ១៩៨០ ។ របាយការណ៍ទាំងអស់នេះផ្អែកលើគោលការណ៍ដែលថា ការអភិវឌ្ឍន៍ត្រូវតែប្រកបដោយចីរភាព លើផ្នែកអេកូឡូស៊ី សេដ្ឋកិច្ច និងសង្គម ។ នេះមានន័យថា កិច្ចខិតខំប្រឹងប្រែង ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់មនុស្ស ត្រូវតែអនុវត្តនៅក្នុងក្របខ័ណ្ឌនៃកំរិតកំនត់របស់ធនធាន ដែលមាននៅលើភពផែនដីរបស់យើង ។

គោលបំណងនៃអនុសញ្ញានេះគឺ :

- *អភិរក្សជីវៈចំរុះ*
- *ប្រើប្រាស់ធនធានជីវសាស្ត្រដោយនិរន្តរភាព និង*
- *បែងចែកផលប្រយោជន៍ដែលបានពីការប្រើប្រាស់ធនធានសេនេទិច ប្រកបដោយសមធម៌ និងយុត្តិធម៌ ។*

គោលបំណងទាំងអស់នេះ ឆ្លុះបញ្ចាំងអំពីមូលដ្ឋានគ្រឹះទាំងបីនៃការអភិវឌ្ឍន៍ប្រកបដោយចីរភាព ( ស្ថានភាព[illegible] ប្រព័ន្ធអេកូឡូស៊ី ចីរភាពសេដ្ឋកិច្ច និងសមធម៌ក្នុងសង្គម) ។ ដូច្នេះ អនុសញ្ញាជីវៈចំរុះគឺជាកិច្ចព្រមព្រៀង[illegible]ការអភិវឌ្ឍន៍ ប្រកបដោយចីរភាពលើពិភពលោក ដែលទាមទារឱ្យមានការអភិរក្សជីវៈចំរុះ និងប្រើប្រាស់ធនធាន[illegible]ដោយនិរន្តរភាព ។ វាបង្ហាញឱ្យឃើញពីការយល់ដឹងនូវទំនាក់ទំនងរវាងសកម្មភាពមនុស្ស និងពិភពធម្មជាតិ ព្រមទាំង[illegible]

ដើម្បីទ្រទ្រង់សារពាង្គកាយមានជីវិត ភាពសំបូរបែបនៃសេនេទិច និងភាពគង់វង្សនៃប្រព័ន្ធអេកូឡូស៊ី ។ វាអាចនឹងមានឥទ្ធិពលយ៉ាងជ្រាលជ្រៅចំពោះអនាគតនៃជីវិតនៅលើផែនដី ។ ការអនុវត្តន៍អនុសញ្ញានេះ ទាមទារឱ្យមានការផ្លាស់ប្តូរជាចំបងនូវមធ្យោបាយ ដែលយើងប្រើប្រាស់ និងគ្រប់គ្រងសារពាង្គកាយមានជីវិតនានា ។ បណ្តាប្រជាជាតិនៅលើពិភពលោកត្រូវប្រកាន់យកវិធីដោះស្រាយ ដោយមានកិច្ចសហការគ្នាល្អ មានការចូលរួមពីអន្តរស្ថាប័ន និងដោយផ្អែកលើភាពជាដៃគូ ។

## កិច្ចខំប្រឹងប្រែងបច្ចុប្បន្នសំរាប់ការអភិវឌ្ឍន៍ដោយចីរភាព និងការអភិរក្សជីវៈចំរុះក្នុងប្រទេសកម្ពុជា

ការប្តេជ្ញាចិត្តរបស់ព្រះរាជាណាចក្រកម្ពុជាចំពោះកិច្ចការពារបរិស្ថាន បានស្តែងឡើងតាមរយៈការអនុវត្តន៍វិធានការច្បាប់សំខាន់ៗមួយចំនួន ដើម្បីទប់ស្កាត់ការបំពុលបរិស្ថាន ការបំផ្លិចបំផ្លាញទីជំរក និងកិច្ចការពារសត្វព្រៃ រួមទាំងការបង្កើតរដ្ឋលេខាធិការដ្ឋានគ្រប់គ្រងបរិស្ថាននៅឆ្នាំ ១៩៩៣ ការអនុម័តច្បាប់ស្តីពី "កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ" នៅឆ្នាំ ១៩៩៦ ដែលជាមូលដ្ឋាននាំឱ្យមានការបង្កើតឡើងនូវក្រសួងបរិស្ថាន និងការអនុម័តផែនការបរិស្ថានជាតិនៅឆ្នាំ ១៩៩៨ ។ សភាជាតិនៃកម្ពុជាក៏បានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិជាច្រើន ដែលពាក់ព័ន្ធនឹងបរិស្ថាន រួមមាន អនុសញ្ញាជីវៈចំរុះ អនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ អនុសញ្ញាស្តីពីតំបន់ដីសើមមានសារៈសំខាន់ជាអន្តរជាតិ អនុសញ្ញាស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិនូវបណ្តាប្រភេទសត្វ និងរុក្ខជាតិកំពុងប្រឈមគ្រោះថ្នាក់ អនុសញ្ញាស្តីពីបេតិកភណ្ឌពិភពលោក និងកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសំរាប់ការអភិវឌ្ឍន៍ដោយចីរភាពក្នុងអាងទន្លេមេគង្គ ជាដើម ។

យុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះជាតិនេះ ឆ្លុះបញ្ចាំងឱ្យឃើញនូវគោលដៅកាត់បន្ថយភាពក្រីក្រ តាមរយៈកំណើនសេដ្ឋកិច្ច និរន្តរភាពបរិស្ថាន និងសមភាពសង្គម ។ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនេះរួមចំណែកយ៉ាងសំខាន់នៅក្នុងការកសាងផែនការអភិវឌ្ឍន៍ប្រទេស ។ ដីធ្លី ទឹក វាលស្មៅ ប្រព័ន្ធអេកូឡូស៊ីដីគោកនិងសមុទ្រ ព្រមទាំងសត្វព្រៃ និងជាពិសេសធនធានក្នុងមជ្ឈដ្ឋានទឹក មានសារៈសំខាន់ជាចំបង សំរាប់ការអភិវឌ្ឍន៍វិស័យកសិកម្ម ជលផល និងទេសចរណ៍ ។ កិច្ចការពារទីជំរក ការអភិរក្សធនធានធម្មជាតិ និងជំរើសនៃការប្រើប្រាស់ដោយនិរន្តរភាព ផ្តល់ឱកាសដ៏សំខាន់ ដើម្បីបង្ហាញថា ការអភិរក្សជីវៈចំរុះ គឺជាការវិនិយោគដ៏សំខាន់មួយ ក្នុងការធានាចីរភាពនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម សំរាប់ប្រទេសកម្ពុជា នាពេលអនាគត ។

## តួនាទី និងសារៈសំខាន់នៃជីវៈចំរុះ

គ្រប់ប្រព័ន្ធអេកូឡូស៊ីផ្តល់ទីជំរកសំរាប់រុក្ខជាតិ សត្វ និងមីក្រូសារពាង្គកាយ ដែលយើងអាចប្រើប្រាស់ ឬដែលអាចបំពេញមុខនាទីជាប្រយោជន៍សំរាប់មនុស្ស ។ វិទ្យាស្ថានធនធានពិភពលោកបានហៅប្រព័ន្ធអេកូឡូស៊ីថា "គ្រឿងយន្តផលិតកម្មនៃពិភពផែនដី " ដែលផ្តល់ឱ្យយើងទាំងអស់គ្នានូវអ្វីៗគ្រប់បែបយ៉ាង រួមទាំងទឹកដែលយើងផឹក អាហារដែលយើងបរិភោគ និងសរសៃធម្មជាតិដែលយើងប្រើប្រាស់សំរាប់ផលិតសំលៀកបំពាក់ ក្រដាស ឬឈើសំរាប់ការសាងសង់ (WRI, 2000) ។ល។ តារាងទី ១ បង្ហាញនូវឧទាហរណ៍អំពីសេវាកម្ម និងផលិតផល ដែលផ្តល់ដោយប្រព័ន្ធអេកូឡូស៊ីមួយចំនួន ។

តារាងទី ១ : ឧទាហរណ៍អំពីសេវាកម្ម និងផលិតផល ដែលផ្តល់ដោយប្រព័ន្ធអេកូឡូស៊ី

| ប្រព័ន្ធអេកូឡូស៊ី | ប្រភេទផលិតផល | ប្រភេទសេវាកម្ម |
| --- | --- | --- |
| ប្រព័ន្ធអេកូឡូស៊ីកសិកម្ម | ▪ ដំណាំសំរាប់ជាអាហារ<br>▪ ផលិតផលបន្ថែម (ឧ. ត្រីនៃសាទពីស្រែ)<br>▪ ដំណាំសសៃ<br>▪ ដំណាំធនធានសេនេទិច | ▪ ទ្រទ្រង់មុខងារទីជំរាលមួយចំនួន (ចំរោះទឹក បន្ថយល្បឿនទឹកហូរ ការពារសមណឹកដី)<br>▪ ផ្តល់ទីជំរកសំរាប់សត្វស្លាប រុក្ខជាតិផ្តល់លំអង សារពាង្គកាយមានជីវិតក្នុងដី ដែលមានសារៈសំខាន់សំរាប់កសិកម្ម<br>▪ បង្កើតសារធាតុសរីរាង្គនៃដី<br>▪ ស្រូបកាបូនពីក្នុងបរិយាកាស<br>▪ ផ្តល់មុខរបរ |
| ប្រព័ន្ធអេកូឡូស៊ីព្រៃឈើ | ▪ ឈើសំណង់<br>▪ អុស<br>▪ ទឹកសំរាប់ផឹក និងស្រោចស្រព<br>▪ ចំណីសត្វ<br>▪ អនុផលព្រៃឈើ (វល្លិ ឬស្សី ស្លឹក ។ល។)<br>▪ អាហារ (ទឹកឃ្មុំ ផ្សិត ផ្លែឈើ និងរុក្ខជាតិហូបបានផ្សេងទៀត និងល្បែងកំសាន្ត)<br>▪ ធនធានសេនេទិច | ▪ កាត់បន្ថយការបំពុលខ្យល់ បញ្ចេញអុកស៊ីសែន<br>▪ ធានាវដ្តសារធាតុចិញ្ចឹម<br>▪ ការពារធនធានទឹក (ចំរោះទឹក បន្សុទ្ធទឹក បន្ថយល្បឿនទឹកហូរ រក្សាតុល្យភាពដី)<br>▪ រក្សាជីវៈចំរុះ<br>▪ ស្រូបកាបូនពីក្នុងបរិយាកាស<br>▪ សំរាលធាតុអាកាសតឹងតែង និងកាត់បន្ថយផលប៉ះពាល់<br>▪ បង្កើនគុណភាពដី<br>▪ ផ្តល់មុខរបរ<br>▪ ផ្តល់សោភ័ណភាពធម្មជាតិ និងការកំសាន្ត |
| ប្រព័ន្ធអេកូឡូស៊ីមជ្ឈដ្ឋានទឹក | ▪ ទឹកសំរាប់ផឹក និងស្រោចស្រព<br>▪ ត្រី និងសារពាង្គកាយផ្សេងទៀតពីមជ្ឈដ្ឋានទឹក<br>▪ វារីអគ្គីសនី<br>▪ គ្រឿងសំណង់ផ្ទះ<br>▪ ឱសថ<br>▪ ធនធានសេនេទិច | ▪ កាត់បន្ថយ ឬទប់ស្កាត់ផលប៉ះពាល់ពីទឹកជំនន់<br>▪ ពង្រាវ និងបញ្ជូនសំណល់ទៅឆ្ងាយ<br>▪ ធានាវដ្តសារធាតុចិញ្ចឹម<br>▪ រក្សាជីវៈចំរុះ<br>▪ ផ្តល់ផ្លូវសំរាប់ដឹកជញ្ជូន<br>▪ ផ្តល់មុខរបរ<br>▪ ផ្តល់សោភ័ណភាពធម្មជាតិ និងផ្តល់ការកំសាន្ត |
| ប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ | ▪ ត្រី និងសិប្បីសត្វ<br>▪ សារ៉ាយសមុទ្រ (ជាអាហារ និងសំរាប់ប្រើក្នុងឧស្សាហកម្ម)<br>▪ អំបិល<br>▪ ធនធានសេនេទិច | ▪ កាត់បន្ថយផលប៉ះពាល់ពីខ្យល់ព្យុះ (ព្រៃកោងកាង កោះរបាំង)<br>▪ ផ្តល់ជំរកដល់សត្វព្រៃ (សមុទ្រ និងដែនដីគោក)<br>▪ រក្សាជីវៈចំរុះ<br>▪ ពង្រាវ និងប្រព្រឹត្តកម្មសំអាតសំណល់<br>▪ ផ្តល់ចំណតកំពង់ផែ និងផ្លូវដឹកជញ្ជូន<br>▪ ផ្តល់មុខរបរ<br>▪ ផ្តល់សោភ័ណភាពធម្មជាតិ និងផ្តល់ការកំសាន្ត |

ប្រភព: កែសំរួលពី WRI 2000. Global Ecosystem Assessment.

មានវិធីជាច្រើនសំរាប់ឱ្យតំលៃជីវៈចំរុះ ។ ការកំណត់តំលៃធនធានជីវៈចំរុះដែលមានលក់នៅទីផ្សារ ដូចជា ស្រូវ ឈើ ឱសថ ។ល។ មិនមែនជាការលំបាកទេ ប៉ុន្តែនៅមានមុខងារជាច្រើនដែលមិនអាចគណនាជាប្រាក់បាន ។ ឧទាហរណ៍ សេវាប្រព័ន្ធអេកូឡូស៊ី ឬផលប្រយោជន៍សង្គម ។ ចំពោះប្រជាជនជាច្រើន ដែលពឹងផ្អែកលើផលិតផលបានមកពីប្រព័ន្ធអេកូឡូស៊ី សំរាប់ជីវិតរស់នៅប្រចាំថ្ងៃ ការឱ្យតម្លៃផលិតផលទាំងអស់ដែលពួកគាត់ប្រើប្រាស់ ឬទទួលប្រយោជន៍ ជាតំលៃទឹកប្រាក់ ពិតជាមានការលំបាក ។

តំបន់ធម្មជាតិទាំងឡាយជាប្រព័ន្ធទ្រទ្រង់ធនធានធម្មជាតិដែលមានតម្លៃសំរាប់ធ្វើពាណិជ្ជកម្ម ។ ឧទាហរណ៍ កន្លែងត្រីពងកូនក្នុងព្រៃលិចទឹក ព្រៃកោងកាង និងតំបន់ដីសើម ។ ជំរកដទៃទៀត មាននាទីជាអាងស្តុកសេនេទិចសំរាប់ដំណាំពាណិជ្ជកម្ម ។ ដោយសារគេនៅពុំទាន់ស្គាល់ប្រភេទជាច្រើននៃសត្វ និងរុក្ខជាតិនៅក្នុងប្រទេសកម្ពុជា និងនៅប្រទេសដទៃទៀត យើងអាចសន្មតថា ការរីកចំរើននៃចំណេះដឹងអាចនឹងរកឃើញធនធានជីវសាស្ត្រថ្មីៗ សំរាប់បង្កើនសុខុមាលភាពមនុស្សជាតិ ។ បច្ចុប្បន្នទំនាក់ទំនងរវាងការអភិរក្សជីវៈចំរុះ និងរបកគំហើញនៃធនធានជីវសាស្ត្រថ្មីៗត្រូវបានបង្ហាញកាន់តែច្បាស់ឡើង ។

## ការពិពណ៌នាអំពីជីវៈចំរុះនៅប្រទេសកម្ពុជា

### ប្រវត្តិដើម

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយស្ថិតនៅជ្រោយឧបទ្វីបនៃដែនដីគោកក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលជាប់នឹងឈូងសមុទ្រថៃ និងមានផ្ទៃដី ១៨១.០៣៥ គ.ម$^{២}$ ។ កម្ពុជាមានឆ្នេរសមុទ្រប្រវែង ៤៣៥ គ.ម និងមានព្រំដែនដីគោកសរុបប្រវែង ២.៤៣៨ គ.ម ។ ប្រទេសនេះមានព្រំប្រទល់ខាងលិចជាប់នឹងប្រទេសថៃ ខាងកើតជាប់នឹងប្រទេសវៀតណាម និងខាងជើងជាប់នឹងប្រទេសលាវ ។ តាមស្ថានភាពជីវភូមិសាស្ត្រ ប្រទេសកម្ពុជាសំបូរដោយដីទំនាបនៅតាមដងទន្លេមេគង្គ និងបឹងទន្លេសាប ដែលជាតំបន់មានប្រជាជន និងសកម្មភាពកសិកម្មច្រើន ។ ក្រៅពីនេះ ប្រទេសនេះមានតំបន់ភ្នំចំនួនបីនៅភាគនិរតី ភាគខាងជើង និងឦសាន្ត ដែលជាភូមិភាគមានប្រជាជនរស់នៅតិច ហើយសំបូរទៅដោយធនធានព្រៃឈើ ។

លក្ខណៈភូមិសាស្ត្រនេះ បង្កើតឱ្យមានបាតុភូតប្លែក ដែលនៅរដូវវស្សាទឹកទន្លេមេគង្គជន់ ហើយហូរចូលទៅក្នុងបឹងទន្លេសាប ធ្វើបឹងនេះកើនទំហំដល់ប្រមាណបួនដង ។ បឹងទន្លេសាបជាប្រភពផ្តល់ធនធានជីវសាស្ត្រដ៏សំបូរបែប ។ ជាក់ស្តែង ទឹកជំនន់តាមរដូវក្នុងបឹងទន្លេសាប បង្កើតលក្ខខណ្ឌសមស្របសំរាប់ផលិតកម្មស្រូវ និងមច្ឆាជាតិ ដែលនៅតែជាអាហារដ៏សំខាន់នៅប្រទេសកម្ពុជា ។ នេះប្រហែលជាមូលហេតុដែលអាណាចក្រអង្គរបុរាណតាំងនៅជិតមាត់បឹងនេះ ។ ការពិពណ៌នាតាមរយៈចំលាក់លើផ្ទាំងសិលា អំពីរុក្ខជាតិ និងសត្វនានានៅតាមប្រាសាទអង្គរវត្ត ជាសញ្ញាបង្ហាញពីវត្តមានជីវៈចំរុះសំបូរបែប និងសារៈសំខាន់នៃជីវៈចំរុះក្នុងតំបន់នេះ ។ ប្រជាជនជាច្រើនតែងចាត់ទុកប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាប ថាជាបេះដូងនៃប្រទេសជាតិ ។

ទោះបីជាគេនៅពុំទាន់ដឹងច្បាស់អំពីវិសាលភាពនៃជីវៈចំរុះក្នុងប្រទេសកម្ពុជានៅឡើយក្តី ប៉ុន្តែដោយសារប្រទេសកម្ពុជាស្ថិតក្នុងតំបន់ត្រូពិច គេរំពឹងថា ប្រទេសនេះមានប្រភេទសត្វ និងរុក្ខជាតិយ៉ាងសំបូរបែប ហើយត្រូវបានចាត់ទុកជាតំបន់ដែលមានជីវៈចំរុះសំខាន់ ។ បើប្រៀបធៀបនឹងបណ្តាប្រទេសជិតខាង ប្រទេសកម្ពុជាមានដង់ស៊ីតេប្រជាជនទាប ហើយមានផ្ទៃដី [illegible]ភាពធម្មជាតិនៅឡើយ ធំទូលាយ ។

## ការប្រើប្រាស់ជីវៈចំរុះ

ជីវៈចំរុះទ្រទ្រង់សង្គមមនុស្ស ទាំងខាងផ្នែកសេដ្ឋកិច្ច វប្បធម៌ អេកូឡូស៊ី និងខាងស្មារតី ។ ប្រទេសកម្ពុជា ជាទីជំរកនៃសារពាង្គកាយមានជីវិតជាច្រើនប្រភេទ ដែលគេអាចសង្កេតឃើញដោយផ្ទាល់ តាមរយៈការប្រើប្រាស់ធនធានជីវសាស្ត្រ ដូចជា ក្នុងវិស័យកសិកម្ម ព្រៃឈើ និងជលផល ជាដើម ។

ក្នុងវិស័យកសិកម្ម សារៈសំខាន់នៃប្រព័ន្ធអេកូឡូស៊ី ផ្អែកលើប្រភេទដែលនិយមប្រើប្រាស់ជាអាហារ ហើយនានាភាព (ភាពសំបូរបែប) សេនេទិចនៃប្រភេទទាំងនេះ អាចជួយបង្កើនសមត្ថភាពទប់ទល់នឹងជំងឺ និងសត្វចង្រៃនានា ។ ប្រភេទខ្លះទៀតមានសារៈសំខាន់ ក្នុងការត្រួតពិនិត្យសត្វចង្រៃបំផ្លាញដំណាំកសិកម្មនៅក្នុងធម្មជាតិ (ឧទាហរណ៍ : ពួកមំសាសត្វបំផ្លាញពួកសត្វករកេរ សត្វស្លាប ជួយការពារដំណាំដោយវាស៊ីសត្វល្អិតចង្រៃ) ការប្រឆាំងនឹងសត្វចង្រៃ (ឧទាហរណ៍ : សត្វប្រចៀវចាប់សត្វល្អិត ត្រីស៊ីដង្កូវទឹក) ឬមាននាទីក្នុងដំណើរលំអងនៃរុក្ខជាតិ (ឧទាហរណ៍ : ឃ្មុំ) ។ សត្វស្លាបត្រូវបានគេផ្សាំង និងចិញ្ចឹម សំរាប់យកស៊ុត និងសាច់ សត្វក្អែកទឹកត្រូវបានគេប្រើប្រាស់ជាជំនួយក្នុងការនេសាទត្រី ប្រភេទខ្លះមានការទាក់ទាញភ្ញៀវទេសចរ (ឧទាហរណ៍ : ដំរី និង សត្វស្លាប) តែប្រភេទខ្លះទៀតជាបរាសិត និងជាភ្នាក់ងារចំលងជំងឺដល់សត្វចិញ្ចឹម និងមនុស្សផងដែរ (ឧទាហរណ៍ : មូស) ។

## ស្ថានភាពជីវៈចំរុះ

គេច្រើនបញ្ចូលសមាសភាគបីទៅក្នុងនិយមន័យរបស់ជីវៈចំរុះ ពោលគឺ សេនេទិច ប្រភេទ និងប្រព័ន្ធអេកូឡូស៊ី ។ ពតិមានស្តីពីសមាសភាគទាំងបីនេះ ក្នុងប្រទេសកម្ពុជា និងនៅលើពិភពលោក ទំនងជាមានកំរិតខុសគ្នា ។ ជាទូទៅ គេមានការយល់ដឹងច្រើនជាងគេអំពីប្រភេទ ឯការសិក្សាអំពីសេនេទិចត្រូវបានផ្តោតតែលើប្រភេទមួយចំនួនតូចតែប៉ុណ្ណោះ ដែលមានសារៈសំខាន់ក្នុងផ្នែកពាណិជ្ជកម្ម ហើយការសិក្សាអំពីមុខនាទីពិតប្រាកដនៃប្រព័ន្ធអេកូឡូស៊ី ទើបតែត្រូវបានគេយកចិត្តទុកដាក់ នៅពេលថ្មីៗនេះតែប៉ុណ្ណោះ ។ ខាងក្រោមនេះជាការអធិប្បាយដោយសង្ខេបនូវចំណេះដឹងបច្ចុប្បន្ន អំពីស្ថានភាពសមាសភាគទាំងបីនៃជីវៈចំរុះ ក្នុងប្រទេសកម្ពុជា ។

### នានាភាពសេនេទិច

ដោយសារមានការសិក្សាស្រាវជ្រាវតិចតួចប៉ុណ្ណោះ ដែលបានធ្វើនៅក្នុងប្រទេសកម្ពុជា គេមានការយល់ដឹងតិចតួចណាស់អំពីនានាភាពសេនេទិចនៃប្រភេទនានានៅក្នុងប្រទេសកម្ពុជា ។ គេចែកនានាភាពសេនេទិចទាំងឡាយជាធនធានសេនេទិចសត្វ និងរុក្ខជាតិ ហើយជាញឹកញាប់គេច្រើនតែសំដៅលើសេនេទិចនៃសត្វ និងរុក្ខជាតិដែលបានប្រើប្រាស់ដោយមនុស្ស ។

#### *ធនធានសេនេទិចរុក្ខជាតិ*

ពាក់ព័ន្ធនឹងធនធានសេនេទិចរុក្ខជាតិ ការដាំដំណាំនៅក្នុងប្រទេសកម្ពុជាពឹងផ្អែកជាចំបងលើពូជ[illegible] ចាស់ៗ ដែលមានពីមុនមក និងពូជមូលដ្ឋាន (ពូជដែលដុះនៅកន្លែងណាមួយតាំងពីយូរមកហើយ) ។ ផ្ទៃដី[illegible]

ត្រូវ ប្រើប្រាស់ សំរាប់ដាំស្រូវ ពោត ល្ង បន្លែ និងដំឡូងជ្វា ដែលជាប្រភេទពូជមូលដ្ឋាន និងមិនមានការកែលំអ ។ តាមធម្មតា កសិករប្រើប្រាស់ផលិតផលរបស់ខ្លួនធ្វើជាពូជ សំរាប់ដាំនៅរដូវក្រោយៗទៀត ដោយពុំមានធ្វើការផ្លាស់ប្តូរអ្វីឡើយ ។ សត្វចង្រៃ និងពួកភ្នាក់ងារបង្ករោគថ្មីៗ បានរួមចំណែកយ៉ាងច្រើនក្នុងការធ្វើឱ្យបាត់បង់នានាភាព នៃពូជមូលដ្ឋាន ។ ភាពសំបូរបែបត្រូវបានបង្កើតឡើង ក្នុងចំណោមដំណាំនានា ដូចជា ស្រូវ ពោត សណ្តែកសៀង ល្ង ដំឡូងជ្វា សណ្តែកដី និងបន្លែ ។ សួនច្បារ និងសួនដំណាំក្បែរៗផ្ទះ មានដំណាំជាច្រើនប្រភេទខុសៗគ្នា ។ គេនៅខ្វះពត៌មានជាច្រើនស្តីពីរបាយ និងកំណកំណើតប្រភេទរុក្ខជាតិព្រៃ និងដំណាំ ដែលជាសណ្តាននៃប្រភេទរុក្ខជាតិព្រៃ នៅក្នុងប្រទេសកម្ពុជា ។ ប្រការនេះកើតឡើងដោយសារកង្វះខាតការស្រាវជ្រាវវិទ្យាសាស្ត្រជាយថាក្រម ឬការធ្វើចំណែកថ្នាក់ (taxonomy) និងការកំនត់អំពីលក្ខណៈពិសេសនៃពូជនានា ។ ស្រូវជាដំណាំដែលមានច្រើនលើសលុបក្នុងប្រទេសកម្ពុជា ហើយការស្រាវជ្រាវមួយចំនួនដែលបានអនុវត្តដោយកម្មវិធី IRRI បានរកឃើញពូជស្រូវជាង ២.000 និងប្រភេទស្រូវដែលមានសណ្តានពីរុក្ខជាតិព្រៃ ដែលសំណាកនៃពូជទាំងនោះត្រូវបានយកទៅរក្សាទុកក្នុងឃ្លាំងពូជរបស់កម្មវិធី IRRI ។

## *ធនធានសេនេទិចសត្វ*

ប្រទេសកម្ពុជាមានធនធានសេនេទិចសត្វស្រុក និងសត្វព្រៃយ៉ាងសំខាន់ ។ ប៉ុន្តែការសិក្សាអំពីធនធានសេនេទិចសត្វ រឹតតែមានកំរិតទាបជាងការសិក្សាអំពីធនធានសេនេទិចរុក្ខជាតិទៅទៀត ។ ប្រភេទ និងកូនកាត់នៃពូជសត្វស្រុកជាមួយសត្វព្រៃ ដែលគេកត់សំគាល់ឃើញក្នុងប្រទេសកម្ពុជា រួមមានប្រភេទសត្វស្រុក សត្វរួចពីការការចិញ្ចឹមចូលទៅក្នុងព្រៃវិញ (feral) និងប្រភេទសត្វព្រៃ ។ ក្របីស្រុកត្រូវបានគេប្រើប្រាស់ ហើយគេជឿថាក្របីព្រៃនៅមានវត្តមាននៅឡើយ ។ មានពូជជ្រូកកូនកាត់មួយចំនួន រួមទាំងពូជក្នុងស្រុក ពូជបានពីប្រទេសចិន និងពូជមួយចំនួនបានពីអឺរ៉ុប ។ ប្រទេសកម្ពុជាមានពូជប្លែកៗ ដូចជាពូជសេះតឿ (South-East Asian pony) ចំណែកដំរីស្រុកនៅតែមានប្រើនៅឡើយ នៅតាមទីជនបទដាច់ស្រយាលនៃប្រទេសនេះ ។ លើសពីនេះ គេជឿថា ភាគច្រើននៃបសុសត្វលើពិភពលោកមានប្រភពពីប្រភេទ ដែលរស់នៅក្នុងព្រៃនៃតំបន់អាស៊ីអាគ្នេយ៍ ហើយបច្ចុប្បន្នប្រទេសកម្ពុជាមានទាំងប្រភេទពូជផ្សាំងក្នុងស្រុក និងពូជនាំចូលពីប្រទេសក្រៅនៃសត្វមាន់ ក្ងាន ទា និងពូជកូនកាត់ដែលកំពុងប្រឈមគ្រោះថ្នាក់ គឺមាន់បារាំង ។

## នានាភាពប្រភេទ

នៅប្រទេសកម្ពុជា ទោះបីវត្តមាននៃពត៌មានស្តីពីប្រភេទនៅមានកំរិតស្តួចស្តើង ក៏ពត៌មានបែបនេះមានក្រាស់ក្រែលជាង បើប្រៀបធៀបនឹងពត៌មានស្តីពីនានាភាពសេនេទិច ឬពីប្រព័ន្ធអេកូឡូស៊ី ។ ខាងក្រោមនេះជាការប៉ាន់ប្រមាណចំនួនប្រភេទ ដែលគេបានរកឃើញក្នុងប្រទេសកម្ពុជា និងដែលបានមកពីអ្នកនិពន្ធនានា ដែលបានផ្តល់ឯកសារទាំងនោះសំរាប់ការរៀបចំរបាយការណ៍ស្តីពីស្ថានភាពជីវៈចំរុះនៃប្រទេសកម្ពុជា ។

*ប្រភេទថនិកសត្វ*

មានថនិកសត្វដីគោកប្រមាណ ១០០ ប្រភេទ ត្រូវបានកត់ត្រាសំរាប់ប្រទេសកម្ពុជា ។ បច្ចុប្បន្នអង្គការ IUCN (២០០០) បានចុះកត់ត្រានូវថនិកសត្វសរុបចំនួន ៤៩ ប្រភេទដែលកំពុងរងការគំរាមកំហែងជាសាកល ជិតរងការគំរាមកំហែង ឬពុំមានទិន្នន័យគ្រប់គ្រាន់ ហើយដែលប្រភេទខ្លះមានវត្តមានក្នុងប្រទេសកម្ពុជា ។ ប៉ុន្តែ មានសត្វចំនួន ១៧ ប្រភេទ ដែលគេមិនទាន់អាចបញ្ជាក់បាននៅឡើយថា មានវត្តមានក្នុងប្រទេសកម្ពុជា ខ្លះទៀតមិនទំនងជាមានវត្តមានក្នុងប្រទេសកម្ពុជា ចំណែកសត្វប្រចៀវបីប្រភេទទើបតែត្រូវបានរាប់ចូលជាបន្ថែមនៅពេលថ្មីៗនេះ ។ មកទល់សព្វថ្ងៃ ក្នុងចំណោមប្រភេទថនិកសត្វដីគោកដែលបានចុះបញ្ជីអង្គការ IUCN មាន ៣៥ ប្រភេទ ដែលគេបានរកឃើញក្នុងប្រទេសកម្ពុជា ។ ក្នុងចំណោមសត្វទាំងនោះ មានគោព្រៃដែលទំនងជាបានវិនាសផុតពូជក្នុងក្របខ័ណ្ឌពិភពលោក និងរមាសកុយមួយ ដែលទំនងជាបានវិនាសផុតពូជក្នុងក្របខ័ណ្ឌប្រទេសកម្ពុជា ។

*ប្រភេទសត្វស្លាប*

មានសត្វស្លាបជាង ៥០០ ប្រភេទ ត្រូវបានកត់ត្រាសំរាប់ប្រទេសកម្ពុជា ប៉ុន្តែផ្អែកតាមទិន្នន័យពីប្រទេសជិតខាង (ថៃ លាវ និងវៀតណាម) អាចមានសត្វស្លាបលើសពី ៦០០ ប្រភេទ នៅក្នុងប្រទេសកម្ពុជា ។ អង្គការ BirdLife International បានអះអាងថា នៅប្រទេសកម្ពុជាមានសត្វស្លាបចំនួន ៣៩ ប្រភេទ កំពុងរងការគំរាមកំហែងជាសាកល ឬជិតរងការគំរាមកំហែងជាសាកល ។ ក្នុងចំណោមប្រភេទខាងលើនេះ មានសត្វស្លាប ២៥ ប្រភេទ ដែលភាគច្រើនជាសត្វស្លាបទឹកធំៗ ពឹងអាស្រ័យជាសំខាន់លើតំបន់ដីសើម ។ នៅប្រទេសកម្ពុជា មានតំបន់ពីរដែលមានសារៈសំខាន់បំផុតសំរាប់ការអភិរក្សប្រភេទសត្វស្លាប ដែលរងការគំរាមកំហែងជាសាកល គឺបឹងទន្លេសាប តំបន់លិចទឹកជុំវិញបឹងទន្លេសាប និងវាលរាបព្រៃជំរុះស្លឹក (dipterocarp) នៅភាគខាងជើង ។

*ប្រភេទត្រី*

នៅប្រទេសកម្ពុជា គេបានគេប៉ាន់ប្រមាណថា ចំនួនប្រភេទត្រីទឹកសាប មានប្រមាណ ៨៥០-១២០០ ប្រភេទ ។ ប៉ុន្តែតាមរបាយការណ៍របស់ Fishbase ដែលបានសរសេរយោងលើឯកសារជាច្រើន បានប៉ាន់ប្រមាណចំនួនប្រភេទត្រីទឹកសាបក្នុងប្រទេសកម្ពុជាត្រឹម ៤៨៦ និងត្រីសមុទ្រ/ទឹកភ្លាវត្រឹម ៣៥៧ ប្រភេទ ដែលជាសរុបត្រីក្នុងប្រទេសកម្ពុជាមានចំនួន ៨៤៣ ប្រភេទ ។ ប្រភេទត្រីទឹកសាបក្នុងប្រទេសកម្ពុជាមានសភាពប្លែកគ្នាយ៉ាងខ្លាំង ដោយសារភាពផ្សេងៗគ្នានៃប្រព័ន្ធអេកូឡូស៊ី និងការប្រែប្រួលខាងផ្នែកភូគព្ភសាស្ត្រជាប្រវត្តិសាស្ត្រ ។ ជាទូទៅ ឈូងសមុទ្រថៃ និងដែនទឹកតំបន់ឆ្នេរនៃសមុទ្រចិនភាគខាងត្បូង ពិសេសដែនទឹកជិតប្រទេសកម្ពុជា ត្រូវបានគេបង្ហាញថា ជាតំបន់ដែលមានផលិតភាពជីវសាស្ត្រខ្ពស់ និងជាកន្លែងដ៏ល្អសំរាប់ត្រីពងកូន ។ គេរំពឹងថា នៅពេលមានការស្រាវជ្រាវវិទ្យាសាស្ត្រថ្មីៗបន្ថែម គេនឹងអាចរកឃើញត្រីជាច្រើនប្រភេទបន្ថែមទៀត ក្នុងប្រទេសកម្ពុជា ។

*ប្រភេទថលជលិក និងល្មូន*

ការសិក្សាអង្កេតពពួកថលជលិក និងល្មូនទើបបានធ្វើឡើងនៅពេលថ្មីៗនេះប៉ុណ្ណោះ ហើយពុំទាន់មានការសិក្សាធ្វើចំណែកថ្នាក់ (taxonomy) ឱ្យបានល្អិតល្អន់ ឬការត្រួតពិនិត្យលទ្ធផលនៃការស្រាវជ្រាវប្រកបដោយប្រសិទ្ធិភាពនៅឡើយទេ ។ ដូច្នេះ គេនៅពុំទាន់អាចធ្វើការសន្និដ្ឋានពីចំនួនប្រភេទបានឡើយ ។ ប៉ុន្តែ មានសត្វល្មូនចំនួន ២៨ ប្រភេទ ដែលមានចុះក្នុងបញ្ជីអនុសញ្ញា CITES សំរាប់ប្រទេសកម្ពុជា ដែលជាការបង្ហាញពីសារៈសំខាន់ជាអន្តរជាតិ និងប្រចាំតំបន់ នៃបណ្តាប្រភេទទាំងនោះដែលគេបានរកឃើញមានក្នុងប្រទេសកម្ពុជា ។ ការសិក្សាថ្មីៗនេះអាចនឹងបង្ហាញលទ្ធផលដែលមានជាក់លាក់ជាងមុន សំរាប់ការប៉ាន់ប្រមាណអំពីចំនួនប្រភេទសត្វល្មូន និងថលជលិកក្នុងប្រទេសកម្ពុជា ។

*ប្រភេទរុក្ខជាតិ*

មកទល់បច្ចុប្បន្ន គេនៅពុំមានការវាយតំលៃជាក់លាក់ណាមួយអំពីទំហំនៃសារពើរុក្ខជាតិក្នុងប្រទេសកម្ពុជានៅឡើយ ។ អ្នកស្រី Dy Phon (1982) បានអះអាងថា មានរុក្ខជាតិចំនួន ២.៣០៨ ប្រភេទ ដែលគេបានស្គាល់ ប៉ុន្តែចំនួននេះហាក់ដូចជាមានកំរិតទាបពេកណាស់ បើប្រៀបធៀបនឹងការប៉ាន់ប្រមាណសរុប ១២.០០០-១៥.០០០ ប្រភេទ សំរាប់ប្រទេសលាវ កម្ពុជា និងវៀតណាមរួមគ្នា ។ គេមិនរំពឹងថាប្រទេសកម្ពុជាមានរុក្ខជាតិសាមីក្នុងកំរិតខ្ពស់នោះទេ ប៉ុន្តែព្រៃសើមនៃជួរភ្នំក្រវាញ និងជួរភ្នំដំរី និងព្រៃលិចទឹកបឹងទន្លេសាប អាចជាទីដែលមានប្រភេទរុក្ខជាតិដុះតែនៅក្នុងប្រទេសកម្ពុជា ។

**នានាភាពប្រព័ន្ធអេកូឡូស៊ី**

ប្រទេសកម្ពុជាមានប្រព័ន្ធអេកូឡូស៊ីជាច្រើនបែបគួរឱ្យចាប់អារម្មណ៍ ដែលរួមមាន តំបន់ឆ្នេរ តំបន់ដីសើម ព្រៃឈើ និងតំបន់កសិកម្ម ។ តំបន់ឆ្នេរមាន ផ្កាថ្ម ស្មៅសមុទ្រ កោះ និងព្រៃកោងកាង ដែលគេប្រទះឃើញនៅតាមបណ្តោយឆ្នេរសមុទ្រប្រវែង ៤៣៥ គ.ម ។ វិសាលភាពធំធេងនៃតំបន់ដីសើមគ្របដណ្តប់លើផ្ទៃដីរហូតដល់ ៣០% នៃផ្ទៃប្រទេសទាំងមូល និងមានទំនាក់ទំនងជាមួយស្ថានភាពភូមិសាស្ត្រ ទន្លេមេគង្គ និងអាកាសធាតុមូសុង ។ ព្រៃឈើ ដែលកាលពីមុនបានគ្របដណ្តប់លើផ្ទៃប្រទេសភាគច្រើនជាគំរបបៃតង រួមមាន ព្រៃតំបន់ទំនាប ព្រៃតំបន់ភ្នំ និងព្រៃមិនប្រចាំតំបន់ (azonal) ។ សំរាប់ប្រជាជនកម្ពុជា តំបន់ដែលមានសារៈសំខាន់បំផុត គឺប្រព័ន្ធអេកូឡូស៊ីកសិកម្ម ដែលនៅទីនោះជាកន្លែងផលិតកម្មស្រូវ និងការធ្វើកសិកម្មពនេចរច្រើនលើសលុប ។ ប្រព័ន្ធអេកូឡូស៊ីទាំងនេះរួមគ្នា បង្កើតបានជាប្រព័ន្ធតូចៗ (mosaic) នៃផ្ទៃប្រទេស ហើយដែលប្រព័ន្ធធម្មជាតិបែបនេះ បង្កើតជាគំរូនៃការប្រើប្រាស់ដីដូចមាននាពេលបច្ចុប្បន្ន ។

## ការគំរាមគំហែងចំពោះជីវៈចំរុះ

ការបាត់បង់ជីវៈចំរុះគឺជាការគំរាមគំហែងដ៏ធំបំផុតដល់ជីវៈចំរុះ ។ ការវិនាសផុតពូជ ឬការស្លាប់នៃប្រភេទទាំងមូល ការបាត់បង់ជំរកធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ីដែលមានលក្ខណៈប្លែកពីគេ ឬការថយចុះនៃភាពសំបូរបែបសេនេទិចនៅក្នុងប្រភេទមួយ គឺសុទ្ធតែចាត់ទុកថាជាការបាត់បង់ជីវៈចំរុះ ។ ដោយសារយើងមានការយល់ដឹងតិចតួចអំពីជីវៈចំរុះ យើងពុំបានដឹងថា តើមានការបាត់បង់ជីវៈចំរុះប៉ុន្មាននោះទេ ហេតុនេះយើងតែងតែមានការលំបាកក្នុងការស្វែងយល់អំពីការគំរាមគំហែងចំពោះជីវៈចំរុះ ។

ការគំរាមគំហែងចំបងចំពោះជីវៈចំរុះកើតចេញពីសំពាធនៃកំនើនប្រជាជន អវត្តមាននៃការធ្វើផែនការ ភាពទន់ខ្សោយនៃការអនុវត្តន៍ច្បាប់គ្រប់គ្រងធនធានធម្មជាតិ និងភាពមិនច្បាស់លាស់អំពីកម្មសិទ្ធិដីធ្លី ។ ដោយទើបឆ្លងផុតពីសង្គ្រាម និងកោលាហលរយៈពេលបីទសវត្សរ៍កន្លងមកនេះ ប្រទេសកម្ពុជាត្រូវការបង្កើតឡើងវិញនូវក្របខ័ណ្ឌស្ថាប័នរបស់ខ្លួន និងមានតំរូវការបន្ទាន់ជាច្រើនសំរាប់ការអភិវឌ្ឍន៍ ។ ប្រជាជនភាគច្រើននៅក្នុងប្រទេសកម្ពុជា ពឹងផ្អែកដោយផ្ទាល់លើធនធានជីវសាស្ត្រសំរាប់ការចិញ្ចឹមជីវិតរបស់ពួកគេ ប៉ុន្តែធនធានជីវសាស្ត្រត្រូវបានធ្វើឯកជនភាវូបនីយកម្ម ហើយក្នុងករណីជាច្រើនត្រូវបានគេធ្វើអាជីវកម្មហួសហេតុ ។ រាជរដ្ឋាភិបាលបានចាត់វិធានការដ៏សំខាន់ជាច្រើន ដើម្បីកាត់បន្ថយការគំរាមគំហែងចំពោះជីវៈចំរុះ ដោយបង្កើនការគ្រប់គ្រងតាមបែបសហគមន៍ និងអភិបាលកិច្ចល្អ ប៉ុន្តែកង្វល់ដ៏ធំបំផុតគឺគេត្រូវការពេលវេលា និងធនធានចាំបាច់សំរាប់អនុវត្តនូវវិធានការទាំងនេះ ។

តំបន់មួយចំនួននៅពុំទាន់ទទួលការរំខាននៅឡើយ ដោយសារគេចាត់ទុកថា ពុំមានសុវត្ថិភាពគ្រប់គ្រាន់ ។ ក្នុងឆ្នាំកន្លងទៅថ្មីៗនេះ ជាមួយនឹងកំនើនសន្តិសុខនៅទូទាំងប្រទេស មានការផ្លាស់ប្តូរទីកន្លែងរបស់ប្រជាជន ចូលទៅក្នុងតំបន់នានា ដែលពីមុនត្រូវបានគេគិតថាពុំមានសុវត្ថិភាព ។ ដូច្នេះហើយ សកម្មភាពប្រហាក់ប្រហែលគ្នានៃធ្វើអាជីវកម្មធនធានធម្មជាតិដោយពុំមាននិរន្តរភាព កំពុងកើតមានឡើងនៅទូទាំងប្រទេស ។ ប្រសិនបើនិន្នាការបែបនេះនៅតែបន្ត តំបន់មួយចំនួនដែលមានសារៈសំខាន់សំរាប់ការអភិរក្សជីវៈចំរុះអាចនឹងរេចរឹល ឬបាត់បង់យ៉ាងឆាប់រហ័ស ហើយផលវិបាកធ្ងន់ធ្ងរនឹងកើតមានចំពោះបរិស្ថាន និងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ។

បច្ចុប្បន្ន យើងដឹងថា មានការគំរាមកំហែងដោយផ្ទាល់ជាច្រើនបែប ដែលបង្កឱ្យបាត់បង់ជីវៈចំរុះ ។ ក្នុងចំណោមការគំរាមកំហែងទាំងនោះ គេអាចចាត់ទុកកំនើនចំនួនប្រជាជន ថាជាឫសគល់នៃមូលហេតុ ដោយសារវាជាមូលដ្ឋាននៃការគំរាមកំហែងផ្សេងៗទៀត ។ ការគំរាមកំហែងដទៃទៀតរួមមាន កង្វះខាតចំណេះដឹង បញ្ហាគោលនយោបាយ ការធ្វើពាណិជ្ជកម្មអន្តរជាតិ វិសមធម៌ កង្វះការចូលរួម គ្រោះធម្មជាតិ មហន្តរាយបង្កដោយមនុស្ស ការប្រែប្រួលអាកាសធាតុ ការបាត់បង់ទីជំរក ការធ្វើអាជីវកម្មហួសហេតុចំពោះធនធានជីវសាស្ត្រ ការធ្វើពាណិជ្ជកម្មសត្វព្រៃ ការបំពុលបរិស្ថាន ការធ្វើកសិកម្មទំនើប ការរាតត្បាតនៃប្រភេទមកពីក្រៅប្រទេស និងជីវបច្ចេកវិទ្យា ។ ការគ្រប់គ្រងរាល់ការគំរាមកំហែងទាំងនេះក្នុងពេលបច្ចុប្បន្ន មានសារៈសំខាន់ណាស់ ព្រោះថានៅពេលដែលមានកំនើនចំនួនប្រជាជន ការគំរាមគំហែងទាំងនេះនឹងបង្កជាបញ្ហាកាន់តែច្រើន និងស្មុគស្មាញសំរាប់ប្រទេសកម្ពុជា នាពេលអនាគត ។

## សន្និដ្ឋាន

សេចក្ដីសង្ខេបអំពីជីវៈចំរុះ ដែលបានបង្ហាញជូនខាងលើនេះ ផ្អែកលើពតិមានមួយចំនួន ដែលមានក្នុងប្រទេសកម្ពុជា និងជាការបង្ហាញអំពីបញ្ហាខ្លះៗ ដែលទាក់ទងទៅនឹងជីវៈចំរុះ ។ យោងតាមពតិមានស្ដួចស្ដើងដែលមានបច្ចុប្បន្ន គេសង្កេតឃើញថា ប្រទេសកម្ពុជាសំបូរទៅដោយនានាភាពសេនេទិច ប្រភេទ និងប្រព័ន្ធអេកូឡូស៊ី ច្រើនបែបប្លែកៗគ្នា ហើយសមាសភាគទាំងអស់នៃជីវៈចំរុះទាំងនេះ ក៏កំពុងរងការគំរាមកំហែងផងដែរ ។ ពាក់ព័ន្ធនឹងជីវៈចំរុះក្នុងប្រទេសកម្ពុជា គេនៅមានប្រការជាច្រើនដែលទាមទារឱ្យមានការសិក្សាជាបន្ថែមទៀត ប៉ុន្តែកម្ពុជាបានអនុវត្តរួចមកហើយនូវវិធានការជាជំហានដំបូងរបស់ខ្លួន សំដៅឈានទៅពង្រីកចំណេះដឹង ពង្រឹងការយល់ដឹង និងការឱ្យតំលៃជីវៈចំរុះ ។ នៅពេលយើងបានសិក្សាកាន់តែច្រើនអំពីជីវៈចំរុះ យើងនឹងទទួលស្គាល់អំពីសារៈសំខាន់របស់វា ចំពោះការរីកចំរើននៃប្រទេសកម្ពុជា និងគុណភាពនៃការរស់នៅជាទូទៅ ។ ប្រការនេះអាចនឹងកើតឡើងបាន លុះត្រាណាតែប្រជាជនមានឆន្ទៈការពារ គ្រប់គ្រង និងប្រើប្រាស់ជីវៈចំរុះក្នុងប្រទេសកម្ពុជាប្រកបដោយនិរន្តរភាព ។

ពតិមានអំពីជីវៈចំរុះក្នុងប្រទេសកម្ពុជាមានតិចតួចតែប៉ុណ្ណោះ ជាពិសេសច្រើនតែមានក្នុងឯកសារ ដែលគេចាត់ទុកថាមានពតិមានមិនទាន់ច្បាស់លាស់ ព្រោះពតិមានទាំងនោះបានពីប្រភពដែលពុំទាន់ឆ្លងកាត់ការត្រួតពិនិត្យតាមបែបវិទ្យាសាស្ត្រឱ្យបានល្អិតល្អន់នៅឡើយ ។ ប៉ុន្តែ គេមិនត្រូវចាត់ទុកកង្វះពតិមានតាមបែបវិទ្យាសាស្ត្របែបនេះ ថាជាហេតុផល ជាលេស ដើម្បីពុំធ្វើសកម្មភាពអ្វីសោះនោះឡើយ តែផ្ទុយទៅវិញ គេត្រូវតែយល់ថា វាជាហេតុផលសំរាប់ឱ្យមានការប្រុងប្រយ័ត្ន ចំពោះការអនុវត្តនីវិធានការពាក់ព័ន្ធនានា ។ បច្ចុប្បន្ន មូលដ្ឋានពតិមានអំពីជីវៈចំរុះនៅកម្ពុជាកំពុងត្រូវបានពង្រីកជាបណ្ដើរៗ ហើយកំនើននៃចំណេះដឹង និងការយល់ដឹងបែបនេះ អាចជាជំនួយនៅក្នុងការប្រើប្រាស់ ការពារ និងគ្រប់គ្រងជីវៈចំរុះ សំរាប់ការអភិវឌ្ឍន៍ដោយចីរភាពនៅក្នុងប្រទេសកម្ពុជា ។

ជីវៈចំរុះនៅប្រទេសកម្ពុជាកំពុងរងការគំរាមគំហែងជាច្រើន ។ គួបផ្សំនឹងកំនើនចំនួនប្រជាជន ការគំរាមកំហែងទាំងនេះអាចនឹងបង្កើនអត្រានៃការបាត់បងជីវៈចំរុះ ។ នៅពេលដែលជីវៈចំរុះកាន់តែច្រើនត្រូវបាត់បង់ គេកាន់តែមានការលំបាកថែមទៀតក្នុងការកំនត់មាគ៌ាឆ្ពោះទៅការអភិវឌ្ឍន៍ដោយចីរភាព និងភាពរុងរឿងនាពេលអនាគត សំខាន់ជាងនេះទៀត គឺគេនឹងកាន់តែមានការលំបាក ក្នុងការធានារក្សាសន្តិសុខស្បៀង និងមុខងារប្រព័ន្ធអេកូឡូស៊ី ដែលជាមូលដ្ឋានទ្រទ្រង់គុណភាពនៃការរស់នៅ ។

រាជរដ្ឋាភិបាលកម្ពុជា និងអង្គការអន្តរជាតិនានា បានទទួលស្គាល់នូវសារៈសំខាន់នៃជីវៈចំរុះក្នុងប្រទេសកម្ពុជា និងកំពុងបង្ហាញនូវការចាប់អារម្មណ៍កាន់តែខ្លាំងឡើង ក្នុងការអនុវត្តន៍សកម្មភាព ដែលអាចកាត់បន្ថយការគំរាមគំហែងចំពោះជីវៈចំរុះ ។ សកម្មភាពជាច្រើន ដែលកំពុងអនុវត្តនៅពេលបច្ចុប្បន្ន ផ្ដោតជាពិសេសលើទំនាក់ទំនងចំបងរវាងជីវៈចំរុះ និងការអភិវឌ្ឍន៍ដោយចីរភាព ព្រមជាមួយនឹងការលើកទឹកចិត្តឱ្យមានកិច្ចការពារសមាសភាគសំខាន់ៗ ដែលជាតំណាងឱ្យជីវៈចំរុះក្នុងប្រទេស ។ វិធីសាស្ត្របែបនេះនឹងជួយធានាសមត្ថភាពស្ថាប័ន និងប្រជាជនកម្ពុជា ដើម្បីប្រើប្រាស់ ការពារ និងគ្រប់គ្រងជីវៈចំរុះ សំរាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងភាពរុងរឿងទៅអនាគត ។

# យុទ្ធសាស្ត្រ

## ទស្សនៈវិស័យនៃជីវៈចំរុះ

ការអភិវឌ្ឍន៍ប្រទេសកម្ពុជា មានគោលដៅឆ្ពោះទៅការកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កើនសន្ទុះរីកចំរើននៃសេដ្ឋកិច្ច និរន្តរភាពបរិស្ថាន និងសមធម៌សង្គម ។ ក្នុងន័យនេះ ប្រជាជនកម្ពុជាមានទស្សនៈស្របគ្នាអំពីជីវៈចំរុះ ដូចខាងក្រោម :

*" វិបុលភាពសេដ្ឋកិច្ចប្រកបដោយសមធម៌ និងគុណភាពនៃការរស់នៅកាន់តែប្រសើរឡើង តាមរយៈការប្រើប្រាស់ កិច្ចការពារ និងការគ្រប់គ្រងធនធានជីវសាស្ត្រ ដោយនិរន្តរភាព "* ។

## ការថ្លែងនូវបេសកកម្ម

*ប្រើប្រាស់ ការពារ និងគ្រប់គ្រងជីវៈចំរុះសំរាប់ការអភិវឌ្ឍន៍ដោយចីរភាពនៅកម្ពុជា*

## គោលដៅចំបង

- ថែទាំជីវៈចំរុះ និងផលិតភាពនៃប្រព័ន្ធអេកូឡូស៊ី តាមរយៈកិច្ចការពារប្រភេទនានានៃសារពាង្គកាយមានជីវិត ទាំងនៅក្នុងបរិស្ថានធម្មជាតិ ទាំងនៅក្នុងបរិស្ថានសិប្បនិម្មិត ជាពិសេស ព្រៃឈើ ប្រព័ន្ធអេកូឡូស៊ីទឹកសាប សមុទ្រ តំបន់ដីសើម និងដីកសិកម្ម ។
- គ្រប់គ្រងសកម្មភាពមនុស្ស និងប្រើប្រាស់ធនធានជីវសាស្ត្រ តាមវិធីដែលអាចរក្សាការពារ សំរាប់រយៈពេលវែង នូវធនធានធម្មជាតិ ដែលមានសារៈប្រយោជន៍ចាំបាច់សំរាប់ជីវិតមនុស្ស និងការអភិវឌ្ឍន៍ ។
- ធានាថា ផលប្រយោជន៍បានពីការប្រើប្រាស់ដោយនិរន្តរភាពនូវធនធានជីវសាស្ត្រ នឹងរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកំពស់គុណភាពនៃការរស់នៅ សំរាប់ជនកម្ពុជាគ្រប់រូប ។

## គោលការណ៍គ្រឹះ

- ជីវៈចំរុះមានតំលៃខាងផ្នែកអេកូឡូស៊ី សេដ្ឋកិច្ច សង្គម វប្បធម៌ និងតំលៃអត្ថិភាព ។
- ប្រជាជនកម្ពុជាពឹងអាស្រ័យលើជីវៈចំរុះ និងមានការទទួលខុសត្រូវ ក្នុងការរួមវិភាគទានដល់ការអភិរក្សជីវៈចំរុះ និងប្រើប្រាស់ធនធានជីវសាស្ត្រដោយនិរន្តរភាព ។
- ប្រជាជនកម្ពុជាគ្រប់រូបនឹងត្រូវបានលើកទឹកចិត្តឱ្យធ្វើការស្វែងយល់ និងទទួលស្គាល់តំលៃនៃជីវៈចំរុះ ព្រមទាំងចូលរួមក្នុងការធ្វើសេចក្តីសំរេច ពាក់ព័ន្ធនឹងការប្រើប្រាស់ទឹក ដីធ្លី រុក្ខជាតិ សត្វ និងធនធានដទៃទៀត ។
- វិធីដោះស្រាយតាមអេកូឡូស៊ីក្នុងការគ្រប់គ្រងធនធាន (ecological approach) គឺជាវិធីសំខាន់ជាងគេក្នុងការអភិរក្សជីវៈចំរុះ និងការប្រើប្រាស់ធនធានជីវសាស្ត្រដោយនិរន្តរភាព ។

- រាល់ការធ្វើសេចក្តីសំរេចពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ ត្រូវឆ្លុះបញ្ចាំងអំពីតំលៃខាងផ្នែកអេកូឡូស៊ី សេដ្ឋកិច្ច សង្គម និង តំលៃផ្នែកស្មារតី នៃប្រជាជនមូលដ្ឋាន ។
- ប្រព័ន្ធអេកូឡូស៊ីដែលមានស្ថានភាពល្អ និងមានការវិវត្តន៍តាមធម្មជាតិ និងការថែទាំដំណើរធម្មជាតិ គឺជាលក្ខខណ្ឌ ចាំបាច់នៃការអភិរក្សជីវៈចំរុះនៅនឹងកន្លែង និងការប្រើប្រាស់ធនធានជីវសាស្ត្រដោយនិរន្តរភាព ។
- គេអាចគួរឱ្យមានការចាត់វិធានការអភិរក្សនៅក្រៅតំបន់ សំរាប់ទ្រទ្រង់ការអភិរក្សប្រភេទ និងបណ្តាភាវៈមួយចំនួន ហើយវិធានការទាំងនេះមានសារៈសំខាន់ ដើម្បីធានាការប្រើប្រាស់ដោយនិរន្តរភាពនៃធនធានកសិកម្ម ព្រៃឈើ និង ធនធាននៅក្នុងទឹក ។
- ត្រូវទទួលស្គាល់ចំណេះដឹង ការច្នៃប្រឌិត និងទំលាប់អនុវត្តន៍របស់សហគមន៍មូលដ្ឋាន និងត្រូវប្រើប្រាស់ ព្រមទាំងថែ រក្សាចំណេះដឹង ការច្នៃប្រឌិត និងទំលាប់អនុវត្តន៍ទាំងនោះ ដោយមានការគាំទ្រ និងចូលរួមពីសហគមន៍ ទាំងនោះផង ។
- ត្រូវប្រើប្រាស់ចំណេះដឹងប្រសើរបំផុតដែលមាន និងវិធីសាស្ត្រដែលបានសិក្សាសំរាំងជាប្រចាំ នៅក្នុងការអភិរក្សជីវៈចំរុះ និងការប្រើប្រាស់ធនធានជីវសាស្ត្រដោយនិរន្តរភាព ។
- កិច្ចសហប្រតិបត្តិការនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងកំរិតពិភពលោក ក៏ដូចជាការចែករំលែកចំណេះដឹង ថ្លៃចំណាយ និង ផលប្រយោជន៍ គឺជាប្រការចាំបាច់នៅក្នុងការអភិរក្សជីវៈចំរុះ និងការប្រើប្រាស់ធនធានជីវសាស្ត្រដោយនិរន្តរភាព ។

## ការអង្កេតតាមដាន និងការវាយតំលៃនៅក្នុងការអនុវត្តន៍យុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះជាតិ

គេត្រូវចាត់ទុកយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះនេះ ថាជាដំណើរការមួយ ដែលត្រូវអនុវត្តនៅពេលបច្ចុប្បន្ន និងត្រូវធ្វើបន្តជាប់ជានិច្ចទៅអនាគត ព្រមទាំងត្រូវអនុវត្តជាលំដាប់លំដោយ ទៅតាមដំណាក់កាលជាទៀងទាត់ ហើយសកម្មភាព នានា ដែលមានចែងក្នុងយុទ្ធសាស្ត្រនេះ នឹងត្រូវអនុវត្ត ស្របគ្នានឹងការអភិវឌ្ឍន៍ប្រទេស ក្នុងក្របខ័ណ្ឌតំបន់ និងអន្តរជាតិ ។ ក្នុងន័យនេះ អ្នកធ្វើផែនការថ្នាក់ជាតិនឹងក្លាយជាអ្នកអនុវត្តផែនការជាតិ ដើម្បីធានាថា ការអភិរក្សជីវៈចំរុះមាននិរន្តរភាព ហើយ ការគ្រប់គ្រងជីវៈចំរុះអាចមានឥទ្ធិពលវិជ្ជមានចំពោះសេដ្ឋកិច្ចជាតិ និងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ។ យន្តការនានា ដែល បានស្នើឡើង សំរាប់ការអនុវត្តន៍យុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះជាតិនេះ រួមមាន :

- សំរបសំរួលការអនុវត្តន៍ចំនុចដែលមានសារៈសំខាន់នៅថ្នាក់ជាតិ និងអន្តរជាតិ ដែលមានចែងក្នុងយុទ្ធសាស្ត្រនេះ តាម រយៈគណៈកម្មាធិការអន្តរក្រសួងដឹកនាំការងារជីវៈចំរុះ និងលេខាធិការដ្ឋានជាតិសំរាប់កិច្ចការជីវៈចំរុះ ។
- ចងក្រងរបាយការណ៍ជាតិប្រចាំឆ្នាំ ស្តីពីគោលនយោបាយ សកម្មភាព និងផែនការអនុវត្តន៍យុទ្ធសាស្ត្រ ។
- វិធានការនានាដែលអនុញ្ញាត និងលើកទឹកចិត្តឱ្យមានការចូលរួមពីសំណាក់ស្ថាប័នមិនមែនរដ្ឋាភិបាល ក្នុងការអនុវត្តន៍ យុទ្ធសាស្ត្រនេះ ។
- ធ្វើរបាយការណ៍ជាទៀងទាត់អំពីសន្ទស្សន៍នៃការអនុវត្តន៍គោលបំណងជាយុទ្ធសាស្ត្រនីមួយៗ ។
- រាយការណ៍ស្តីពីស្ថានភាពនៃជីវៈចំរុះក្នុងប្រទេស ។
- ពិនិត្យ និងកែសំរួលយុទ្ធសាស្ត្រនេះ ក្រោយពីបានអនុវត្តជំហានដំបូង ដែលមានរយៈពេល ២ ឆ្នាំ ។

ជោគជ័យនៃការអនុវត្តន៍យុទ្ធសាស្ត្រនេះ អាស្រ័យទៅនឹងកំរិតនៃការទទួលយកនូវចក្ខុវិស័យ និងគោលការណ៍នានារបស់យុទ្ធសាស្ត្រ និងការរួមចំណែកសំរេចគោលដៅនៃយុទ្ធសាស្ត្រនេះ ពីសំណាក់ប្រជាជនគ្រប់ស្រទាប់ក្នុងសង្គម ។ ប្រការសំខាន់គឺថា ការអភិរក្សជីវៈចំរុះ និងការប្រើប្រាស់ធនធានជីវសាស្ត្រដោយនិរន្តរភាព ទាមទារឱ្យមានការគាំទ្រ និងការចូលរួមពីប្រជាជនគ្រប់រូប សហគមន៍មូលដ្ឋាន អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ក្រុមអភិរក្ស ស្ថាប័នពាណិជ្ជកម្ម ឧស្សាហកម្ម អប់រំ និងស្ថាប័នស្រាវជ្រាវ ។

ដើម្បីតាមដាន និងវាយតំលៃដំណើរការរីកចំរើនតាមរយៈរបាយការណ៍ គេចាំបាច់ត្រូវកំនត់គោលដៅសំរាប់សន្ទស្សន៍មួយចំនួននៅក្នុងផែនការនេះ ។ គេអាចប្រើប្រាស់តារាងម៉ាទ្រិចស្តីពីសកម្មភាព និងសន្ទស្សន៍ ដែលមានចែងក្នុងឯកសារយុទ្ធសាស្ត្រ និងផែនការសកម្មភាពនេះ (ឧបសម្ព័ន្ធ ១) សំរាប់តាមដាន និងវាយតំលៃប្រសិទ្ធិភាពនៃការអនុវត្តន៍យុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះ តាមរយៈសន្ទស្សន៍សំរាប់ប្រធានបទពាក់ព័ន្ធនឹងសកម្មភាពនីមួយៗ ។

យុទ្ធសាស្ត្រនេះចែងអំពីក្របខ័ណ្ឌសំរាប់អនុវត្តសកម្មភាពនៅគ្រប់លំដាប់ថ្នាក់ ដែលនឹងជួយពង្រឹងសមត្ថភាពក្នុងការធានាផលិតភាព ភាពសំបូរបែប និងភាពគង់វង្សនៃប្រព័ន្ធធម្មជាតិ ព្រមទាំងជួយពង្រឹងប្រទេសកម្ពុជា ឱ្យក្លាយជាប្រជាជាតិ ដែលមានសមត្ថភាពធ្វើការអភិវឌ្ឍន៍ដោយចីរភាព ។ យុទ្ធសាស្ត្រនេះជំរុញការអភិរក្សជីវៈចំរុះ និងការប្រើប្រាស់ធនធានជីវសាស្ត្រដោយនិរន្តរភាព ព្រមទាំងបង្ហាញពីវិធីដែលប្រទេសកម្ពុជាអាចរួមចំណែក ក្នុងកិច្ចប្រឹងប្រែងជាអន្តរជាតិ ដើម្បីអនុវត្តអនុសញ្ញាស្តីពីជីវៈចំរុះ ។

ផែនការសកម្មភាពចែងពីបណ្តាសកម្មភាពជាអាទិភាពសំរាប់ក្រសួង នាយកដ្ឋាន និងអង្គភាពនានា ដើម្បីប្រតិបត្តិនៅក្នុងដំណាក់កាលអនុវត្តន៍នៃផែនការនេះ ។ បណ្តាសកម្មភាពជាអាទិភាព ដែលអនុម័តដោយរាជរដ្ឋាភិបាល អាចចែកជាបីក្រុមដូចខាងក្រោម :

- សកម្មភាពបង្កើនការយល់ដឹង និងកសាងសមត្ថភាពមន្ត្រីរដ្ឋាភិបាល ក៏ដូចជាសហគមន៍មូលដ្ឋាន សំរាប់អភិរក្សជីវៈចំរុះ និងប្រើប្រាស់ធនធានជីវសាស្ត្រដោយនិរន្តរភាព ។
- សកម្មភាពជំរុញឱ្យមានការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ។
- សកម្មភាពសំដៅកែសំរួលដែនសិទ្ធិអំណាចរបស់ស្ថាប័ន កាត់បន្ថយភាពត្រួតគ្នានៃការទទួលខុសត្រូវ និងជំរុញការងារសំរបសំរួល និងកិច្ចសហប្រតិបត្តិការអន្តរក្រសួង ក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ដោយចីរភាព ។

ដើម្បីអនុវត្តតាមផែនការសកម្មភាពនេះ គេត្រូវរៀបចំគំរោង និងកំណត់សកម្មភាពនានា ផ្អែកតាមគោលការណ៍ណែនាំដែលមានចែងក្នុងយុទ្ធសាស្ត្រនេះ ដោយផ្តោតការយកចិត្តទុកដាក់ចំពោះការកសាងសមត្ថភាព ការចូលរួមរបស់សហគមន៍ និងកិច្ចសហប្រតិបត្តិការអន្តរស្ថាប័ន ។

## ការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះជាតិ

យុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះជាតិបានត្រូវរៀបចំឡើង ដោយមានការជួបប្រជុំជាមួយស្ថាប័ន[illegible] សិក្ខាសាលាស្តីពីជីវៈចំរុះថ្នាក់ជាតិចំនួនពីរ និងថ្នាក់ខេត្តចំនួនបី ។ សិក្ខាសាលាបានលើកឡើងនូវចំនុចជាគន្លឹះ[illegible]ជីវៈចំរុះនៅក្នុងប្រទេសកម្ពុជា ដែលមានអធិប្បាយនៅក្នុងប្រធានបទនីមួយៗ ។ ស្ថាប័នជំនាញនីមួយៗបានផ្តល់ពត៌មាន និង[illegible]

ប្រធានបទពាក់ព័ន្ធ ជាពិសេសបានបង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ចំពោះសកម្មភាពជាអាទិភាព ដែលពាក់ព័ន្ធនឹងប្រធានបទទាំងនេះ ។

## ទំនាក់ទំនងរវាងបណ្តាប្រធានបទដែលមានចែងក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះ

ប្រធានបទនីមួយៗ ដែលមាននៅក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពនេះ បានបង្ហាញពីវិធីសាស្ត្ររបស់ស្ថាប័ននីមួយៗ ក្នុងការគ្រប់គ្រងជីវៈចំរុះ ។ ដោយសារជីវៈចំរុះគឺជាបញ្ហាអន្តរស្ថាប័ន ដូច្នេះនៅក្នុងប្រធានបទទាំងនោះ មានចំនុចត្រួតគ្នាជាច្រើន ប៉ុន្តែចំនុចត្រួតគ្នានេះអាចចាត់ទុកថាជាការបំពេញឱ្យគ្នា តែមិនមែនជាការធ្វើជាន់គ្នាទេ ។ នេះគឺជាផែនការដំបូងបំផុត ប៉ុន្តែយើងសង្ឃឹមថា នៅពេលអនាគត ផែនការនេះនឹងត្រូវកែសំរួលឡើងវិញ ដោយមានការពិចារណាបានប្រសើរជាងនេះ អំពីទំនាក់ទំនងអន្តរស្ថាប័ន រវាងប្រធានបទនានា ។

# ប្រធានបទទី ១ : កិច្ចការពារធនធានធម្មជាតិ

## ១.១ តំបន់ការពារធម្មជាតិ

### បរិបទ

កម្ពុជាគឺជាប្រទេសទីមួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលបានបង្កើតឧទ្យានជាតិនៅឆ្នាំ ១៩២៥ ដែលនៅពេលនោះ ផ្ទៃដីព្រៃឈើ ១០.៨០០ ហិចតា ជុំវិញប្រាសាទអង្គរវត្ត ត្រូវបានប្រកាសជាតំបន់ការពារធម្មជាតិ ។ នៅឆ្នាំ ១៩៦៩ ប្រទេសកម្ពុជា បានបង្កើតឧទ្យានជាតិ និងដែនជំរកសត្វព្រៃចំនួនប្រាំមួយ ដែលមានវិសាលភាពសរុបជិត ២.២ លានហិចតា ត្រូវជាប្រមាណ ១២% នៃផ្ទៃដីប្រទេសទាំងមូល ។ សង្គ្រាមស៊ីវិលបានបង្អាក់សកម្មភាពគ្រប់គ្រងនៅក្នុងតំបន់ឧទ្យានទាំងនោះ ប៉ុន្តែនៅពេលដែល សង្គ្រាមបានបញ្ចប់ ប្រទេសកម្ពុជាបានបន្តសកម្មភាពអភិរក្សឡើងវិញ ដោយបានបង្កើតតំបន់ការពារធម្មជាតិចំនួន ២៣ ។

នៅខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ព្រះមហាក្សត្រ សម្តេចព្រះ **នរោត្តម សីហនុ** បានចេញព្រះរាជក្រឹត្យ កំណត់តំបន់ការពារ ធម្មជាតិចំនួន ២៣ កន្លែង គ្របដណ្តប់លើផ្ទៃដីប្រមាណ ៣.៣ លានហិចតា (១៨.២៣% នៃផ្ទៃដីសរុប) ដែលរួមមាន ឧទ្យានជាតិ ចំនួន ៧ ដែនជំរកសត្វព្រៃ ១០ តំបន់ការពារទេសភាពធម្មជាតិ ៣ និងតំបន់ប្រើប្រាស់ច្រើនយ៉ាងចំនួន ៣ ។ ចំណែកថ្នាក់ទាំង បួនខាងលើ ឆ្លុះបញ្ចាំងអំពីសំណុំលក្ខណៈ និងគោលបំណងផ្សេងៗ នៃការគ្រប់គ្រងតំបន់ទាំងនេះ ហើយឆ្លើយតបទៅនឹងចំណែក ថ្នាក់ជាអន្តរជាតិ ដូចជាចំណែកថ្នាក់ដោយអង្គការសហភាពអភិរក្សពិភពលោក (IUCN) ជាដើម ។

ព្រំប្រទល់ឧទ្យានជាតិព្រះសុរាម្រិតកុសមៈ "គីរីរម្យ" និងឧទ្យានជាតិ ព្រះសីហនុ "រាម" ត្រូវបានកំណត់ស្ទើរតែទាំងស្រុង ដោយមានការចូលរួមពីភាគីពាក់ព័ន្ធមួយចំនួន និងត្រូវបានទទួលស្គាល់ដោយស្ថាប័នពាក់ព័ន្ធនានា រួមទាំងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាជ្ញាធរខេត្ត និងសហគមន៍មូលដ្ឋានផងដែរ ។ ក្រៅពីនេះ បង្គោលសំគាល់ព្រំប្រទល់ត្រូវបានបោះ នៅតាមទីតាំងសំខាន់ៗនៃព្រំប្រទល់តំបន់ការពារធម្មជាតិមួយចំនួន ។ ទីស្នាក់ការកណ្តាលសំរាប់ឧទ្យានជាតិ ស្នាក់ការឧទ្យានុរក្ស សញ្ញាសំគាល់នានា បង្គោលសំគាល់ព្រំប្រទល់ និងផ្លាកសញ្ញាអប់រំនានា ត្រូវបានកសាងឡើងតាមរូបភាពសាមញ្ញ និងងាយយល់ សំរាប់តំបន់ការពារធម្មជាតិចំនួន ១២ ដើម្បីផ្តល់នូវកិច្ចការពារ និងការយល់ដឹងជាមូលដ្ឋានដល់សាធារណៈជន អំពីការគ្រប់គ្រង តំបន់ការពារធម្មជាតិទាំងនោះ ។ ការចុះអង្កេតសត្វព្រៃដូចជា បក្សី ថនិកសត្វ ក៏បានធ្វើនៅក្នុងតំបន់ការពារធម្មជាតិមួយចំនួន ដែរ ។ ការចុះអង្កេតប្រភេទសត្វសំខាន់ៗ ដូចជា ខ្លា និងដំរី ត្រូវបានចាប់ផ្តើមនៅក្នុងឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" វីរៈជ័យ និង ឧទ្យានជាតិព្រះសុរាម្រិតកុសមៈ "គីរីរម្យ" ដែនជំរកសត្វព្រៃភ្នំព្រិច គូលែនព្រហ្មទេព លំផាត់ ភ្នំឱរាល់ និងដែនជំរកសត្វព្រៃ ភ្នំសំកុស ។ល។ ពត៌មាន និងឯកសារបានពីការសិក្សានៅតាមមូលដ្ឋាន ត្រូវបានផ្សព្វផ្សាយដល់បណ្តាភាគីពាក់ព័ន្ធ តាមរយៈ សិក្ខាសាលាមួយចំនួន ។ ការវាយតំលៃជំហានដំបូង និងការកំណត់អាទិភាពសំរាប់ការអភិរក្សតាមតំបន់នានា ត្រូវបានរៀបចំ ។ នៅដើមឆ្នាំ ២០០១ ឧទ្យានុរក្សចំនួន ៥២៥ នាក់ ត្រូវបានជ្រើសរើស និងដាក់ឱ្យបំរើការ នៅតាមស្នាក់ការចំនួន ៥៩ ក្នុងតំបន់ ការពារធម្មជាតិនានា ។ ចំនួនឧទ្យានុរក្សត្រូវបានគ្រោង នឹងជ្រើសរើសបន្ថែមឱ្យគ្រប់ចំនួន ៦០០ នាក់ នៅឆ្នាំ ២០០៣ [illegible] ។ ឧទ្យានុរក្សទាំងនេះបាន និងកំពុងអនុវត្តសកម្មភាពល្បាតជាប្រចាំ ហើយធ្វើការត្រួតពិនិត្យបទល្មើសជាមូលដ្ឋាននៅក្នុងតំបន់ ការពារធម្មជាតិ ។ ឧទ្យានុរក្សប្រមាណ ១៥% បានទទួលការបណ្តុះបណ្តាលជាមូលដ្ឋាន ។ ដើម្បីជំរុញការអភិវឌ្ឍន៍[illegible] ការអប់រំបរិស្ថាន ការអភិវឌ្ឍន៍ជីវភាពសហគមន៍ និងកិច្ចការពារតាមទីតាំងក្នុងតំបន់ការពារធម្មជាតិ នាយកដ្ឋាន[illegible]

ធម្មជាតិ បានធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយស្ថាប័នអភិរក្សមួយចំនួន ។ ប៉ុន្តែ ការវិភាគជាយថាក្រម អំពីការគំរាមកំហែងចំពោះធនធានធម្មជាតិនៅពុំទាន់បានធ្វើនៅឡើយទេ ។ ការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ អនុលោមតាមពហុគោលបំណងនៃការគ្រប់គ្រង ត្រូវបានធ្វើរួចមកហើយ នៅក្នុងតំបន់ការពារធម្មជាតិចំនួនពីរគឺ ឧទ្យានជាតិព្រះសីហនុ "រាម" និងឋបនីយជីវមណ្ឌលបឹងទន្លេសាប ។ គណៈកម្មាធិការពិគ្រោះយោបល់ និងដោះស្រាយទំនាស់ថ្នាក់ជាតិ និងថ្នាក់ខេត្ត ត្រូវបានបង្កើតឡើង ប៉ុន្តែគណៈកម្មាធិការនេះមិនមានឱកាសជួបប្រជុំញឹកញាប់ដើម្បីដោះស្រាយទំនាស់ឡើយ ។ ការចូលរួមរបស់ប្រជាជនមូលដ្ឋាន ក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព កំពុងត្រូវបានជំរុញនៅតាមតំបន់ការពារធម្មជាតិមួយចំនួន ។ ឯកសារគោលនយោបាយជាតិ ដូចជា ផែនការបរិស្ថានជាតិសំរាប់ឆ្នាំ ១៩៩៨-២០០២ ត្រូវបានរៀបចំ និងអនុម័ត រីឯឯកសារគោលនយោបាយដទៃទៀត ដូចជាច្បាប់ស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងអនុក្រឹត្យស្តីពី សហគមន៍ព្រៃឈើ-នេសាទ ក៏កំពុងតែត្រូវបានរៀបចំជាសេចក្តីព្រាងដែរ ។

ថ្វីត្បិតតែតំបន់ការពារធម្មជាតិមានវិសាលភាពធំ បើប្រៀបធៀបនឹងផ្ទៃប្រទេសកម្ពុជាទាំងមូលក្តី (ប្រមាណ ១៨% នៃផ្ទៃប្រទេស) ក៏ប៉ុន្តែនៅមានតំបន់មួយចំនួនទៀត ដែលគួរកំណត់បញ្ចូលក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ។ ថ្មីៗនេះ បឹងទន្លេសាបត្រូវបានកំណត់ជាផ្លូវការ ថាជាឋបនីយជីវមណ្ឌល ។ ក្រៅពីនេះ មានតំបន់បឹកន្លែងក្នុងប្រទេសកម្ពុជា ដែលត្រូវបានកំនត់ថា ជាតំបន់ដីសើមមានសារៈសំខាន់ជាអន្តរជាតិ (ពោលគឺ បឹងទន្លេឆ្មា កោះកាពិ និងផ្នែកមួយចំនួននៃដងទន្លេមេគង្គ) និងតំបន់បេតិកភណ្ឌពិភពលោកមួយកន្លែងថ្មីទៀត ត្រូវបានគ្រោងនឹងបង្កើត សំរាប់ជាតំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជា ។ ការកំណត់តំបន់គ្រប់គ្រង និងអភិរក្សដែនបំរុងសត្វក្រៀល នៅអាងត្រពាំងថ្ម ក្នុងខែ កុម្ភៈ ឆ្នាំ ២០០០ ឆ្លុះបញ្ចាំងពីតំរូវការ និងលទ្ធភាពក្នុងការកំណត់ដែនបំរុង សំរាប់ការពារ និងថែរក្សាប្រភេទសត្វ ហើយដែលគួរតែដាក់បញ្ចូលទៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ ។

នៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិបច្ចុប្បន្ន មានតំបន់ការពារធម្មជាតិចំនួន ៧ ដែលស្ថិតនៅជាប់ព្រំប្រទល់ប្រទេស ។ ឧទ្យានជាតិវីរៈជ័យ ដែលជាតំបន់មួយ ក្នុងចំណោមតំបន់ការពារធម្មជាតិទាំង ៧ ខាងលើ (៣៣២.៥០០ ហិចតា) និងដែលស្ថិតនៅភាគឦសាន្តនៃប្រទេស បានផ្តល់ឱកាសសំរាប់បង្កើតជាដែនបំរុងឆ្លងព្រំប្រទល់ជាមួយតំបន់ដុងអាមផាន (Dong Amphan, ១២២.១០០ ហិចតា ) ដែលត្រូវបានស្នើជាឧទ្យានជាតិនៃប្រទេសលាវ និងជាមួយឧទ្យានជាតិ មុំ រ៉ាយ (Mom Ray, ១០១.៤០០ ហិចតា) នៃប្រទេសវៀតណាម ។ ប៉ុន្តែ គេនៅពុំទាន់បានធ្វើការអង្កេតតំបន់នេះពេញលេញនៅឡើយទេ រីឯព្រំប្រទល់ ក៏នៅពុំទាន់បានដាំបង្គោលនៅឡើយ ចំណែកឯសកម្មភាពអភិរក្ស និងគ្រប់គ្រងតំបន់ឧទ្យានជាតិទាំងនេះ ក៏នៅមិនទាន់បានអនុវត្តនៅឡើយដែរ ។ ការអង្កេតសត្វខ្លា និងដំរី បានចាប់ផ្តើមពង្រីកយ៉ាងទូលំទូលាយ ដោយប្រើប្រាស់ម៉ាស៊ីនថតស្វ័យប្រវត្តិ និងបច្ចេកទេសកំណត់ដានជើងសត្វ ។

តំបន់ការពារធម្មជាតិមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ទេសចរណ៍ និងផ្តល់សេវាកម្មអេកូឡូស៊ី (ការពារទីជំរាលវាលទឹក ទីជម្រកសម្រាប់រុក្ខជាតិ និងសត្វព្រៃ) ។ ប៉ុន្តែ តំបន់ការពារធម្មជាតិមួយចំនួនត្រូវបានគេប្រើប្រាស់ដោយសេរីជាទីវាលស្មៅសំរាប់សត្វចិញ្ចឹម ការធ្វើនេសាទហួសកំរិត ការកាប់ឈើល្មើសច្បាប់ ការកាប់ឈើធ្វើអុស ការប្រមូលអនុផលព្រៃឈើ និងបង្កឱ្យ

មានការបំផ្លិចផ្លាញ និងការរំខានដល់ទីជំរក ។ ដំណោះស្រាយដ៏ប្រសើរចំពោះបញ្ហាទាំងនេះ គឺការកសាង និងអនុវត្តផែនការគ្រប់គ្រង ដែលផ្អែកលើការចូលរួមយ៉ាងសកម្មពីសំណាក់សហគមន៍មូលដ្ឋាន ។

បញ្ហាចំបង

- ក្របខ័ណ្ឌច្បាប់ ស្ថាប័ន និងការពង្រឹងសកម្មភាពអនុវត្តច្បាប់នៅមានកំរិតទាប ។
- ខ្វះការសំរបសំរួល និងកិច្ចសហការជិតស្និទ្ធជាមួយភាគីពាក់ពន្ធ័ និងសហគមន៍មូលដ្ឋាន ។
- ពតិមានជាមូលដ្ឋានសំរាប់ការធ្វើសេចក្តីសំរេចនៅមានតិចតួច ។
- ការផ្សព្វផ្សាយចំណេះដឹងជាសាធារណៈនៅមានកំរិតទាប និងពុំទាន់គ្រប់គ្រងឱ្យបានសមស្រប ។
- មានកត្តារាំងស្ទះខាងនយោបាយ និងសង្គម ។
- បញ្ហាពាក់ព័ន្ធនឹងការគ្រប់គ្រងនៅនឹងកន្លែង និងការល្បាត ។
- ខ្វះធនធានមនុស្ស និងហិរញ្ញវត្ថុ ។
- ខ្វះបច្ចេកទេសជំនាញ និងធនធានមនុស្ស ។
- ព្រំប្រទល់នៅនឹងកន្លែង និងតំបន់គ្រប់គ្រងមិនទាន់បានកំណត់ជាក់លាក់ ។
- កំនើនការគំរាមកំហែងចំពោះតំបន់ការពារធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ី ដោយសារសកម្មភាពក្នុងវិស័យរុក្ខកម្ម កសិកម្ម ការនេសាទ ការកសាងផ្លូវថ្នល់ ទេសចរណ៍ និងនគរូបនីយកម្ម ។
- សកម្មភាពល្មើសច្បាប់ និងទំនាស់ជាមួយប្រជាជនមូលដ្ឋាន ។
- អវត្តមាននៃផែនការគ្រប់គ្រង ឬការអនុវត្តនីផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិដែលមានស្រាប់ពុំទាន់បានពេញលេញ ។
- តំបន់សំខាន់ៗមួយចំនួនមិនទាន់បានកំណត់បញ្ចូលក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិបច្ចុប្បន្ន ។

គោលដៅ

- កសាង និងថែទាំប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលអាចធានាបាននូវការរក្សាសមាសភាគចំបងៗនៃជីវៈចំរុះ និងធនធានវប្បធម៌ ព្រមទាំងអាចធានាការអភិវឌ្ឍន៍សកម្មភាពទេសចរណ៍ និងការកំសាន្តមួយចំនួនប្រកបដោយចីរភាព ។
- អភិរក្សលក្ខណៈសំបូរបែបនៃរុក្ខជាតិ និងសត្វនៅក្នុងតំបន់ការពារធម្មជាតិដែលមានស្រាប់ និងតំបន់ដែលបានស្នើ សំរាប់កំនត់បន្ថែមជាតំបន់ការពារធម្មជាតិ ។
- ជំរុញឱ្យមានការចូលរួមយ៉ាងសកម្មពីសហគមន៍មូលដ្ឋាន ក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ។

គោលបំណងជាយុទ្ធសាស្ត្រ (*សន្ទស្សន៍បង្ហាញ*)

១.១.១ កសាងផែនការគ្រប់គ្រងសំរាប់តំបន់ការពារធម្មជាតិទាំងអស់ និងតំបន់ទ្រនាប់នានា ដោយសហការជាមួយសហគមន៍មូលដ្ឋាន និងក្រសួងពាក់ព័ន្ធ ( *ចំនួនផែនការគ្រប់គ្រងដែលបានកសាង* ) ។

១.១.២ កសាងហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន ផ្គត់ផ្គង់សំភារៈ មន្ត្រី និងឧបករណ៍ចាំបាច់ សំរាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិទាំងអស់ ( *កំណើនថវិកាសំរាប់តំបន់ការពារធម្មជាតិនីមួយៗ* ) ។

១.១.៣ បោះបង្គោលព្រំប្រទល់តំបន់ការពារធម្មជាតិឱ្យបានសមស្រប ( *ចំនួនបង្គោលនិងផ្លាកសញ្ញា និងចំនួនតំបន់ការពារធម្មជាតិ ដែលបានបោះបង្គោលព្រំប្រទល់* ) ។

១.១.៤ បញ្ចូលតំបន់ថ្មីៗផ្សេងទៀត ដែលមានសារៈសំខាន់ខាងផ្នែកជីវសាស្ត្រ ជាបន្ថែមទៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិបច្ចុប្បន្ន ( *ចំនួនតំបន់ការពារធម្មជាតិបង្កើតថ្មីជាបន្ថែម* ) ។

១.១.៥ បង្កើនការយល់ដឹងសាធារណៈបន្ថែមទៀត អំពីសារៈសំខាន់នៃតំបន់ការពារធម្មជាតិ ( *ចំនួនប្រជាជនដែលបានទទួលការផ្សព្វផ្សាយកម្មវិធីបង្កើនការយល់ដឹង* ) ។

១.១.៦ ជំរុញឱ្យមានការកសាងសមត្ថភាព ការផ្លាស់ប្តូរបច្ចេកវិទ្យា និងពត៌មាន រវាងតំបន់ការពារធម្មជាតិនានា ( *ចំនួនរបាយការណ៍ ការប្រជុំ និងសិក្ខាសាលា* ) ។

១.១.៧ ទប់ស្កាត់ការធ្វើអាជីវកម្មធនធានធម្មជាតិខុសច្បាប់ នៅក្នុងតំបន់ការពារធម្មជាតិ ( *ចំនួនករណីល្មើសច្បាប់ដែលបានកត់ត្រាទុក និងចំនួនករណីផាកពិន័យ* ) ។

១.១.៨ ជំរុញ និងពង្រឹងទំនាក់ទំនង ក៏ដូចជាការសំរបសំរួលរវាងស្ថាប័ន ផ្អែកលើយន្តការដែលមានស្រាប់ ដើម្បីដោះស្រាយទំនាស់អំពីផលប្រយោជន៍ ។ ( *ចំនួនការប្រជុំ ចំនួនករណីទំនាស់ដែលដោះស្រាយ ចំនួនសេចក្តីព្រមព្រៀងរួមដែលបានចុះហត្ថលេខា* ) ។

១.១.៩ កសាងសមត្ថភាព និងប្រព័ន្ធគ្រប់គ្រងស្ថាប័ន នៅក្នុងនាយកដ្ឋានការពារអភិរក្សធម្មជាតិ ដើម្បីឱ្យមានសមត្ថភាពដឹកនាំ និងផ្តល់សេវាកម្មដ៏មានប្រសិទ្ធិភាព ទាំងសំរាប់ថ្នាក់ជាតិ និងសំរាប់តំបន់ការពារធម្មជាតិនីមួយៗ ។ ( *ចំនួនគោលការណ៍ណែនាំសំរាប់គ្រប់គ្រង អនុក្រឹត្យស្តីពីតំបន់ការពារធម្មជាតិត្រូវបានកសាងឡើង រចនាសម្ព័ន្ធអង្គការចាត់តាំងបានកែសំរួល គោលនយោបាយបានកែសំរួល គោលការណ៍ណែនាំសំរាប់ការសិក្សាតាមដាននិងសំរាប់វាយតំលៃបានរៀបចំ* ) ។

១.១.១០ បង្កើតប្រព័ន្ធសំរាប់អភិវឌ្ឍន៍យន្តការហិរញ្ញវត្ថុថ្នាក់ជាតិ ( *ការបង្កើតមូលនិធិទាយជ្ជទាន ការវាយតំលៃនិរន្តរភាពនៃយន្តការហិរញ្ញវត្ថុករិតជាតិ* ) ។

១.១.១១ បង្កើតប្រព័ន្ធថ្នាក់ជាតិសំរាប់ត្រួតពិនិត្យតំបន់ការពារធម្មជាតិ ( *ប្រព័ន្ធពិតមានភូមិសាស្ត្រ និងមូលដ្ឋានទិន្នន័យ (Database) ត្រូវបានបង្កើត និងចែកចាយ សំរាប់ប្រើប្រាស់. យន្តការចែកចាយពត៌មានត្រូវបានបង្កើត* ) ។

## យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះ

ជំរើសនានា

- ជ្រើសរើសតំបន់ជាអាទិភាពដើម្បីធ្វើការអភិរក្ស (កំណត់លក្ខណៈវិនិច្ឆ័យសំរាប់បង្កើតតំបន់ការពារធម្មជាតិ ដោយយោងតាមភាពងាយខូចខាត ភាពកំរ ឬភាពប្រឈមនឹងគ្រោះថ្នាក់នៃប្រព័ន្ធអេកូឡូស៊ី) ។
- ធ្វើអត្តសញ្ញាណស្ថានភាពនៃទីជំរក និងប្រភេទសត្វ ព្រមទាំងរុក្ខជាតិ នៅក្នុងតំបន់ស្នើបញ្ចូលជាតំបន់ការពារធម្មជាតិ ។
- សិក្សាស្រាវជ្រាវលក្ខណៈភូមិសាស្ត្រនៃតំបន់ការពារធម្មជាតិតាមរយៈផែនទី ឬនៅទីកន្លែងជាក់ស្តែង ។
- ប្រមូល និងពិនិត្យឡើងវិញនូវឯកសារ និងពត៌មានដែលមានស្រាប់ ស្តីពីតំបន់ការពារធម្មជាតិ ។
- ធ្វើសារពើភ័ណ្ឌធនធានជីវសាស្ត្រក្នុងតំបន់ការពារធម្មជាតិ ។
- កសាងផែនការគ្រប់គ្រង បែងចែកតំបន់ ទេសចរណ៍ និងផែនការប្រើប្រាស់ផ្សេងៗដោយនិរន្តរភាព សំរាប់តំបន់ការពារធម្មជាតិ រួមទាំងសំរាប់ការកំសាន្ត ។
- កសាងប្រព័ន្ធផ្លូវនៅក្នុងតំបន់ការពារធម្មជាតិ ។
- បង្កើតប្រព័ន្ធទឹកស្អាត និងរៀបចំបណ្តាញប្រព័ន្ធថាមពលអគ្គិសនី នៅក្នុងតំបន់ការពារធម្មជាតិ ។
- អភិវឌ្ឍន៍ធនធានមនុស្ស និងជ្រើសរើស ព្រមទាំងជួលបុគ្គលិកដែលមានសមត្ថភាពគ្រប់គ្រាន់ ។
- កម្មវិធីបណ្តុះបណ្តាលឧទ្យានុរក្ស អំពីបច្ចេកទេសល្បាត និងត្រួតពិនិត្យបទល្មើសនៅនឹងកន្លែង វិធីជាមូលដ្ឋានក្នុងការពង្រឹងការអនុវត្តច្បាប់ ការធ្វើអត្តសញ្ញាណសត្វព្រៃក្នុងស្ថានភាពជាក់ស្តែង បច្ចេកទេសវាយតំលៃស្ថានភាពនៅជនបទដោយមានការចូលរួម (PRA) របៀបប្រើប្រាស់សំភារៈជាប់ខ្លួន ។
- កសាងសមត្ថភាពដឹកនាំ និងកម្មវិធីបណ្តុះបណ្តាលជំនាញ ពាក់ព័ន្ធនឹងការសិក្សាតាមដាន ការស្រាវជ្រាវ ការគ្រប់គ្រង និងការបកស្រាយអំពីធនធានធម្មជាតិ និងធនធានវប្បធម៌ក្នុងតំបន់ការពារធម្មជាតិ ។
- ផ្តល់ប្រាក់បៀវត្សរ៍ និងប្រាក់ឧបត្ថម្ភឱ្យបានសមរម្យ ។
- ផ្តល់សេវាថែរក្សាសុខភាពដល់បុគ្គលិកនៅក្នុងតំបន់ការពារធម្មជាតិ ។
- ផ្គត់ផ្គង់សំភារៈឱ្យបានគ្រប់គ្រាន់ សំរាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ។
- កសាងផែនការសកម្មភាព ដើម្បីអភិរក្សប្រភេទសំខាន់ៗមួយចំនួន ដូចជា ខ្លាធំ ទោច ដំរី ខ្លាឃ្មុំ បក្សី ។ល។ ធានាឱ្យមានការចូលរួមរបស់ប្រជាជនមូលដ្ឋាន ក្នុងការរៀបចំគំរោង ការដាក់បង្គោលសីមា និងការគ្រប់គ្រងតំបន់អភិរក្សធម្មជាតិ ។
- អប់រំសាធារណជនអំពីសារៈសំខាន់នៃតំបន់ការពារធម្មជាតិ និងផ្សព្វផ្សាយច្បាប់ និងបទបញ្ញត្តិនានា ចាប់ពីថ្នាក់ជាតិរហូតដល់ថ្នាក់មូលដ្ឋាន ។
- បង្កើន និងពង្រឹងសកម្មភាពយាមល្បាត ។
- ចាត់វិធានការប្រឆាំងសកម្មភាពល្មើសច្បាប់ តាមរយៈការផាកពិន័យ និងដាក់ទណ្ឌកម្ម និងការប្រ[illegible] សាធារណៈ ។
- ផ្គត់ផ្គង់សំភារៈ និងមូលនិធិដល់សហគមន៍ ។

- ផ្តល់អាទិភាពដល់សហគមន៍ក្នុងការចូលបំរើការងារ និងការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិដោយនិរន្តរភាព ។
- ផ្តល់អាទិភាពសំរាប់កម្មវិធីអភិវឌ្ឍន៍ ដល់សមាជិកសហគមន៍មូលដ្ឋានរូបណា ដែលបានចូលរួមក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ។
- បង្កើនការទទួលស្គាល់តំលៃខាងផ្នែកអេកូឡូស៊ី សេដ្ឋកិច្ច និងសង្គម នៃតំបន់ការពារធម្មជាតិ តាមរយៈការបង្កើនផលប្រយោជន៍សំរាប់ប្រជាជនដែលរស់នៅក្នុង និងជុំវិញតំបន់ទាំងនោះ ។
- ប្រមូលពត៌មានដែលមានស្រាប់ និងស្វែងរកជាបន្ថែមនូវទិន្នន័យសេដ្ឋកិច្ចសង្គម និងអេកូឡូស៊ី ស្តីពីតំបន់ការពារធម្មជាតិ ។
- កំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិឱ្យបានច្បាស់លាស់ ដោយដាក់បង្គោល ឬផ្លាកសញ្ញាឱ្យបានត្រឹមត្រូវ ។
- ធ្វើអត្តសញ្ញាណ និងទប់ស្កាត់ការនាំចូលប្រភេទសត្វ និងរុក្ខជាតិពីក្រៅ ទៅក្នុងតំបន់ការពារធម្មជាតិ ។
- បង្កើតក្រុមអង្កេតតាមដានសកម្មភាពល្មើសច្បាប់ និងការធ្វើអាជីវកម្មល្មើសច្បាប់នៅក្នុងតំបន់ការពារធម្មជាតិ ។
- សិក្សា និងបង្កើនការយល់ដឹង អំពីទិដ្ឋភាពអេកូឡូស៊ីនៃតំបន់ការពារធម្មជាតិ ។
- ប្រើប្រាស់បណ្តាញពត៌មានអេឡិចត្រូនិច និងរៀបចំការប្រជុំរវាងមន្ត្រីតំបន់ការពារធម្មជាតិ ។
- បង្កើតកម្មវិធីទស្សនកិច្ចសិក្សានានា ។
- ផ្សព្វផ្សាយគោលនយោបាយ អំពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ ទៅដល់វិនិយោគិនឯកជននានា ។
- បង្កលក្ខណៈងាយស្រួលដល់វិនិយោគិននានា ។
- រៀបចំការប្រជុំពិភាក្សា អំពីតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធនានា ។
- បង្កើតក្រុមប្រឹក្សាអន្តរក្រសួង ដើម្បីសំរបសំរួលការងារ ឬសកម្មភាព ក្នុងតំបន់ការពារធម្មជាតិ ។
- បង្កើនការផ្តល់ថវិកាប្រចាំឆ្នាំដោយរាជរដ្ឋាភិបាល ។
- ស្វែងរកមូលនិធិទ្រទ្រង់ពីអង្គការជាតិ និងអន្តរជាតិ ។
- សន្សំប្រាក់ចំណូលពីសេវាអ្នកចូលទស្សនា និងពីការផាកពិន័យបទល្មើសក្នុងតំបន់ការពារធម្មជាតិ ។
- កសាងផែនការចំណូល និងចំណាយប្រចាំឆ្នាំ សំរាប់តំបន់ការពារធម្មជាតិ ។
- បង្កើតក្រុមត្រួតពិនិត្យប្រាក់ចំណូល និងចំណាយ សំរាប់តំបន់ការពារធម្មជាតិ ។
- ជំរុញការគ្រប់គ្រងតំបន់ការពារធម្មជាតិដោយផ្អែកលើបទពិសោធន៍អន្តរជាតិ ។
- ត្រួតពិនិត្យជីវៈចំរុះ រួមទាំងការវាយតំលៃផលប៉ះពាល់បណ្តាលពីបាតុភូតធម្មជាតិ និងពីសកម្មភាពមនុស្សនៅក្នុងតំបន់ការពារធម្មជាតិ ។
- ទស្សនកិច្ចសិក្សា ដើម្បីផ្លាស់ប្តូរបទពិសោធន៍នៅក្នុងប្រទេស និងក្រៅប្រទេស ។
- ដាំព្រំប្រទល់ជាលក្ខណៈធម្មជាតិ ដូចជាការដាំប្រភេទឈើក្នុងស្រុកជាជួរតាមព្រំប្រទល់ ។

សកម្មភាពជាអាទិភាព (ស្ថាប័នសំរបសំរួល និងចូលរួមអនុវត្ត)

១.១.១ ពង្រឹងការគ្រប់គ្រងបច្ចុប្បន្ននៅក្នុងតំបន់ការពារធម្មជាតិ ដោយកសាង និងពង្រឹងគោលនយោបាយ គោលការណ៍ណែនាំ និងផែនការគ្រប់គ្រង (ក្រ.បស្ថ កសក អជប រជនស មហផ) (រួមទាំង ច្បាប់ស្តីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ ការកំណត់ព្រំប្រទល់ ការអង្កេតជីវសាស្ត្រ កម្មវិធីបង្កើនការយល់ដឹង ការកែសំរួលស្ថាប័នការវាយតំលៃមាត្រានៃច្បាប់ និងគោលនយោបាយ ការចូលរួមរបស់សហគមន៍ សំភារៈ ការផ្តល់ហិរញ្ញវត្ថុ ឥទ្ធិពលពីសកម្មភាពរបស់មនុស្ស ការវាយតំលៃបុគ្គលិក និងហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍន៍កម្មវិធីបណ្តុះបណ្តាលឧទ្យានុរក្ស និងថ្នាក់ដឹកនាំ ការអភិវឌ្ឍន៍ផែនការគ្រប់គ្រង គោលការណ៍ណែនាំ ការគ្រប់គ្រងសកម្មភាពសិក្សាតាមដាន និងពតិមាន ការឃ្លាំមើលសកម្មភាព ប្រព័ន្ធបែងចែកតំបន់ ការសំរបសំរួលគណៈកម្មាធិការដឹកនាំថ្នាក់ខេត្ត និងថ្នាក់ជាតិ ។ល។) ។

១.១.២ ធ្វើសមាហរណកម្មការគ្រប់គ្រងតំបន់ស្នូលនៃបរិមណ្ឌលជីវមណ្ឌលបឹងទន្លេសាប ទៅក្នុងការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីបឹងទន្លេសាបទាំងមូល ដើម្បីធានាឱ្យមានការប្រើប្រាស់ជីវៈចំរុះដោយនិរន្តរភាព (ក្រ.បស្ថ កសក និង គជទមគ) (ការគ្រប់គ្រងបរិមណ្ឌលជីវមណ្ឌល ការគ្រប់គ្រងសហគមន៍នេសាទ ការកំណត់ព្រំប្រទល់ ការគ្រប់គ្រងនេសាទជាលក្ខណៈឧស្សាហកម្ម ការសិក្សាតាមដានសត្វព្រៃ និងជលផល សន្តិសុខដីធ្លី ការសំរបសំរួល និងទំនាក់ទំនងអន្តរស្ថាប័ន កម្មវិធីបណ្តុះបណ្តាលមន្ត្រីនៅមូលដ្ឋាន និងសហគមន៍ ការអប់រំ និងបង្កើនការយល់ដឹងអំពីបរិស្ថាន និងការស្រាវជ្រាវនៅមូលដ្ឋាន អភិបាលកិច្ចមូលដ្ឋាន) ។

១.១.៣ ធ្វើអត្តសញ្ញាណ និងកំណត់ជាតំបន់ការពារធម្មជាតិថ្មីនូវទីជំរកក្នុងតំបន់ដីសើម នៅតំបន់ឆ្នេរ និងសមុទ្រ (ក្រ.បស្ថ និង កសក) ។

១.១.៤ ធ្វើអត្តសញ្ញាណ និងកំណត់ឡូត៍បំរុងសំរាប់ការពារត្រី (ក្រ.កសក) ។

១.១.៥ ការវាយតំលៃសេដ្ឋកិច្ច និងប៉ាន់ប្រមាណធនធាន ដើម្បីពិនិត្យសក្តានុពលភាពសំរាប់អភិវឌ្ឍន៍សកម្មភាពដែលផ្តល់ចំណូលនៅក្នុងតំបន់ការពារធម្មជាតិ (ក្រ.បស្ថ និងកសក) ។ ការអភិវឌ្ឍន៍អេកូទេសចរណ៍ក្នុងតំបន់ការពារធម្មជាតិ និងការគ្រប់គ្រងតំបន់ទ្រនាប់ ដើម្បីបង្កើនផលប្រយោជន៍សំរាប់សហគមន៍ ។

១.១.៦ កម្មវិធីបណ្តុះបណ្តាលសំរាប់ឧទ្យានុរក្ស មន្ត្រីបច្ចេកទេស នាយកឧទ្យានជាតិ និងសហគមន៍មូលដ្ឋាន (ក្រ.បស្ថ) (រួមទាំងប្រភេទ និងប្រព័ន្ធតំបន់ការពារធម្មជាតិ ការគ្រប់គ្រងដោយមានការចូលរួម ទស្សនាទានអំពីការកំណត់ព្រំប្រទល់ និងបែងចែកតំបន់ តួនាទីនិងការទទួលខុសត្រូវរបស់ក្រសួងបរិស្ថាន/នាយកដ្ឋានការពារអភិរក្សធម្មជាតិនិងឧទ្យានុរក្ស ការប្រើប្រាស់ផែនទី ត្រីវិស័យ និង GPS ក្របខ័ណ្ឌនយោបាយ និងច្បាប់សំរាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ការដោះស្រាយទំនាស់ក្នុងតំបន់ការពារធម្មជាតិ បច្ចេកទេសអង្កេតជាក់ស្តែង និងធ្វើរបាយការណ៍ បច្ចេកទេសល្បាត និងផែនការការងារ ការធ្វើអត្តសញ្ញាណសត្វព្រៃ ការគូសផែនទីអំពីធនធាន ។ល។) ។

១.១.៧ ការអភិរក្ស និងការអភិវឌ្ឍន៍ចំរុះតំបន់ការពារធម្មជាតិជួរភ្នំក្រវាញ (ផែនការគ្រប់គ្រង ការល្បាត ការបណ្តុះបណ្តាល ការដាក់បង្គោលព្រំប្រទល់ ការវាយតំលៃអេកូឡូស៊ី និងសង្គម សន្តិសុខនៃការប្រើប្រាស់ដីរបស់សហគមន៍ និរន្តរភាពនៃការផ្តល់ហិរញ្ញវត្ថុ កិច្ចការពារជំរកសំខាន់ៗ ការចាត់បញ្ចូលជាបេតិកភណ្ឌពិភពលោក កិច្ចការពង្រឹង[illegible]

ការកាត់បន្ថយភាពក្រីក្រ ការសំរបសំរួល និងការចូលរួមរបស់ភាគីពាក់ព័ន្ធនានា អភិបាលកិច្ចនៅមូលដ្ឋាន កិច្ចការពារទីជំរាល ។ល។ ) ( ក្រ.បស្ថ កសក និង រដនស ) ។

១.១.៨ បញ្ចូលការគ្រប់គ្រងដែនជំរកសត្វព្រៃគូលែនព្រហ្មទេព ទៅក្នុងការអភិរក្សតំបន់វាលរាបភាគខាងជើង ។ (ផែនការគ្រប់គ្រង ការល្បាត ការបណ្តុះបណ្តាល ការកំណត់ព្រំប្រទល់ ការវាយតំលៃ និងស្រាវជ្រាវអំពីអេកូឡូស៊ីនិងសង្គម សន្តិសុខនៃការប្រើប្រាស់ដីរបស់សហគមន៍ និរន្តរភាពនៃការផ្តល់ហិរញ្ញវត្ថុ កិច្ចការពារដែនជំរកសំខាន់ៗ ការកាត់បន្ថយភាពក្រីក្ររបស់សហគមន៍មូលដ្ឋាន ការចូលរួមរបស់ភាគីពាក់ព័ន្ធនានា អភិបាលកិច្ចនៅមូលដ្ឋាន ការអភិវឌ្ឍន៍ផ្លូវសំរាប់សត្វផ្លាស់ទី) ។ ( ក្រ.បស្ថ កសក រដនស និង អជប ) ។

១.១.៩ បញ្ចូលការគ្រប់គ្រងតំបន់ការពារធម្មជាតិទៅក្នុងកម្មវិធីអភិរក្សតំបន់ព្រៃខ្ពង់រាបប៉ែកឦសាន្ត ។ (ផែនការគ្រប់គ្រង ការល្បាត ការបណ្តុះបណ្តាល ការកសាងហេដ្ឋារចនាសម្ព័ន្ធសំរាប់តំបន់ការពារធម្មជាតិ ការកំណត់ព្រំប្រទល់ ការវាយតំលៃសង្គម និងអេកូឡូស៊ី សន្តិសុខនៃការប្រើប្រាស់ដីរបស់សហគមន៍ និរន្តរភាពនៃការផ្តល់ហិរញ្ញវត្ថុ កិច្ចការពារដែនជំរកសំខាន់ៗ ការកាត់បន្ថយភាពក្រីក្ររបស់សហគមន៍មូលដ្ឋាន ការចូលរួមនៃភាគីពាក់ព័ន្ធនានា អភិបាលកិច្ចនៅមូលដ្ឋាន ការអភិវឌ្ឍន៍ផ្លូវសំរាប់សត្វផ្លាស់ទី) ។ ( ក្រ.បស្ថ កសក រដនស និង អជប ) ។

១.១.១០ បញ្ចូលការគ្រប់គ្រងជីវៈចំរុះ និងឧទ្យានជាតិវីរៈជ័យ ជាមួយការអភិវឌ្ឍន៍សហគមន៍ជនជាតិភាគតិច ដើម្បីផ្តល់នូវគំរូនៃការអភិរក្ស និងការអភិវឌ្ឍន៍ចំរុះប្រកបដោយចីរភាព ។ (ផែនការគ្រប់គ្រងឧទ្យានជាតិ ការអង្កេតអេកូឡូស៊ីនិងសេដ្ឋកិច្ចសង្គម ការកំណត់ព្រំប្រទល់ ការតាមដានសភាពប្រែប្រួលនៃការប្រើប្រាស់ដី យន្តការសំរបសំរួលឆ្លងព្រំដែននៃប្រទេស ការអភិវឌ្ឍន៍ជីវភាពរបស់សហគមន៍ ការគ្រប់គ្រងធនធានធម្មជាតិផ្អែកលើសហគមន៍ ការបណ្តុះបណ្តាលឧទ្យានុរក្ស ការកសាងហេដ្ឋារចនាសម្ព័ន្ធសំរាប់ឧទ្យាន ការអប់រំ និងស្រាវជ្រាវក្នុងមូលដ្ឋានរបស់សហគមន៍ អភិបាលកិច្ចនៅមូលដ្ឋាន ការបង្កើតឥណទានជនបទ និងការសំរបសំរួលភាគីពាក់ព័ន្ធ) ។ ( ក្រ.បស្ថ រដនស និង អជប ) ។

១.១.១១ បង្កើតវិធីសាស្ត្រដើម្បីភ្ជាប់ទំនាក់ទំនងរវាងការអភិរក្ស និងសង្គមក្នុងមូលដ្ឋាន ដោយជំរុញឱ្យមានការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនូវធនធានជីវសាស្ត្រ ដែលមាននៅក្នុងឧទ្យានជាតិព្រះសុរាម្រិតកុសមៈ "គិរីរម្យ" ឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" និងឧទ្យានជាតិព្រះសីហនុ "រាម" ។ ( ក្រ.បស្ថ ) ។

## ១.២ ប្រភេទកំពុងប្រឈមគ្រោះថ្នាក់

**បរិបទ**

ប្រភេទសត្វមួយចំនួនដែលធ្លាប់មាននៅក្នុងប្រទេសកម្ពុជា ប៉ុន្តែបច្ចុប្បន្ននេះត្រូវបានគេជឿជាក់ថាវិនាសផុតពូជ គឺរមាសស្នែងមួយ ។ ប្រភេទកំពុងប្រឈមគ្រោះថ្នាក់រួមមាន គោព្រៃ ដំរី ខ្លា ទន្សោង ផ្សោតទឹកសាប ត្រដក់ធំ ក្រៀល ក្ងោក [illegible] ត្រីភ្នំ និងអណ្តើកសមុទ្រ ។ ត្រីរាជដែលអាចមានប្រវែងរហូតដល់ ៣ ម៉ែត និងប្រភេទត្រីយ៉ាងតិចបំផុត ១៤ ប្រភេទទៀត ក៏ត្រូវបានចាត់ចូលជាប្រភេទកំពុងប្រឈមគ្រោះថ្នាក់ដែរ ។ ក្នុងចំណោមសត្វដទៃទៀត ដែលបច្ចុប្បន្នត្រូវបាន[illegible]ឬអាយប្រឈមគ្រោះថ្នាក់ មាន ប្រើសស្នែងធំ ខ្ទីង រញ្ជីភ្លើង ទោច ខ្លាឃ្មុំតូច ប្រភេទអណ្តើកភ្នំមួយចំនួន

ទុងប្រផេះ និងប្រភេទសត្វស្លាបមួយចំនួនទៀត។ ការគំរាមកំហែងចំពោះប្រភេទទាំងនេះ រាប់បញ្ចូលទាំងការលួចបរបាញ់ ការប្រមូលស៊ុត ការបំពុល ការចាប់សត្វស្លាបដោយអ្នកនេសាទត្រី និងការបំផ្លាញជំរក ។

ប្រភេទរុក្ខជាតិមួយចំនួននៅក្នុងប្រទេសកម្ពុជា និងដែលបច្ចុប្បន្នកំពុងរងការគំរាមកំហែង រួមមាន ប្រភេទឈើមានតំលៃ និងមានដោយកំរ ដូចជា ច័ន្ទក្រស្នា *Aquilaria crassna*, Pierre ឈើខ្មៅ *Diospyros crumenata*, Thw. នាងនួន *Dalbergia bariensis*, Pierre បេង *Afzelia xylocarpa*, (Kurz)Craib ក្រញូង *Dalbergri cochinchinensis*, Pierre តាត្រាវ *Fagraea fragrans*, Roxb. ម្រះព្រៅភ្នំ *Disoxylon loureiri*, Pierre ឈើភ្លើង *Diosyros nitida*, Merr ធ្នង់ *Pterocarpus pedatus*, Pierre រួមទាំងប្រភេទសាមី (endemisms) ចំនួន ២១៤ ប្រភេទទៀត ដែលមានដែនដំណុះតែមួយគត់នៅកម្ពុជា ដូចជាប្រភេទផ្កាមហាហង្ស ប្រភេទមួយចំនួននៃអ័រគីដេ ។ល។ ការគំរាមកំហែងចំបងៗចំពោះរុក្ខជាតិដីគោក បង្កដោយសកម្មភាពរបស់មនុស្សដូចជា ការកាប់រានយកដីដើម្បីតាំងទីលំនៅ ការធ្វើអាជីវកម្មខុសច្បាប់ ភ្លើងឆេះព្រៃ ការដុតព្រៃធ្វើចំការរបស់ជនជាតិភាគតិច ការរានដីព្រៃដើម្បីពង្រីកផ្ទៃដីកសិកម្ម ឬពាណិជ្ជកម្មដី ការធ្វើពាណិជ្ជកម្មផលឬអនុផលព្រៃឈើល្មើសច្បាប់សំរាប់បំរើទីផ្សារក្នុងតំបន់ និងអន្តរជាតិ ។

ការខិតខំថ្មីៗនេះក្នុងការវាយតំលៃស្ថានភាពនៃប្រភេទផ្សេងៗនៅមានកំរិត ហើយគេនៅមិនទាន់ដឹងច្បាស់អំពីរបាយនៃប្រភេទទាំងនេះ និងប្រភេទសត្វសំខាន់ៗផ្សេងទៀត នៅក្នុងប្រទេសនៅឡើយទេ ។ ដោយសារសមត្ថភាពរបស់ស្ថាប័នពាក់ព័ន្ធនឹងការពង្រឹងការអនុវត្តន៍ច្បាប់នៅមានកំរិតទាប ការធ្វើពាណិជ្ជកម្មល្មើសច្បាប់កើតមានជាទូទៅចំពោះប្រភេទសត្វមួយចំនួន ។

បញ្ហាចំបង

- វិធានការការពារនៅមានកំរិតទាប ។
- ការសិក្សាតាមដានជាយថាក្រមនូវបណ្ណាភារៈនៃប្រភេទទាំងអស់នៅមានកំរិត ។
- ខ្វះពតិមានលំអិតស្តីពី វត្តមាន ស្ថានភាព និងទីជំរកចាំបាច់នៃប្រភេទដែលងាយប្រឈមគ្រោះថ្នាក់ ។
- ការបាត់បង់ជំរកបណ្តាលពីសកម្មភាពនៃការធ្វើអាជីវកម្មឈើ ការបំផ្លាញទីជំរក និងការបរបាញ់ ។
- ការធ្វើពាណិជ្ជកម្មឈើ និងសត្វព្រៃដោយល្មើសច្បាប់ ។

គោលដៅ

ធានាឱ្យមានកិច្ចការពារ អភិរក្ស និងការស្តារឡើងវិញនៅក្នុងទីជំរកធម្មជាតិ នូវប្រភេទរុក្ខជាតិ និងសត្វ ដែលគេបានដឹងថាកំពុងប្រឈមគ្រោះថ្នាក់ ។

គោលបំណងជាយុទ្ធសាស្ត្រ (*សន្ទស្សន៍បង្ហាញ*)

១.២.១ បង្កើត និងអនុវត្តកម្មវិធីស្តារឡើងវិញនូវពពួកសត្វឆ្អឹងកង និងរុក្ខជាតិមានសរសៃរុក្ខរស ដែលកំពុងប្រឈមគ្រោះថ្នាក់ (*ចំនួនកម្មវិធីស្តារឡើងវិញអនុវត្តនៅនឹងកន្លែង*) ។

១.២.២ ជំរុញការអនុវត្តន៍អនុសញ្ញាស្តីពីការធ្វើពាណិជ្ជកម្មជាអន្តរជាតិនូវប្រភេទកំពុងប្រឈមគ្រោះថ្នាក់ (CITES) និងកាត់បន្ថយផលប៉ះពាល់បណ្តាលពីការធ្វើពាណិជ្ជកម្មសត្វព្រៃដោយល្មើសច្បាប់ ( *ចំនួនករណីផាកពិន័យ* ) ។

១.២.៣ បង្កើតមូលដ្ឋានទិន្នន័យ (database) ថ្នាក់ជាតិ អំពីប្រភេទងាយប្រឈមគ្រោះថ្នាក់ ( *បរិមាណទិន្នន័យប្រមូលបាន* ) ។

ជំរើសនានា

- គ្រប់គ្រង និងអភិរក្សប្រភេទកំពុងប្រឈមគ្រោះថ្នាក់ និងទីជំរករបស់វា ។
- បង្កើនការត្រួតពិនិត្យលើការបរបាញ់ និងតាមដានការធ្វើពាណិជ្ជកម្មល្មើសច្បាប់ ជាពិសេសចំពោះប្រភេទដែលមាននៅក្នុងតារាងអនុសញ្ញា CITES ។
- កំណត់ស្ថានភាពសំរាប់ប្រភេទដែលងាយប្រឈមគ្រោះថ្នាក់ អនុលោមតាមស្តង់ដា និងលក្ខណៈវិនិច្ឆ័យអន្តរជាតិ ។
- ស្តារឡើងវិញនូវប្រភេទដែលកំពុងប្រឈមគ្រោះថ្នាក់ និងប្រភេទសាមី (endemic) ។
- ជំរុញឱ្យមានការចូលរួមពីសហគមន៍មូលដ្ឋាននៅក្នុងកម្មវិធីនាំប្រភេទដែលបាត់បង់ចូលមកក្នុងកន្លែងដើមវិញ ។
- ពង្រឹងស្ថាប័ន CITES ( ដែលបានបង្កើតហើយនៅក្រសួងកសិកម្ម) ។
- កសាងសមត្ថភាពពាក់ព័ន្ធនឹងការចាត់ចែងការងារ CITES និង បទបញ្ជា ការអនុវត្តន៍ ការធ្វើអត្តសញ្ញាណប្រភេទ ការស្តារប្រភេទឡើងវិញ និងនីតិវិធីនាំប្រភេទដែលបាត់បង់ចូលមកកន្លែងដើមវិញ ។
- បង្កើនការយល់ដឹងនៅក្នុងប្រទេស អំពីសារៈសំខាន់នៃអនុសញ្ញា CITES និងការអនុវត្តន៍អនុសញ្ញានេះ និងតួនាទីរបស់អនុសញ្ញានេះនៅក្នុងការអភិរក្សជីវៈចំរុះក្នុងមូលដ្ឋាន និងនៅលើពិភពលោក ។
- អនុវត្តសកម្មភាពតាមដានជាយថាក្រម ដើម្បីអង្កេតបណ្តាប្រភេទដែលងាយប្រឈមគ្រោះថ្នាក់ ។
- អនុវត្តវិធានការការពាររុក្ខជាតិកំរ និងដែលងាយប្រឈមគ្រោះថ្នាក់ ព្រមទាំងប្រភេទសត្វកំពុងប្រឈមគ្រោះថ្នាក់ឈានទៅការបាត់បង់ ឬផុតពូជ ។
- ហាមឃាត់សកម្មភាព និងការអភិវឌ្ឍន៍ដែលគំរាមកំហែងជំរកសត្វព្រៃ ។
- បង្កើតមូលដ្ឋានទិន្នន័យ (database) ជាតិ ស្តីពីប្រភេទកំពុងប្រឈមគ្រោះថ្នាក់ ។

សកម្មភាពជាអាទិភាព (ស្ថាប័នសំរបសំរួល និងចូលរួមអនុវត្ត)

១.២.១ ការវាយតំលៃ និងការរៀបចំកម្មវិធីថ្នាក់ជាតិសំរាប់ស្តារឡើងវិញនូវប្រភេទ បណ្តាភាវៈ និងប្រព័ន្ធអេកូឡូស៊ី ដែលកំពុងប្រឈមគ្រោះថ្នាក់ ( ក្រ.កសក និង បស្ថ) រួមមាន :

- វាយតំលៃស្ថានភាពប្រភេទដែលទំនងជាកំពុងប្រឈមគ្រោះថ្នាក់ ( ក្នុងបញ្ជីក្រហម) ។
- សិក្សាតាមដានជាយថាក្រមនូវប្រភេទដែលប្រឈមគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ ។
- អភិវឌ្ឍន៍ និងអនុវត្តកម្មវិធីស្តារឡើងវិញ ។
- អនុវត្តវិធានការដើម្បីធានាការពារជំរកសំខាន់ៗ ។

១.២.២ ការអនុវត្តន៍លក្ខណៈវិនិច្ឆ័យតាមបញ្ជីក្រហមរបស់អង្គការ IUCN សំរាប់គ្រប់ក្រុម និងការបង្កើតបញ្ជីក្រហមជាតិ (ក្រ.កសក និង បស្ថ) ។

១.២.៣ ការអនុវត្តអនុសញ្ញា CITES ការកសាងសមត្ថភាព និងកម្មវិធីបង្កើនការយល់ដឹង (ក្រ.កសក និង បស្ថ) ។

១.២.៤ ការកែលំអកម្មវិធីស្តារឡើងវិញសំរាប់ប្រភេទកំពុងប្រឈមគ្រោះថ្នាក់ធ្ងន់ធ្ងរ ដោយផ្តោតលើការការអភិរក្ស និងការអភិវឌ្ឍន៍ប្រភេទទាំងនោះ (ក្រ.កសក និង បស្ថ) ។

## ១.៣ ការអភិរក្សក្រៅតំបន់

### បរិបទ

ការអភិរក្សក្រៅតំបន់ មិនត្រូវបានចាត់ជាដំណោះស្រាយសំរាប់ការអភិរក្សរយៈពេលវែងនោះទេ ។ សួនសត្វ សួនរុក្ខជាតិ តិណ្ណាល័យ ថ្នាលបណ្តុះកូនឈើ ធនាគារគ្រាប់ពូជ ធនាគារសែន អាចដើរតួនាទីមួយដ៏សំខាន់នៅក្នុងការអភិរក្ស នៅពេលណាត្រូវគេធ្វើឡើងទន្ទឹមនឹងការអភិរក្សនៅនឹងកន្លែង និងការអនុវត្តន៍កសិកម្ម រុក្ខកម្ម និងការចិញ្ចឹមសត្វប្រកបដោយនិរន្តរភាព ។

ប្រទេសកម្ពុជាពុំទាន់មានមធ្យោបាយសមស្របសំរាប់ការអភិរក្សក្រៅតំបន់ ដូចជាធនាគារសែនថ្នាក់ជាតិ ដើម្បីអភិរក្សអង្គជីវកំណ (germplasm) សំរាប់រយៈពេលវែង ពុំមានកែវចិញ្ចឹម (in vitro) ឬបន្ទប់បង្កក (cryobank) ឡើយ ។ ភាគច្រើននៃអង្គជីវកំណដែលបានប្រមូល ត្រូវបានថែទាំក្នុងលក្ខខណ្ឌធម្មជាតិ និងច្រើនតែបន្តពូជជាបន្តបន្ទាប់នៅនឹងកន្លែង ។ ឧទាហរណ៍ គ្រប់អង្គជីវកំណនៃស្រូវទាំងអស់ត្រូវបានគេថែទាំនៅក្នុងកម្មវិធី IRRI កម្ពុជា-អូស្ត្រាលីភ្នំពេញ ហើយគំរូសំណាកដូចគ្នាដែរ ត្រូវបានយកទៅថែទាំ នៅមជ្ឈមណ្ឌលធនាគារសែន IRRI Los Baños ប្រភេទហ្វីលីពីន ។ ក្នុងកិច្ចសហប្រតិបត្តិការជាមួយ IRRI ប្រទេសកម្ពុជាបានធ្វើការអង្កេតដ៏មហាញឹក ដើម្បីប្រមូលផ្តុំនូវប្រភេទពូជស្រូវមូលដ្ឋានចំរុះ ចំនួន ២.២០៩ ថែមទៀត (១៩៨៩-១៩៩៤) ដែលការសិក្សានេះទំនងជាគ្រាន់តែជាការចងក្រងឯកសារធនធានសេនេទិចនៅក្នុងប្រទេស ឱ្យបានច្បាស់លាស់តែប៉ុណ្ណោះ ។ គេនៅពុំទាន់មានកម្មវិធីវាយតំលៃប្រភេទនានានៅឡើយ ហើយទិន្នន័យ និងពតិមានផ្សេងៗ ក៏ពុំទាន់មានលក្ខណៈសមស្របនៅឡើយដែរ ។

បច្ចុប្បន្ន រាជរដ្ឋាភិបាលកំពុងគ្រប់គ្រងសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ ដែលបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៤ ក្នុងគោលបំណងប្រមូលសត្វព្រៃពីសកម្មភាពប្រមាញ់ល្មើសច្បាប់ទាំងអស់មកថែទាំ ។ ប្រសិនបើមានការអភិវឌ្ឍន៍សមស្រប មជ្ឈមណ្ឌលនេះនឹងដើរតួនាទីដ៏សំខាន់មួយក្នុងការបង្កើនចំណេះដឹងជាសាធារណៈ ។ ថ្មីៗនេះ យ៉ាងហោចណាស់មានសួនសត្វឯកជនចំនួន ៩ កន្លែង ត្រូវបានបង្កើតឡើង ដែលភាគច្រើនមាននៅខេត្តកំពត សៀមរាប និងព្រៃវែង ។ ជាអកុសល សួនសត្វឯកជនទាំងនោះពុំមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ម្យ៉ាងទៀតបុគ្គលិកបំរើការនៅទីនោះ ពុំដែលបានទទួលការបណ្តុះបណ្តាលសមស្របណាមួយ ពាក់ព័ន្ធទៅនឹងការបង្កាត់ពូជសត្វទេ ហើយអត្រាសត្វងាប់នៅតាមសួនសត្វទាំងនោះមានកំរិតខ្ពស់ណាស់ ។ សត្វដែលយកមកគ្រប់គ្រងជាលក្ខណៈឯកជន ច្រើនតែបានមកពីការចាប់ និងការធ្វើពាណិជ្ជកម្មល្មើសច្បាប់ [illegible] ពាសពេញប្រទេស ហើយសកម្មភាពបង្កើតសួនសត្វឯកជនបែបនេះ អាចជាការលើកទឹកចិត្តដល់អ្នកលប [illegible] ដើម្បីស្វែងរកសត្វព្រៃដែលមានដោយកំរ ។ សកម្មភាពទាំងនេះ បានចូលរួមដោយប្រយោលក្នុងការ [illegible]

គំរាមកំហែងចំពោះសត្វព្រៃក្នុងប្រទេសកម្ពុជា ។ បច្ចុប្បន្ន ពុំទាន់មានសួនភូតគាមបង្កើតនៅក្នុងប្រទេសកម្ពុជានៅឡើយទេ គឺមានត្រឹមតែការប្រមូលផ្តុំរុក្ខជាតិក្នុងស្រុកជាទ្រង់ទ្រាយតូចនៅឯភ្នំតាម៉ៅតែប៉ុណ្ណោះ ។ ថ្នាលបណ្តុះកូនឈើ ហ៊ុន សែន ក្រាំងយ៉ូវ និងមជ្ឈមណ្ឌលកប់ស្រូវ ជាកន្លែងប្រមូលគ្រាប់ពូជ និងបណ្តុះកូនឈើសំរាប់កសិករ ។ ការបណ្តុះពូជឈើក្នុងស្រុក ក្នុងគោលបំណងដាំព្រៃឈើឡើងវិញ នៅមានកំរិតទាបនៅឡើយ ។ ការអភិវឌ្ឍន៍ដ៏ត្រឹមត្រូវដោយប្រើប្រាស់មធ្យោបាយថ្មីៗ និងមធ្យោបាយដែលមានស្រាប់ គួរតែផ្តោតលើការបណ្តុះប្រភេទឈើក្នុងស្រុក សំរាប់ការដាំព្រៃឈើឡើងវិញ ។

### បញ្ហាចំបង

- ខ្វះហេដ្ឋារចនាសម្ព័ន្ធសំរាប់ការអភិរក្សក្រៅតំបន់ ។
- កំនើនសេចក្តីត្រូវការសត្វសំរាប់សួនសត្វឯកជន ។
- ពុំមានផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព សំរាប់ការគ្រប់គ្រងចំរុះនូវការអភិរក្សក្រៅតំបន់ឡើយ ។
- ពុំមានតំណាងពូជគ្រប់គ្រាន់ ក្នុងធនាគារគ្រាប់ពូជដែលមានស្រាប់ ។
- ការខិតខំប្រឹងប្រែងកសាងសមត្ថភាពបច្ចេកទេសនៅពុំទាន់គ្រប់គ្រាន់ ។

### គោលដៅ

អភិរក្សក្រៅតំបន់ នូវសមាសភាពដែលងាយទទួលរងគ្រោះថ្នាក់ រងការផុតពូជ ឬសមាសធាតុពិសេសនៃធម្មជាតិ ឬសមាសភាគកសិកម្ម របស់ជីវៈចំរុះ ។

### គោលបំណងជាយុទ្ធសាស្ត្រ (*សន្ទស្សន៍បង្ហាញ*)

១.៣.១ បង្កើតអ្នកជំនាញថ្នាក់ជាតិក្នុងការអភិរក្សក្រៅតំបន់ (*ប្រជាជនជាច្រើនបានចូលរួមសិក្ខាសាលា ឬកម្មវិធីបណ្តុះបណ្តាលនានា*) ។

១.៣.២ បង្កើនសមត្ថភាព អភិរក្សក្រៅតំបន់ សំរាប់រុក្ខជាតិព្រៃ និងពូជដែលទទួលរងគ្រោះថ្នាក់ (*មានរុក្ខជាតិ និងតំណាងពូជជាច្រើននៅក្នុងធនាគារពូជ ឬការប្រមូលផ្តុំក្រៅតំបន់នានា*) ។

១.៣.៣ បង្កើនការប្រើប្រាស់ប្រភេទឈើក្នុងស្រុកនៅក្នុងគំរោងដាំឈើឡើងវិញ (*ប្រភេទឈើ ក្នុងស្រុកជាច្រើនត្រូវបានដាំក្នុងសកម្មភាពដាំឈើឡើងវិញ*) ។

### ជំរើសនានា

- [illegible]ការអភិរក្សធនធានសេនេទិច នៃរុក្ខជាតិដែលទទួលរងគ្រោះថ្នាក់នៅក្នុងកែវចិញ្ចឹម (in vitro) ឬបន្ទប់ត្រជាក់ (cryobank) ។
- [illegible]សួនភូតគាមជាតិ ដើម្បីសកម្មភាពអភិរក្សក្នុង និងក្រៅតំបន់ ។

- បណ្តុះបណ្តាលអំពីវិធីសង្គ្រោះសត្វព្រៃតាមបច្ចេកទេសទំនើបដល់មន្ត្រីជំនាញ ។
- ទប់ស្កាត់ការបង្កើតសួនសត្វឯកជន ។
- បង្កើតមជ្ឈមណ្ឌលដើម្បីអភិរក្ស និងធ្វើឱ្យប្រសើរឡើងនូវធនធានសេនេទិចនៃសត្វ និងរុក្ខជាតិក្នុងស្រុក ។
- ពង្រឹងធនាគារសែននៃរុក្ខជាតិដំណាំកសិកម្ម ។
- ការចូលរួមរបស់សហគមន៍មូលដ្ឋានក្នុងការអនុវត្តន៍ការអភិរក្សក្រៅតំបន់ ។
- ពង្រីកឧទ្យានជាតិនានាដែលមានស្រាប់ ដើម្បីដាក់បញ្ចូលសួនរុក្ខតគាម ដែលអាចផ្តល់នូវថ្នាលបណ្តុះកូនឈើក្នុងស្រុក ព្រមទាំងរុក្ខជាតិឱសថផងដែរ ។
- លើកទឹកចិត្តដល់ការចូលរួមរបស់ប្រជាជនមូលដ្ឋានក្នុងការអនុវត្តន៍ការអភិរក្សក្រៅតំបន់ ។

សកម្មភាពជាអាទិភាព (ស្ថាប័នសំរបសំរួល និងចូលរួមអនុវត្ត)

១.៣.១ ការបង្កើតសួនរុក្ខតគាមជាតិ ( ក្រ.កសក បស្ថ និងCARDI) ។

១.៣.២ ការបង្កើតតិណ្ណាល័យទូទៅ ( ក្រ.កសក បស្ថ និង CARDI) ។

១.៣.៣ ធ្វើអត្តសញ្ញាណកម្ម ប្រមូលប្រភេទរុក្ខជាតិ និងពូជដែលចាំបាច់ការពារសំរាប់ការផ្សព្វផ្សាយ ( ក្រ.កសក បស្ថ និង CARDI) ។

១.៣.៤ កម្មវិធីបណ្តុះបណ្តាលផ្នែកបច្ចេកទេសចិញ្ចឹមសត្វព្រៃ ដល់មន្ត្រីមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅនិងសួនសត្វឯកជន ( ក្រ.កសក) ។

## ប្រធានបទទី ២ : ធនធានសត្វព្រៃ

### បរិបទ

ប្រទេសកម្ពុជាសំបូរដោយសត្វច្រើនបែប ។ ប្រភេទខ្លះមានសារៈសំខាន់ក្នុងការកំចាត់សត្វចង្រៃដែលបំផ្លាញផលិតផលកសិកម្ម (ឧទាហរណ៍ : ពពួកមំសាសត្វកំចាត់ពពួកសត្វកកេរ សត្វស្លាបការពារផលដំណាំដោយស៊ីសត្វល្អិតជាអាហារ) កំចាត់សត្វចង្រៃ (ឧទាហរណ៍ : ប្រចៀវស៊ីមូស ត្រីស៊ីដង្កូវទឹក) ឬការជញ្ជូនលំអងផ្កា (សត្វឃ្មុំ) ។ ពពួកសត្វស្លាបខ្លះត្រូវបានយកមកផ្សាំងដើម្បីចិញ្ចឹមយកស៊ុត និងសាច់ ។ ប្រភេទមួយចំនួនអាចទាក់ទាញភ្ញៀវទេសចរ (ដូចជាដំរី សត្វស្លាប) ប៉ុន្តែសត្វប្រភេទខ្លះក៏អាចជាបរាសិត និងជាភ្នាក់ងារបង្ករោគរាតត្បាតដល់សត្វ និងមនុស្សផងដែរ (មូស) ។

ពិតមែនតែការបរបាញ់ជាសកម្មភាពល្មើសច្បាប់ក្តី ក៏វាបានកើតមានជាទូទៅ និងបង្កការគំរាមកំហែងចំពោះសត្វស្លាប និងប្រភេទថនិកសត្វមួយចំនួន ជាពិសេសប្រភេទដែលងាយប្រឈមគ្រោះថ្នាក់ និងប្រភេទកំរ ។ បច្ចុប្បន្ន ការធ្វើអាជីវកម្មសត្វពស់ព្រលិត កង្កែប តឹង្កក់ អាពីង ខ្យង កន្ដេះឡង់ កណ្តូប នៅមិនទាន់បង្កការគំរាមកំហែងចំពោះប្រភេទទាំងនេះនៅឡើយទេ ហើយសកម្មភាពទាំងនេះបាន និងកំពុងកើតមានជាទូទៅ សំរាប់ផ្គត់ផ្គង់តំរូវការនៅទីផ្សារក្នុងស្រុក ។ អណ្តើក សត្វស្លាប និងស្វាត្រូវបានគេចាប់យកទៅលក់ សំរាប់ធ្វើជាអាហារ ឬជាសត្វចិញ្ចឹមលំអ ។ មេអំបៅ ស្លាបក្ងោក គេងកង និងញ៉ាំងត្រូវបានគេចាប់យកទៅលក់សំរាប់ជាគ្រឿងលំអ ឬវត្ថុអនុស្សាវរីយ៍ ។ ការធ្វើពាណិជ្ជកម្មសត្វរស់ និងផលិតផលសត្វទាំងនោះ គឺជាកត្តាចំបង ក្នុងការធ្វើឱ្យប្រភេទមួយចំនួនថយចុះ ជាពិសេសពពួកល្មូន សត្វស្លាប និងថនិកសត្វ ។

ការបំផ្លាញ និងទន្ទ្រានជំរកដោយការប្រើប្រាស់ដីមិនសមស្រប ការបំពុលបរិស្ថាន និងការទន្ទ្រាននៃប្រភេទមកពីក្រៅស្រុក គឺជាការគំរាមកំហែងចំបងចំពោះសត្វព្រៃជាច្រើនប្រភេទ (មើលផ្នែកទី ១.២) ។ សកម្មភាពជាច្រើននាពេលថ្មីៗនេះ ដូចជាការពង្រីកទីក្រុង និងការអភិវឌ្ឍន៍ (ឧទាហរណ៍ : ការកសាងផ្លូវថ្នល់ ការសាងសង់ទំនប់) បង្កការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ទីជំរក និងធ្វើឱ្យទីជំរកប្រែប្រួល ។ សកម្មភាពផ្សេងទៀត ដូចជាការជីកយករ៉ែ ការធ្វើអាជីវកម្មព្រៃឈើ និងកសិកម្ម ក៏ធ្វើឱ្យបាត់បង់ជំរកផងដែរ ។ ការកែប្រែផ្លូវទឹក និងការផ្លាស់ប្តូរស្ថានភាពចែកចាយទឹកនៅក្នុងទីជំរាល ធ្វើឱ្យប៉ះពាល់ជីវៈចំរុះ ទាំងនៅក្នុងទឹក ទាំងនៅលើដី ។ ការគ្រប់គ្រង និងប្រើប្រាស់ថ្នាំសំលាប់សត្វល្អិតពុំសមស្រប បណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមាន ចំពោះជីវៈចំរុះក្នុងទឹក និងបង្កមហន្តរាយដល់សត្វនានា ដែលមិនមែនជាគោលដៅត្រូវកំចាត់ ដូចជាពពួកសត្វអាត្រូប៉ូត ល្មូន ថលជលិក និងសត្វស្លាប រួមទាំងបង្កការគំរាមកំហែងចំពោះសុខភាពមនុស្សផងដែរ ។ ការនាំចូលប្រភេទត្រីពីខាងក្រៅប្រទេសមកចិញ្ចឹម ក៏អាចបង្កការគំរាមកំហែង ចំពោះប្រភេទពូជត្រីក្នុងស្រុកផងដែរ ។

គេមានពតិមានតិចតួចណាស់អំពីស្ថានភាព និងការវិវត្តន៍នៃប្រភេទសត្វភាគច្រើនក្នុងប្រទេសកម្ពុជា ដូច្នេះប្រទេសនេះចាំបាច់ត្រូវមានវិធានការជាបន្ទាន់ ដើម្បីកសាងសមត្ថភាព សំរាប់សិក្សាតាមដាន និងគ្រប់គ្រង សត្វព្រៃឱ្យបានខ្ជាប់ខ្ជួន និងដើម្បីអាចធានាការប្រើប្រាស់ធនធានដ៏សំខាន់ទាំងនេះដោយនិរន្តរភាព ក៏ដូចជាដើម្បីទប់ស្កាត់ការវិនាសផុតពូជនៃប្រភេទនានា ដែលមិនអាចកើតឡើងវិញបាន ។

**បញ្ហាចំបង**

- កង្វះខាតពត៌មានស្តីពីស្ថានភាពសត្វព្រៃ ។
- ការបំផ្លាញជំរក ការរេចរឹល និងការបំពុល ។
- ការបរបាញ់ល្មើសច្បាប់ ការធ្វើអាជីវកម្មហួសកំរិត និងការធ្វើពាណិជ្ជកម្មល្មើសច្បាប់ ។
- ការរាតត្បាតនៃប្រភេទមកពីក្រៅស្រុក ។

**គោលដៅ**

ធានាការអភិរក្ស និងការប្រើប្រាស់ធនធានសត្វព្រៃដោយនិរន្តរភាព ។

**គោលបំណងជាយុទ្ធសាស្ត្រ (*សន្ទស្សន៍បង្ហាញ*)**

២.១ កាត់បន្ថយការបរបាញ់ល្មើសច្បាប់ និងការធ្វើពាណិជ្ជកម្មសត្វព្រៃ (*ចំនួនករណីផាកពិន័យ*) ។

២.២ កាត់បន្ថយផលប៉ះពាល់នៃការរាតត្បាតដោយប្រភេទពីក្រៅស្រុក ចំពោះប្រភេទសត្វក្នុងស្រុក (*វិធានការទប់ស្កាត់ការសាយភាយនៃប្រភេទពីក្រៅស្រុក*) ។

២.៣ សិក្សាតាមដានអំពីស្ថានភាព និងកំរិតនៃការធ្វើអាជីវកម្មសត្វព្រៃ (*កម្មវិធីសិក្សាតាមដានបាន និងកំពុងអនុវត្ត*) ។

**ជំរើសនានា**

- លើកកំពស់ ប្រសិទ្ធិភាពនៃការអនុវត្តច្បាប់ ដើម្បីប្រឆាំងសកម្មភាពបរបាញ់ល្មើសច្បាប់ ។
- បង្កើតក្រុមការងារ ដើម្បីត្រួតពិនិត្យការគំរាមកំហែង បណ្តាលមកពីការទន្ទ្រានរនៃប្រភេទពីក្រៅស្រុក និងកសាងផែនការសកម្មភាពដោះស្រាយបញ្ហាដែលកំពុងមានបច្ចុប្បន្ន ។
- បង្កើតយន្តការថ្នាក់សហគមន៍មូលដ្ឋានសំរាប់ត្រួតពិនិត្យសកម្មភាពបរបាញ់ ។
- សកម្មភាពបង្កើនការយល់ដឹងដល់សហគមន៍ ដោយផ្តោតលើសារៈសំខាន់នៃប្រភេទសត្វព្រៃចំពោះមនុស្ស (ឧទាហរណ៍ សត្វស្វាបកំចាត់សត្វល្អិតចង្រៃ និងប្រចៀវមានសារៈសំខាន់ក្នុងដំនើរលំអងផ្កា) ។
- ពង្រីកចង្កោមតំបន់ការពារធម្មជាតិ ដើម្បីការពារជំរកឱ្យបានទូលាយ ។

**សកម្មភាពជាអាទិភាព (ស្ថាប័នសំរបសំរួល និងចូលរួមអនុវត្ត)**

២.១ យុទ្ធនាការថ្នាក់ជាតិ ប្រឆាំងការបរបាញ់ល្មើសច្បាប់ (ក្រ.កសក និង បស្ថ) ។

២.២ កម្មវិធីសិក្សាតាមដានថ្នាក់ជាតិ និងមូលដ្ឋានទិន្នន័យ អំពីប្រភេទពីក្រៅស្រុក និងប្រភេទសត្វព្រៃដែលត្រូវបានធ្វើអាជីវកម្ម (ក្រ.កសក និង បស្ថ) ។

២.៣ វិធានការគ្រប់គ្រងប្រភេទដែលមានតំលៃពាណិជ្ជកម្ម (ក្រ.កសក និង បស្ថ) ។

## ប្រធានបទទី ៣ : ផលផលទឹកសាប និងវារីវប្បកម្ម

### បរិបទ

ប្រទេសកម្ពុជាមានអំណោយផល និងជាប្រទេសដែលសំបូរត្រីទឹកសាបបំផុតមួយ ក្នុងចំណោមប្រទេសនានាលើពិភពលោក ។ មានត្រីទឹកសាបប្រមាណ ៤៨៦ ប្រភេទ រស់នៅក្នុងសំបុកអេកូឡូស៊ី (ecological niches) ប្លែក១ ដែលរួមមាន ពពួកស៊ីប្លង់តុងជាចំណី ពពួកស៊ីកំទេចកំណ ពពួកស៊ីសាច់ និងពពួកស៊ីចំណីចំរុះ ។ យ៉ាងហោចមានត្រី ៤៥ ប្រភេទ ដែលគេទទួលស្គាល់ថា មានសារៈសំខាន់សេដ្ឋកិច្ច ។ ដែននេសាទទឹកសាបរួមមាន ទន្លេ បឹង ព្រែក វាលភក់ ទំនាបលិចទឹក (និងព្រៃលិចទឹក) និងតំបន់ដីសើម ។ ទន្លេមេគង្គ និងបឹងទន្លេសាប ជាទីជំរកសំខាន់បំផុតរបស់ត្រីក្នុងប្រទេសកម្ពុជា ។ ការផ្លាស់ប្តូរទិសចរន្តទឹករវាងទន្លេមេគង្គ និងបឹងទន្លេសាបទៅតាមរដូវ និងជំនន់លិចទំនាប ជាបាតុភូតចំបង ដែលរួមចំណែកធ្វើឱ្យដែននេសាទមានផលិតភាពខ្ពស់ ។ ផលិតភាពត្រីអាស្រ័យនឹងវិសាលភាពនៃទឹកជំនន់ ។ នៅក្នុងឆ្នាំដែលមានទឹកជំនន់តូច ផលិតភាពត្រីទាបជាងឆ្នាំដែលទឹកជំនន់ធំ ។ ហេតុនេះការកសាងទំនប់ទឹក និងប្រព័ន្ធបង្វែរទឹកតាមទន្លេ អាចជះឥទ្ធិពលជាអវិជ្ជមានដល់ផលិតភាពត្រី ។

ត្រីជាប្រភពដ៏សំខាន់នៃប្រូតេអ៊ីនសំរាប់ប្រជាជនកម្ពុជា ។ ការប៉ាន់ប្រមាណអត្រាបរិភោគត្រីជាមធ្យមប្រចាំឆ្នាំក្នុងម្នាក់គឺ ៧៥ គ.ក សំរាប់ប្រជាជននៅតំបន់ទំនាបកណ្តាលនៃប្រទេស និងអត្រាមធ្យម ៣០-៤០ គ.ក/ម្នាក់/ឆ្នាំ សំរាប់ប្រជាជនកម្ពុជាទូទៅ ។ ភាគច្រើននៃត្រីស្រស់ ឬផលិតផលត្រី (ប្រហុក) នៅមានថ្លៃទាប ដែលប្រជាជនក្រីក្រនៅជនបទអាចមានលទ្ធភាពទិញបាន ។ ត្រី និងស្រូវបង្កើតជាមូលដ្ឋាននៃសន្តិសុខស្បៀងក្នុងប្រទេសកម្ពុជា ។ ផលនេសាទប្រចាំឆ្នាំត្រូវបានប៉ាន់ប្រមាណក្នុងរវាង ៣០០.០០០ ទៅ ៤៥០.០០០ តោន និងមានតំលៃលក់ដុំសរុបប្រមាណ ២០០-២៥០ លានដុល្លារអាមេរិក ។ តំលៃសរុបបានពីការលក់ត្រីតាមថ្លៃលក់រាយនៅទីផ្សារត្រូវបានប៉ាន់ប្រមាណក្នុងកំរិត ២៥០-៥០០ លានដុល្លារអាមេរិក ។

ទិន្នន័យប៉ាន់ប្រមាណអំពីផលនេសាទបច្ចុប្បន្នអាចខ្ពស់ជាងផលនេសាទកាលពីអតីតកាល ប៉ុន្តែទិន្នផលនេសាទសំរាប់អ្នកនេសាទម្នាក់មាននិន្នាការថយចុះ អត្រាត្រីធំកាន់តែថយចុះ ដែលជាការបង្ហាញថា មានការនេសាទលើសកំរិត ។ មានរបាយការណ៍ខ្លះបានឱ្យដឹងថា ប្រភេទត្រីមួយចំនួនកំពុងប្រឈមនឹងគ្រោះថ្នាក់ ។ ទីជំរកនៅក្នុងតំបន់ទំនាបលិចទឹក ដូចជាព្រៃលិចទឹក រួមចំណែកធ្វើឱ្យមានផលិតភាពត្រីខ្ពស់ និងសំបូរបែប ។ សកម្មភាពកាប់ព្រៃឈើ ឬការវាតដីព្រៃលិចទឹកសំរាប់ធ្វើកសិកម្ម បានធ្វើឱ្យបាត់បង់វិសាលភាព និងគុណភាពនៃទីជំរកទាំងនេះ ។

ការនេសាទនៅប្រទេសកម្ពុជាត្រូវបានចែកជាបីក្រុម គឺ ការនេសាទឧស្សាហកម្ម សិប្បកម្ម និងលក្ខណៈគ្រួសារ ។ ការនេសាទឧស្សាហកម្មប្រព្រឹត្តទៅនៅក្នុងឡូត៍នេសាទ តាមរយៈការដេញថ្លៃ ដើម្បីទទួលសិទ្ធិធ្វើអាជីវកម្មសំរាប់អណត្តិពីរឆ្នាំ ។ ជាទូទៅ ឡូត៍នេសាទធំ១អាចមានបណ្តោយពី ១៥ ទៅ ២០ គ.ម និងទទឹងពី ៥ ទៅ ១០ គ.ម ដែលអាចដេញថ្លៃក្នុងតម្លៃ ២០០.០០០ ដុល្លារអាមេរិកក្នុងមួយឆ្នាំ ចំណែកឯឡូត៍នេសាទតូចអាចមានតម្លៃពី ២.០០០ ទៅ ៥.០០០ ដុល្លារអាមេរិក ។ ចំណូលបានពីការនេសាទ រួមចំណែកប្រមាណ ៨-១០% នៃផលិតផលក្នុងស្រុកសរុប ។

ឧបករណ៍ និងវិធីនេសាទអាចចែកចេញជាពីរក្រុម គឺ : ការនេសាទក្នុងឡូត៍នេសាទ និងការនេសាទ[illegible] ។ [illegible] គ្រប់គ្រងនេសាទតាមប្រពន្ធ័ឡូត៍នេសាទត្រូវបានអនុវត្តនៅកម្ពុជាជាងមួយសតវត្សរ៍មកហើយ ។ ការជួល[illegible] រូបភាពដេញថ្លៃឡូត៍នេសាទរបស់រាជរដ្ឋាភិបាល តែងត្រូវបានទទួលការចោទប្រកាន់ថា ពុំមានតម្លាភាព ។ ឡូត៍នេ[illegible]

ទីតាំងក្នុងបឹងទន្លេសាប លាតសន្ធឹងលើវិសាលភាពប្រមាណ ៨០% នៃឆ្នេរបឹង រួមទាំងព្រៃលិចទឹកផងដែរ ។ ការកំនត់ថ្លៃឡូត៍នេសាទធ្វើឡើង ដោយផ្អែកតាមការយល់ឃើញអំពីផលិតភាពត្រីក្នុងឡូត៍ ហើយនេះជាមូលហេតុ ដែលនាំឱ្យមានការលំបាកក្នុងការប្រមូលទិន្នន័យឱ្យបានសុក្រឹត ។

ម្ចាស់ឡូត៍អនុវត្តការនេសាទត្រីដោយដាក់របាំងព្រួលធ្វើអំពីឬស្សី ហើយការប្រមូលផលចុងក្រោយប្រព្រឹត្តិទៅនៅចុងរដូវនេសាទ ពោលគឺនៅពេលទឹកក្នុងបឹងនៅសល់តិចបំផុត ។ ការប្រមូលផលបានតិច ឬច្រើន អាស្រ័យនឹងកំពស់ទឹកនៅក្នុងបឹង និងល្បឿនទឹកស្រកពីបឹង ។ តាមធម្មតា ម្ចាស់ឡូត៍ជួលបន្តផ្នែកខ្លះៗនៃឡូត៍នេសាទទៅឱ្យអ្នកជួលបន្ត ដោយសារឡូត៍នេសាទមានទំហំធំពេក ដែលគាត់មិនមានលទ្ធភាពគ្រប់គ្រាន់ដើម្បីនេសាទទាន់ពេល ។ នៅពេលដែលឡូត៍នេសាទត្រូវបានជួលបន្ត ឡូត៍ទាំងនោះត្រូវបានបែងជាចំណែកតូចៗ ដែលអាចឱ្យគេមានលទ្ធភាពធ្វើនេសាទយ៉ាងមានប្រសិទ្ធភាព ។

ឡូត៍នេសាទនីមួយៗមានសៀវភៅបន្ទុក ដែលចែងពីព្រំប្រទល់ឡូត៍ ពេលវេលាអនុញ្ញាតឱ្យធ្វើនេសាទ ទីកន្លែង និងពេលវេលាដែលកំនត់សំរាប់ការធ្វើនេសាទជាសាធារណៈ ។ ជាទូទៅ ឡូត៍នេសាទជាអ្នកការពារពីសកម្មភាពលួចនេសាទ និងដើម្បីការពារទីជំរកត្រី ។ មានទំនាស់ជាច្រើនរវាងអ្នកឡូត៍នេសាទ និងប្រជានេសាទមូលដ្ឋាន ពាក់ព័ន្ធនឹងបញ្ហាព្រំប្រទល់ឡូត៍ ការរំលោភយកដី និងការនេសាទល្មើសច្បាប់ ។

ការនេសាទសាធារណៈ ត្រូវបានគេសង្កេតឃើញមានសភាពកើនឡើងយ៉ាងខ្លាំង ក្នុងពេលថ្មីៗនេះ ។ ការនេសាទបែបនេះអាចចែកជា : ការនេសាទជាលក្ខណៈគ្រួសារ ការនេសាទសិប្បកម្ម និងការនេសាទល្មើសច្បាប់ ។ ការនេសាទទ្រង់ទ្រាយតូច ឬនេសាទជាលក្ខណៈគ្រួសារ អាចប្រើប្រាស់ឧបករណ៍ជាច្រើនប្រភេទប៉ុន្តែមានទំហំតូច ។ ការនេសាទជាលក្ខណៈគ្រួសារអាចប្រព្រឹត្តទៅគ្រប់រដូវ ។ ការនេសាទសិប្បកម្មមានប្រើប្រាស់ឧបករណ៍នេសាទទំហំធំជាង នឹងត្រូវសុំលិខិតអនុញ្ញាត ដែលតំរូវឱ្យនេសាទតែក្នុងរដូវបើកនេសាទ គឺពីថ្ងៃទី ១ ខែ តុលា ដល់ថ្ងៃទី ៣១ ខែ ឧសភា ចំពោះដែននេសាទដែលស្ថិតនៅខាងជើងខ្សែស្របទន្លេទន្លេចតុមុខ និងពីថ្ងៃទី ១ ខែ វិច្ឆិកា ដល់ ថ្ងៃទី ៣០ ខែ មិថុនា ចំពោះដែននេសាទដែលស្ថិតនៅខាងត្បូងខ្សែទន្លេចតុមុខ ។ នៅក្នុងច្បាប់គ្រប់គ្រងជលផលមានចែងអំពីឧបករណ៍នេសាទមួយចំនួន ទៅតាមប្រភេទ និងទំហំ ដូចជាមង អួន លប ។ល។ ដែលការនេសាទដោយឧបករណ៍ទាំងនេះត្រូវមានលិខិតអនុញ្ញាត ។ ការនេសាទល្មើសច្បាប់ជាប្រភេទនេសាទដែលពុំមានចែងក្នុងច្បាប់ជលផល ដូចជាការដាក់សំរាស់ និងការនេសាទដោយគ្រឿងផ្ទុះ ជាដើម ។

ថ្មីៗនេះនាយកដ្ឋានជលផលបានអនុវត្តគោលនយោបាយរាជរដ្ឋាភិបាល ក្នុងការកែទំរង់វិស័យជលផល ដែលក្នុងនោះដែនឡូត៍នេសាទប្រមាណ ៥០០.០០០ ហ.ត ត្រូវកាត់ផ្ទេរជូនប្រជារាស្ត្រ នៅក្នុងខែ មិថុនា ឆ្នាំ ២០០១ សំរាប់គ្រប់គ្រងតាមបែបសហគមន៍ ។

ვារីវប្បកម្មទឹកសាប

ប្រជាកសិករច្រើនដែលរស់នៅតាមភូមិបណ្តែតទឹកជុំវិញបឹងទន្លេសាប ចិញ្ចឹមត្រីក្នុងបែ ។ ការចិញ្ចឹមត្រីក្នុងបែនេះគឺជាការចិញ្ចឹមប្រភេទត្រីក្នុងស្រុក ដោយយកពូជត្រីមកប្រស់ទុកក្នុងបែ និងផ្តល់ចំណីដើម្បីបំប៉នឱ្យធំធាត់ មុនពេលចាប់លក់នៅពេល[illegible]ខ្ពស់ ។ នាយកដ្ឋានជលផលបានសហការជាមួយអង្គការអន្តរជាតិនានា ដើម្បីជំរុញ និងផ្សព្វផ្សាយវារីវប្បកម្ម

យ៉ាងសកម្ម នៅតាមបណ្តាខេត្តនានា ដើម្បីធានាសន្តិសុខស្បៀង ។ ភាគច្រើននៃការងារចិញ្ចឹមត្រីនេះ មានលក្ខណៈជាគ្រួសារ ឬទ្រង់ទ្រាយតូចប៉ុណ្ណោះ ហើយមានអ្នកខ្លះចិញ្ចឹមត្រីក្នុងស្រែតែម្តង ។

ទិន្នផលវារីវប្បកម្មទឹកសាប ជាពិសេស ការចិញ្ចឹមត្រីក្នុងស្រះ បានកើនឡើងពី ១.៦០០ តោន ក្នុងឆ្នាំ ១៩៨៤ ទៅដល់ ១៥.០០០ តោន ក្នុងឆ្នាំ ១៩៩៩ ។ សន្ទុះកើនឡើងយ៉ាងឆាប់រហ័សនៃទិន្នផលវារីវប្បកម្មបែបនេះ បង្ហាញពីសក្តានុពលក្នុងការពង្រីកវិស័យវារីវប្បកម្មទៅអនាគត ។ បច្ចុប្បន្ននៅប្រទេសកម្ពុជា មានការចិញ្ចឹមប្រភេទត្រីក្រៅស្រុក ដែលអាចបង្កឥទ្ធិពលដល់ប្រព័ន្ធអេកូឡូស៊ីប្រភេទត្រីក្នុងស្រុកយ៉ាងខ្លាំងក្នុងពេលអនាគត ពិសេសប៉ះពាល់ដល់វារីជីវៈចំរុះ ។ រហូតមកទល់បច្ចុប្បន្ននេះ កម្ពុជាពុំទាន់មានគោលការណ៍ណែនាំ សំរាប់ការនាំចូលប្រភេទត្រីពីបរទេសមកចិញ្ចឹមនៅក្នុងស្រុកឡើយ ។ ក្នុងលក្ខខ័ណ្ឌនេះ ការអភិវឌ្ឍន៍វារីវប្បកម្មទឹកសាបអាចបង្កឱ្យមានផលប៉ះពាល់អវិជ្ជមាន បណ្តាលពីប្រភេទត្រីក្រៅស្រុក ចំពោះត្រីក្នុងស្រុក និងអាចជះឥទ្ធិពលអាក្រក់ដល់សន្តិសុខស្បៀងនៅកម្ពុជា ។

បញ្ហាចំបង

- ការនេសាទជាលក្ខណៈបំផ្លាញ ។
- ការបំផ្លាញជំរក (ការបំផ្លាញព្រៃលិចទឹក កំនើនកំទេចកំនរ) ។
- ការអនុវត្តន៍ច្បាប់ និងបទបញ្ញត្តិ ។
- អាជីវកម្មធនធានជលផលហួសកំរិត (ការនេសាទល្មើសច្បាប់ និងការនេសាទហួសកំរិត) ។
- ចំណេះដឹងអំពីធនធានជលផល ។
- ការកំណត់តំបន់ព្រៃលិចទឹក ។
- ការកំណត់តំបន់ឡូត៍នេសាទ ។
- ការទទួលខុសត្រូវរបស់សមត្ថកិច្ចជលផល ។
- ការប្រព្រឹត្តអំពើពុករលួយពីសំណាក់អាជ្ញាធរនៅក្នុងដែននេសាទ ។
- កង្វះខាតចំនួនមន្ត្រីជលផលដែលមានសមត្ថភាពគ្រប់គ្រាន់សំរាប់អភិវឌ្ឍន៍សហគមន៍នេសាទ ។
- សហគមន៍មិនមានជំនាញគ្រប់គ្រង និងមិនបានទទួលការបណ្តុះបណ្តាលសមរម្យ ។
- កង្វះខាតប្រភេទត្រីក្នុងស្រុក ដែលសមស្របសំរាប់ប្រើប្រាស់ក្នុងផលិតកម្មវារីវប្បកម្ម ។
- ការកសាងទំនប់ ប្រព័ន្ធធារាសាស្ត្រ និងកម្មវិធីការពារទឹកជំនន់ ។
- ការវាតទីពង្រីកឡូត៍នេសាទដោយម្ចាស់ឡូត៍ដែលមានអំណាច ។
- កង្វះខាតកិច្ចការពារជំរកសំខាន់ៗក្នុងមជ្ឈដ្ឋានទឹក (ឡូត៍នេសាទបំរុង) ។

## គោលដៅ

លើកកំពស់សន្តិសុខស្បៀង បង្កើនប្រាក់ចំណូលពីវិស័យឧស្សាហកម្មនេសាទ រក្សានូវបរិស្ថានជលផល និងធានាថា ការបង្កើនផលិតកម្មត្រីមិនមានឥទ្ធិពលអវិជ្ជមានដល់គោលការណ៍និរន្តរភាព ។

## គោលបំណងជាយុទ្ធសាស្ត្រ (*សន្ទស្សន៍បង្ហាញ*)

៣.១ រៀបចំ និងគាំទ្រសហគមន៍នេសាទ (*ចំនួនសហគមន៍នេសាទដែលបានបង្កើត*) ។

៣.២ ជំរុញការប្រើប្រាស់បច្ចេកទេសនេសាទ ដែលមិនបង្កហេតុប៉ះពាល់ដល់បរិស្ថាន (*ចំនួនអ្នកនេសាទដែលទទួលការផ្សព្វផ្សាយ អំពីកម្មវិធីបង្កើនការយល់ដឹង ឬកម្មវិធីបណ្តុះបណ្តាល*) និងកាត់បន្ថយបទល្មើសនេសាទ (*ចំនួនករណីបទល្មើសដែលបានកត់ត្រាទុក មានការថយចុះ*) ។

៣.៣ ធ្វើឱ្យមានតម្លាភាព និងគណនេយ្យភាពក្នុងផ្នែកអាជីវកម្មនេសាទ និងធានាឱ្យមានកិច្ចការពារ និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយការទទួលខុសត្រូវពីសំណាក់ម្ចាស់ឡូត៍ (*ចំនួនករណីបទល្មើសកត់ត្រាទុក*) ។

៣.៤ ជំរុញ និងរក្សាការអភិវឌ្ឍន៍វារីវប្បកម្មដោយនិរន្តរភាព (*ចំនួនស្រះត្រីដែលបានបង្កើតឡើង*) ។

៣.៥ ថែរក្សាបរិស្ថានជលផល (*ភាគរយនៃព្រៃលិចទឹក ព្រៃកោងកាង និងប្រព័ន្ធអេកូឡូស៊ីតំបន់ដីសើមដែលបានការពារ*) ។

៣.៦ បង្កើនចំណេះដឹងអំពីប្រពន្ធ័អេកូឡូស៊ី និងភាពសំបូរបែបនៃដែននេសាទ (*បរិមាណទិន្នន័យប្រមូលបាន*) ។

## ជំរើសនានា

- កំណត់ព្រំប្រទល់ និងគ្រប់គ្រងដែននេសាទគ្រប់ប្រភេទ ដូចជាឡូត៍នេសាទ ដែននេសាទសាធារណៈ និងឡូត៍នេសាទបំរុងទុក ។
- ជំរុញការប្រើប្រាស់ប្រភេទត្រីក្នុងស្រុកក្នុងការធ្វើវារីវប្បកម្ម ។
- ជំរុញ និងកែសំរួលបទបញ្ញត្តិជលផល ដើម្បីគាំទ្រសហគមន៍នេសាទ ។
- បង្កើតសហគមន៍នេសាទ ។
- ជំរុញកិច្ចសហការ និងផ្ទេរជំនាញរវាងសហគមន៍ និងស្ថាប័ននានា ។
- ធានាឱ្យមានកិច្ចការពារព្រៃឈើជុំវិញដែននេសាទ និងតំបន់លិចទឹកនានា ។
- ធ្វើសារពើភ័ណ្ឌជីវៈចំរុះនៃប្រព័ន្ធអេកូឡូស៊ីដែននេសាទទឹកសាប ។
- បញ្ចូលពត៌មានអំពីប្រព័ន្ធអេកូឡូស៊ីដែននេសាទទៅក្នុងកម្មវិធីអប់រំសំរាប់ភាគីពាក់ព័ន្ធទាំងអស់ ។
- បង្កើនចំណេះដឹងអំពីដែននេសាទសំខាន់ៗ និងបង្ហាញអំពីសារៈសំខាន់នៃតំបន់ទាំងនោះ ។
- [illegible]លើការគំរាមកំហែងចំពោះសន្និធិធម្មជាតិនៃប្រភេទក្នុងស្រុកបណ្តាលពីការនាំចូលប្រភេទពីក្រៅមកចិញ្ចឹម ។
- ជំរុញការអភិវឌ្ឍន៍ឡូត៍នេសាទបំរុងទុករបស់សហគមន៍ ដើម្បីធានាឱ្យមានសន្និធិសំរាប់បំពេញក្នុងធម្មជាតិនៅរដូវ[illegible] ។

- រៀបរៀងឯកសារបង្រៀនអំពីការគ្រប់គ្រងការនេសាទដោយសហគមន៍ ។
- កំណត់ប្រភេទឧបករណ៍នេសាទគ្រួសារឱ្យបានសមស្រប ដើម្បីធានានិរន្តរភាពសេដ្ឋកិច្ចគ្រួសារ ។
- កំណត់កន្លែងសមស្របសំរាប់បង្កើតឡូត៍នេសាទបំរុងទុក ដើម្បីថែរក្សាសន្និធិត្រីក្នុងធម្មជាតិ ។

## សកម្មភាពជាអាទិភាព (ស្ថាប័នសំរបសំរួល និងចូលរួមអនុវត្ត)

៣.១ ការកំណត់ព្រំប្រទល់ និងគ្រប់គ្រងដែននេសាទ (ក្រ.កសក) (រួមមាន ការកែសំរួលប្រព័ន្ធឡូត៍នេសាទឡើងវិញ ការដៅព្រំប្រទល់ ការចូលរួមពីសហគមន៍មូលដ្ឋាន ការរៀបចំសៀវភៅបន្ទុកឡើងវិញ ការគ្រប់គ្រងអ្នកកាន់កាប់ឡូត៍នេសាទ) ។

៣.២ កម្មវិធីគ្រប់គ្រងជលផលដោយសហគមន៍ (ក្រ.កសក និង បស្ថ) (រួមទាំងការបណ្តុះបណ្តាលមន្ត្រីជំនាញ ការរៀបចំឯកសារបង្រៀន និងផ្គត់ផ្គង់ថវិកា) ។

៣.៣ កម្មវិធីគ្រប់គ្រងចំរុះតំបន់ទំនាបបឹងទន្លេសាប (ក្រ.កសក និង បស្ថ) (រួមទាំងផែនការប្រើប្រាស់ដី កំនត់តំបន់ធនធាន ការអភិវឌ្ឍន៍សហគមន៍ អភិវឌ្ឍន៍ឧស្សាហកម្មខ្នាតតូច ការកែច្នៃផលនេសាទនិងផលិតផលកសិកម្ម ការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន) ។

៣.៤ កម្មវិធីការពារបរិស្ថានជលផល (ក្រ.កសក បស្ថ និង អយក) (រួមទាំងកម្មវិធីលំអិតសំរាប់អប់រំបរិស្ថាននៅថ្នាក់ឃុំ ដោយផ្តោតលើកិច្ចការពារ និងគ្រប់គ្រងរុក្ខជាតិធម្មជាតិជាជំរកត្រី ការបង្កើតឡូត៍នេសាទបំរុង) ។

៣.៥ គំរោងអភិវឌ្ឍន៍វារីវប្បកម្មប្រភេទត្រីក្នុងស្រុក (ក្រ.កសក) (រួមទាំង ការជំរុញផលិតកម្មត្រីប្រភេទក្នុងស្រុក) ។

៣.៦ កម្មវិធីការពារ និងសិក្សាតាមដានប្រព័ន្ធអេកូឡូស៊ីដែននេសាទសំខាន់ៗ (ក្រ.កសក និង បស្ថ) (រួមទាំង ការធ្វើអត្ត-សញ្ញាណ និងសិក្សាតាមដានតំបន់ជាអាទិភាព និងការបង្កើតឡូត៍នេសាទបំរុង) ។

៣.៧ រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនាយកដ្ឋានជលផលឡើងវិញ (ក្រ.កសក) (រួមទាំង ការកំណត់តួនាទី និងភារកិច្ចឱ្យបានច្បាស់លាស់ ការតំឡើងឋានៈដល់មន្ត្រីរាជការ ដោយផ្អែកលើគុណសម្បត្តិ ការបង្កើនប្រាក់បៀវត្ស ការចាត់វិធានការបង្កើនប្រសិទ្ធិភាពការងាររបស់មន្ត្រីរាជការ និងការទទួលខុសត្រូវ) ។

# ប្រធានបទទី ៤ : ធនធានតំបន់ឆ្នេរ និងសមុទ្រ

**បរិបទ**

ប្រទេសកម្ពុជាមានឆ្នេរសមុទ្រប្រវែង ៤៣៥ គ.ម មាន ឆ្នេរខ្សាច់ ព្រៃកោងកាង ផ្កាថ្ម និងស្មៅសមុទ្រ ដែលមានតួនាទីយ៉ាងសំខាន់ក្នុងផលិតកម្មនៃប្រព័ន្ធអេកូឡូស៊ី ។ កម្ពុជាមានតំបន់សេដ្ឋកិច្ចផ្តាច់មុខ (EEZ) ដែលមានផ្ទៃក្រឡា ៥០០.០០០ គ.ម[២] (SEAPOL, 1991) ។

សារពើសត្វដែលមានសារៈសំខាន់ចំពោះការអភិរក្សជីវៈចំរុះនៅតំបន់ឆ្នេរ និងសមុទ្រ រួមមាន ជ្រូកទឹក ផ្សោតសមុទ្រ បាឡែន អណ្តើកសមុទ្រ ត្រី គ្រួស្តាសេ និងសិប្បីសត្វសមុទ្រ ។ មានពត៌មានតិចតួចស្តីពីស្ថានភាពសន្និធិត្រី ដែលជាពត៌មានចាំបាច់សំរាប់ការអភិវឌ្ឍន៍កម្មវិធីគ្រប់គ្រងជលផល ។ តាមតួលេខរបស់នាយកដ្ឋានជលផល ផលនេសាទសមុទ្រប្រចាំឆ្នាំជាមធ្យមមាន ៣០.០០០ តោន តែផលនេសាទពិតប្រាកដអាចខ្ពស់ជាងនេះ ព្រោះតួលេខនេះពុំបានរាប់បញ្ចូលផលនេសាទដោយទូកនេសាទធំៗពីបរទេសដែលមិនបានផ្ទេរផលត្រីនៅក្នុងប្រទេសកម្ពុជា ទូកនេសាទខុសច្បាប់ និងការនេសាទតូចតាច ។ ដែននេសាទនៅក្បែរឆ្នេរបានរងការនេសាទហួសកំរិត ដោយអ្នកនេសាទបែបសិប្បកម្ម ដែលពុំមានលទ្ធភាពទៅនេសាទនៅឯសមុទ្រក្រៅ ។

នាយកដ្ឋានជលផលពុំមានលទ្ធភាពពេញលេញក្នុងការបង្ក្រាបការធ្វើនេសាទខុសច្បាប់ និងសិក្សាតាមដានធនធាន ដោយសារកង្វះខាតសមត្ថភាពបច្ចេកទេស ឧបករណ៍សំភារៈមិនគ្រប់គ្រាន់ និងពុំមានថវិកាគ្រប់គ្រាន់ ទោះបីនាយកដ្ឋាននេះរកចំណូលបានក្រាស់ក្រែលពីសកម្មភាពជាច្រើនក្តី ដូចជាតាមរយៈការលក់អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត ការផាកពិន័យ និងកម្រៃផ្សេងៗទៀត ពីខេត្ត-ក្រុងទាំងបួន នៅជាប់តំបន់ឆ្នេរ ( ចំនួន ៤ លានដុល្លារអាមេរិក នៅឆ្នាំ ១៩៩៥) ។

តំបន់ឆ្នេរសមុទ្រគឺជាទីជំរកដ៏សំខាន់សំរាប់ប្រភេទជាច្រើន និងត្រូវតែទទួលបាននូវកិច្ចការពារឱ្យបានសមស្រប ។ ព្រៃកោងកាងបំពេញនាទីយ៉ាងសំខាន់ក្នុងការទ្រទ្រង់ជីវិតនៃប្រភេទត្រីមួយចំនួន និងសារពាង្គកាយមានជីវិតដទៃទៀតនៅក្នុងសមុទ្រ ។ ព្រៃកោងកាងមាននាទីជាកន្លែងពងកូន និងរកចំណីសំរាប់ត្រី និងសិប្បីសត្វជាច្រើនប្រភេទ ដែលមានសារៈសំខាន់ខាងសេដ្ឋកិច្ច ។ ដូចនេះ ការធ្វើអាជីវកម្មព្រៃកោងកាងហួសកំរិត អាចមានផលប៉ះពាល់ជាអវិជ្ជមានចំពោះធនធានជលផល ។

ព្រៃកោងកាងរងការខូចខាតធ្ងន់ធ្ងរ ដោយសារការកាប់ឈើសំរាប់ផលិតធ្យូង និងការប្រើប្រាស់ផ្សេងទៀត ការពង្រីកទីក្រុង ការអភិវឌ្ឍន៍តំបន់ឆ្នេរ ការបំពុលបរិស្ថាន និងប្រព័លវប្បកម្មបង្គា ដែលប្រែក្លាយតំបន់ប្រកបដោយផលិតភាពខ្ពស់ទាំងនេះ ទៅជាដីកសិកម្ម ។ ជួរផ្កាថ្ម និងស្មៅសមុទ្រ ដែលមានសារៈសំខាន់បំផុតចំពោះផលិតភាពក្នុងសមុទ្រ ត្រូវរងការគំរាមកំហែងដោយសកម្មភាពរបស់មនុស្ស ដូចជាការអភិវឌ្ឍន៍ប្រេងកាត និងឧស្ម័ននៅសមុទ្រក្រៅ និងការបំពុលបណ្តាលពីសកម្មភាពទាំងនេះ ។ ដោយសារសកម្មភាពមនុស្សដែលអាចនឹងកើនឡើងនៅពេលអនាគត ការកសាងផែនការប្រើប្រាស់ដីក្នុងតំបន់ឆ្នេរដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន មានសារៈសំខាន់ណាស់ ក្នុងការការពារតំបន់ចំបងៗទាំងនេះ សំរាប់ការនេសាទនាពេលអនាគត ។

**បញ្ហាចំបងៗ**

- ការខូចខាតទីជម្រាល

- ការបំពុលដែលបង្កដោយការហៀរកំពប់ប្រេង និងសកម្មភាពដទៃទៀតរបស់មនុស្ស ។
- ការនេសាទហួសកំរិតនូវធនធានមានតម្លៃខ្ពស់នៅតំបន់ឆ្នេរ ។
- សំណឹកដីតំបន់ឆ្នេរ និងការបាត់បង់ព្រៃកោងកាង ។
- កង្វះពត៌មានអំពីសន្និធិត្រី ។
- អនុផលបានពីការនេសាទ ដែលមិនមែនជាគោលដៅនៃការនេសាទ ឬដែលជាប្រភេទដែលត្រូវការពារ ។
- ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ និងការនេសាទក្នុងរដូវហាមឃាត់ ។
- សមត្ថភាពរបស់នាយកដ្ឋានជលផលក្នុងការងារគ្រប់គ្រង ត្រួតពិនិត្យ និងពង្រឹងការអនុវត្តច្បាប់នៅមានកំរិតទាប ។
- វារីវប្បកម្មតំបន់ឆ្នេរគ្មាននិរន្តរភាព ។

**គោលដៅ**

ធានាការអភិរក្សភាវៈមានជីវិតនៅសមុទ្រ និងតំបន់ឆ្នេរនិងការនេសាទប្រភេទត្រីដែលមានតំលៃសេដ្ឋកិច្ចដោយនិរន្តរភាព ។

**គោលបំណងជាយុទ្ធសាស្ត្រ (*សន្ទស្សន៍បង្ហាញ*)**

៤.១ លើកកំពស់ការប្រើប្រាស់បច្ចេកទេសនេសាទឱ្យបានត្រឹមត្រូវតាមគោលការណ៍បរិស្ថាន (*ចំនួនអ្នកនេសាទបានទទួលការផ្សព្វផ្សាយកម្មវិធីបង្កើនការយល់ដឹង និងការបណ្តុះបណ្តាល*) ។

៤.២ រៀបចំគ្រប់គ្រងទីជម្រាល

៤.៣ ធានាឱ្យមានកិច្ចការពារព្រៃកោងកាង និងតំបន់ឆ្នេរទូទៅ (*ភាគរយនៃតំបន់ឆ្នេរបញ្ចូលទៅក្នុងតំបន់ការពារធម្មជាតិ ចំនួនករណីផាកពិន័យ*) ។

៤.៤ សិក្សាតាមដានស្ថានភាពនៃប្រភេទ និងជំរកសត្វសមុទ្រ និងផលប៉ះពាល់ជាអវិជ្ជមាន (*ការបង្កើតមូលដ្ឋានទិន្នន័យ ចំនួនទិន្នន័យដែលបញ្ចូលក្នុងមូលដ្ឋានទិន្នន័យ*) ។

៤.៥ កែលំអសមត្ថភាពបច្ចេកទេសនៃមន្ត្រីនាយកដ្ឋានជលផល (*ចំនួនមន្ត្រីដែលបានបណ្តុះបណ្តាល*) ។

**ជំរើសធានា**

- កសាងក្របខ័ណ្ឌគោលនយោបាយ និងច្បាប់ ដើម្បីសំរួលការចូលរួមរបស់សហគមន៍ក្នុងការធ្វើផែនការ និងគ្រប់គ្រងធនធានតំបន់ឆ្នេរ ។
- ធ្វើអត្តសញ្ញាណកន្លែងពងកូននៃប្រភេទសំខាន់ៗ ដែលមានតំលៃសេដ្ឋកិច្ច ។
- ដាំព្រៃកោងកាងឡើងវិញ ។
- កំណត់ទីជម្រករបស់សប្បិសត្វ ផ្កាថ្ម និងស្មៅសមុទ្រ
- រៀបចំ និងអនុវត្តផែនការគ្រប់គ្រង (រួមទាំងផែនការប្រើប្រាស់ដី) សំរាប់តំបន់ព្រៃកោងកាង ។

- បណ្តុះបណ្តាលមន្ត្រីរាជការអំពីការស្រាវជ្រាវ គ្រប់គ្រង ត្រួតពិនិត្យ និងពង្រឹងការអនុវត្តន៏ច្បាប់ ព្រមទាំងវិធីសាស្ត្រសិក្សាអង្កេតសេដ្ឋកិច្ចសង្គម ។
- ផ្តល់ទូកល្បាត និងឧបករណ៍ចាំបាច់ សំរាប់ការិយាល័យជលផលខេត្តក្រុង និងនាយកដ្ឋានជលផល ។
- រក្សាតុល្យភាព រវាងការនេសាទតាមបែបប្រពៃណី និងការនេសាទឧស្សាហកម្ម ដោយពិនិត្យមើលតុល្យភាព រវាងតំបន់នេសាទ និងសមត្ថភាពនេសាទ ។
- កាត់បន្ថយសំពាធលើធនធានមច្ឆាជាតិប្រភេទតូចៗដែលរស់នៅផ្ទៃទឹកស្រទាប់លើ (Pelagic) និងលើកទឹកចិត្តអ្នកនេសាទតាមបែបប្រពៃណី ឱ្យទៅនេសាទនៅតំបន់ទឹកជ្រៅ ។
- កសាងហេដ្ឋារចនាសម្ព័ន្ធសំរាប់ចាត់ចែង និងរក្សាផលនេសាទ ។
- រឹតបន្តឹងវិធានការត្រួតពិនិត្យ និងពង្រឹងការអនុវត្តន៍ច្បាប់ប្រឆាំង នឹងអំពើល្មើស ។
- ជំរុញការប្រើប្រាស់ឧបករណ៍ដែលមានសមត្ថភាពនេសាទជ្រើសយកតែប្រភេទគោលដៅ ដើម្បីកាត់បន្ថយការចាប់ត្រីដែលមិនត្រូវការ ។
- គាំទ្រ និងជំរុញការស្រាវជ្រាវជលផល និងការសិក្សាអង្កេតផ្នែកអេកូឡូស៊ី និងជីវសាស្ត្រ សំដៅបង្កើនចំណេះដឹងអំពីប្រភេទគោលដៅដែលត្រូវនេសាទ ជីវម៉ាស និងសមត្ថភាពផលិតរបស់វា ។
- បន្តអនុវត្ត និងត្រួតពិនិត្យវិធានការកំណត់តំបន់ហាមឃាត់ និងរដូវបិទនេសាទ សំរាប់ប្រភេទងាយប្រឈមគ្រោះថ្នាក់ ដូចជា ខ្យងប៉ោហ៊ឺ (abalone) គ្រុំយក្ស (Tridacna squamosa)ខ្យងដោះក្រមុំ (cellana radiata) បង្គា និងបង្កងសមុទ្រ ។
- យកចិត្តទុកដាក់អំពីបញ្ហាបរិស្ថាន និងតម្រូវការក្នុងការរៀបចំប្លង់ និងការសាងសង់ផែនេសាទថ្មី ។
- ចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រជាជាតិស្តីពីការធ្វើចរាចរសន្និធិប្រភេទត្រីក្នុងសមុទ្រអន្តរជាតិ (Straddling stock) និងប្រភេទធ្វើចរាចររយៈឆ្ងាយ សេចក្តីសំរេចសហប្រជាជាតិស្តីពីអូនហ៊ាំ បទបញ្ជាអនុវត្តរបស់អង្គការស្បៀង និងកសិកម្មសហប្រជាជាតិស្តីពីការទទួលខុសត្រូវលើការធ្វើនេសាទ ។
- បណ្តុះបណ្តាលមន្ត្រីល្បាត ដើម្បីពង្រឹងការអនុវត្តច្បាប់ និងបង្កើនការយល់ដឹងសាធារណៈអំពីការអភិរក្ស និងបំពាក់មធ្យោបាយសុវត្ថិភាព។
- បង្កើត និងគ្រប់គ្រងតំបន់អភិរក្សជំរកត្រី ។
- ជំរុញការគ្រប់គ្រងសហគមន៍នេសាទ ។
- កំណត់លក្ខណៈវិនិច្ឆ័យជាក់លាក់ ដូចជាព្រំប្រទល់ និងជំរៅទឹកសំរាប់ការនេសាទគ្រួសារ និងការនេសាទឧស្សាហកម្មក្នុងតំបន់សមុទ្រ ។

សកម្មភាពជាអាទិភាព (ស្ថាប័នសំរបសំរួល និងចូលរួមអនុវត្ត)

៤.១ កសាងផែនការលំអិតអំពីការតាមដានឃ្លាំមើល និងត្រួតពិនិត្យ (Monitoring survellance and control: MSC) ការធ្វើនេសាទជាលក្ខណៈឧស្សាហកម្ម និងបង្កើតគ្រោងការសាកល្បងសំរាប់ការតាមដានឃ្លាំមើល និងការត្រួតពិនិត្យការនេសាទសិប្បកម្ម ( ក្រ.កសក និង បស្ថ) (រួមទាំង កម្មវិធីបង្កើនការយល់ដឹង និងបណ្តុះបណ្តាលអ្នកនេសាទសិប្បកម្ម) ។

៤.២ កម្មវិធីសិក្សាតាមដាន និងគ្រប់គ្រងប្រភេទត្រីសំខាន់ៗ ( ក្រ.កសក) ។

៤.៣ កិច្ចការពារព្រៃកោងកាង (រួមបញ្ចូលផែនការប្រើប្រាស់ដី ការចូលរួមរបស់សហគមន៍មូលដ្ឋាន) ( ក្រ.បស្ថ កសក និង រដនស) ។

៤.៤ កម្មវិធីកសាងសមត្ថភាព និងបណ្តុះបណ្តាលមន្ត្រីជលផល ( ក្រ.កសក) ។

៤.៥ ការផ្តល់នាវាល្បាតដល់នាយកដ្ឋានជលផល ( ក្រ.កសក) ។

## ប្រធានបទទី ៥ : ធនធានព្រៃឈើ និងរុក្ខជាតិព្រៃ

### បរិបទ

ប្រទេសកម្ពុជាមានព្រៃឈើចំរុះប្រភេទជាច្រើនបែប ដែលរួមមានព្រៃកោងកាង ព្រៃលិចទឹក ព្រៃឬស្សី ព្រៃស្លឹកម្ជុល ព្រៃរបោះស្ងួត ព្រៃរបោះសើម ព្រៃស្រោងសើមបៃតងជានិច្ច ព្រៃស្រោងពាក់កណ្តាលជំរុះស្លឹក ព្រៃភ្នំសើម និងព្រៃតឿ ។ល។ ប្រព័ន្ធអេកូឡូស៊ីនៃព្រៃទាំងនេះប្រែប្រួលទៅតាមរយៈកំពស់ លក្ខខណ្ឌអាកាសធាតុ លក្ខខណ្ឌដី សំណើមដី និងជាធនធានដ៏មានតម្លៃបំផុត ។ ជាមួយគ្នានេះដែរ ប្រទេសកម្ពុជាមានធនធានអនុផលព្រៃឈើមានតំលៃជាច្រើនទៀត ដូចជា ផ្តៅ ឫស្សី តាលព្រឹក្ស រុក្ខជាតិផ្តល់ផ្លែ រុក្ខជាតិផ្តល់មើម រុក្ខជាតិផ្តល់ជ័រមានតំលៃ រុក្ខជាតិក្រអូប និងរុក្ខជាតិឱសថ ។ ប៉ុន្តែ គេឃើញមានការខ្វះចន្លោះនូវពត៌មានស្តីពីរបាយ ដំណុះនៃរុក្ខជាតិព្រៃ និងសន្តានរុក្ខជាតិព្រៃនៃដំណាំ ។ ការខ្វះខាតទាំងនេះកើតឡើងដោយសារអវត្តមាននៃការសិក្សាវិទ្យាសាស្ត្រជាយថាក្រម និងការអធិប្បាយអំពីចំណាត់ថ្នាក់ប្រភេទ (taxonomy) និងការកំនត់ពូជនៃរុក្ខជាតិទាំងនោះ ។

អត្រាដកហូតផលិតផលព្រៃឈើបច្ចុប្បន្ន ដោយរួមទាំងការដកហូតឈើសំរាប់ឧស ធ្យូងផង មានប្រមាណប្រាំពីរដងលើសកំរិតនិរន្តរភាព ហើយអាចបំផ្លាញឈើឈរពាណិជ្ជកម្មដែលនៅសល់ ក្នុងរង្វង់ ១០ ឆ្នាំខាងមុខ ។ ប៉ុន្តែមានឱកាសជាច្រើនដែលអាចបង្វែរនិន្នាការអវិជ្ជមានបច្ចុប្បន្ន តាមរយៈការពិនិត្យតាមដានសកម្មភាពអាជីវកម្មព្រៃសម្បទានឱ្យបានប្រសើរជាងមុន ការបង្កើនសមត្ថភាពសំរាប់ពង្រឹងការអនុវត្តន៍ច្បាប់ ព្រមទាំងការបង្កើតព្រៃដាំ ដោយប្រើប្រាស់ ទាំងប្រភេទឈើដែលលូតលាស់រហ័ស និងប្រភេទឈើក្នុងស្រុកដែលមានតំលៃពាណិជ្ជកម្មខ្ពស់ ។ ទង្វើបែបនេះមិនត្រឹមតែជួយ បង្កើនធនធានព្រៃឈើប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់នូវមុខរបរ និងការបង្កើនចំណូលសំរាប់ប្រជាជននៅជនបទផងដែរ ។ ការងារទាំងនេះអាចសំរេចបាន លុះត្រាតែមានការចូលរួមខ្លាំងក្លាពីសហគមន៍មូលដ្ឋាន និងផ្នែកឯកជន នៅក្នុងកិច្ចការពារ គ្រប់គ្រង និងកែលំអវិស័យព្រៃឈើ ។

ក្របខ័ណ្ឌគោលនយោបាយព្រៃឈើទទួលស្គាល់ថា ផលប្រយោជន៍យូរអង្វែងអំពីធនធានព្រៃឈើក្នុងប្រទេសកម្ពុជាអាចបង្កើនជាអតិបរិមាបាន អាស្រ័យដោយការគ្រប់គ្រង និងការអភិរក្សឱ្យបានសមស្រប ព្រោះថាវាអាចផ្តល់ប្រយោជន៍ ជាបន្ថែមក្នុងផ្នែកធារាសាស្ត្រ និងបរិស្ថាន (ឧទាហរណ៍ : ការកាត់បន្ថយភាពកើតមានញឹកញាប់ និងភាពធ្ងន់ធ្ងរនៃជំនន់ សំណឹកដី កំណកល្បាប់តាមផ្លូវទឹក ការបាត់បង់ធនធានជលផលទឹកសាបជាដើម) និងធានានិរន្តរភាពប្រាក់ចំណូលសំរាប់រយៈពេលវែងចំពោះរដ្ឋាភិបាលផងដែរ ។ ការគ្រប់គ្រងព្រៃឈើសមស្របនឹងផ្តល់ផលប្រយោជន៍ផងដែរ ដល់ប្រជាជនដែលរស់នៅក្នុងឬក្បែរតំបន់ព្រៃឈើដែលពឹងពាក់អាស្រ័យទៅលើព្រៃឈើសំរាប់ជាអាហារ ឈើសំរាប់ធ្វើឧស និងអនុផលព្រៃឈើដទៃទៀត ដូចជា ជ័រ ផ្តៅ ឫស្សី វល្លិ ។ល។

### បញ្ហាចំបងៗ

- ការធ្វើអាជីវកម្មព្រៃឈើហ៊ុប ឧស និងធ្យូង ហួសកំរិត ។
- ការផ្តល់ព្រៃសម្បទានសំរាប់ធ្វើអាជីវកម្ម ។
- ការអនុវត្តន៍ច្បាប់ និងបទបញ្ញត្តិនានា ។

- ការគ្រប់គ្រងអាជីវកម្មព្រៃឈើពុំបានល្អ ។
- ការរានព្រៃដើម្បីពង្រីកផ្ទៃដីកសិកម្ម និងធ្វើពាណិជ្ជកម្មដី ។
- ការកសាងហេដ្ឋារចនាសម្ព័ន្ធ ( កសាងផ្លូវ ) ។
- ប្រពៃណីកាប់រានព្រៃធ្វើកសិកម្មពនេចរ ។
- ភាពរេចរឹលនៃទីជំរាល ។
- ការកំណត់ព្រំប្រទល់តំបន់ព្រៃឈើ ។
- ចំណេះដឹងទាប អំពីស្ថានភាព និងការវិវឌ្ឍន៍នៃព្រៃឈើ ។

គោលដៅ

- ធានាឱ្យមានកិច្ចការពារ ប្រើប្រាស់ និងគ្រប់គ្រងប្រកបដោយនិរន្តរភាពនូវរុក្ខជាតិព្រៃ ប្រភេទឈើ និងព្រៃឈើ ។
- លើកកំពស់ប្រសិទ្ធិភាព និងនិរន្តរភាពការធ្វើអាជីវកម្ម ការកែច្នៃ និងការប្រើប្រាស់ផលិតផលព្រៃឈើ ។

គោលបំណងជាយុទ្ធសាស្ត្រ (*សន្ទស្សន៍បង្ហាញ*)

៥.១ ជំរុញការដាំព្រៃឈើឡើងវិញ និងការស្តារតំបន់ព្រៃរេចរឹល ( *វិសាលភាពផ្ទៃដីដាំព្រៃឡើងវិញ* ) ។

៥.២ ពង្រឹងការអនុវត្តន៍ច្បាប់ ដើម្បីទប់ស្កាត់សកម្មភាពកាប់ឈើល្មើសច្បាប់គ្រប់រូបភាព ( *ចំនួនករណីផាកពិន័យ* ) ។

៥.៣ តាមដាន និងវាយតំលៃការផ្តល់ និងការគ្រប់គ្រងព្រៃសម្បទាន ( *ចំនួនព្រៃសម្បទានដែលបានតាមដាន* ) ។

៥.៤ ការចូលរួមរបស់សហគមន៍មូលដ្ឋានក្នុងកិច្ចការពារ គ្រប់គ្រង និងកែលំអព្រៃឈើ ( *ចំនួនគំរោងគ្រប់គ្រង និងស្តារព្រៃឈើដែលផ្អែកលើសហគមន៍ត្រូវបានបង្កើតឡើង និងអនុវត្ត* ) ។

៥.៥ លើកកំពស់ការអនុវត្តន៍វិធីសាស្ត្រធ្វើអាជីវកម្មព្រៃដែលសមស្របនឹងគោលការណ៍បរិស្ថាន ( *ចំនួនព្រៃសម្បទានដែលបានផ្សព្វផ្សាយកម្មវិធីបង្កើនការយល់ដឹង និងបណ្តុះបណ្តាល* ) ។

៥.៦ តាមដានស្ថានភាព និងការវិវត្តន៍នៃធនធានព្រៃឈើ ( *បរិមាណទិន្នន័យប្រមូលបាន* ) ។

៥.៧ កំណត់ជាតំបន់ព្រៃឈើ សំរាប់ការពារ អភិរក្ស ការប្រើប្រាស់ក្នុងសហគមន៍ និងតាមបែបឧស្សាហកម្ម ( *ទំហំផ្ទៃដី ដែលបានកំនត់ជាតំបន់ព្រៃការពារ* ) ។

៥.៨ បែងចែកតំបន់ព្រៃឈើផ្អែកតាមស្ថានភាពបច្ចុប្បន្ន តាមរយៈការធ្វើសារពើភ័ណ្ឌ និងវាយតំលៃអត្រាខូចខាត ( *បរិមាណទិន្នន័យប្រមូលបាន និងវិធានការសមស្របដែលបានអនុវត្ត* ) ។

- លើកកំពស់តម្លាភាពក្នុងផ្នែកហិរញ្ញវត្ថុពាក់ព័ន្ធនឹងការធ្វើអាជីវកម្មធនធានធម្មជាតិ ។

- កសាងផែនការធ្វើអាជីវកម្ម និងគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ដោយផ្អែកតាមបទបញ្ជា និងគោលការណ៍ណែនាំ ដែលធានាដល់ការការពារ និងការប្រើប្រាស់ធនធានជីវៈចំរុះដោយនិរន្តរភាព និងដែលស្របជាមួយគោលនយោបាយ ស្ថាប័នពាក់ព័ន្ធ ។
- ពង្រឹងការអនុវត្តន៍ច្បាប់ដើម្បីការគ្រប់គ្រងព្រៃឈើ ។
- ស្រាវជ្រាវប្រភេទរុក្ខជាតិក្នុងតំបន់ដែលមានជីវៈចំរុះសំខាន់ៗ ក្នុងប្រទេសកម្ពុជា ។
- បង្កើនចំណេះដឹងផ្អែកភូតតាមសាស្ត្រ (កែតំរូវជាថ្មីនូវសារពើភ័ណ្ឌរុក្ខជាតិព្រៃ និងប្រព័ន្ធអេកូឡូស៊ី) ។
- ធានាថាប្រភេទឈើក្នុងស្រុកដែលមានដុះដោយធម្មជាតិក្នុងប្រព័ន្ធអេកូឡូស៊ីដូចគ្នា ត្រូវបានប្រើប្រាស់នៅក្នុងរាល់គំរោង ដាំព្រៃឈើឡើងវិញ) ។
- វាយតំលៃលើឥទ្ធិពលសេវាកម្មបរិស្ថាននៃព្រៃដាំថ្មី នៅទីកន្លែងផ្សេងៗគ្នា ពាក់ព័ន្ធនឹងការទ្រទ្រង់ប្រភពទឹកក្រោមដី ការពារទឹកជំនន់ ការពារទីជំរាល ការពារច្រាំងទន្លេ និងវត្ថមានជីវៈចំរុះ ។
- ជំរុញការអនុវត្តន៍ផែនការយុទ្ធសាស្ត្រជាតិសំរាប់ការស្តារព្រៃឡើងវិញ ។
- បង្កើតគំរោងសាកល្បងសំរាប់ស្តារព្រៃក្នុងប្រព័ន្ធអេកូឡូស៊ីប្លែកៗគ្នា ដោយផ្អែកលើសហគមន៍ ។
- ប្រភពផលិតកម្មពូជឈើសមស្រប ដើម្បីរួមចំណែកក្នុងការអភិរក្សនៅនឹងកន្លែង ។

សកម្មភាពជាអាទិភាព (ស្ថាប័នសំរបសំរួល និងចូលរួមអនុវត្ត)

៥.១ ការកសាងផែនការជាតិដ៏ពេលលេញគ្រប់ជ្រុងជ្រោយមួយ សំរាប់គ្រប់គ្រងធនធានព្រៃឈើ (ក្រ.កសក) ក្នុងនោះមាន ការពិនិត្យឡើងវិញ និងការកែលំអច្បាប់ព្រៃឈើបច្ចុប្បន្ន ដោយផ្តោតទៅលើគ្រប់ទិដ្ឋភាពនៃកិច្ចការពារធនធានព្រៃឈើ សំដៅឈានទៅប្រើប្រាស់អាជ្ញាប័ណ្ណអាជីវកម្មព្រៃឈើស្របតាមបទដ្ឋានអន្តរជាតិ កិច្ចការពារសិទ្ធិនៃជនជាតិភាគតិច ក្នុងការកាន់កាប់ និងប្រើប្រាស់ធនធានធម្មជាតិ ការបង្កើតសហគមន៍ព្រៃឈើ ការកំនត់ដំណើរការចូលរួម ការអភិវឌ្ឍន៍ ការដាំដុះតាមបែបរុក្ខវប្បកម្ម ។ល។

៥.២ ការកសាងផែនការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព (ក្រ.កសក) ។

៥.៣ ការកសាងគោលការណ៍ណែនាំអំពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន សំរាប់សកម្មភាពអាជីវកម្មព្រៃឈើ (ក្រ.កសក និង បស្ថ) ។

៥.៤ ការគ្រប់គ្រងព្រៃសម្បទាន និងគំរោងសាកល្បងត្រួតពិនិត្យ (ក្រ.កសក) ។

៥.៥ កម្មវិធីគ្រប់គ្រងព្រៃឈើដោយផ្អែកលើសហគមន៍ (ក្រ.កសក និង បស្ថ) (រួមទាំង ការរៀបចំគោលការណ៍ណែនាំ សំរាប់គំរោង សហគមន៍ព្រៃឈើ )

៥.៦ ការសិក្សាស្រាវជ្រាវសារពើរុក្ខជាតិ និងការវាយតំលៃលើស្ថានភាពបច្ចុប្បន្ននៃការដកហូតផលព្រៃឈើ (ក្រ.កសក)

៥.៧ បន្តគំរោងតាមដានបទល្មើសព្រៃឈើ (ក្រ.កសក និង បស្ថ ដោយសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល Global Witness) ។

៥.៨ កសាងគោលនយោបាយ និងគោលការណ៍ណែនាំសំរាប់ជំរុញឱ្យមានការប្រើប្រាស់ប្រភេទក្នុងស្រុកក្នុងការដាំដុះ និងដាក់កំរិតលើការប្រើប្រាស់ប្រភេទនាំចូលពីក្រៅប្រទេស ( ក្រ.កសក) ។

# ប្រធានបទទី ៦ : កសិកម្ម និងផលិតកម្មសត្វ

## បរិបទ

### ការងារដាំដុះ

ជាប្រពៃណី កសិកម្មគឺជាវិស័យដ៏ចំបងមួយនៅក្នុងសេដ្ឋកិច្ចនៃតំបន់អាស៊ីភាគអាគ្នេយ៍ រហូតដល់ពេលថ្មីៗនេះ ។ ប្រហែល ៩០% នៃប្រជាជនកម្ពុជានៅតែចិញ្ចឹមជីវិតដោយពឹងផ្អែកលើកសិកម្ម ។ សេដ្ឋកិច្ចជាតិកម្ពុជាក៏ពឹងផ្អែកជាចំបងលើវិស័យកសិកម្ម ដែលភាគច្រើនអាស្រ័យនឹងរបបទឹកភ្លៀង ឯកវប្បកម្មមុខដំណាំ និងផ្អែកលើដំណាំស្រូវជាមូលដ្ឋាន ។ ប្រព័ន្ធអេកូឡូស៊ីកសិកម្មនៅក្នុងប្រទេសកម្ពុជាអាចចែកចេញជា : ប្រព័ន្ធដំណាំស្រូវ កសិកម្មពនេចរ ចំការដំណាំ ច្បារដំណាំតាមលំនៅដ្ឋាន និងប្រព័ន្ធដំណាំដែលមានអាយុកាលវែង ។ នៅក្នុងប្រព័ន្ធអេកូឡូស៊ីកសិកម្មទាំងនេះ ធនធានផ្សេងទៀត ក៏អាច និងកំពុងត្រូវបានអភិវឌ្ឍន៍ផងដែរ ។ ឧទាហរណ៍ : ការចិញ្ចឹមត្រីនៅក្នុងស្រែ ដែលបង្ហាញជាទិន្នផលត្រី និងផលិតផលស្រូវនៅក្នុងប្រព័ន្ធអេកូឡូស៊ីកសិកម្មមួយចំនួន ។

កសិករច្រើនជាអ្នកក្រីក្រ និងរស់នៅក្រោមការកៀបសង្កត់នៃកត្តាក្សេត្រ-អេកូឡូស៊ី និងកត្តាសេដ្ឋកិច្ច-សង្គម ។ ស្រូវជាដំណាំសំខាន់ជួរមុខបំផុត បន្ទាប់មកគឺដំណាំពោត ។ សណ្តែកសៀង គឺជាដំណាំសំខាន់ផងដែរ បន្ទាប់មកគឺដំណាំសណ្តែក បាយ ។ សណ្តែកដី និងល្ង ត្រូវបានរាប់បញ្ចូលក្នុងចំណោមពពួកដំណាំយកប្រេង ។ នៅក្នុងចំណោមដំណាំឧស្សាហកម្ម គេច្រើននិយមដាំដើមត្នោត អំពៅ ក្រចៅ និងថ្នាំជក់ ។ ដំណាំបន្លែត្រូវបានគេដាំដុះនៅលើផ្ទៃដីធំធេង ហើយដំឡូងជ្វាគឺជាដំណាំដែលត្រូវបានគេនិយមដាំ ចំណែកឯដំណាំដំឡូងឈើក៏មានដាំដែរ ។

នៅកម្ពុជា ការដាំដុះដំណាំច្រើនពឹងផ្អែកទៅលើពូជប្រពៃណី ពូជចាស់ៗដែលមានពីមុនមក និងពូជនៅតាមមូលដ្ឋានទីមួយៗ ។ នៅចុងទសវត្សឆ្នាំទី ៩០ ផ្ទៃដីដាំដុះប្រហែល ៨០% ត្រូវបានប្រើប្រាស់សំរាប់ដាំពូជក្នុងស្រុក ដែលគ្មានការកែលំអ រួមមាន ស្រូវ ពោត ល្ង បន្លែ និងដំឡូងជ្វា ។ ជាទូទៅ កសិករនិយមប្រើប្រាស់ជាបន្តបន្ទាប់នូវកសិផលរបស់គាត់ផ្ទាល់ ជាពូជដំណាំដោយគ្មានការផ្លាស់ប្តូរអ្វីឡើយ ។ កត្តាចង្រៃ និងភ្នាក់ងារបង្ករោគថ្មីៗ បានរួមចំណែកធ្វើឱ្យបាត់បង់ពូជដំណាំមូលដ្ឋាន ។ ការបង្កើតធនាគារសែន អាគារសំរាប់ទុកដាក់ ថែរក្សាពូជដំណាំ និងមន្ទីរពិសោធន៍ធនធានសេនេទិចរុក្ខជាតិនៅថ្នាក់ជាតិ គឺជាតំរូវការ ដែលចាំបាច់សំរាប់ធ្វើឱ្យមាននិរន្តរភាពនៃផលិតផលស្បៀង ។

កសិកម្មទំនើបច្រើនតែកាត់បន្ថយភាពសំបូរបែបនៃពូជដំណាំ និងភាពសំបូរបែបនៃប្រភេទ ដែលធ្លាប់បានប្រើប្រាស់ក្នុងប្រព័ន្ធអេកូឡូស៊ីកសិកម្ម ។ គេបានផ្តោតការយកចិត្តទុកដាក់ចំពោះពូជមួយចំនួនតូចប៉ុណ្ណោះនៃមុខដំណាំ ដែលជាប្រការអាចធ្វើឱ្យអន្តរាយចំពោះសន្តិសុខស្បៀងក្នុងប្រទេសកម្ពុជា ។ សន្តិសុខស្បៀងពិតប្រាកដ ត្រូវពឹងផ្អែកទៅលើភាពសំបូរបែបនៃពូជដំណាំក្នុងប្រភេទ និងរវាងប្រភេទ ។ កាលណាដំណាំបាត់បង់ភាពសំបូរបែប វាងាយនឹងប្រឈមគ្រោះថ្នាក់ណាស់ ។ លើសពីនេះទៅទៀត ដំណាំមួយមុខច្រើនតែអាចផ្តល់ទិន្នផលខ្ពស់បំផុត តាមរយៈការធ្វើឯកវប្បកម្ម ។ ក្នុងករណីនេះ វាអាចផ្តល់ផលិតផលតែមួយមុខបានយ៉ាងច្រើន តែវាពុំអាចផ្តល់អ្វីផ្សេងទៀតសំរាប់កសិករប្រើប្រាស់ឡើយ ។ ភាពសំបូរបែបនៃពូជ និងប្រភេទដំណាំទាំងអស់ ដែលបានប្រើប្រាស់ក្នុងប្រព័ន្ធអេកូឡូស៊ីកសិកម្ម មានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងកំណើនសន្តិសុខស្បៀង និងផលតាំងទ

តួនាទីនៃប្រព័ន្ធអេកូឡូស៊ីកសិកម្ម រួមមាន បន្សាំនឹងលក្ខខណ្ឌធម្មជាតិ ជំនើរលំអងផ្កា កំណកំណើតដី ជីជាតិដី និងការត្រួតពិនិត្យកត្តាចង្រៃ ។

កំនើន និងការប្រើប្រាស់ថ្នាំកសិកម្មនិងជីគីមីមិនសមស្រប អាចបង្កហេតុប៉ះពាល់ធ្ងន់ធ្ងរដល់ប្រព័ន្ធអេកូឡូស៊ីកសិកម្ម និងប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ។ អនុលោមទៅតាមអនុសញ្ញាអន្តរជាតិស្ដីពីកិច្ចការពារដំណាំ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតកម្មវិធីគ្រប់គ្រងដំណាំចំរុះថ្នាក់ជាតិ ។ នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៨ រាជរដ្ឋាភិបាលបានអនុម័តអនុក្រឹត្យលេខ ៦៩ អនក្រ.បក ស្ដីពីស្តង់ដា និងការគ្រប់គ្រងសំភារៈកសិកម្ម ដែលហាមឃាត់ការនាំចូលថ្នាំកសិកម្មណា ដែលមិនទាន់បានទទួលការអនុញ្ញាត និងតំរូវឱ្យបិទផ្លាកសញ្ញាណែនាំអំពីការប្រើប្រាស់ជាភាសាខ្មែរ ប៉ុន្តែការដាក់ឱ្យអនុវត្តអនុក្រឹត្យនេះជួបការលំបាកជាខ្លាំង ។

**ផលិតកម្មសត្វ**

ជាយូរមកហើយ សត្វត្រូវបានផ្សាំងនៅក្នុងស្រុក ឬនាំចូលពីប្រទេសដទៃ ។ សត្វទាំងនេះបានបន្សាំនឹងលក្ខខណ្ឌអេកូឡូស៊ី និងបានបាត់បង់លក្ខណៈដើមរបស់វា ។ លទ្ធភាពនៃការបង្កើតសេនេទិចថ្មីៗ ក្នុងទំរង់ជាសត្វរស់ អំប្រ៊ីយ៉ុង និងមេជីវិតបានធ្វើឱ្យមានការបង្កាត់រវាងពូជនានាជាទូទៅនៅពាសពេញតំបន់អាស៊ី ដែលអាចបន្ថយនូវលក្ខណៈពិសេសដោយឡែកនៃធនធានសេនេទិចរបស់សត្វ និងនិរន្តរភាពរបស់វា ។ ប្រទេសកម្ពុជាពុំបានជួបប្រទះនូវការប្រែប្រួលក្នុងចំណោមពូជសត្វក្នុងស្រុក ដូចដែលបណ្ដាប្រទេសនានានៅអាស៊ីអាគ្នេយ៍នេះឡើយ ប៉ុន្តែក្នុងពេលបច្ចុប្បន្ននេះ ប្រទេសនេះកំពុងតែឆ្លងកាត់នូវការផ្លាស់ប្ដូរយ៉ាងឆាប់រហ័សបំផុត ។

មានពូជគោស្រុកជាច្រើនដែលជួបប្រទះក្នុងប្រទេសកម្ពុជា ។ ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបនៃពូជគោដែលមានលក្ខណៈខុសៗគ្នា ។ ពូជគោដែលបានមកពីការផ្សាំងពីព្រៃនៃប្រភេទមានបូក និងគ្មានបូក និងប្រភេទពូជគោព្រៃ ដែលត្រូវបានគេស្គាល់ថាជាគោ Burmese Gaur ។ ក្របីត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយពាសពេញប្រទេសកម្ពុជា ។ នៅកម្ពុជា មានពូជជ្រូកមួយចំនួន រួមមាន ពូជជ្រូកកណ្ដុរ និងពូជជ្រូកមានប្រភពពីប្រទេសចិន និងអឺរ៉ុប ។ កម្ពុជាមានពូជសេះតឿម៉្យាងប្លែកពីគេ (South-East Asia Pony) ។ ដីរស្រុកនៅត្រូវបានគេប្រើប្រាស់តាមជនបទដាច់ស្រយាលនៅក្នុងប្រទេសកម្ពុជា ។

សត្វស្លាបភាគច្រើនលើពិភពលោកត្រូវបានគេជឿជាក់ថា មានប្រភពក្លាយមកពីប្រភេទសត្វព្រៃពីអាស៊ីភាគអាគ្នេយ៍ ។ លក្ខណៈសំគាល់មួយចំនួននៃពូជសត្វស្លាបក្នុងស្រុកពីប្រទេសកម្ពុជា មានបង្ហាញជូនខាងក្រោម ។ គេជឿថាមានពូជថ្មីៗផ្សេងទៀត កំពុងត្រូវបាននាំចូលមកក្នុងប្រទេសកម្ពុជា ប៉ុន្តែគេពុំមានឯកសារគ្រប់គ្រាន់បញ្ជាក់អំពីពូជទាំងនោះឡើយ ។ មានពូជមាន់មួយចំនួនដែលត្រូវបានចាត់ទុកថាជាពូជក្នុងស្រុក និងដែលបន្សាំយ៉ាងល្អនឹងលក្ខខណ្ឌបរិស្ថានស្រុក ។ មានប្រភេទពូជក្ងាន និងប្រភេទទាស្រុកមួយចំនួនដែលគេចាត់ទុកថាជាពូជក្នុងស្រុក ។ ទាស្រុកប្រភេទ Muscovy មាននាំចូលមកចិញ្ចឹមនៅកម្ពុជា ចំណែកមាន់បារាំងត្រូវបានចាត់ទុកថាជាពូជកំពុងប្រឈមគ្រោះថ្នាក់ ។

ការកើនឡើងគំហែងធ្ងន់ធ្ងរជាងគេលើពិភពលោក ដល់ភាពសំបូរបែបនៃពូជសត្វស្រុក បណ្ដាលពីផលិតកម្មឧស្សាហកម្មសត្វដោយសារការប្រើប្រាស់បច្ចេកទេសដែលមានលក្ខណៈឯកទេសខ្ពស់ ។ នៅក្នុងបណ្ដាប្រទេសឧស្សាហកម្មជឿនលឿន ការចិញ្ចឹមសត្វជា[illegible]ផ្អែកលើការប្រើប្រាស់ពូជសត្វមួយចំនួនតូចប៉ុណ្ណោះ ដែលបានពីការជ្រើសរើស សំរាប់ប្រពលវប្បកម្មយកសាច់ ទឹកដោះ

ឬស៊ុត និងនៅក្នុងលក្ខខណ្ឌ ដែលមានការត្រួតពិនិត្យយ៉ាងហ្មត់ចត់ ។ ការរីកលូតលាស់នៃឧស្សាហកម្មកសិកម្មនៅក្នុងតំបន់ភូមិភាគខាងត្បូង បានធ្វើឱ្យពូជសត្វក្នុងស្រុកត្រូវប្រឈមនឹងការរលាយបាត់លក្ខណៈដើមនៃសេនេទិច ឬជំនួសដោយប្រភេទសត្វនាំចូលពីបរទេស ។ ជាទូទៅ ពូជសត្វដែលនាំចូលមកអាមេរិចខាងជើង និងអឺរ៉ុបខាងលិច ពុំអាចធានាបាននូវផលិតផលខ្ពស់ក្នុងលក្ខខណ្ឌដែលមិនសូវអនុគ្រោះនៃភូមិភាគខាងត្បូងឡើយ ។ ការចិញ្ចឹមពូជទាំងនោះ ទាមទារនូវការគ្រប់គ្រង ដោយហ្មត់ចត់ និងចំណាយថ្លៃដើមខ្ពស់សំរាប់ចំណីដែលមានប្រូតេអ៊ីនខ្ពស់ ការប្រើប្រាស់ថ្នាំ ការសាងសង់ទ្រុងដែលត្រួតត្រាលក្ខខណ្ឌអាកាសធាតុបាន ។ ការនាំចូលនូវផលិតកម្មសត្វតាមបែបប្រពលវប្បកម្មនៅតំបន់ជាច្រើនក្នុងភូមិភាគខាងត្បូង ធ្វើឱ្យតំបន់ទាំងនោះត្រូវពឹងផ្អែកលើបច្ចេកវិទ្យា និងអង្គជីវកំន (Germplasm) ហើយដែលកសិករក្រីក្រមិនមានលទ្ធភាពជាវ ឬប្រើប្រាស់បច្ចេកទេសទាំងនេះដោយនិរន្តរភាពឡើយ ។ ផលិតកម្មបសុសត្វនៅកម្ពុជាមិនទាន់មានការរីកចំរើននៅឡើយទេ ប៉ុន្តែថ្មីៗនេះ មានការប្រែប្រួលពីការចិញ្ចឹមបែបគ្រួសារ ទៅជាការចិញ្ចឹមតាមបែបពាណិជ្ជកម្ម ។ គេចាំបាច់ត្រូវអភិវឌ្ឍន៍បច្ចេកទេសចិញ្ចឹមសត្វ វិធានការអនាម័យ សេវាកម្មបសុព្យាបាល ការត្រួតពិនិត្យគុណភាព ដើម្បីគាំទ្រដល់ការផ្លាស់ប្តូរនេះ ។

បញ្ហាចំបង

- ការបោសសំអាតចំការមីន និងការប្រើប្រាស់ដី ( ការបាត់បង់ដីកសិកម្ម) ។
- ការដាំដុះដំណាំឧស្សាហកម្ម ។
- ការកាប់ឆ្ការ និងការដុតបំផ្លាញព្រៃយកដី ។
- ការបំពុលដី និងទឹក ដោយការប្រើប្រាស់ជីគីមី ថ្នាំកំចាត់សត្វចង្រៃ និងថ្នាំសំលាប់ស្មៅ ។
- ការអភិវឌ្ឍន៍ធនធានមនុស្ស ។
- កិច្ចសហប្រតិបត្តិការរវាងស្ថាប័ន ។
- ការបាត់បង់សេនេទិច ( ពូជមួយចំនួនតូច) ។
- ការទុកដីសំរាប់លែងសត្វឱ្យស៊ីស្មៅ ។
- ឯកវប្បកម្មដំណាំ ។
- កង្វះបច្ចេកទេសនៃការចិញ្ចឹមសត្វ និងវិធានការអនាម័យនៃផលិតកម្មបសុសត្វ ។

គោលដៅ

- សំរេចបាននូវសន្តិសុខស្បៀង និងបង្កើនឱកាសរកប្រាក់ចំណូលសំរាប់កសិករតាមរយៈកិច្ចការពារ ការប្រើប្រាស់ និងការគ្រប់គ្រងធនធានកសិកម្មដោយនិរន្តរភាព ។
- អភិរក្សប្រព័ន្ធអេកូឡូស៊ី សត្វព្រៃ និងមនុស្ស ពីការអនុវត្តការងារកសិកម្មដែលប៉ះពាល់ជាអវិជ្ជមាន និងកាត់បន្ថយការបាត់បង់នូវភាពសំបូរបែបនៃកសិកម្ម ។

គោលបំណងជាយុទ្ធសាស្ត្រ (*សន្ទស្សន៍បង្ហាញ*)

៦.១ ការពារដីកសិកម្ម ធនធានរុក្ខជាតិ និងបសុសត្វពីហេតុប៉ះពាល់អវិជ្ជមាន ភាពតានតឹងជីវសាស្ត្រ និង ការប្រើប្រាស់មិនរើសមុខ ( *ទំហំដីកសិកម្មបាត់បង់ជារៀងរាល់ឆ្នាំ ចំនួនការពារតាមរយៈវិធានការអនាម័យ* ) ។

៦.២ ធានាការផ្ទេរបច្ចេកវិទ្យា និងពត៌មានដល់កសិករ អ្នកចិញ្ចឹមសត្វ និងអ្នកចិញ្ចឹមត្រី ( *ចំនួនកសិករទទួលការផ្សព្វផ្សាយតាមរយៈកម្មវិធីបណ្តុះបណ្តាល ឬយុទ្ធនាការបង្កើនការយល់ដឹង* ) ។

៦.៣ កាត់បន្ថយការប្រើប្រាស់ជីគីមី និងថ្នាំកំចាត់សត្វចង្រៃ តាមរយៈការបណ្តុះបណ្តាលសមស្រប និងមធ្យោបាយជីវសាស្ត្រ ( *បរិមាណជីគីមី និងថ្នាំកំចាត់សត្វចង្រៃប្រើប្រាស់ដោយកសិករ* ) ។

ជំរើសនានា

- កសាងផែនការប្រើប្រាស់ដីសមស្របសំរាប់វិស័យកសិកម្ម ។
- លើកទឹកចិត្តឱ្យមានការប្រើប្រាស់ធនធានធម្មជាតិដែលមាននៅក្នុងស្រុក ។
- ស្រាវជ្រាវពីហេតុប៉ះពាល់នៃប្រភេទនាំចូលពីបរទេស ។
- រៀបចំគោលការណ៍ណែនាំអំពីការប្រើប្រាស់ធនធានធម្មជាតិ ដោយផ្អែកទៅលើបច្ចេកវិទ្យាសមស្រប ។
- ប្រមែប្រមូលអង្គជីវកំនរនៃធនធានសេនេទិចដំណាំក្នុងស្រុក និងរុក្ខជាតិព្រៃ ។
- បង្កើតធនាគារសែនថ្នាក់ជាតិ សំរាប់រក្សាទុកពូជដំណាំនានា ។
- រៀបចំអភិវឌ្ឍន៍តំបន់ដែលតំណាងកសិកម្មចំរុះសំបូរបែប ។
- ការផ្សព្វផ្សាយដោយផ្អែកទៅលើអនុសាសន៍បច្ចេកទេសសមស្រប ។
- ជំរុញការអនុវត្តន៍បច្ចេកទេសដាំដុះ ប្រើប្រាស់ និងកែច្នៃធនធានកសិកម្ម ដោយមិនបំពុលបរិស្ថាន ។
- ជំរុញ និងពង្រឹងការគោរពបទបញ្ជាពាក់ព័ន្ធនឹងការធ្វើអាជីវកម្មធនធានធម្មជាតិ ។
- កំណត់ឱ្យបានច្បាស់លាស់នូវតំបន់សំរាប់ធ្វើអាជីវកម្មកសិកម្ម ។
- កម្មវិធីអភិវឌ្ឍន៍ការបណ្តុះបណ្តាលជំនាញស្តីពីផលិតកម្មសត្វ និងបសុព្យាបាលដល់សហគមន៍ជនបទ ។
- អភិវឌ្ឍន៍ និងលើកកំពស់ការអនុវត្តន៍កសិកម្មប្រកបដោយនិរន្តរភាព ។
- ការបណ្តុះបណ្តាលកសិករជាគ្រូបង្គោល ដើម្បីធ្វើការផ្សព្វផ្សាយអំពីវិធីសាស្ត្រសមស្រប ដែលអាចគាំទ្រដល់កសិកម្មចំរុះ ។
- ពង្រីកកម្មវិធីទាំងឡាយ ដែលបាន និងកំពុងគាំទ្រដល់កសិកម្មចំរុះនៅទូទាំងប្រទេស ។
- កំណត់ និងលើកកំពស់ផលប្រយោជន៍កសិកម្មពីជីវៈចំរុះ ។

សកម្មភាពជាអាទិភាព (ស្ថាប័នសំរបសំរួល និងចូលរួមអនុវត្ត)

៦.១ ការបណ្តុះបណ្តាលកសិករអំពីប្រព័ន្ធកែលំអការដាំដុះ និងផលិតកម្ម ព្រមទាំងបសុព្យាបាលដោយគោរពទៅតាមគោលការណ៍គ្រប់គ្រង សមស្របនឹងតំរូវការបរិស្ថាន ( ក្រ.កសក ) ដោយរាប់បញ្ចូល :

- របៀបគ្រប់គ្រងដី និងដាក់ជីកំប៉ុកដើម្បីរក្សាសំណើមនៅក្នុងដី ។
- ការជ្រើសរើសប្រភេទ និងពូជដំណាំសមស្របនឹងវត្តមានទឹកនៅតាមតំបន់នីមួយៗ ។
- ការបណ្តុះបណ្តាលអំពីការប្រើប្រាស់ជីគីមី និងថ្នាំកំចាត់សត្វចង្រៃឱ្យបានសមស្រប ។
- ការប្រើប្រាស់ជីសរីរាង្គ ជំនួសជីគីមី ។
- ការអនុវត្តន៍កសិកម្មចំរុះ ដោយមានការដាំដុះដំណាំ និងការចិញ្ចឹមសត្វនៅក្នុងប្រព័ន្ធតែមួយ ។
- ការប្រើប្រាស់ និងការធ្វើចំណីសត្វ ដោយប្រើប្រាស់សំណល់រុក្ខជាតិ និងជីបៃតង ។
- ការបញ្ចូលដំណាំឆ្លាស់ និងការប្រើប្រាស់វាលស្មៅសំរាប់ការចិញ្ចឹមសត្វតាមរយៈការប្តូរវេនគ្នា ។
- ជំរុញការប្រើប្រាស់ទូលំទូលាយ នូវពូជដំណាំសុទ្ធ ។
- ការបញ្ចូលកសិកម្មអេកូឡូស៊ី ដោយមានការដាំដុះ និងការចិញ្ចឹមសត្វ រួមជាមួយ កសិរុក្ខកម្ម ។
- បង្កើនប្រសិទ្ធិភាពក្នុងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងទឹក ។
- ជៀសវាងការភ្ជួរជ្រៅនៅលើស្រទាប់ដីកសិកម្មរាក់ និងការដាំដើមឈើដើម្បីការពារសំណឹកដី ។
- លើកកំពស់ការប្រមូលផលកសិកម្មតាមបច្ចេកវិទ្យាសមស្រប ។

៦.២ ការផ្សព្វផ្សាយអំពីកម្មវិធីវិធានការចំរុះថៃទាំដំណាំ តាមរយៈសាលារៀនស្រែកសិករ ( ក្រ.កសក) ។

៦.៣ កម្មវិធីជំរុញការអនុវត្តន៍កសិកម្មចំរុះ ដើម្បីធានាសន្តិសុខស្បៀង ( ក្រ.កសក ) ។

៦.៤ កម្មវិធីការពារ និងប្រើប្រាស់ដីកសិកម្ម ( ក្រ.កសក) ។

៦.៥ អនុម័ត និងកែលំអប្រព័ន្ធគ្រប់គ្រងការដាំដុះឱ្យមាននិរន្តរភាព ( ក្រ.កសក) ។

៦.៦ ពង្រឹងការសិក្សាស្រាវជ្រាវអំពីពូជដំណាំថ្មីៗ និងការផ្លាស់ប្តូរមុខដំណាំ ( ក្រ.កសក) ។

## ប្រធានបទទី ៧ : ធនធានថាមពល

### បរិបទ

តាមការសិក្សារបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងក្រសួងឧស្សាហកម្មរ៉ែ និងថាមពល នៅឆ្នាំ ១៩៩៦ ការប្រើប្រាស់ថាមពលពាណិជ្ជកម្ម (ប្រេងឥន្ធនៈ ឧស្ម័ន អគ្គិសនី) របស់ប្រទេសកម្ពុជាមានតិចជាង ១៨% នៃថាមពលដែលប្រើសរុប ។ ផ្នែកដែលនៅសល់ ៨២% មានប្រភពពីឈើ (៨០.៥% រួមទាំងធ្យូង) និងបានពីប្រភពជីវម៉ាសដទៃទៀត ដូចជា សំណល់ពីដំណាំ (១.៦%) ។ អុសជាប្រភពថាមពលចំបងសំរាប់ការដាំស្លនៃគ្រួសារភាគច្រើនក្នុងប្រទេសកម្ពុជា (៩២%) ហើយប្រេងកាតត្រូវបានគេប្រើក្នុងអត្រាប្រើប្រាស់តិចតួចសំរាប់ចំអិនអាហារ (តិចជាង ២%) ។ នៅតាមជនបទ ៩៥% នៃគ្រួសារប្រើប្រាស់អុស ជាប្រភពថាមពលចំបងសំរាប់ការចំអិនអាហារ ។

ជាទូទៅ ឈើគឺជាធនធានដែលអាចកើតមានឡើងវិញបាន និងដែលអាចបំពេញតំរូវការផ្នែកថាមពលក្នុងគ្រួសារដោយគ្មានកាលកំណត់ ។ ប៉ុន្តែ ជាធម្មតាឈើត្រូវបានប្រើប្រាស់ក្នុងអត្រាខ្ពស់ជាងអត្រានៃការដាំឡើងវិញ ដែលជាប្រការអាចបណ្តាលឱ្យវិសាលភាពព្រៃត្រូវរួមតូច បាត់បង់ជំរកសត្វព្រៃ បាត់បង់ដី សំណឹកដី បាត់បង់ជីជាតិដី មានទឹកជំនន់នៅតំបន់ផ្នែកខាងក្រោម កំនើនកំទេចកំនរ ធ្វើឱ្យទឹកតាមបណ្តាញខ្សែទឹកនានាទៅជាល្អក់ និងបញ្ហាដទៃជាច្រើនទៀត ។ ស្របនឹងការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនប្រជាជន គេរំពឹងថា ការប្រើប្រាស់អុសនឹងកើនឡើងជាបន្តបន្ទាប់ ដែលនឹងធ្វើឱ្យមានកំនើនសំពាធទៅលើព្រៃឈើ និងព្រៃកោងកាង ។

នៅប្រទេសកម្ពុជា ការប្រើប្រាស់ប្រេងឥន្ធនៈសំរាប់ផលិតថាមពលអគ្គិសនី ស្ថិតក្នុងលំដាប់ទី ២ បន្ទាប់ពីការប្រើប្រាស់ក្នុងផ្នែកដឹកជញ្ជូន ។ កំនើនជាអចិន្ត្រៃយ៍នៃសេចក្តីត្រូវការផ្នែកថាមពលអគ្គិសនី អាចនឹងតំរូវឱ្យមានការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី តាមដងទន្លេមេគង្គ និងស្ទឹងនានា ។ គេចាំបាច់ត្រូវពិនិត្យដោយហ្មត់ចត់នូវគំរោងទាំងនេះ លើហេតុប៉ះពាល់អវិជ្ជមានដែលអាចកើតចំពោះដីជាតិដីកសិកម្ម និងផលិតភាពទីជំរកមច្ឆាជាតិ ។

សកម្មភាពរុករកប្រេង និងឧស្ម័នធម្មជាតិនៅសមុទ្រក្រៅ បានធ្វើឡើងនៅក្នុងប្រទេសកម្ពុជា តាំងពីទសវត្សរ៍ឆ្នាំទី ៦0 មកម្ល៉េះ ។ អ្នកជំនាញការនានាជឿថា ប្រទេសកម្ពុជាមានសក្តានុពលភាពខ្ពស់ក្នុងការផលិតឧស្ម័នធម្មជាតិ ប៉ុន្តែការរុករកមកទល់បច្ចុប្បន្ន នៅពុំទាន់បានរកឃើញអាងធម្មជាតិ ដែលមានតំលៃសំរាប់ធ្វើអាជីវកម្មនៅឡើយទេ ។ ប្រសិនបើការធ្វើអាជីវកម្មបែបពាណិជ្ជកម្មចាប់ផ្តើម គេត្រូវមានការប្រុងប្រយ័ត្ន ដើម្បីទប់ស្កាត់នូវគ្រោះថ្នាក់ ដែលអាចកើតឡើង ដោយសារការហៀរកំពប់ប្រេង និងផលប៉ះពាល់ដទៃទៀត ចំពោះប្រព័ន្ធអេកូឡូស៊ីធម្មជាតិ បណ្តាលពីសកម្មភាពទាំងនេះ ។

### បញ្ហាចំបងៗ

- ការកាប់ព្រៃឈើ និងការបំផ្លិចបំផ្លាញព្រៃកោងកាងសំរាប់ផលិតអុស ។
- ហេតុប៉ះពាល់ដែលអាចកើតឡើងចំពោះប្រព័ន្ធអេកូឡូស៊ី បណ្តាលពីផលិតកម្មថាមពល ។

គោលដៅ

- លើកស្ទួយប្រសិទ្ធិភាពនៃការផលិត និងប្រើប្រាស់ថាមពល ។
- ធានាឱ្យមានការផ្គត់ផ្គង់អុសដោយនិរន្តរភាព និងទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានចំពោះប្រព័ន្ធអេកូឡូស៊ីធម្មជាតិបណ្តាលមកពីការអភិវឌ្ឍន៍ និងប្រើប្រាស់ថាមពល ។
- ជំរុញឱ្យមានការប្រើប្រាស់ប្រភពថាមពល្យផ្សេងៗទៀត ដើម្បីកាត់បន្ថយការប្រើប្រាស់អុស ។

គោលបំណងជាយុទ្ធសាស្ត្រ (*សន្ទស្សន៍បង្ហាញ*)

៧.១ កាត់បន្ថយការប្រើប្រាស់អុស នៅក្នុងតំបន់ទាំងឡាយដែលមានព្រៃឈើតិចតួច តាមរយៈវិធានការបង្កើនប្រសិទ្ធិភាពប្រើប្រាស់ថាមពល និងប្រើប្រាស់ប្រភពថាមពលផ្សេងជាជំនួស ( *បរិមាណឧសដែលបានប្រើប្រាស់តាមគ្រួសារ* ) ។

ជំរើសនានា

- សិក្សាពីចលនាអុសដើម្បីធ្វើការប៉ាន់ប្រមាណនូវនិរន្តរភាពនៃការប្រើប្រាស់ និងការផលិត ។
- ពិចារណាលើការដាំចំការឈើសំរាប់ប្រើជាថាមពល ។
- សិក្សាបន្ថែមទៀតអំពីហេតុប៉ះពាល់នៃការកាប់ព្រៃឈើ បណ្តាលពីការប្រើប្រាស់អុស ។
- បង្កើតវិធីសាស្ត្រផលិតធ្យូងប្រកបដោយប្រសិទ្ធិភាពខ្ពស់ ។
- ជំរុញឱ្យប្រើប្រាស់ចង្ក្រានដែលមានការកែលំអប្រសិទ្ធិភាពនៅតាមគ្រួសារនានា និងនៅតាមសហគ្រាសធុនតូច ។ល។
- ជំរុញឱ្យមានការប្រើប្រាស់តាមគ្រួសារនូវចង្ក្រានជីវៈឧស្ម័ន នៅក្នុងសហគមន៍ ដែលជួបប្រទះបញ្ហាប្រើប្រាស់អុស និងដែលសំបូរលាមកសត្វ ។
- វាយតំលៃឱ្យបានចប់សព្វគ្រប់នូវហេតុប៉ះពាល់បរិស្ថាននៃគំរោងទំនប់វារីអគ្គីសនី និងគំរោងធ្វើអាជីវកម្មប្រេងកាត ។

សកម្មភាពជាអាទិភាព (ស្ថាប័នសំរបសំរួល និងចូលរួមអនុវត្ត )

៧.១ កម្មវិធីប្រសិទ្ធភាពថាមពលតាមគ្រួសារក្នុងតំបន់ដែលខ្សត់អុស ( ក្រ.ឧរថ កសក និង អជប) (រួមមាន ចង្ក្រានប្រើអុសកែលំអ ឧបករណ៍ផលិតជីវៈឧស្ម័ន) ។

៧.២ ជំរុញឱ្យមានការដាំដើមឈើសំរាប់ធ្វើអុស និងសំរាប់ការប្រើប្រាស់ច្រើនមុខ តាមគ្រួសារ និងតាមសហគមន៍ ( ក្រ.ឧរថ កសក និង អជប) ។

៧.៣ គោលការណ៍ណែនាំអំពីបរិស្ថាន និងការវាយតំលៃហេតុប៉ះពាល់បរិស្ថានសំរាប់គំរោងអភិវឌ្ឍន៍ថាមពល ( ក្រ.ឧរថ និង

## ប្រធានបទទី ៨ : ធនធានរ៉ែ

### បរិបទ

ធនធានរ៉ែនៅក្នុងប្រទេសកម្ពុជាត្រូវបានបែងចែកជា ៥ ក្រុម : រ៉ែឥន្ធនៈ រ៉ែសំរាប់សំណង់ រ៉ែឧស្សាហកម្ម លោហៈ និងអលោហៈ ថ្មមានតំលៃ និងត្បូងសំរាប់តែងលំអ ។ រ៉ែដែលគេប្រើប្រាស់សំរាប់សាងសង់អាគារ និងផ្លូវថ្នល់ ត្រូវបានជីកយកពីតំបន់ផ្សេងៗ ហើយរួមមាន : សិលាបាសាល់ សិលាក្រានីត ថ្មកំបោរ ថ្មសិលាចម្លាក់ សិលាក្វាត សិលាក្រែ និងថ្មម៉ាប ។ ថ្មកំបោរ និងថ្មម្នាងសិលា ដែលគេប្រើប្រាស់នៅក្នុងឧស្សាហកម្មស៊ីម៉ងត៍ ត្រូវបានជីកយក និងកែច្នៃនៅក្នុងខេត្តកំពត ឯរ៉ែផូស្វាត ដែលមាននៅខេត្តកំពត និងបាត់ដំបង ត្រូវបានគេយកមកកែច្នៃដើម្បីផលិតជាជីផូស្វាត ។

មានតំបន់ពីរសំខាន់ៗ ដែលមានត្បូងថ្ម ។ ត្បូងកណ្ដៀង ត្បូងទទឹម និងពេជ្រខ្មែរ ត្រូវបានរងការធ្វើអាជីវកម្មយ៉ាងធ្ងន់ធ្ងរ ឯការជីកយកពេជ្រខ្មែរ ត្បូងកណ្ដៀង និងរ៉ែមាស នៅខេត្តរតនគិរី មានលក្ខណៈជាទ្រង់ទ្រាយតូច និងប្រព្រឹត្តិទៅតែនៅរដូវប្រាំងប៉ុណ្ណោះ ។ ត្បូងតែងលំអ និងថ្មកែវ នៅខេត្តពោធិសាត់ ត្រូវបានប្រើប្រាស់សំរាប់ការផលិតគ្រឿងតែងលំអខ្មែរ ។

ជាទូទៅ ការធ្វើអាជីវកម្ម ការទាញយកផល និងការកែច្នៃធនធានរ៉ែ បង្កការគំរាមគំហែងយ៉ាងធ្ងន់ធ្ងរដល់ជំរកធម្មជាតិ និងសត្វព្រៃ ។ សកម្មភាពជីកយករ៉ែបានបំផ្លាញទេសភាពតំបន់ និងគំរបរុក្ខជាតិ និងជះឥទ្ធិពលដល់សត្វព្រៃ ។ ទឹកដែលជ្រាបចេញពីរោងចក្រកែច្នៃ និងកំទេចអាចម៍រ៉ែអាចបំពុលប្រភពទឹក និងដី ។ ទឹកភ្លៀងដែលហូរជ្រាបតាមគំនរសំនល់ពីការទាញយករ៉ែអាចក្លាយជាកខ្វក់ ទៅជាជូរ ឬល្អក់ ដែលអាចបង្កមហន្តរាយដល់ផ្លូវទឹកនៅក្បែរៗនោះ ។ ទឹក និងរុក្ខជាតិដែលរងភាពកខ្វក់អាចក្លាយជាពុល ឬអាចបង្កឱ្យមានជំងឺដល់មនុស្ស និងសត្វទាំងឡាយដែលប្រើប្រាស់វា ។

### បញ្ហាចំបង

- មានការបំផ្លិចបំផ្លាញ និងការបំពុលទីជំរកធម្មជាតិដោយសកម្មភាពជីកយករ៉ែ ។
- ខ្វះការគិតគូរពិចារណាអំពីកិច្ចការពារជីវៈចំរុះក្នុងសកម្មភាពជីកយករ៉ែ ។
- ខ្វះវិធីសាស្ត្រជីកយករ៉ែដែលសមស្រប ។
- ពុំមានកម្មវិធីតាមដានណែនាំបានត្រឹមត្រូវ ។

### គោលដៅ

កាត់បន្ថយហេតុប៉ះពាល់ចំពោះជីវៈចំរុះបណ្ដាលពីសកម្មភាពជីកយករ៉ែ ។

### គោលបំណងជាយុទ្ធសាស្ត្រ (*សន្ទស្សន៍បង្ហាញ*)

៨.១ គាំទ្រសកម្មភាពនៃការអភិវឌ្ឍន៍ធនធានរ៉ែទាំងឡាយណា ដែលបង្កផលប៉ះពាល់ក៏រិតទាបបំផុតចំពោះជីវៈចំរុះ (ឧទាហរណ៍ *គំរោងជីកយករ៉ែ ដែលបានដាក់ស្នើសំរាប់ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន*) ។

៨.២ គាំទ្រវិធានការនានា ដែលកាត់បន្ថយផលប៉ះពាល់ដល់ជីវចំរុះ បណ្តាលពីសកម្មភាពពាក់ព័ន្ធនឹងការជីកយករ៉ែ និងគំរោងដែលយល់ព្រមស្តារប្រព័ន្ធអេកូឡូស៊ីដែលរងការខូចខាត ( *ចំនួនទីតាំងអណ្តូងរ៉ែ ដែលបានសិក្សាតាមដាន*) ។

៨.៣ ជំរុញឱ្យមានការស្តារឡើងវិញនូវទីតាំងដែលទទួលរងការខូចខាតដោយសារការជីកយកធនធានរ៉ែ ( *ទំហំដីនៃទីតាំងដែលត្រូវបានស្តារឡើងវិញ*) ។

ជំរើសនានា

- តាមដានរាល់សកម្មភាពជីកយករ៉ែ ដែលបង្កផលប៉ះពាល់ដល់ជីវៈចំរុះ និងការស្តារឡើងវិញនូវជំរកនិងទីតាំងដែលរងការរំខាន ។
- កំណត់ជាបន្ថែមនូវសកម្មភាពជីកយករ៉ែ ដែលមានសុវត្ថិភាពដល់បរិស្ថាន ដោយធ្វើការសិក្សាហេតុប៉ះពាល់បរិស្ថាន និងវាយតំលៃហានិភ័យគ្រោះថ្នាក់ដែលអាចកើតមាន ។
- អនុវត្តន៏យ៉ាងម៉ឹងម៉ាត់នូវវិធានការកាត់បន្ថយហេតុប៉ះពាល់ ដូចបានកំណត់ក្នុងនីតិវិធីធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន តាមរយៈការតាមដាន ណែនាំ និងការធ្វើអធិការកិច្ចឱ្យបានទៀងទាត់ ។
- រួមបញ្ចូលកិច្ចការពារជីវៈចំរុះ ទៅក្នុងគោលនយោបាយរ៉ែ និងថាមពល ។
- ធានាថា ទីកន្លែងទុកដាក់សំណល់នានាមិនធ្វើឱ្យកខ្វក់ដល់បណ្តាប្រភេទ និងប្រព័ន្ធអេកូឡូស៊ី ។
- រួមបញ្ចូលប្រព័ន្ធគ្រប់គ្រងបរិស្ថានទៅក្នុងសកម្មភាពជីកយករ៉ែ ។

សកម្មភាពជាអាទិភាព (ស្ថាប័នសំរបសំរួល និងចូលរួមអនុវត្ត )

៨.១ សិក្សាអំពីលទ្ធភាព ថ្លៃចំណាយ និងផលចំណេញនៃការកែលំអវិធីធ្វើអាជីវកម្មរ៉ែ ឱ្យស្របតាមគោលការណ៍បរិស្ថាន ( ក្រ.ឧរថ និង បស្ថ) ។

៨.២ កសាងគោលការណ៍ណែនាំបរិស្ថាន សំរាប់សកម្មភាពជីកយករ៉ែ ( ក្រ.ឧរថ និង បស្ថ) ។

៨.៣ កសាងនូវនីតិវិធីធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន សំរាប់គំរោងអាជីវកម្មរ៉ែ ( ក្រ.ឧរថ និង បស្ថ) ។

# ប្រធានបទទី ៩ : ឧស្សាហកម្ម បច្ចេកវិទ្យា និងសេវាកម្ម

## ៩.១ កម្មន្តសាល

### បរិបទ

នៅក្នុងប្រទេសកម្ពុជាមានរោងចក្រខ្នាតធំ មធ្យម ឬសហគ្រាសខ្នាតតូចរាប់ពាន់ ដែលបង្កផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលចំពោះបរិស្ថាន ។ សហគ្រាសដែលទំនងជាបង្កការប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះជីវៈចំរុះ តាមរយៈការបញ្ចេញសំណល់រឹង និងរាវ និងដែលបំពុលទឹក ខ្យល់ និងដី រួមមាន រោងចក្រសំលាប់ស្បែក រោងចក្រតម្បាញ រោងចក្រកាត់ដេរ រោងចក្រប្លាស្ទិច រោងចក្រកែច្នៃកៅស៊ូ និងរោងចក្រផលិតបំពង់ទុយយោ ។

រោងចក្រភាគច្រើនពុំទាន់មានបំពាក់ដោយប្រព័ន្ធគ្រប់គ្រងបរិស្ថាននៅឡើយទេ ទោះបីវិធីនេះមានប្រសិទ្ធិភាពក្នុងការបន្ថយហេតុប៉ះពាល់បរិស្ថាននៃបណ្តារោងចក្រ និងកែលំអទិន្នផល និងការប្រកួតប្រជែងផលិតផលក្តី ។ ទោះបីមានច្បាប់ហើយក្តី ក៏គេនៅពុំទាន់មានការណែនាំអំពីនីតិវិធីនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថានសំរាប់តំរោងឧស្សាហកម្មថ្មីៗនៅឡើយ ។ កំនើននៃការគោរពតាមគោលការណ៍បរិស្ថាននៅក្នុងវិស័យនេះ មិនត្រឹមតែអាចជួយបង្កើនទិន្នផលប៉ុណ្ណោះទេ តែថែមទាំងជួយសំរួលក្នុងការលក់ផលិតផលឧស្សាហកម្មនៅតាមទីផ្សារអន្តរជាតិ ដែលចាប់អារម្មណ៍អំពីបញ្ហាបរិស្ថានទៀតផង ។

### បញ្ហាចំបង

- ការគ្រប់គ្រងសារធាតុប្រកបដោយគ្រោះថ្នាក់ និងសំណល់ដទៃៗទៀតនៅមានកំរិតទាប ។
- ខ្វះការយល់ដឹងអំពីបញ្ហាបរិស្ថាននៅក្នុងវិស័យឧស្សាហកម្ម ។
- ខ្វះឧបករណ៍សំរាប់ត្រួតពិនិត្យ និងវិភាគ ។

### គោលដៅ

- កាត់បន្ថយហេតុប៉ះពាល់បរិស្ថាននៃសកម្មភាពផលិតកម្មឧស្សាហកម្ម ។
- ស្តារឡើងវិញនូវទីតាំងដែលទទួលរងគ្រោះដោយសកម្មភាពផលិតកម្មឧស្សាហកម្ម ។

### គោលបំណងជាយុទ្ធសាស្ត្រ (*សន្ទស្សន៍បង្ហាញ*)

៩.១.១ ជំរុញឱ្យមានការប្រើប្រាស់ដំណើរការផលិតកម្មក្នុងវិស័យឧស្សាហកម្ម ដោយគោរពតាមគោលការណ៍បរិស្ថាន ។ (*ចំនួនក្រុមហ៊ុនដែលទទួលបានការផ្សព្វផ្សាយតាមរយៈយុទ្ធនាការបង្កើនការយល់ដឹង*) ។

៩.១.២ ជំរុញការអនុវត្តនីប្រព័ន្ធគ្រប់គ្រងបរិស្ថាននៅក្នុងរោងចក្រខ្នាតធំ និងមធ្យម (*ចំនួនសហគ្រាសប្រើប្រព័ន្ធគ្រប់គ្រងបរិស្ថាន*) ។

ជំរើសទានា

- ត្រួតពិនិត្យការបញ្ចេញសំណល់វាវឧស្សាហកម្ម ដោយអនុលោមតាមលក្ខណៈវិនិច្ឆ័យ និងខ្នាតគំរូ ជាតិ និងអន្តរជាតិ ។
- ត្រួតពិនិត្យការគ្រប់គ្រងសំណល់រឹងឧស្សាហកម្ម និង/ឬ សំណល់ពីទីប្រជុំជន ដោយអនុលោមតាមលក្ខណៈវិនិច្ឆ័យ និងខ្នាតគំរូជាតិ និងអន្តរជាតិ ។
- បង្កើតនីតិវិធីនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន សំរាប់គំរោងការអភិវឌ្ឍន៍ឧស្សាហកម្មថ្មីៗ ។
- អនុវត្តប្រព័ន្ធគ្រប់គ្រងបរិស្ថានក្នុងឧស្សាហកម្ម និងមូលដ្ឋានផលិតកម្មខ្នាតធំ និងមធ្យម ។
- ពង្រឹងការត្រួតពិនិត្យ និងតាមដានការបំពុលពីវិស័យឧស្សាហកម្ម ។
- ចងក្រងឯកសារអំពីទិន្នន័យ និងពត៌មានពាក់ព័ន្ធនឹងសំណល់រឹង ឧស្ម័ន និងសំណល់រាវ ពីវិស័យឧស្សាហកម្ម ។
- ជំរុញឱ្យមានគំរោងការពារបរិស្ថាន ដែលមានប្រសិទ្ធិភាពសេដ្ឋកិច្ច ក្នុងវិស័យឧស្សាហកម្ម ។

សកម្មភាពជាអាទិភាព (ស្ថាប័នសំរបសំរួល និងចូលរួមអនុវត្ត)

៩.១.១ កម្មវិធីបង្កើនការយល់ដឹងអំពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងប្រព័ន្ធត្រួតពិនិត្យ និងតាមដានការបំពុលបរិស្ថាន សំរាប់វិស័យផលិតកម្មឧស្សាហកម្ម (ក្រ.ឧរថ បស្ថ កសក និង ពណក) ។

## ៩.២ ជីវបច្ចេកវិទ្យា និងជីវសុវត្ថិភាព

### បរិបទ

មនុស្សលោកបានប្រើសារពាង្គកាយ ហើយធ្វើអាជីវកម្មលើដំណើរការជីវសាស្ត្រ និងសំណុំលក្ខណៈរបស់វា អស់រយៈកាលជាច្រើនពាន់ឆ្នាំមកហើយ ។ បច្ចេកវិទ្យាដំបូងគឺការបង្កាត់ជ្រើសពូជសត្វ និងរុក្ខជាតិ ព្រមទាំងការប្រើប្រាស់មីក្រូសារពាង្គកាយ ក្នុងចំណោមសារពាង្គកាយនានា ដើម្បីផលិតស្រា ស្រាបៀរ នំប៉័ង ហ្វ្រូម៉ាស និងផលិតផលពីសណ្តែកសៀង ដែលបណ្តាប្រទេសនៅលើពិភពលោកបានយកមកប្រើប្រាស់ និងធ្វើការកែលំអជាបន្តបន្ទាប់ ។ បច្ចុប្បន្ន បច្ចេកទេសបុរាណ និងសាមញ្ញបែបនេះ នៅតែមានប្រើប្រាស់នៅតាមជនបទ និងឧស្សាហកម្មនៅឡើយ តែមានភាពខុសគ្នាបន្តិច ដោយសារវាមានភាពសាំញ៉ាំជាងមុន និងអនុវត្តក្នុងទ្រង់ទ្រាយធំជាងមុន ។ នៅប្រទេសកម្ពុជា ជីវបច្ចេកវិទ្យាតាមបែបបុរាណ ត្រូវបានគេប្រើប្រាស់ជាច្រើនរយឆ្នាំមកហើយ សំរាប់ការជ្រើសរើសពូជរុក្ខជាតិ និងសត្វ ការផលិតស្រាបៀរ ផលិតផលពីសណ្តែកសៀង ផលិតកម្មស្រាសពីអង្ករ និងទឹកត្នោតជូរ ។

ក្នុងរយៈពេល ៣០ ឆ្នាំចុងក្រោយនេះ មានបច្ចេកទេសថ្មីៗ និងមានអានុភាពខ្លាំងជាងមុន បានបង្កើតឡើងបន្ថែមចំពោះបច្ចេកទេសបែបបុរាណ ។ បច្ចេកទេសថ្មីៗមួយចំនួន ដូចជា ការចិញ្ចឹមជាលិកា ការរលាយចូលគ្នានៃកោសិកា ការផ្ទេរអំប្រ៊ីយ៉ុង បច្ចេកវិទ្យា DNA សំរាប់បង្កាត់ពូជ និងបច្ចេកទេសកែច្នៃជីវៈចំរុះថ្មីជាដើម បានផ្តល់លទ្ធភាពដល់អ្នកវិទ្យាសាស្ត្រ ក្នុងការបណ្តុះ[illegible]ទាំងមូល ចេញពីកោសិកាទោល ការផ្សំប្រភេទកោសិកាផ្សេងគ្នា ដើម្បីបង្កើតពូជកាត់ ដែលមានគុណភាព ដូច[illegible] ។ ក្រៅពីនេះ មានបច្ចេកទេសធ្វើឱ្យសត្វមានកូន ដោយបញ្ចូលអំប្រ៊ីយ៉ុងពីសត្វផ្សេង បំបែកសែនពី

សារពាង្គកាយ ដើម្បីបញ្ចូលសែនដែលបំបែកចេញនោះ ទៅក្នុងសត្វផ្សេងទៀត និងកែច្នៃវត្ថុនានា ដូចជាអាហារ និងសំណល់ ប្រកបដោយប្រសិទ្ធិភាពកាន់តែខ្ពស់ ។ បច្ចេកទេសខ្លះក្នុងផ្នែកជីវបច្ចេកវិទ្យាទំនើប កំពុងត្រូវបានប្រើប្រាស់ក្នុងពេលបច្ចុប្បន្ន សំរាប់ជួយអភិរក្សជីវៈចំរុះ និងប្រើប្រាស់សមាសភាគរបស់វាដោយនិរន្តរភាព ជាពិសេសសំរាប់ធនធានសេនេទិច ។

ប៉ុន្តែមនុស្សភាគច្រើនយល់ថា វិស្វកម្មសេនេទិច គឺជាជីវបច្ចេកវិទ្យា ។ ដោយប្រើប្រាស់បច្ចេកទេសវិស្វកម្មសេនេទិច សែនមួយដែលកំណត់លក្ខណៈដោយឡែកមួយ អាចត្រូវបានបំបែកពីសារពាង្គកាយមួយ និងដាក់បញ្ចូលដោយផ្ទាល់ទៅក្នុងសារពាង្គកាយមួយផ្សេងទៀត ទោះបីសារពាង្គកាយទាំងពីរមិនមែនជាប្រភេទដូចគ្នាក៏ដោយ ។ នេះគឺជាការរីកចំរើនជឿនលឿនដ៏សំបើមខាងផ្នែកបង្កាត់ពូជរុក្ខជាតិ និងសត្វ ។ អានុភាពខ្លាំងក្លានៃវិស្វកម្មសេនេទិច ក៏បានបង្កជាកង្វល់សំរាប់មនុស្សជាច្រើន ដែលបារម្ភអំពីក្រមសីលធមិនៃការប្រើប្រាស់បច្ចេកវិទ្យានេះ ពីសុវត្ថិភាពសំរាប់មនុស្ស និងបរិស្ថាន ព្រមទាំងពីផលប៉ះពាល់សេដ្ឋកិច្ច-សង្គមនៃផលិតផលបានពីបច្ចេកវិទ្យាបែបនេះ ។

ជីវបច្ចេកវិទ្យាមានសក្តានុពលក្នុងការផ្តល់ផលប្រយោជន៍សំរាប់លើកស្ទួយសុខមាលភាពមនុស្ស ។ ប៉ុន្តែមនុស្សជាច្រើនព្រួយបារម្ភថា ការប្រើប្រាស់ផលិផលបានពីជីវបច្ចេកវិទ្យា អាចផ្តល់គ្រោះថ្នាក់ចំពោះជីវៈចំរុះ និងសុខភាពមនុស្ស ។ គេចាំបាច់ត្រូវធ្វើអត្តសញ្ញាណ និងគ្រប់គ្រងគ្រោះថ្នាក់ទាំងនេះ មុនពេលដែលមានការបង្កើត និងដាក់ឱ្យប្រើប្រាស់ផលិតផលថ្មី (IUCN, 1999 សេចក្តីណែនាំនៃអនុសញ្ញាជីវៈចំរុះ) ។

អនុសញ្ញាជីវៈចំរុះ និងពិធីសារដែលទើបបានអនុម័តថ្មីស្តីពីជីវសុវត្ថិភាព តំរូវឱ្យប្រទេសជាសមាជិកចាត់វិធានការ ដើម្បីដាក់កំហិត គ្រប់គ្រង ឬត្រួតពិនិត្យគ្រោះថ្នាក់ ដែលអាចកើតមានចំពោះជីវៈចំរុះ និងសុខភាពមនុស្ស បណ្តាលមកពីការ ប្រើប្រាស់ និងការបញ្ចេញទៅក្នុងបរិស្ថាន នូវសារពាង្គកាយមានជីវិត ដែលផលិតដោយជីវបច្ចេកវិទ្យា និងដែលទំនងជាបង្កហេតុប៉ះពាល់អវិជ្ជមានដល់បរិស្ថាន ។ បណ្តាប្រទេសជាសមាជិកអាចអនុវត្តកម្មវិធី ដើម្បីដោះស្រាយគ្រោះថ្នាក់ទាំងនេះ តាមរយៈការចាត់វិធានការនានា ដូចជា បទបញ្ញត្តិ ការគ្រប់គ្រង ឬមធ្យោបាយផ្សេងៗ សំរាប់ត្រួតពិនិត្យ ។ ជីវបច្ចេកវិទ្យាទំនើបពុំទាន់ត្រូវបានពង្រីកខ្លាំងក្លានៅឡើយទេ ទោះបីជាមានសក្តានុពលបែបនេះក៏ដោយ ។

បញ្ហាចំបង

- ខ្វះសមត្ថភាពជំនាញក្នុងផ្នែកជីវបច្ចេកវិទ្យាទំនើប ។
- ខ្វះវិធានការការពារ ប្រឆាំងនឹងសារពាង្គកាយមានជីវិតដែលផ្លាស់ប្តូរដោយជីវបច្ចេកវិទ្យា ។

គោលដៅ

- បង្កើតការអប់រំអំពីជីវបច្ចេកវិទ្យា និងអំពីការបង្ការគ្រោះថ្នាក់ដល់បរិស្ថាន និងសុខភាព ពាក់ព័ន្ធនឹងការប្រើ និងការបញ្ចូលទៅក្នុងបរិស្ថាននូវសារពាង្គកាយមានជីវិតបានពីជីវបច្ចេកវិទ្យា ។
- ការពារជីវៈចំរុះដែលមានកំនើតនៅនឹងកន្លែង ទប់ទល់នឹងនឹងការនាំចូល និងប្រើប្រាស់សារពាង្គកាយមានជីវិត ដែលជាផលិតផលជីវបច្ចេកវិទ្យា ។

គោលបំណងជាយុទ្ធសាស្ត្រ (*សន្ទស្សន៍បង្ហាញ*)

៩.២.១ អនុវត្តយុទ្ធសាស្ត្រជាតិអំពីជីវសុវត្ថិភាព ( *អនុម័តដោយអនុក្រឹត្យ* ) ។

៩.២.២ កសាងសមត្ថភាពជាតិ ក្នុងផ្នែកជីវបច្ចេកវិទ្យាទំនើប ( *ចំនួននិស្សិត ឬអ្នកជំនាញបានពីកម្មវិធីបណ្តុះបណ្តាល* ) ។

ជំរើសនានា

- រៀបចំការសិក្សា និងស្រាវជ្រាវអំពីជីវៈចំរុះមីក្រុប ។
- ប្រើប្រាស់ជីវបច្ចេកវិទ្យា ដើម្បីកាត់បន្ថយការប្រើប្រាស់សារធាតុគីមី ។
- ប្រើប្រាស់ជីវបច្ចេកវិទ្យា ដើម្បីត្រួតពិនិត្យការបំពុល និងលើកកំពស់សុខភាពបរិស្ថាន ព្រមទាំងទិដ្ឋភាពផ្សេងៗនៃបរិស្ថាន ។
- ប្រើប្រាស់ជីវបច្ចេកវិទ្យា ដើម្បីបង្កើតផលិតផលសំបូរប្រូតេអ៊ីន សំរាប់ប្រើជាចំណីសត្វ ជី សរីរាង្គសារធាតុសំរាប់ការពារគុណភាពដី និងសំរាប់រក្សាតុល្យភាពគុណភាពដី ។
- ជំរុញវិស្វកម្មសេនេទិចសមស្រប ដើម្បីបង្កើនផលិតផលត្រី និងដំណាំកសិកម្ម ។
- ជំរុញការផលិតជីវឧស្ម័ន ជីសរីរាង្គ និងថាមពល ដែលជាផលិតផលបន្ទាប់បន្សំបានពីដំណើរល្បឿង ។
- បង្កើតបញ្ជីស្តីពីធនធានមនុស្សដែលធ្វើការខាងផ្នែកពាក់ព័ន្ធនឹងជីវបច្ចេកវិទ្យា និងជីវសុវត្ថិភាព ។
- បង្កើតកម្មវិធីបណ្តុះបណ្តាលអំពីជីវបច្ចេកវិទ្យា ។
- បង្កើនធនធាននៅសាកលវិទ្យាល័យសំរាប់ការស្រាវជ្រាវ និងអភិវឌ្ឍន៍ជីវបច្ចេកវិទ្យា ។
- ដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សា នូវទស្សនាទានអំពីភាពសំបូរបែបនៃសេនេទិច សារៈសំខាន់នៃសេនេទិច និងការអនុវត្តន៍វិស្វកម្ម និងបច្ចេវិទ្យាសេនេទិច ។
- បង្កើតច្បាប់ជាតិស្តីពីក្រមសីលធម៌ និងគោលការណ៍ណែនាំ សំរាប់ប្រើប្រាស់ជីវបច្ចេកវិទ្យា ការប្រើប្រាស់សារពាង្គកាយរស់ ដែលត្រូវបានកែប្រែរូបសណ្ឋាន និងសេនេទិចតាមរយៈជីវវិទ្យា ។

សកម្មភាពជាអាទិភាព (*ស្ថាប័នសំរបសំរួល និងចូលរួមអនុវត្ត*)

៩.២.១ កសាង និងអនុវត្តយុទ្ធសាស្ត្រ ផែនការសកម្មភាពជីវសុវត្ថិភាព ដោយអនុលោមតាម ពិធីសារអន្តរជាតិស្តីពីជីវសុវត្ថិភាព ( ក្រ.កសក ឧរថ បស្ថ និង ពណក ) ។

## ៩.៣ វិស័យទេសចរណ៍

### បរិបទ

វិស័យទេសចរណ៍ក្នុងប្រទេសកម្ពុជាផ្តល់ឱកាសជាច្រើន សំរាប់ការស្តារសេដ្ឋកិច្ចប្រទេសជាតិ ហើយបច្ចុប្បន្នវិស័យនេះក៏កំពុងរីកចំរើនខ្លាំងផងដែរ ។ ការអភិវឌ្ឍន៍ដោយចីរភាពក្នុងវិស័យទេសចរណ៍ផ្អែកលើយុទ្ធសាស្ត្របី :

- កិច្ចការពារ និងការថែរក្សានូវបរិស្ថានធម្មជាតិ និងវប្បធម៌សង្គម ព្រមទាំងភាពចាំបាច់ក្នុងកិច្ចការពារប្រាង្គប្រាសាទ និងរមណីយដ្ឋាន បុរាណវត្ថុ រួមជាមួយនិងបេតិកភ័ណ្ឌវប្បធម៌ផ្សេងទៀតរបស់ប្រទេស ។
- ការអភិវឌ្ឍន៍ និងការកែលំអហេដ្ឋារចនាសម្ព័ន្ធ និងសណ្ឋាគារ ។
- ការអភិវឌ្ឍន៍ធនធានមនុស្ស ។

ការបង្កើត និងគ្រប់គ្រងឱ្យបានត្រឹមត្រូវនូវប្រព័ន្ធដ៏រឹងមាំនៃតំបន់ការពារធម្មជាតិ និងរមណីយដ្ឋានវប្បធម៌ ដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍វិស័យទេសចរណ៍ ។ ក្នុងន័យនេះ ប្រទេសកម្ពុជាមានសក្តានុពលធំធេងក្នុងការអភិវឌ្ឍន៍អេកូទេសចរណ៍ និងទេសចរណ៍បែបផ្សងព្រេង ផ្អែកលើសត្វព្រៃ និងទេសភាពធម្មជាតិ ។

ការបង្កើត និងអនុវត្តន៍គោលការណ៍ណែនាំ និងត្រួតពិនិត្យមួយចំនួនក្នុងវិស័យទេសចរណ៍ នឹងជួយថែរក្សាបរិស្ថាន ឱ្យនៅមានសុខភាពល្អ និងគង់វង្ស ។ ការកសាងផ្លូវថ្នល់ និងសណ្ឋាគារថ្មីៗ ត្រូវទាមទារឱ្យមានការប្រុងប្រយ័ត្ន ដើម្បីទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានចំពោះទេសភាពធម្មជាតិ និងភាពគង់វង្សនៃប្រពន្ធ័អេកូឡូស៊ីធម្មជាតិ ។ គេចាំបាច់ត្រូវធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន នៃរាល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច ឧស្សាហកម្ម និងហេដ្ឋារចនាសម្ពន្ធ័សង្គម ។ ត្រូវមានគោលនយោបាយធានាការចូលរួមរបស់សហគមន៍មូលដ្ឋាន ដើម្បីឱ្យមានការចែករំលែកផលប្រយោជន៍ និងប្រាក់ចំណូលពីវិស័យទេសចរណ៍ សំរាប់ការគាំទ្រកិច្ចការពារបរិស្ថាន ។ ត្រូវមានការគ្រប់គ្រងបណ្តាសេវាកម្មពាក់ព័ន្ធ សកម្មភាពសណ្ឋាគារ ដើម្បីទប់ស្កាត់ការបំពុល និងការខូចខាតបរិស្ថាន ។ ភ្នាក់ងារទេសចរណ៍ និងមគ្គុទ្ទេសក៍ទេសចរណ៍ ត្រូវទទួលខុសត្រូវ ក្នុងការជំរុញឱ្យភ្ញៀវទេសចរប្រកាន់យកឥរិយាបទ និងអាកប្បកិរិយាប្រកបដោយការទទួលខុសត្រូវ និងត្រូវផ្តល់ពត៌មានគ្រប់គ្រាន់ អំពីបណ្តាបទបញ្ជា និងបទបញ្ញត្តិនានាដល់ភ្ញៀវទេសចរ ។ ឧទាហរណ៍ នៅតំបន់ឆ្នេរ ការដែលពួកអ្នកមុជទឹកបរបាញ់ និងប្រមូលយកសារពាង្គកាយរស់ក្នុងសមុទ្រ និងការបោះយុថ្កាចតទូក សុទ្ធសឹងជាសកម្មភាពបំផ្លាញផ្កាថ្ម ។ ការផ្តល់ពត៌មានគ្រប់គ្រាន់ និងបច្ចេកទេសចតទូកសមស្រប អាចទប់ស្កាត់ការបំផ្លិចបំផ្លាញបែបនេះបាន ។

### បញ្ហាចំបង

- ការបំពុល និងការខូចខាតជំរកធម្មជាតិបណ្តាលពីសកម្មភាពខុសច្បាប់ក្នុងផ្នែកទេសចរណ៍ ។
- ការបង្កើនកំរិតយល់ដឹង និងការបណ្តុះបណ្តាលទីភ្នាក់ងារទេសចរណ៍ និងមគ្គុទ្ទេសក៍ភ្ញៀវទេសចរ ។

គោលដៅ

ធានាឱ្យមានការអភិវឌ្ឍន៍សកម្មភាពទេសចរណ៍ ដែលរក្សាការពារបរិស្ថាន និងបំពេញបានតាមតំរូវការ និងការរំពឹងទុករបស់សហគមន៍មូលដ្ឋាន ។

គោលបំណងជាយុទ្ធសាស្ត្រ (*សន្ទស្សន៍បង្ហាញ*)

៩.៣.១ តំរូវឱ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ចំពោះគំរោងអភិវឌ្ឍន៍ទេសចរណ៍ "ខ្នះ១" រួមទាំងការវាយតំលៃហេតុប៉ះពាល់សង្គម មុននឹងផ្តល់ការអនុញ្ញាត (*ភាគរយនៃគំរោងទេសចរណ៍បានទទួលការវាយតំលៃហេតុប៉ះពាល់បរិស្ថាន*) ។

៩.៣.២ តាមដាន និងគ្រប់គ្រងដោយនិរន្តរភាព នូវហេតុប៉ះពាល់ពីការធ្វើទេសចរណ៍ក្នុងតំបន់ការពារធម្មជាតិ (*ចំនួនផែនការគ្រប់គ្រង និងតាមដានបានត្រូវរៀបចំ*) ។

៩.៣.៣ បង្កឱកាសឱ្យសហគមន៍មូលដ្ឋាន បានចូលរួមក្នុងសកម្មភាពអេកូទេសចរណ៍ (*ចំនួនគំរោងអេកូទេសចរណ៍ផ្អែកលើសហគមន៍*) ។

ជំរើសនានា

- កសាងផែនការមេថ្នាក់ជាតិ ដើម្បីជំរុញអេកូទេសចរណ៍នៅតាមតំបន់ធម្មជាតិនានា ។
- បង្កើតគំរោងសិក្សាបរិស្ថានលំអិត ដើម្បីធ្វើអត្តសញ្ញាណធនធានធម្មជាតិ និងវប្បធម៌ក្នុងតំបន់ ដែលមានសក្តានុពលជារមណីយដ្ឋានទេសចរណ៍ ។
- បញ្ចូលកង្វល់អំពីការអភិរក្សជីវៈចំរុះទៅក្នុងគោលការណ៍ណែនាំសំរាប់ទេសចរណ៍ដែលមាននិរន្តរភាព ។
- តាមដានជាទៀងទាត់នូវហេតុប៉ះពាល់បរិស្ថាន បណ្តាលមកពីសកម្មភាពទេសចរណ៍តាមតំបន់ធម្មជាតិ ។
- បញ្ចូលចំនុចនានាស្តីពីការគ្រប់គ្រងធម្មជាតិទៅក្នុងគោលការណ៍គ្រប់គ្រងឧស្សាហកម្មទេសចរណ៍ ។
- កាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានបណ្តាលមកពីប្រជាជនមូលដ្ឋាន និងភ្ញៀវទេសចរ ចំពោះជីវៈចំរុះ ក្នុងតំបន់ដែលមានការទាក់ទាញទេសចរណ៍ ។
- កសាងហេដ្ឋារចនាសម្ព័ន្ធសំរាប់បំរើអេកូទេសចរណ៍នៅតំបន់ការពារធម្មជាតិ ។
- ស្តារទីរមណីដ្ឋានធម្មជាតិ និងវប្បធម៌មួយចំនួនឡើងវិញ សំរាប់ទទួលភ្ញៀវទេសចរ ។
- ស្តារឡើងវិញ និងធ្វើឱ្យប្រសើរឡើងនូវជីវៈចំរុះនៃតំបន់មួយចំនួន ដើម្បីបន្ថែមគុណតំលៃដល់តំបន់ទាំងនោះ ។
- អនុវត្តការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម សមរាប់សកម្មភាពទេសចរណ៍ ។
- ជំរុញសកម្មភាពទេសចរណ៍ដែលគោរពតាមគោលការណ៍បរិស្ថាន ។
- កសាងផែនការគ្រប់គ្រងភ្ញៀវទេសចរ សំរាប់តំបន់ទាក់ទាញភ្ញៀវទេសចរសំខាន់ៗ ។

- រៀបចំផែនការសមស្រប និងបច្ចេកវិទ្យាសមស្រប សំរាប់បង្កើតភោជនាល័យនៅក្នុងមូលដ្ឋាន តាមតំបន់ដែលងាយរងមហន្តរាយផ្នែកបរិស្ថាន ។

សកម្មភាពជាអាទិភាព (ស្ថាប័នសំរបសំរួល និងចូលរួមអនុវត្ត)

៩.៣.១ ដាក់បញ្ចូលបញ្ហាអភិរក្សជីវៈចំរុះ និងការគ្រប់គ្រងបរិស្ថាន ទៅក្នុងគោលនយោបាយ ផែនការអភិវឌ្ឍន៍ និងគោលការណ៍ណែនាំ ពាក់ព័ន្ធនឹងទេសចរណ៍ (ក្រ.ទច បស្ថ កសក និង វវស) (រួមទាំងការតំរូវឱ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានសំរាប់គំរោងអភិវឌ្ឍន៍ទេសចរណ៍) ។

៩.៣.២ កម្មវិធីអភិវឌ្ឍន៍ភូមិទេសចរណ៍ (ក្រ.ទច បស្ថ កសក និង វវស) (រួមបញ្ចូលទាំងការធ្វើសារពើភ័ណ្ឌបណ្តាគំរោងដែលមានសក្តានុពល គោលការណ៍ណែនាំសំរាប់ការអភិវឌ្ឍន៍អេកូទេសចរណ៍ និងយុទ្ធសាស្ត្រប្រើប្រាស់សហគមន៍មូលដ្ឋានសំរាប់អភិវឌ្ឍន៍ទេសចរណ៍) ។

៩.៣.៣ បញ្ចូលការអភិរក្សបេតិកភណ្ឌវប្បធម៌ និងធម្មជាតិ តាមរយៈកម្មវិធីអភិវឌ្ឍន៍ទេសចរណ៍នៅក្នុងតំបន់ នៅតំបន់ដែលបានកំណត់ជាតំបន់ការពារទេសភាពធម្មជាតិ (ក្រ.ទច បស្ថ និង វវស) ។

៩.៣.៤ កសាងផែនការមេថ្នាក់ជាតិ ដើម្បីជំរុញអេកូទេសចរណ៍នៅតាមតំបន់ការពារធម្មជាតិ ។ (ក្រ.បស្ថ ទច វជនស និង អជប) ។

## ប្រធានបទទី ១០ : សន្តិសុខបរិស្ថាន

**បរិបទ**

កម្ពុជាស្ថិតនៅក្នុងចំណោមប្រទេសទាំង ១៤ នៅទ្វីបអាស៊ី ដែលនាយកដ្ឋានកិច្ចការមនុស្សធម៌សហប្រជាជាតិ បានចាត់ទុកថា ជាប្រទេសដែលងាយទទួលរងគ្រោះមហន្តរាយ ។ គ្រោះមហន្តរាយធម្មជាតិ ដែលប្រទេសកម្ពុជាធ្លាប់ប្រឈមមុខ រួមមាន ទឹកជំនន់ ភាពរាំងស្ងួត ភ្លើងឆេះ ការរាតត្បាតនៃជំងឺគ្រុនចាញ់ អាសន្នរោគ និងជំងឺគ្រុនឈាម ។ គ្រោះមហន្តរាយដែលបង្កដោយមនុស្ស តាមរយៈសង្គ្រាម និងជំលោះក្នុងស្រុក ក្នុងអំឡុងពេល ៣០ ឆ្នាំកន្លងទៅនេះ បានបង្កឱ្យមានជនភៀសខ្លួន និងប្រជាជនដែលផ្លាស់ប្តូរទីលំនៅក្នុងស្រុកយ៉ាងច្រើន ។

បច្ចុប្បន្ន សុវត្ថិភាពនៅតែចោទជាបញ្ហាធ្ងន់ធ្ងរនៅឡើយ នៅក្នុងតំបន់ដែលមានមីនបង្កប់ក្នុងដី ។ ការគំរាមកំហែងចំបងចំពោះមនុស្ស និងសត្វព្រៃ គឺគ្រាប់មីនប្រឆាំងមនុស្ស ។ នៅក្នុងប្រទេស មានគ្រាប់មីនកប់ក្នុងដីប្រមាណ ៦-៩ លានគ្រាប់ ហើយយោងតាមរបាយការណ៍របស់ធនាគារពិភពលោក ឆ្នាំ ១៩៩៤ មីនទាំងនេះបានសំលាប់ ឬធ្វើឱ្យពិការមនុស្សប្រមាណ ១០០ នាក់ក្នុងមួយថ្ងៃ ។ លើសពីនេះ ការកាប់ឈើខុសច្បាប់ច្រើនតែកើតឡើងដោយមានការការពារប្រដាប់អាវុធ ។ ជារឿងគួរឱ្យហួសចិត្ត បញ្ហាអសន្តិសុខក្នុងប្រទេសបានជួយការពារជំរកធម្មជាតិមួយករិត ចាប់តាំងពីឆ្នាំ ១៩៨០ មក ។ នៅពេលនោះ គេពុំមានលទ្ធភាពបង្កើតកម្មវិធីអភិរក្ស នៅក្នុងតំបន់អសន្តិសុខនានាទេ ហើយជាមួយគ្នានេះ ការអភិវឌ្ឍន៍ទ្រង់ទ្រាយធំក៏មិនអាចប្រព្រឹត្តទៅបានដែរនៅក្នុងតំបន់ទាំងនោះ លើកលែងតែសកម្មភាពល្មើសច្បាប់ ។ នៅក្នុងដំណើររំសាយកងទ័ព រាជរដ្ឋាភិបាលបានប្រឹងប្រែងបង្កើនសន្តិសុខ និងកាត់បន្ថយសកម្មភាពល្មើសច្បាប់ ។

ការត្រួតពិនិត្យ និងបង្ការទឹកជំនន់ក៏ជាកង្វល់ទាក់ទិននឹងសន្តិសុខបរិស្ថានផងដែរ ។ ឧទាហរណ៍ នៅឆ្នាំ ២០០០ ទឹកជំនន់បានធ្វើឱ្យបាត់បង់ជីវិតមនុស្សចំនួន ៨០០ នាក់ និងបង្កទុក្ខលំបាកវេទនា ព្រមទាំងបានបំផ្លាញហេដ្ឋារចនាសម្ព័ន្ធភាគច្រើន ធ្វើឱ្យរាំងស្ទះសកម្មភាពសង្គម និងសេដ្ឋកិច្ច ធ្វើឱ្យបាត់បង់ដីកសិកម្ម និងដំណាំ ។ ដោយហេតុថា វិធានការបង្ការ និងស្តារការខូចខាតបណ្តាលពីទឹកជំនន់ អាចបង្កផលប៉ះពាល់ធ្ងន់ធ្ងរចំពោះជំរកធម្មជាតិ ការដាក់បញ្ចូលការគិតគូរពីជីវៈចំរុះ ទៅក្នុងផែនការទាំងនេះមានសារៈសំខាន់ណាស់ ។ ឧទាហរណ៍ ការសាងសង់ទំនប់ និងអាងស្តុកទឹក អាចកាត់បន្ថយផលិតភាពកសិកម្ម និងផលិតកម្មត្រីដោយសារការប្រែប្រួលរបបទឹកហូរ (សូមអានផ្នែកទី ៣) ។ ការកាប់បំផ្លាញព្រៃឈើអាចបង្កើនសំណឹកដី និងបាតុភូតទឹកជំនន់ភ្លាមៗ ។ ការដាំដើមឈើតាមច្រាំងទន្លេ និងការទប់ស្កាត់ការបាត់បង់ព្រៃឈើក្នុងទីជំរាល អាចជួយកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីគ្រោះទឹកជំនន់ សំណឹកដី និងការបាក់ដី ។ ដូចគ្នានេះដែរ ការអប់រំប្រជាជននៅជនបទអំពីបញ្ហាបរិស្ថាន អំពីរបៀបដាំដំណាំសមស្រប អំពីសុខភាព និងអនាម័យ អាចជួយកាត់បន្ថយគ្រោះថ្នាក់ពីការរាតត្បាតនៃជំងឺផ្សេងៗ ។

នៅខែមិថុនា ឆ្នាំ ១៩៩៩ ប្រទេសកម្ពុជាបានបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីលើកកំពស់ការគ្រប់គ្រងគ្រោះមហន្តរាយនៅទូទាំងប្រទេស តាមរយៈកិច្ចសហប្រតិបត្តិការជាមួយអង្គការ និងស្ថាប័នរដ្ឋាភិបាលមួយចំនួន ។ សកម្មភាពបច្ចុប្បន្នរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវតែនាំទៅរកការរៀបចំនូវយុទ្ធសាស្ត្រគ្រប់គ្រងគ្រោះមហន្តរាយដ៏ទូលំទូលាយមួយ ។

### បញ្ហាចំបង

- ការអភិវឌ្ឍន៍ធនធានធម្មជាតិត្រូវជួបឧបសគ្គដោយសារមីនបង្កប់ក្នុងដី និងបញ្ហាសន្តិសុខផ្សេងៗ ។
- ផលប៉ះពាល់អវិជ្ជមាននៃទឹកជំនន់ចំពោះធនធានជីវៈចំរុះ ។
- ខ្វះការយល់ដឹងពីវិធានការបង្ការគ្រោះមហន្តរាយ និងអំពីតួនាទីនៃជីវៈចំរុះ ។

### គោលដៅ

- ទប់ស្កាត់ហេតុប៉ះពាល់អវិជ្ជមាននៃគ្រោះមហន្តរាយចំពោះធនធានជីវៈចំរុះ តាមរយៈវិធានការបរិស្ថានសមស្រប ។
- បង្កើនសន្តិសុខក្នុងតំបន់ដែលមានសារៈសំខាន់ខាងផ្នែកជីវសាស្ត្រ ។

### គោលបំណងជាយុទ្ធសាស្ត្រ (*សន្ទស្សន៍បង្ហាញ*)

១០.១ បន្តបោសសំអាតមីននៅក្នុង និងនៅជុំវិញតំបន់ការពារធម្មជាតិ ( *ចំនួនគ្រាប់មីនដែលបានបំផ្លាញ* ) ។

១០.២ បញ្ចូលវិធានការការពារជីវៈចំរុះទៅក្នុងផែនការបង្ការទឹកជំនន់ និងផែនការស្តារការខូចខាតដោយសារទឹកជំនន់ ( *ចំនួនវិធានការដែលបញ្ចូលទៅក្នុងផែនការគ្រប់គ្រង* ) ។

### ជំរើសនានា

- ជំរុញការប្រើប្រាស់វិធានការបង្ការទឹកជំនន់ដែលមិនបង្កគ្រោះថ្នាក់ដល់ជីវៈចំរុះ ។
- បោសសំអាតដីមីនក្នុងតំបន់ការពារធម្មជាតិ ។
- យុទ្ធនាបង្កើនការយល់ដឹងជាសាធារណៈស្តីពីការបង្ការជំងឺរាតត្បាតផ្សេងៗ ។

### សកម្មភាពជាអាទិភាព (ស្ថាប័នសំរបសំរួល និងចូលរួមអនុវត្ត)

១០.១ រួមបញ្ចូលវិធានការការពារជីវៈចំរុះ ទៅក្នុងកម្មវិធីបង្កើនការយល់ដឹងអំពីវិធីបង្ការទឹកជំនន់ និងផែនការស្តារការខូចខាតបណ្តាលពីទឹកជំនន់ (គជគម បស្ក ធទខ កសក អជប វជនស និង ឧរថ) (ការដាំដើមឈើតាមមាត់ទន្លេ និងតាមជើងភ្នំទប់ស្កាត់ការបំផ្លាញឈើ ។ល។) ។

១០.២ ការអភិរក្ស និងជំរុញកិច្ចការពារបរិស្ថាន ជីវៈចំរុះ និងអេកូឡូស៊ីគឺជាប្រការសំខាន់បំផុត ។ ក្របខ័ណ្ឌសំរាប់ការងារនេះរួមមានសកម្មភាពនានាដូចខាងក្រោម :

- បង្កើតមជ្ឈមណ្ឌលទិន្នន័យបរិស្ថាន និងធនធានធម្មជាតិ ។
- បង្កើតយន្តការទូលំទូលាយសំរាប់តាមដានគុណភាពទឹក ដោយរួមបញ្ចូលទាំងវិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ទៅក្នុងយន្តការនេះ ។
- បង្កើត និងដាក់ឱ្យអនុវត្តនូវស្តង់ដាគុណភាពទឹក និងការបញ្ចេញចោលទឹកសំអុយ ។

- ធ្វើការសំអាតប្រភពទឹកដែលបានរងការបំពុល ។
- បញ្ចូលយុទ្ធសាស្ត្របង្ការជាមុនទៅក្នុងសកម្មភាពទាំងអស់នៃសង្គម ដើម្បីកាត់បន្ថយការបំពុលប្រភពទឹកក្នុងធម្មជាតិ ។ យុទ្ធសាស្ត្រនេះត្រូវយកទៅអនុវត្តនៅក្នុងផលិតកម្ម ការប្រើប្រាស់ ការអប់រំ ការស្រាវជ្រាវ ការអភិវឌ្ឍន៍សាធារណៈការ ទំនាក់ទំនងពិតមាន ការគ្រប់គ្រងសំណល់ ។ល។ (គជគម ក្រ.បស្ថ ធទឱ កសក អជប វជនស និង ឱវថ) ។

១០.៣ ធ្វើឱ្យមានសន្តិសុខបរិស្ថាន សំរាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹក និងជីវៈចំរុះតាមបែបសមាហរណកម្ម (គជគម ក្រ.បស្ថ ធទឱ កសក អជប វជនស និង ឱវថ) (រួមទាំង ការកសាង និងអនុម័តគោលនយោបាយស៊ីសង្វាក់គ្នាសំរាប់វិស័យធនធានទឹកទូទាំងប្រទេស ដែលមានទាំងការប្រើប្រាស់ធនធានទឹក និងការធ្វើផែនការអភិវឌ្ឍន៍ធនធានទឹក វិធានការសេដ្ឋកិច្ចសំរាប់ការគ្រប់គ្រងធនធានទឹក ការបង្កើតតំបន់ការពារធម្មជាតិ ការសំរបសំរួលអន្តរស្ថាប័ន វិធានការបង្ការទឹកជំនន់ ការគ្រប់គ្រងទីជំរាល និងពិន័យ) ។

១០.៤ ទប់ស្កាត់ការខូចខាតដោយសារទឹកជំនន់ ភាពរាំងស្ងួត ការបំផ្លិចបំផ្លាញទីជំរាល សំណឹកដី និងកំណកំទេច ដើម្បីការពារធនធានក្នុងទឹក មច្ឆាជាតិ និងជីវៈចំរុះផ្សេងទៀត (ក្រ.ធទឱ ឱវថ និង បស្ថ) (រួមទាំង សកម្មភាពសាងសង់ ឬជួសជុលរបាំងការពារច្រាំងទន្លេ ទំនប់ សំណង់អាងស្តុកទឹក. ហាមឃាត់ឬតំរូវឱ្យមានការសុំអាជ្ញាប័ណ្ណពាក់ព័ន្ធនឹងសកម្មភាពលុបអាងទឹក សកម្មភាពធ្វើឱ្យប្រែប្រួលរបបទឹកហូរឬការបង្ហូរទឹកចេញ និងការហាមឃាត់សកម្មភាពយកខ្សាច់ពីបាត និងច្រាំងនៃប្រភពទឹកនានា ព្រមទាំងការជំរុញឱ្យសហគមន៍ចូលរួមក្នុងសកម្មភាពដែលជាទិសដៅក្នុងកិច្ចការពារជីវៈចំរុះ និងការប្រើប្រាស់ប្រភពធនធានធម្មជាតិក្នុងទីជំរាលប្រកបដោយនិរន្តរភាព) ។

# ប្រធានបទទី ១១ : ការធ្វើផែនការប្រើប្រាស់ដីធ្លី

## បរិបទ

សកម្មភាពមនុស្សតែងកែប្រែ និងជះឥទ្ធិពលដល់ស្ថានភាពដីធ្លី និងទេសភាពធម្មជាតិ ។ ការស្ថាបនាទីក្រុង ភូមិ ផ្លូវ និងការបង្កើតស្រះ ការឈូសឆាយទំនប់ ព្រែកជីក គឺជាការកែប្រែដែលឃើញច្បាស់ជាងគេ ។ ការប្រើប្រាស់ដីធ្លី និងការធ្វើសេចក្តីសំរេចអំពីការប្រើប្រាស់ដីធ្លីជាប្រការសំខាន់ណាស់ ដោយសារសេចក្តីសំរេចភាគច្រើនមិនអាចត្រូវកែប្រែបាន ហើយអាចមានផលវិបាកដល់មនុស្សជំនាន់ក្រោយ ។

នៅកម្ពុជា ការកាន់កាប់ដីធ្លីបានធ្វើឡើងតាមច្បាប់ភូមិបាលឆ្នាំ ១៩៩២ ។ ច្បាប់ភូមិបាលថ្មីត្រូវបានសភាជាតិអនុម័ត និងប្រកាសឱ្យប្រើប្រាស់នៅឆ្នាំ២០០១។ យោងតាមរដ្ឋធម្មនុញ្ញ ប្រជាជនកម្ពុជាមានសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ និងមានសិទ្ធិពេញលេញជាម្ចាស់កម្មសិទ្ធិ និងប្រើប្រាស់ដីធ្លី សំរាប់សង់ផ្ទះ និងការដាំដុះ ។ ដីសម្បទាន គឺជាដីដែលមានទំហំធំជាងប្រាំហិចតា ហើយដែលត្រូវបាន អនុញ្ញាតឱ្យប្រើប្រាស់សំរាប់ផលិតកម្មដំណាំ" សំរាប់ទ្រទ្រង់សេដ្ឋកិច្ចជាតិ" ។ ទស្សនៈនេះត្រូវបានពង្រីកជាបន្ថែមនៅក្នុងច្បាប់ភូមិបាលថ្មី ដែលរួមមានកម្មសិទ្ធិរដ្ឋ កម្មសិទ្ធិឯកជន និងកម្មសិទ្ធិសាធារណៈ ។

នៅប្រទេសកម្ពុជា បញ្ហាមួយដែលពាក់ព័ន្ធនឹងដីធ្លី គឺការណ៍ដែលកសិករមួយចំនួនតូចកាន់កាប់ដីធ្លី ដែលពួកគេកំពុងរស់នៅ និងប្រកបការងារ ប៉ុន្តែជាក់ស្តែងជាញឹកញាប់អាទិភាពត្រូវបានផ្តល់សំរាប់ការអភិវឌ្ឍន៍មុខជំនួញទៅវិញ ។ កង្វល់ផ្សេងទៀតគឺការទន្ទ្រានយកតំបន់ដីសើម និងដីព្រៃ សំរាប់ការអភិវឌ្ឍន៍កសិកម្ម តាំងទីលំនៅ ជីកជញ្ជូន ឬឧស្សាហកម្ម ដោយពុំបានពិចារណាពីការខូចខាតផលប្រយោជន៍ ដែលអាចបានពីការរក្សាទុកប្រព័ន្ធដី និងជីវៈចំរុះ សំរាប់ពេលអនាគត ។ អវត្តមានក្របខ័ណ្ឌគោលនយោបាយប្រើប្រាស់ដីធ្លី ភាពទន់ខ្សោយនៃការសំរបសំរួលអន្តរក្រសួង និងនាយកដ្ឋាន ដែលពាក់ពន្ធ័នឹងការអភិវឌ្ឍន៍ធនធានធម្មជាតិ និងការប្រើប្រាស់ដីធ្លី ព្រមទាំងកង្វះខាតពតិមានជាក់លាក់ សំរាប់ណែនាំការបែងចែកដីធ្លីសំរាប់ប្រើប្រាស់ ក៏ជាបញ្ហាចំបងផងដែរដែលរាជរដ្ឋាភិបាលកំពុងជួបប្រទះ ។ ស្ថាប័នរដ្ឋាភិបាលក៏មានកង្វះខាតជំនាញក្នុងផ្នែកនេះដែរ ។

ដើម្បីប្រើប្រាស់ធនធានដីធ្លីឱ្យបានសមស្រប រាជរដ្ឋាភិបាលបានចាប់ផ្តើមគិតគូរអំពីការខាតបង់ខាងផ្នែកសង្គម បរិស្ថាន និងសេដ្ឋកិច្ច នៅពេលដែលពិនិត្យអំពីផលចំណេញនៃការអភិវឌ្ឍន៍ដីថ្មីនៅទីតាំងណាមួយ ។ រាល់ការអភិវឌ្ឍន៍ថ្មី គួរតែធានាផងដែរនូវភាពស្រុះស្រួលនៃការបែងចែកដីធ្លីសំរាប់ប្រើប្រាស់ ជាមួយសហគមន៍មូលដ្ឋាន ដែលកំពុងប្រើប្រាស់ដោយផ្ទាល់ ឬដែលត្រូវការចំណែកដីនោះសំរាប់ប្រើប្រាស់ដោយប្រយោលផងដែរ ។

## បញ្ហាចំបង

- ការពង្រីកគំរោងអភិវឌ្ឍន៍ ដែលធ្វើឱ្យបាត់បង់ដីធ្លីធ្វើកសិកម្មបាន និងជំរកធម្មជាតិ (ជាពិសេសតំបន់ដីសើម) ។
- ខ្វះក្របខ័ណ្ឌគោលនយោបាយ និងពតិមានជាក់លាក់ សំរាប់ណែនាំការបែងចែកការប្រើប្រាស់ដី ។
- ខ្វះសមត្ថភាពធ្វើផែនការប្រើប្រាស់ដីធ្លីប្រកបដោយប្រសិទ្ធិភាព ។
- តួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នមិនច្បាស់លាស់ ។

គោលដៅ

ធានាឱ្យមានកិច្ចការពារ និងប្រើប្រាស់ដោយនិរន្តរភាព នូវដីធ្លីដែលសំបូរដោយជីវៈចំរុះនៅក្នុងផែនការប្រើប្រាស់ដីធ្លី ។

គោលបំណងជាយុទ្ធសាស្ត្រ (*សន្ទស្សន៍បង្ហាញ*)

១១.១ ពង្រឹងសមត្ថភាពស្ថាប័នក្នុងការកសាងផែនការប្រើប្រាស់ និងការគ្រប់គ្រងដីធ្លី (*ចំនួនបុគ្គលិកបានបណ្តុះបណ្តាល*) ។

១១.២ កសាងផែនការមេស្តីពីការប្រើប្រាស់ដីធ្លីថ្នាក់ជាតិ និងថ្នាក់ខេត្ត ដោយមានការពិចារណាពេញលេញអំពីបញ្ហាបរិស្ថាន នៅក្នុងដំណើរការកសាងផែនការសេដ្ឋកិច្ច-សង្គម និងកំណត់ជំរើសផ្សេង និងអាទិភាព (*ចំនួនផែនការប្រើប្រាស់ដីធ្លីដែលបានរៀបចំ*) ។

ជំរើសនានា

- ចែងឱ្យច្បាស់ពីការទទួលខុសត្រូវ និងភារកិច្ចនៃស្ថាប័ន ដែលពាក់ពន្ធ័នឹងការកសាងផែនការប្រើប្រាស់ដី និងគ្រប់គ្រង ដូចមានចែងនៅក្នុងច្បាប់ ។
- កំណត់អាទិភាព និងបង្កើតយន្តការច្បាស់លាស់ សំរាប់ការកសាងផែនការប្រើប្រាស់ដីធ្លី ដើម្បីកែលំអការសំរបសំរួល និងកិច្ចសហប្រតិបត្តិការអន្តរស្ថាប័ន និងដើម្បីជៀសវាងការត្រួតភារកិច្ចគ្នា ក្នុងដំណើរការអនុវត្តសកម្មភាព ដែលពាក់ព័ន្ធនឹងការបែងចែក និងការប្រើប្រាស់ដីធ្លី ។
- បង្កើតគណៈកម្មាធិការអន្តរក្រសួង សំរាប់ដឹកនាំការកសាងផែនការប្រើប្រាស់ដីធ្លី ។
- បណ្តុះបណ្តាលអំពីការធ្វើផែនការប្រើប្រាស់ដីធ្លី ។
- រៀបចំគោលការណ៍ណែនាំបច្ចេកទេស សំរាប់ការធ្វើផែនការប្រើប្រាស់ដីធ្លី ។
- ប្រមូល និងវិភាគពត៌មាន និងទិន្នន័យដែលមានស្រាប់ ពីស្ថាប័នពាក់ពន្ធ័ និងពីអាជ្ញាធរមូលដ្ឋាន ។
- កសាង និងជំរុញយន្តការ គោលការណ៍ និងការណែនាំ សំរាប់ដោះស្រាយទំនាស់នៃការប្រើប្រាស់ដីធ្លី ។
- រៀបចំបទបញ្ជា និងគោលការណ៍ណែនាំ សំរាប់ការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធិភាព ។
- អភិវឌ្ឍន៍ធនធានមនុស្ស សំរាប់ការអនុវត្តន៍ឱ្យមានប្រសិទ្ធិភាព នូវផែនការប្រើប្រាស់ដីធ្លី ច្បាប់ បទបញ្ជា និងគោលការណ៍ណែនាំ ។
- លើកកំពស់ការអប់រំ និងបង្កើនការយល់ដឹងអំពីច្បាប់ និងសារាចរដែលមានបច្ចុប្បន្ន ។
- តាមដាន និងវាយតំលៃការអនុវត្តន៍ច្បាប់ បទបញ្ជា និងគោលការណ៍ណែនាំពាក់ព័ន្ធនឹងជីវៈចំរុះ ។
- នីតិវិធីនៃការអនុវត្តន៍ច្បាប់ ។
- ផ្តល់ការអប់រំនៅមូលដ្ឋាន និងផ្សព្វផ្សាយពីសារៈសំខាន់នៃការកសាងផែនការប្រើប្រាស់ដីធ្លី ។
- ផ្តល់សិទ្ធិ និងឱកាសដល់ប្រជាជនមូលដ្ឋាន ក្នុងការផ្តល់យោបល់ចំពោះការកសាងផែនការប្រើប្រាស់ដីក្នុងសហគមន៍ មូលដ្ឋានរបស់គេ ។

- ជំរុញការអនុវត្តន៍ផែនការប្រើប្រាស់ដីដោយសហគមន៍ អនុលោមតាមគោលការណ៍ណែនាំ ។
- កសាងគោលយោបាយប្រើប្រាស់ដីធ្លី ដែលមានរួមបញ្ចូលតំបន់ទ្រនាប់ជុំវិញតំបន់ទេសចរណ៍ ។
- តាមដានត្រួតពិនិត្យការពង្រីកដីសំរាប់ការអភិវឌ្ឍន៍ ទៅក្នុងតំបន់ដីកសិកម្ម តំបន់ដីសើម និងព្រៃឈើ ។
- ជំរុញឱ្យមានការធ្វើផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួមពីភាគីពាក់ព័ន្ធ ។

សកម្មភាពជាអាទិភាព (ស្ថាប័នសំរបសំរួល និងចូលរួមអនុវត្ត)

១១.១ កម្មវិធីពង្រឹងសមត្ថភាពស្ថាប័នពាក់ព័ន្ធនឹងការកសាងផែនការប្រើប្រាស់ដីធ្លី (ក្រ.រដនស អជប កសក និង ឧរថ) (រួមមានទាំង សៀវភៅណែនាំស្តីពីការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី រៀបរៀងដោយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់) ។

១១.២ ការកសាងផែនការមេអំពីការប្រើប្រាស់ដីធ្លីថ្នាក់ជាតិ និងផែនការប្រើប្រាស់ដីធ្លីថ្នាក់ខេត្ត ដោយមានរួមបញ្ចូលការគិតគូរពីបញ្ហាបរិស្ថាន និងការពិគ្រោះយោបល់ជាមួយសហគមន៍ (ក្រ.រដនស អជប ផក បស្ថ កសក និង ឧរថ) ។

១១.៣ ការកសាងផែនការប្រើប្រាស់ដីធ្លីតាមសហគមន៍មូលដ្ឋាន (ក្រ.រដនស អជប ផក បស្ថ និងកសក) (រួមមានទាំងសៀវភៅណែនាំស្តីពីការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លីរៀបចំដោយក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់) ។

# ប្រធានបទទី ១២ : ធនធានទឹក

## បរិបទ

ប្រទេសកម្ពុជា ដែលមានទីតាំងនៅភាគខាងក្រោមនៃអាងទន្លេមេគង្គ ត្រូវបានគេចាត់ទុកជាប្រទេសដែលសំបូរទឹក ។ បើគិតពីលទ្ធភាពអាចយកទឹកមកប្រើប្រាស់ប្រចាំឆ្នាំក្នុងមនុស្សម្នាក់ៗ ដែលអាចមានដល់ ៥០.០០០ ម៣ ធនធានទឹកសរុបក្នុងប្រទេសកម្ពុជាឈរក្នុងលំដាប់ទី ៣ ក្នុងចំណោមបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ ។ ប៉ុន្តែ នេះគ្រាន់តែជាតំលៃមធ្យមភាគតែប៉ុណ្ណោះ ។ ដោយសារតែរដូវប្រាំងមានរយៈពេលវែង ប្រជាជនភាគច្រើនជួបប្រទះការខ្វះទឹកតាមរដូវ បណ្តាលឱ្យមានការលំបាកក្នុងការផ្គត់ផ្គង់ទឹកសំរាប់ប្រើប្រាស់ បញ្ហាអនាម័យ និងបញ្ហាផលិតកម្មស្បៀង ។ ជាមួយគ្នានេះ ការបំពុលដោយសំណល់ពីមនុស្ស ឬការចិញ្ចឹមសត្វ ការប្រើប្រាស់ជីគីមី ថ្នាំសំលាប់សត្វចង្រៃនៅក្នុងផលិតកម្មកសិកម្ម និងការបញ្ចេញសំណល់ពីឧស្សាហកម្មនានាបានដាក់សម្ពាធទៅលើធនធានទឹក ធនធានជលផល និងប្រព័ន្ធអេកូឡូស៊ីមជ្ឈដ្ឋានទឹក ។

ការសាងសង់ទំនប់ ផ្លូវទឹកសំរាប់នាវាចរណ៍ ប្រព័ន្ធស្រោចស្រព ប្រព័ន្ធប្រឡាយយកទឹកពីទន្លេ ការបង្វែរផ្លូវទឹក ការសង់ផ្លូវថ្នល់កាត់ផ្លូវទឹក អាចកាត់បន្ថយផលិតភាពត្រី និងកសិកម្ម ដោយសារធ្វើឱ្យមានការផ្លាស់ប្តូរបរិមាណកំទេចកំទរ លំហូរសារធាតុចិញ្ចឹម និងចរាចរត្រី ។ ដូចគ្នានេះដែរ ការរេចរឹលនៅតាមច្រាំងទន្លេ មាត់បឹង និងតំបន់តាមដងទន្លេ ក៏នាំឱ្យខូចគុណភាពទឹកផងដែរ ។

## បញ្ហាចំបង

- ការបំពុលបណ្តាលមកពីសកម្មភាពកសិកម្ម ឧស្សាហកម្ម និង សកម្មភាពនានាផ្សេងទៀត ។
- ការប៉ះពាល់អវិជ្ជមានចំពោះផលិតភាពត្រី និងកសិកម្ម បណ្តាលមកពីការសាងសង់ទំនប់ ការសាងសង់កំពង់ផែ ការស្តារផ្លូវទឹកសំរាប់នាវាចរណ៍ ប្រព័ន្ធស្រោចស្រព ការជីកប្រឡាយយកទឹកពីទន្លេ និងការបង្វែរផ្លូវទឹក ។
- ការបាក់រេចរឹលច្រាំងទន្លេ និងតំបន់តាមដងទន្លេ ។

## គោលដៅ

ធានាកុំឱ្យមានការបំពុលទឹក និងគាំទ្រផលិតភាពនៃធនធានជលផល និងប្រព័ន្ធអេកូឡូស៊ីមជ្ឈដ្ឋានទឹក ។

## គោលបំណងជាយុទ្ធសាស្ត្រ (*សន្ទស្សន៍បង្ហាញ*)

១២.១ អនុវត្តយ៉ាងតឹងរ៉ឹង នូវបរិធានច្បាប់ស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងវិធានការសំរាលហេតុប៉ះពាល់បណ្តាលមកពីគំរោងអភិវឌ្ឍន៍ធនធានទឹក និងគំរោងផ្សេងទៀត ដែលអាចមានការប៉ះពាល់ដល់ធនធានទឹក (*ចំនួនគំរោងដាក់ជូនសំរាប់ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន*) ។

១២.២ រក្សានូវចរន្តទឹកហូរ និងធារទឹកក្នុងបឹង ក្នុងកំរិតសមស្រប ដើម្បីការពារបរិស្ថាន និងជលផល (*ចំនួនថ្ងៃដែលកម្រិតទឹកទាបជាងអត្រាអប្បបរិមាសមស្រប*) ។

១២.៣ ថែងឱ្យបានគ្រប់គ្រាន់អំពីការមិនបង្កឧបសគ្គចំពោះចរាចរត្រី នៅក្នុងគំរោងអភិវឌ្ឍន៍ធនធានទឹក និងផ្លូវទឹក ( *ចំនួនគំរោងដែលមានថែងអំពីប្រការទាំងនេះ* ) ។

១២.៤ ទប់ស្កាត់ការបំពុលទឹកពីគ្រប់ប្រភព ( *ទិន្នន័យគុណភាពទឹក* ) ។

១២.៥ ធានាឱ្យមានការការពារច្រាំងទន្លេ មាត់បឹង និងតំបន់តាមដងទន្លេ ( *ប្រវែងសរុបនៃច្រាំងទន្លេ និងមាត់បឹងដែលបានការពារ* ) ។

ជំរើសនានា

- វាយតំលៃឱ្យបានច្បាស់ពីគុណសម្បត្តិ និងគុណវិបត្តិនៃទំនប់ ប្រព័ន្ធស្រោចស្រព និងសំណង់ការពារទឹកជំនន់ផ្សេងៗ និងបន្ថយល្បឿនការសាងសង់ទំនប់ថ្មី រហូតដល់បានបញ្ចប់ការសិក្សាបែបនេះ ។
- ធ្វើប្រព្រឹត្តកម្មសំអាតទឹកល្វសំអុយមុនពេលបង្ហូរចោល ។
- សាងសង់ប្រព័ន្ធស្រះប្រព្រឹត្តកម្មសំអាតទឹកល្វសំអុយ ។
- កសាងមន្ទីរពិសោធន៍សំរាប់វិភាគគុណភាពទឹក ។
- សិក្សាតាមដានជាប្រចាំនូវកំពស់ទឹក និងបង្កើតជាបន្ថែម និងស្តារស្ថានីយ៍ឧតុនិយម និងជលសាស្ត្រ ។
- ជំរុញការគាំទ្ររបស់រាជរដ្ឋាភិបាលដល់ការប្រើប្រាស់បច្ចេកទេសប្រព័ន្ធស្រោចស្រព និងការត្រួតពិនិត្យទឹកជំនន់ ប្រកបដោយការទទួលខុសត្រូវក្នុងផ្នែកបរិស្ថាន ដោយផ្អែកលើបណ្តាអាទិភាព ដែលឆ្លុះបញ្ចាំងពីស្ថានភាពទឹកនៃតំបន់នានាក្នុងព្រះរាជាណាចក្រកម្ពុជា ។
- ពង្រីកកម្មវិធីបង្កើនការយល់ដឹងដល់កសិករអំពីបច្ចេកវិទ្យាស្រោចស្រពទំនើប និងការការពារតំបន់តាមដងទន្លេ និងសំរាប់បង្កើនការយល់ដឹងដល់ប្រជាជនតាមទីប្រជុំជន អំពីសកម្មភាពការពារគុណភាពទឹក ។
- បណ្តុះបណ្តាលកសិករឱ្យយល់ដឹងពីការប្រើប្រាស់ជីគីមី និងថ្នាំសំលាប់សត្វល្អិតសមស្រប ។

សកម្មភាពជាអាទិភាព ( ស្ថាប័នសំរបសំរួល និងចូលរួមអនុវត្ត )

១២.១ កម្មវិធីគ្រប់គ្រងធនធានទឹក ( ក្រ.ធទឧ ) ។

១២.២ កម្មវិធីធ្វើឱ្យប្រសើរឡើងវិញនូវគុណភាពទឹកសាធារណៈ ទៅតាមតំរូវការរបស់អ្នកប្រើប្រាស់ទឹកនាពេលបច្ចុប្បន្ន និងអនាគត និងធានាលទ្ធភាពប្រភពទឹកក្នុងការទ្រទ្រង់ជីវៈចំរុះ និងមច្ឆាជាតិ ដើម្បីការពារសុខមាលភាពរបស់មនុស្ស និងសត្វ ( ក្រ.ធទឧ បស្ថ កសក និង ឧរថ ) ។

១២.៣ កម្មវិធីធានានិរន្តរភាពហិរញ្ញវត្ថុសំរាប់ជួលជុលហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រដែលរួមមានការណែនាំសហគមន៍ប្រើប្រាស់ទឹក ថែទាំ ជួសជុល និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធដែលបានសាងសង់ថ្មី ដើម្បីជំរុញផ្នែកកសិកម្មឱ្យប្រសើរឡើង ( ក្រ.ធទឧ កសក បស្ថ និងឧរថ ) ។

១២.៤ កម្មវិធីត្រួតពិនិត្យធនធានទឹកក្រោមដី ( ក្រ.ធទឧ អជប បស្ថ កសក និង សខភ) ដែលរួមមាន កម្មវិធីពិនិត្យគុណភាពទឹកក្រោមដី ការបូមទឹកក្រោមដីដើម្បីកំណត់ធារទឹកក្រោមដី នីវ៉ូទឹកក្រោមដី ចរន្តទឹកក្រោមដី ការថែរក្សាធនធានទឹកក្រោមដី និងការអភិវឌ្ឍន៍ទឹកក្រោមដី ដើម្បីធ្វើម៉ូដែល និងផែនទីទឹកក្រោមដី ។

១២.៥ កម្មវិធីបង្ការការបំពុលទឹកពីវិស័យឧស្សាហកម្ម ( ក្រ.បស្ថ ធទឧ និង ឧរថ) រួមបញ្ចូលបទបញ្ញត្តិសំរាប់ការបង្ហូរទឹកភ្លៀង ការគ្រប់គ្រងសំណល់រាវ និងការចេញអាជ្ញាប័ណ្ណសំរាប់បញ្ចេលចោល និងធ្វើប្រព្រឹត្តកម្មសំណល់រាវ និងការផ្ទេរបច្ចេកវិទ្យា ។

១២.៦ កម្មវិធីបង្កាការបំពុលទឹកពីវិស័យកសិកម្ម ( ក្រ.កសក បស្ថ និង ធទឧ) (រួមទាំងការការពារមាត់បឹង ច្រាំងទន្លេ និងដាំព្រៃឈើឡើងវិញ ការណែនាំអំពីការបន្ថយការប្រើប្រាស់ជីគីមីកសិកម្ម កម្មវិធីអប់រំសហគមន៍អំពីការសន្សំសំចៃ និងការប្រើប្រាស់ជីគីមីកសិកម្ម ដែលអាចបង្កផលប៉ះពាល់តិច ) ។

១២.៧ កម្មវិធីប្រព្រឹត្តកម្មសំអាតទឹកកខ្វក់ពីទីក្រុង ( អាជ្ញាធរដែនដី ក្រ. បស្ថ ធទឧ រដនស និង ឧរថ) (រួមទាំងការដាក់ប្រព័ន្ធបំពង់លូបង្ហូរទឹកសំអុយតាមតំបន់ទីប្រជុំជន និងការរៀបចំប្រព័ន្ធសំអាតទឹកសំរាប់សហគមន៍ និងតាមគ្រួសារ) ។

## ប្រធានបទទី ១៣ : ការប្រែប្រួលអាកាសធាតុ និងជីវៈចម្រុះ

### បរិបទ

ដោយសារតែកំនើនកំដៅពិភពលោក នីវ៉ូទឹកសមុទ្របានកើនឡើងជាមធ្យមប្រមាណ ១០-២៥ ស.ម ខ្ពស់ជាងកាលពី ១០០ ឆ្នាំមុន ។ ម៉ូដែលនានាបានព្យាករណ៍ថា រហូតដល់ឆ្នាំ ២១០០ នីវ៉ូទឹកសមុទ្រអាចនឹងកើនឡើង ១៥-៩៥ ស.មថែមទៀត ។ បាតុភូតនេះអាចនឹងកើតឡើង ដោយសារតែការរីកមាឌនៃទឹកមហាសមុទ្រនៅពេលឡើងកំដៅ និងការហូរចូលនៃទឹកសាបដោយសារការលាយទឹកកក ។ ទោះបីកត្តាធម្មជាតិមានចំណែកក្នុងការធ្វើឱ្យកើនកំដៅក្តី មានភ័ស្តុតាងបង្ហាញថា ការបញ្ចេញចោលនូវឧស្ម័នកាបូនិច និងឧស្ម័នផ្ទះកញ្ចក់មួយចំនួនទៀតដោយសារសកម្មភាពរបស់មនុស្ស បានបង្កើនសំទុះនៃបាតុភូតនេះ ។

គេរំពឹងថា ឥទ្ធិពលនៃការកើនឡើងកំដៅពិភពលោកនឹងបង្កមហន្តរាយដល់តំបន់ឆ្នេរ និងទំនាបលិចទឹក ។ នៅពេលនីវ៉ូទឹកសមុទ្រកើនឡើង ការជន់លិច និងការហូរច្រោះតាមតំបន់ឆ្នេរនឹងមានកំរិតកាន់តែធ្ងន់ធ្ងរ ដែលបង្កឥទ្ធិពលអាក្រក់ចំពោះផ្នែកកសិកម្ម ជលផល និងវារីវប្បកម្ម ។ វិស័យដទៃទៀតដែលងាយប្រឈមគ្រោះថ្នាក់រួមមាន ទេសចរណ៍ ការតាំងទីលំនៅ និងហេដ្ឋារចនាសម្ព័ន្ធ ។ កំនើននីវ៉ូទឹកសមុទ្រអាចធ្វើឱ្យលិចលង់តំបន់ទំនាបភាគច្រើនលើពិភពលោក បង្កមហន្តរាយចំពោះដីដាំដំណាំ និងធ្វើឱ្យប្រជាជនរាប់លាននាក់ ក្នុងសហគមន៍តំបន់ឆ្នេរ និងកោះតូចៗ ត្រូវផ្លាស់ទីលំនៅ ។ កំនើនជាមធ្យមនៃសីតុណ្ហភាពនឹងធ្វើឱ្យមានការផ្លាស់ប្តូររបបទឹកភ្លៀង ដែលនឹងនាំឱ្យមានការប្រែប្រួលសមាសភាព និងរចនាសម្ព័ន្ធនៃប្រព័ន្ធអេកូឡូស៊ី ក៏ដូចជាចំពោះរបាយ និងភាពសំបូរបែបនៃប្រភេទសត្វ និងរុក្ខជាតិ ។

ប្រព័ន្ធអេកូប្រទេសកម្ពុជា ដែលរួមមាន តំបន់ឆ្នេរ តំបន់ដីសើម និងតំបន់កសិកម្ម រួមទាំងតំបន់ភ្នំ និងព្រៃឈើ ងាយនឹងប្រឈមគ្រោះថ្នាក់ បណ្តាលពីផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ។ ដោយហេតុថា សេដ្ឋកិច្ចប្រទេសកម្ពុជាពឹងផ្អែកជាសំខាន់លើវិស័យកសិកម្ម និងជីវៈចំរុះ ក្រោមរូបភាពជាធនធានធម្មជាតិ ប្រទេសកម្ពុជាងាយប្រឈមនឹងគ្រោះថ្នាក់ដោយសារផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ។

ក្នុងនាមជាប្រទេសហត្ថលេខីនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ កម្ពុជាកំពុងរៀបចំរបាយការណ៍ជាតិលើកទី ១ របស់ខ្លួន សំរាប់ដាក់ជូនសន្និសីទនៃបណ្តាភាគី ។ បច្ចុប្បន្នកម្ពុជាកំពុងរៀបចំផែនការសកម្មភាពជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលរួមមានទាំងបណ្តាវិធានការកាត់បន្ថយ និងបន្សុំានានាផងដែរ ។ វិធានការទាំងនេះ ត្រូវផ្អែកលើការវិភាគលើបណ្តាជំរើសកាត់បន្ថយការបញ្ចេញផ្ទះកញ្ចក់ និងការវាយតំលៃភាពងាយរងគ្រោះ និងបន្សុំា នៅក្នុងវិស័យសំខាន់ៗ ដូចជា កសិកម្ម ការប្រែប្រួលក្នុងការប្រើប្រាស់ដី និងព្រៃឈើ និងតំបន់ឆ្នេរ ។

ក្រៅពីផលប៉ះពាល់ ដែលអាចកើតមានចំពោះជីវៈចំរុះ បណ្តាលពីការប្រែប្រួលអាកាសធាតុ (កំនើននីវ៉ូទឹកសមុទ្រ កំនើនសីតុណ្ហភាព បំរែបំរួលកំពស់ទឹកភ្លៀង ភាពតានតឹងនៃធាតុអាកាស) វិធានការកាត់បន្ថយផលប៉ះពាល់ និងវិធានការបន្សុំា ដែលត្រូវយកទៅអនុវត្ត ក៏អាចនឹងបង្កហេតុប៉ះពាល់ចំពោះជីវៈចំរុះផងដែរ ។ វិធានការមួយ ក្នុងចំណោមបណ្តាវិធានការកាត់បន្ថយផលប៉ះពាល់ គឺការបង្កើតអាងផ្ទុកកាបូន តាមរយៈការដាំប្រភេទឈើដែលលូតលាស់រហ័ស ឬការបង្កើតព្រៃ[illegible] ផល វិជ្ជមានដល់ជីវៈចំរុះ ប្រសិនបើប្រភេទ និងតំបន់ដែលកំណត់សំរាប់ចាត់វិធានការទាំងនោះ ត្រូវបាន[illegible]ដោយប្រុងប្រយ័ត្ន ។ ដូចគ្នានេះដែរ ចំពោះវិធានការទប់ស្កាត់កំនើននីវ៉ូទឹកសមុទ្រ និងទឹកជំនន់ ដែលរួមមានការសាងសង់[illegible]

ផ្នែកខ្សាច់ ឡើងវិញ ការបង្កើតតំបន់ដីសើម និងបទបញ្ញត្តិគ្រប់គ្រងការអភិវឌ្ឍន៍ថ្មី១នៅតាមតំបន់ឆ្នេរ ចាំបាច់ត្រូវពិនិត្យផងដែរលើហេតុប៉ះ ពាល់ ដែលអាចកើតឡើង ចំពោះប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ជលផល និងផលិកម្មកសិកម្ម ។

បញ្ហាចំបង

- ផលប៉ះពាល់ដែលអាចកើតឡើងចំពោះជីវៈចំរុះ បណ្តាលពីកំនើននីវ៉ូទឹកសមុទ្រ កំនើនសីតុណ្ហភាព និងការប្រែប្រួលកំពស់ទឹកភ្លៀង (សមាសភាព របាយ អត្រារស់រានមានជីវិត ។ល។) ។
- ផលប៉ះពាល់ដែលអាចកើតឡើងចំពោះជីវៈចំរុះ បណ្តាលមកពីវិធានការកាត់បន្ថយគ្រោះថ្នាក់ពីការប្រែប្រួលអាកាសធាតុ ឬវិធានការបន្សាំ ។
- ប្រទេសជឿនលឿនជាអ្នកបញ្ចេញច្រើនជាងគេនូវឧស្ម័នដែលបង្កឱ្យមានការប្រែប្រួលអាកាសធាតុ ។

គោលដៅ

- កំណត់វិធានការឆ្លើយតប (ទាំងវិធានការកាត់បន្ថយ និងបន្សាំ) ដើម្បីកាត់បន្ថយផលប៉ះពាល់ដល់ធនធានជីវសាស្ត្រ ។
- វាយតំលៃវិធានការកាត់បន្ថយគ្រោះថ្នាក់ និងបន្សាំ ដើម្បីទប់ស្កាត់ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើជីវៈចំរុះ ។
- ធ្វើការបញ្ចុះបញ្ចូលដល់អន្តរជាតិ ឱ្យកាត់បន្ថយការបញ្ចេញឧស្ម័នដែលបង្ការប្រែប្រួលអាកាសធាតុ ។

គោលបំណងជាយុទ្ធសាស្ត្រ (*សន្ទស្សន៍បង្ហាញ*)

១៣.១ រួមបញ្ចូលការអភិរក្សជីវៈចំរុះ និងបញ្ហាទៅក្នុងផែនការសកម្មភាពជាតិស្តីពីការប្រែប្រួលអាកាសធាតុ (*កង្វល់នានាបានបញ្ចូលក្នុងផែនការសកម្មភាព*) ។

១៣.២ គិតគូរពីគោលបំណងអភិវឌ្ឍន៍ប្រទេស នៅពេលកំនត់វិធានការដោះស្រាយផលប៉ះពាល់លើជីវៈចំរុះ បណ្តាលមកពីការប្រែប្រួលអាកាសធាតុ ។

១៣.៣ សេចក្តីថ្លែងការណ៍ដោយប្រទេសកម្ពុជា ស្តីពីការប្រែប្រួលអាកាសធាតុ ។

សកម្មភាពជាអាទិភាព (ស្ថាប័នសំរបសំរួល និងចូលរួមអនុវត្ត)

១៣.១ ការដាក់បញ្ចូលគោលបំណងអភិរក្សជីវៈចំរុះ ទៅក្នុងផែនការសកម្មភាពជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (ក្រ.បស្ថ និង កសក) (រួមទាំងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដើម្បីកំណត់រកវិធានការតបនឹងការប្រែប្រួលអាកាសធាតុ) ។

១៣.២ ធ្វើ[illegible]សុក្រឹតភាពនៃការព្យាករណ៍អាកាសធាតុ ដើម្បីធានាការប្រកាសអាសន្នទាន់ពេលវេលា អំពីគ្រោះធម្មជាតិដូចជា ខ្យល់ព្យុះ ទឹកជំនន់ និងភាពរាំងស្ងួត ។ ពង្រឹងបណ្តាញឧតុនិយមឱ្យកាន់តែប្រសើរឡើង (ក្រ.ធទឧ) ។

១៣.៣ ធ្វើការបញ្ចុះបញ្ចូលបណ្តាប្រទេសជឿនលឿននានា ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័ន ដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ( ក្រ.បស្ថ តាមរយៈអនុសញ្ញាអន្តរជាតិ) ។

# ប្រធានបទទី ១៤ : ការចូលរួមរបស់សហគមន៍

## បរិបទ

អនុលោមតាមគោលការណ៍ណែនាំនៃយុទ្ធសាស្ត្រនេះ ប្រជាជនកម្ពុជាមានការទទួលខុសត្រូវក្នុងការអភិរក្សជីវៈចំរុះ និងប្រើប្រាស់ធនធានជីវសាស្ត្រប្រកបដោយនិរន្តរភាព ។ ប្រជាជនកម្ពុជាទាំងអស់ គួរត្រូវបានលើកទឹកចិត្តឱ្យស្វែងយល់ និងទទួលស្គាល់តំលៃនៃជីវៈចំរុះ ព្រមទាំងចូលរួមក្នុងការធ្វើសេចក្តីសំរេច ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ទឹក ដី សត្វព្រៃ កសិកម្ម ជលផល ព្រៃឈើ និងធនធានដទៃទៀត ។

បទពិសោធន៍បានបង្ហាញថា ការចូលរួមជាតំណាងប្រកបដោយសមធម៌រវាងបុរស និងស្ត្រី ការជាប់ពាក់ព័ន្ធ និងការចូលរួមរបស់សហគមន៍មូលដ្ឋាន ព្រមទាំងភាគីពាក់ព័ន្ធនានា គឺជាប្រការចាំបាច់ ដើម្បីធានាជោគជ័យនៃគំរោងអភិរក្ស និងប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព ។ ការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសំរេច និងក្នុងការគ្រប់គ្រងយ៉ាងសកម្មនូវធនធានរបស់សហគមន៍ មានសារៈសំខាន់ណាស់ ចំពោះការអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន និងជីវភាពគ្រួសារ ។ ដូចគ្នានេះដែរ ក្រុមជនជាតិភាគតិច ថ្នាក់ដឹកនាំឃុំ និងមេដឹកនាំសាសនា អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជន ត្រូវតែមានការពាក់ព័ន្ធក្នុងការធ្វើផែនការ និងការគ្រប់គ្រងធនធាន ។

នៅប្រទេសកម្ពុជា គំរោងការសាកល្បងមួយចំនួនបាន និងកំពុងប្រើប្រាស់គោលការណ៍នៃការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍ ក្នុងកំរិតផ្សេងៗ សំរាប់ការគ្រប់គ្រងធនធានព្រៃឈើ និងជលផលក្នុងតំបន់ផ្សេងៗនៃប្រទេសកម្ពុជា ។ គំរោងទាំងនេះបានបង្ហាញថា ការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍ គឺជាជំរើសដ៏មានតំលៃបំផុត សំរាប់ដោះស្រាយបញ្ហាភាពក្រីក្រនៅជនបទ និងភាពរេចរឹលនៃបរិស្ថាន ។ លទ្ធផលជាវិជ្ជមានពីបទពិសោធន៍ទាំងនេះ បានលើកទឹកចិត្តរដ្ឋាភិបាលឱ្យពង្រីកវិធីសាស្ត្រនៃការគ្រប់គ្រងធនធានធម្មជាតិ ដោយផ្អែកលើសហគមន៍ក្នុងវិស័យគ្រប់គ្រងជលផល និងព្រៃឈើ និងចាប់ផ្តើមពង្រីកវិធីសាស្ត្រនេះនៅក្នុងវិស័យផ្សេងៗទៀត ដូចជាផែនការប្រើប្រាស់ដី ការគ្រប់គ្រងសត្វព្រៃ ទេសចរណ៍ តំបន់ការពារធម្មជាតិ ដី និងកសិកម្ម ។ រាជរដ្ឋាភិបាលកម្ពុជាកំពុងរៀបចំគោលនយោបាយកែទំរង់វិស័យជលផលជាទ្រង់ទ្រាយធំ ដោយនៅខែមិថុនា ឆ្នាំ ២០០១ ផ្ទៃឡូត៍នេសាទប្រមាណ ៥០០.០០០ ហត ត្រូវបានប្រគល់ជូនសហគមន៍មូលដ្ឋាន សំរាប់គ្រប់គ្រងដោយសហគមន៍ ។ សហគមន៍មូលដ្ឋានដើរតួយ៉ាងសំខាន់ក្នុងការធ្វើអត្តសញ្ញាណធនធាន ការកំនត់អាទិភាពនៃការអភិវឌ្ឍន៍ ការជ្រើសរើសនិងការប្រើប្រាស់បច្ចេកវិទ្យា ព្រមទាំងការអនុវត្តការងារគ្រប់គ្រង ដែលជាលក្ខណៈសំគាល់នៃការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍ ។ ដើម្បីធានាជោគជ័យនៃការគ្រប់គ្រងធនធានធម្មជាតិផ្អែកលើសហគមន៍ គេត្រូវផ្តល់ការគាំទ្រដើម្បីបង្កើនការយល់ដឹងអំពីបរិស្ថាន និងជួយប្រជាពលរដ្ឋក្នុងការរៀបចំសហគមន៍របស់គាត់ ។ គេត្រូវការផងដែរនូវ ក្របខ័ណ្ឌច្បាប់ និងស្ថាប័ន សំរាប់គាំទ្រសិទ្ធិរបស់សហគមន៍ ក្នុងការប្រើប្រាស់ និងការពារធនធានទាំងអស់របស់ពួកគាត់ ។

## បញ្ហាចំបង

- ការចូលរួមរបស់ប្រជាជន និងផ្នែកឯកជន ពុំទាន់បានពេញលេញ នៅក្នុងកិច្ចការពារ និងការគ្រប់គ្រងធនធានជីវៈចំរុះ ។

- កង្វះខាតមន្ត្រីដែលមានការបណ្តុះបណ្តាល និងសមត្ថភាពមានកំរិតរបស់រាជរដ្ឋាភិបាល ដើម្បីអនុវត្តការគ្រប់គ្រងធនធានធម្មជាតិផ្អែកលើសហគមន៍ ។
- កង្វះខាតការគាំទ្រផ្នែកហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍ ។

### គោលដៅ

លើកទឹកចិត្ត និងគាំទ្រការចូលរួមរបស់ស្ត្រី ក្រុមជនជាតិភាគតិច សហគមន៍មូលដ្ឋាន ក្រុមសាសនា អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងផ្នែកឯកជន ក្នុងកិច្ចប្រឹងប្រែង ឆ្ពោះទៅការអភិរក្ស និងប្រើប្រាស់ជីវៈចំរុះដោយនិរន្តរភាព ។

### គោលបំណងជាយុទ្ធសាស្ត្រ (*សន្ទស្សន៍បង្ហាញ*)

១៤.១ ពង្រីកកម្មវិធីគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍ សំរាប់វិស័យព្រៃឈើ ជលផល ការប្រើប្រាស់ដី តំបន់ការពារធម្មជាតិ កិច្ចការពារប្រភេទរងគ្រោះថ្នាក់ ការអភិរក្សក្រៅតំបន់ ការគ្រប់គ្រងសត្វព្រៃ និងជីកសិកម្ម ។ (*ចំនួនកម្មវិធីដែលត្រូវបានបង្កើត*) ។

១៤.២ អនុវត្តវិធានការច្បាប់ សេដ្ឋកិច្ច និងការលើកទឹកចិត្តដទៃទៀត ដែលជំរុញការរួមវិភាគទាន និងការចូលរួមនៃភាគីពាក់ព័ន្ធនានា ក្នុងការអភិរក្ស និងការប្រើប្រាស់ជីវៈចំរុះដោយនិរន្តរភាព (*បញ្ជីកំនត់ពីវិធានការលើកទឹកចិត្ត*) ។

### ជំរើសនានា

- ពង្រីកវិធានការលើកទឹកចិត្ត ដូចជាការផ្តល់រង្វាន់ និងប័ណ្ណសរសើរ ទទួលស្គាល់ការចូលរួមវិភាគទានរបស់បុគ្គល សហគមន៍ និងក្រុមនានាចំពោះការអភិរក្សធម្មជាតិ ។
- បង្កើតគោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍ ។
- ធ្វើសេចក្តីព្រាងគោលការណ៍ណែនាំ ដើម្បីពង្រីកការចូលរួមនៃសង្គមស៊ីវិល និងផ្នែកឯកជន ។
- កសាងយុទ្ធសាស្ត្រជីវៈចំរុះមូលដ្ឋាន សំរាប់តំបន់នានានៅក្នុងប្រទេស ។
- លើកកំពស់ការអភិវឌ្ឍន៍ដោយចីរភាព និងបង្កើតគំរោងការសេដ្ឋកិច្ច-សង្គម នៅថ្នាក់សហគមន៍ (សំរាប់ជាប្រយោជន៍របស់ប្រជាជនមូលដ្ឋាន និងជាមួយប្រជាជនមូលដ្ឋាន) ។
- ការបង្កើតមូលនិធិទាយជ្ជទានជាតិសំរាប់បរិស្ថាន (នៅក្រោមច្បាប់បរិស្ថាន) ។
- ប្រើប្រាស់យន្តការលើកទឹកចិត្តខាងផ្នែកហិរញ្ញវត្ថុ និងសេដ្ឋកិច្ច ដើម្បីជំរុញសហគមន៍ និងសហគ្រាសឯកជន ឲ្យប្រកាន់យកវិធីសាស្ត្រ និងការអនុវត្តន៍ទាំងឡាយ ដែលស្របនឹងគោលការណ៍បរិស្ថាន ។
- [illegible]សហគ្រិន កសិករ និងអ្នកនេសាទ ឲ្យជ្រើសរើសយកបច្ចេកវិទ្យាផលិតកម្ម និងសេវាកម្មសមស្រប ដែលមិនជះឥទ្ធិពល[illegible]ភាពប្រកួតប្រជែងរបស់ពួកគេ ។

- ផ្តល់ការលើកទឹកចិត្តជាការទូទាត់នានាដល់សហគ្រាសទាំងឡាយណា ដែលប្រើប្រាស់បច្ចេកវិទ្យា និងវិធីដែលផ្តល់ចំណេញតិច តែមានហេតុប៉ះពាល់បរិស្ថានតិចតួច ។
- ជំរុញការបង្កើតឱ្យមានគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ឃុំ និងសមាគមន៍អ្នកប្រើប្រាស់ ។
- ចុះបញ្ជីស្តីពីការចូលរួមរបស់ប្រជាជន ដើម្បីកំនត់អាទិភាពសំរាប់គំរោងដែលពួកគាត់ចាប់អារម្មណ៍ និងដើម្បីអភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិ ។
- លើកទឹកចិត្តឱ្យមានការចូលរួមដោយស្ម័គ្រចិត្តជាលក្ខណៈបុគ្គល ក្នុងការងារនៅតាមមូលដ្ឋាន នៅក្នុងការងារសិក្សាអង្កេត និងតាមដាន ការគាំទ្រដោយប្រយោលពីសំណាក់ក្រសួង និងអង្គការពាក់ព័ន្ធនឹងការអភិរក្សជីវៈចំរុះ ។
- លើកកំពស់របបប្រជាធិបតេយ្យសេរីនិយមក្នុងសហគមន៍មូលដ្ឋាន ។
- ធ្វើអត្តសញ្ញាណ និងជំរុញការបង្ហាញបទពិសោធន៍ល្អៗ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងសំភារៈអប់រំ ។

**សកម្មភាពជាអាទិភាព (ស្ថាប័នសំរបសំរួល និងចូលរួមអនុវត្ត)**

១៤.១ ការពង្រឹងចំណេះដឹងស្ថាប័នស្តីពីការគ្រប់គ្រងធនធានធម្មជាតិ ដោយផ្អែកលើសហគមន៍ (សំរាប់មន្ត្រីរុក្ខា កសិកម្ម ជលផល បរិស្ថាន អភិវឌ្ឍន៍ជនបទ និងការគ្រប់គ្រងដីធ្លី (ក្រ.កសក បស្ថ អជប រជនស និង កនអយ) ។

១៤.២ បង្កើតកម្មវិធីការពារសត្វព្រៃដោយផ្អែកលើសហគមន៍ (ក្រ.បស្ថ កសក អជប និង កនអយ) ។

១៤.៣ ការកសាងកម្មវិធីគ្រប់គ្រងព្រៃឈើដោយផ្អែកលើសហគមន៍ (ក្រ.កសក អជប បស្ថ និង កនអយ) ។

១៤.៤ ការកសាងកម្មវិធីគ្រប់គ្រងកសិកម្មដោយផ្អែកលើសហគមន៍ (ក្រ.កសក អជប និង កនអយ) ។

១៤.៥ ការកសាងកម្មវិធីគ្រប់គ្រងជលផល ដោយផ្អែកលើសហគមន៍ (ក្រ.កសក អជប បស្ថ និង កនអយ) ។

១៤.៦ ការកសាងកម្មវិធីគ្រប់គ្រងការប្រើប្រាស់ដី និងអភិវឌ្ឍន៍ជនបទ ដោយផ្អែកលើសហគមន៍ (ក្រ.រជនស អជប ផក សកដជ បស្ថ កសក និងកនអយ) ។

## ប្រធានបទទី ១៥ : ការសំរបសំរួល និងការអភិវឌ្ឍន៍ការយល់ដឹង ការអប់រំ និងការស្រាវជ្រាវ

### បរិបទ

ការបង្កើនចំណេះដឹងដល់សាធារណជន និងការស្វែងយល់ដឹងអំពីសារៈសំខាន់នៃជីវៈចំរុះ ជាកត្តាចាំបាច់ ដើម្បីធានានូវប្រសិទ្ធិភាព និងគោលដៅនៃកិច្ចប្រឹងប្រែងអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាព ។ កិច្ចខំប្រឹងប្រែងអភិរក្សអាចទទួលបានផ្លែផ្កា តែនៅពេលដែលសមាជិកសង្គមយល់ថា បេតិកភណ្ឌជីវសាស្ត្រមានសារៈសំខាន់ចំពោះជីវភាពរបស់ពួកគេ ។ ដើម្បីឱ្យមានប្រសិទ្ធិភាព គេត្រូវមានការស្រាវជ្រាវវិទ្យាសាស្ត្រ និងចងក្រងឯកសារគ្រប់គ្រាន់ សំរាប់ទ្រទ្រង់សកម្មភាពបង្កើនការយល់ដឹង និងអប់រំ ។

ការអប់រំបរិស្ថាននៅក្នុងប្រទេសកម្ពុជា ទើបតែចាប់ផ្តើមនៅពេលថ្មីៗនេះតែប៉ុណ្ណោះ ដែលកាលពីមុន គឺជាកិច្ចការស្ថិតនៅក្រោមការយកចិត្តទុកដាក់នៃសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល ។ ភាគច្រើននៃសកម្មភាពដែលគួរកត់សំគាល់របស់រាជរដ្ឋាភិបាលបានចាប់ផ្តើម ព្រមពេលជាមួយនឹងការបង្កើតក្រសួងបរិស្ថាន និងគណៈកម្មការអន្តរក្រសួងដឹកនាំការងារអប់រំបរិស្ថាន ដែលត្រូវបានបង្កើតនៅឆ្នាំ ១៩៩៣ ។ នាយកដ្ឋានអប់រំ និងផ្សព្វផ្សាយពតិមានបរិស្ថាននៃក្រសួងបរិស្ថាន មាននាទីជាប្រធាននៃគណៈកម្មការអន្តរក្រសួងដឹកនាំការងារអប់រំបរិស្ថាន ។ គណៈកម្មការអន្តរក្រសួងដឹកនាំការងារអប់រំបរិស្ថានទទួលខុសត្រូវលើកម្មវិធីអប់រំបរិស្ថានក្នុងប្រព័ន្ធ សំរាប់ថ្នាក់បឋមសិក្សា មធ្យមសិក្សា និងការអប់រំព្រះសង្ឃ ។ អង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា បានផ្តល់ជំនួយបច្ចេកទេស និងជំនួយហិរញ្ញវត្ថុ សំរាប់ការងារអប់រំបរិស្ថាន ចាប់តាំងពីឆ្នាំ ១៩៩៣ មក ។ សកម្មភាពពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលនឹងជីវៈចំរុះរួមមាន សិក្ខាសាលាបណ្តុះបណ្តាល និងសិក្ខាសាលាបង្កើនសមត្ថភាព ការផលិតសៀវភៅបង្រៀនស្តីពីការអប់រំបរិស្ថានសំរាប់គ្រូបង្រៀនបឋមសិក្សា ឈុតខ្លីៗផ្សាយតាមទូរទស្សន៍ ផ្ទាំងរូបភាពផ្សេងៗ ការរៀបចំទិវាបរិស្ថានជាតិ ។ល។ ប៉ុន្តែ ដោយសារកង្វះខាតថវិកា នាពេលបច្ចុប្បន្ន គណៈកម្មាធិការនេះមិនមានសកម្មភាពឡើយ ។

បន្ថែមលើការងារអប់រំក្នុងប្រព័ន្ធ ក្រសួងនានា អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល បានអនុវត្តសកម្មភាពអប់រំបរិស្ថានក្រៅប្រព័ន្ធផងដែរ ។ ឧទាហរណ៍ កម្មវិធីចំរុះការពារដំណាំ (IPM) ត្រូវបានអនុវត្ត នៅកំរិតសហគមន៍ ដោយមានការជួយឧបត្ថម្ភពីអង្គការស្បៀងអាហារ និងកសិកម្មសហប្រជាជាតិ ។ កម្មវិធីអប់រំសំរាប់ព្រះសង្ឃ ក៏ត្រូវបានបង្កើតឡើងផងដែរ នៅឆ្នាំ ១៩៩៨ ដោយក្រុមការងារអង្គការមិនមែនរដ្ឋាភិបាល ដឹកនាំដោយព្រះតេជព្រះគុណ ព្រះនាម **ញ៉ែម គីមតេង** ដែលជា ព្រះសង្ឃមួយអង្គ ក្នុងចំណោមព្រះសង្ឃឈានមុខគេ ក្នុងផ្នែកអេកូឡូស៊ីនៅប្រទេសកម្ពុជា ។ កម្មវិធីនេះ មានគោលដៅជំរុញការរៀនសូត្រ និងសកម្មភាពបរិស្ថាន ដែលផ្អែកលើសហគមន៍ តាមរយៈវត្តអារាមក្នុងប្រទេសកម្ពុជា ។ គំរោងសាកល្បងផ្នែកគ្រប់គ្រងផ្អែកលើសហគមន៍ដទៃទៀត បានរៀបចំនូវសំភារៈសំរាប់អប់រំ សំរាប់ជំរុញឱ្យមានការ អនុវត្តន៍ការងារកសិកម្ម និងព្រៃឈើឱ្យកាន់តែប្រសើរឡើង ។

នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដេប៉ាតឺម៉ង់វិទ្យាសាស្ត្របរិស្ថានត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០១ ។ នៅពេលមានថវិកាគ្រប់គ្រាន់ ដេប៉ាតឺម៉ង់នេះនឹងធ្វើការស្រាវជ្រាវយ៉ាងច្រើនអំពីបញ្ហាបរិស្ថាន ។ តួនាទីជាក់ស្តែងនៃដេប៉ាតឺម៉ង់នេះ គឺអភិវឌ្ឍន៍ធនធានមនុស្ស ក្នុងវិស័យបរិស្ថាន ។

មកទល់បច្ចុប្បន្ន ការផ្តួចផ្តើមគំនិតទាំងនេះបានធ្វើឱ្យប្រជាជនមួយចំនួនតូចប៉ុណ្ណោះមានការយល់ដឹង ។ គេចាំបាច់ត្រូវពង្រីកកម្មវិធីនេះ នៅគ្រប់តំបន់ទាំងអស់ទូទាំងប្រទេស និងឱ្យដល់មនុស្សគ្រប់ៗរូប ជាពិសេសដល់សហគមន៍មូលដ្ឋាន ដែលរស់នៅក្នុងតំបន់មានជីវៈចំរុះកំរិតខ្ពស់ រួមទាំងតំបន់ដែលមានប្រភេទកំពុងរងការគំរាមកំហែងផងដែរ ។

ការបណ្តុះបណ្តាលបច្ចេកទេស សំដៅបង្កើតទំលាប់ប្រតិបត្តិសមស្របតាមគោលការណ៍បរិស្ថាន អាចរួមចំណែកលើកស្ទួយនិរន្តរភាព និងផលិតភាពនៃសកម្មភាពដែលផ្អែកលើធនធានធម្មជាតិជាមូលដ្ឋាន ។ គេត្រូវពង្រឹងសមត្ថភាពជាបន្ថែមសំរាប់មន្ត្រីរាជការនៃក្រសួង និងនាយកដ្ឋាន ដែលពាក់ព័ន្ធនឹងការងារជីវៈចំរុះ ។ ចាំបាច់ត្រូវមានការបណ្តុះបណ្តាល ជាពិសេសនៅកំរិតបច្ចេកទេស និងអ្នកគ្រប់គ្រង ក្នុងវិស័យគ្រប់គ្រងព្រៃឈើ កសិកម្ម ជលផល សត្វព្រៃ និងតំបន់ការពារធម្មជាតិ ។

ដើម្បីអនុវត្តអនុសញ្ញាជីវៈចំរុះ គេចាំបាច់ត្រូវតែបង្កើត និងដំណើរការនូវកម្មវិធីនានា សំរាប់ការអប់រំ និងបណ្តុះបណ្តាលវិទ្យាសាស្ត្រ-បច្ចេកទេស ហើយក៏ត្រូវរៀបចំបង្កើត និងសំរបសំរួលការងារស្រាវជ្រាវវិទ្យាសាស្ត្រផងដែរ ។ បណ្តាក្រសួង ស្ថាប័ន និងសាកលវិទ្យាល័យ នឹងមានឱកាសក្នុងការអនុវត្តន៍សកម្មភាពស្រាវជ្រាវ ពាក់ព័ន្ធនឹងធនធានជីវសាស្ត្រ ។ រាជរដ្ឋាភិបាលមានបំណងជំរុញ និងសំរបសំរួលឱ្យបានប្រសើរថែមទៀត នូវការបង្កើតបណ្តាសកម្មភាពទាំងនេះ រវាងក្រសួងនានា និងដេប៉ាតឺម៉ង់របស់សាកលវិទ្យាល័យ ។

**បញ្ហាចំបង**

- កង្វះខាតចំណេះដឹង និងការយល់ដឹងអំពីជីវៈចំរុះក្នុងចំណោមប្រជាជនមូលដ្ឋាន ។
- សេវាកម្ម និងមធ្យោបាយសំរាប់ផ្សព្វផ្សាយ ដើម្បីបង្កើនការយល់ដឹងអំពីបរិស្ថាននៅមានកំរិត ។
- ការបញ្ចូលទស្សនាទានអំពីបរិស្ថានទៅក្នុងកម្មវីធីអប់រំនៅមានកំរិតខ្សោយ ។
- កង្វះខាតធនធានមនុស្ស និងជំនាញ ក្នុងវិស័យគ្រប់គ្រងធនធានដោយនិរន្តរភាព ។
- សមត្ថភាពស្រាវជ្រាវជាមូលដ្ឋានក្នុងគ្រប់ផ្នែកពាក់ព័ន្ធនឹងកិច្ចការពារធនធានធម្មជាតិ និងការប្រើប្រាស់ដោយនិរន្តរភាព នៅមានកំរិតទាបនៅឡើយ ។
- កង្វះខាតថវិកាសំរាប់ការអប់រំ និងស្រាវជ្រាវអំពីបរិស្ថាន ។
- កង្វះខាតឯកសារជាភាសាខ្មែរ សំរាប់ការបណ្តុះបណ្តាល និងអប់រំអំពីបរិស្ថាន ។

**គោលដៅ**

- លើកកំពស់ការយល់ដឹងដល់សហគមន៍ ទាំងនៅថ្នាក់ជាតិ និងមូលដ្ឋាន ស្តីពីសារៈសំខាន់នៃការអភិរក្សធនធានជីវសាស្ត្រ និងការប្រើប្រាស់ដោយនិរន្តរភាព ។
- ពង្រឹងសមត្ថភាពបច្ចេកទេសអ្នកជំនាញការជាតិ ក្នុងផ្នែកនានា ពាក់ព័ន្ធនឹងការគ្រប់គ្រងជីវៈចំរុះ ។
- បង្កើតសមត្ថភាពស្រាវជ្រាវថ្នាក់ជាតិក្នុងផ្នែកជីវៈចំរុះ តាមរយៈការផ្តល់ថវិកាគ្រប់គ្រាន់ ។

គោលបំណងជាយុទ្ធសាស្ត្រ (*សន្ទស្សន៍បង្ហាញ*)

១៥.១ ពង្រឹងកម្មវិធីបង្កើនការយល់ដឹងអំពីបរិស្ថាន តាមរយៈប្រព័ន្ធផ្សព្វផ្សាយសាធារណៈ ឯកសារបោះពុម្ព ការតាំងពិពណ៌ សិក្ខាសាលា និងការជួបប្រាស្រ័យដោយផ្ទាល់ជាមួយប្រជាជនក្នុងតំបន់ដែលមានជីវៈចំរុះគំរិតខ្ពស់ ដូចជានៅតំបន់ដែលមានប្រភេទប្រឈមការគំរាមកំហែង ។ (*ចំនួនប្រជាជនបានផ្សព្វផ្សាយតាមរយៈយុទ្ធនាការបង្កើនការយល់ដឹង*) ។

១៥.២ ពង្រីកសកម្មភាពផ្សព្វផ្សាយចំណេះដឹងផ្នែកបរិស្ថានដល់ប្រជាជនគ្រប់ស្រទាប់ ជាពិសេសសំរាប់ប្រជារាស្ត្រនៅតាមសហគមន៍ (*ចំនួនសហគមន៍ដែលបានទទួលការផ្សព្វផ្សាយតាមរយៈយុទ្ធនាបង្កើនការយល់ដឹង*) ។

១៥.៣ ពង្រឹងបន្ថែមទៀតនូវប្រធានបទអភិរក្សធម្មជាតិ និងបញ្ហាពាក់ព័ន្ធនឹងបរិស្ថាន នៅក្នុងកម្មវិធីសិក្សាក្នុងថ្នាក់ (*ការបញ្ចូលខ្លឹមសារបរិស្ថានទៅក្នុងកម្មវិធីអប់រំ*) ។

១៥.៤ ជំរុញការបណ្តុះបណ្តាល និងស្រាវជ្រាវបច្ចេកទេស ក្នុងផ្នែកគ្រប់គ្រងធនធានធម្មជាតិ និងជីវៈចំរុះ (*ចំនួនអ្នកបច្ចេកទេសបានទទួលការបណ្តុះបណ្តាល*) ។

១៥.៥ ផ្សព្វផ្សាយ និងពង្រឹងការអនុវត្តន៍ច្បាប់បរិស្ថាន និងបទបញ្ញត្តិនានា ពាក់ព័ន្ធនឹងកិច្ចការពារ និងអភិរក្សជីវៈចំរុះ ដូចជាច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ជាដើម ។

**ជំរើសនានា**

- វាយតំលៃសេចក្តីត្រូវការបណ្តុះបណ្តាល (ប្រភេទនៃវគ្គបណ្តុះបណ្តាល ពេលវេលា និងថវិកា) សំរាប់ក្រុមគោលដៅដែលបានកំណត់ ។
- បើកវគ្គបណ្តុះបណ្តាល ។
- វាយតំលៃលទ្ធផលនៃវគ្គបណ្តុះបណ្តាល ។
- ទស្សនកិច្ចសិក្សានៅតាមគំរោងពាក់ព័ន្ធនានា ។
- បង្កើតបណ្ណាល័យ ឬមជ្ឈមណ្ឌលពតិមានជីវៈចំរុះជាតិ ។
- បង្កើតមជ្ឈមណ្ឌលពតិមានជីវៈចំរុះតាមបណ្តាសហគមន៍ ។
- បង្កើតបណ្តាញពតិមានអំពីជីវៈចំរុះក្នុងប្រទេសកម្ពុជា ។
- រៀបចំសិក្ខាសាលា ស្តីពីការផ្លាស់ប្តូរពតិមាន ។
- រៀបចំដំណើរការតាមប្រព័ន្ធអាំងទែណែត ។
- ប្រមូលឯកសារទាក់ទងនឹងជីវៈចំរុះ ។
- អប់រំ បណ្តុះបណ្តាល និងផ្សព្វផ្សាយពតិមា នស្តីពីការគ្រប់គ្រងធនធានធម្មជាតិនៅតាមបណ្តាសហគន៍មូលដ្ឋាន ។
- បង្កើតគណៈកម្មាធិការថ្នាក់សហគមន៍ សំរាប់ការគ្រប់គ្រងធនធានធម្មជាតិ ។
- ផលិត និងចែកចាយសៀវភៅ ឯកសារបង្រៀន ផ្ទាំងរូបភាព និងរឿងខ្លីៗ ស្តីពីជីវៈចំរុះ ។
- ប្រារព្ធទិវាជីវៈចំរុះជាតិ ។

- រៀបចំសិក្ខាសាលាស្តីពីការបង្កើតគណៈកម្មាធិការជាតិអប់រំបរិស្ថាន ( តួនាទី ភារៈកិច្ច ការទទួលខុសត្រូវ) ។
- ពង្រីកការបណ្តុះបណ្តាលគ្រូ និងព្រះសង្ឃ ។
- លើកទឹកចិត្តដល់បណ្តាសាកលវិទ្យាល័យ និងស្ថាប័នវិទ្យាសាស្ត្រ ឱ្យដាក់បញ្ចូលប្រធានបទស្តីពីធនធានជីវសាស្ត្រ ក្នុងកម្មវិធីបង្រៀន និងកម្មវិធីស្រាវជ្រាវ ។
- បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលបរិស្ថាន ។
- លើកទឹកចិត្ត គាំទ្រ និងអនុវត្តការសិក្សា ស្រាវជ្រាវនៅតាមមូលដ្ឋាន ដើម្បីធ្វើអត្តសញ្ញាណរបាយប្រភេទដែលគេបានស្គាល់ពីមុនមក និងប្រភេទដែលមិនទាន់បានកត់ត្រាទុកនៅឡើយ និងធ្វើសេចក្តីអធិប្បាយអំពីប្រភេទទាំងនោះ ។
- ជំរុញឱ្យមានការចូលរួមរបស់ប្រជាជនមូលដ្ឋាន នៅក្នុងគំរោងស្រាវជ្រាវតាមមូលដ្ឋាន និងការសិក្សាអង្កេត ។
- ពង្រឹងកិច្ចសហការ និងសហប្រតិបត្តិការរវាងក្រសួងបរិស្ថាន និងក្រសួងអប់រំ យុវជន និងកីឡា ក្នុងការរៀបចំកម្មវិធីអប់រំបរិស្ថានសំរាប់ថ្នាក់បឋមសិក្សា មធ្យមសិក្សា និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ។
- ផលិតឯកសារសំរាប់ការបណ្តុះបណ្តាល និងអប់រំបរិស្ថានជាភាសាខ្មែរ ។

**សកម្មភាពជាអាទិភាព (ស្ថាប័នសំរបសំរួល និងចូលរួមអនុវត្ត )**

១៥.១ កម្មវិធីយល់ដឹងពីជីវៈចំរុះ ( ក្រ.បស្ថ អយក កសក ឧរថ វជនស សខភ ធកស និង កនអយ) (រួមបញ្ចូលប្រព័ន្ធអាំងទែណែតអំពីជីវៈចំរុះ ទិវាជីវៈចំរុះជាតិ ការបោះពុម្ពឯកសារ ផ្ទាំងរូបភាព រូបភាពតាមទូរទស្សន៍ និងល្បែងខ្លីៗតាមវិទ្យុ ដោយមានកិច្ចសហការជាមួយសាកលវិទ្យាល័យ និងអង្គការមិនមែនរដ្ឋាភិបាលនានា ។

១៥.២ បណ្ណាល័យ ឬមជ្ឈមណ្ឌលពត៌មានជីវៈចំរុះជាតិ ( ក្រ.បស្ថ ) ។

១៥.៣ ការបញ្ចូលបញ្ហាជីវៈចំរុះ និងបរិស្ថានទៅក្នុងកម្មវិធីសិក្សាតាមសាលា ( គចអកអបស្ថ ក្រ.អយក និង បស្ថ ) ។

១៥.៤ កម្មវិធីបង្កើនសមត្ថភាពមន្ត្រីរាជការ ( ក្រ.បស្ថ កសក និងស្ថាប័នពាក់ព័ន្ធ) ។

១៥.៥ កម្មវិធីអភិវឌ្ឍន៍ស្រាវជ្រាវជីវៈចំរុះ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ( សភភព) ។

១៥.៦ ការបង្កើតកម្មវិធីបណ្តុះបណ្តាលអំពីការគ្រប់គ្រងធនធានធម្មជាតិ និងការអភិរក្សបរិស្ថានដល់សហគមន៍ ( ក្រ.បស្ថ និង កសក) ។

## ប្រធានបទទី ១៦ : ច្បាប់ និងរចនាសម្ព័ន្ធស្ថាប័ន

### បរិបទ

ដំណោះស្រាយបញ្ហាបរិស្ថាន និងជីវៈចំរុះគឺជាប្រការស្មុគ្រស្មាញមួយ ដែលតម្រូវឱ្យមានការចូលរួមចំណែក និងឯកភាពគ្នា ពីសំណាក់ស្ថាប័នភាគច្រើន ឬទាំងអស់នៃរាជរដ្ឋាភិបាល ជាពិសេសក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ក្រសួងទេសចរណ៍ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងផែនការ ។ល។ ក្រសួងទាំងអស់នេះ ក៏ត្រូវធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ជាមួយសាកលវិទ្យាល័យ ទីភ្នាក់ងារនានា វិទ្យាស្ថានបច្ចេកទេស អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជនផងដែរ ។ បណ្តាស្ថាប័នទាំងនេះតែងជួបប្រទះបញ្ហាមួយចំនួន ដែលជាករណីទូទៅសំរាប់រដ្ឋាភិបាលនៃប្រទេសជាច្រើន ដូចជាភាពត្រួតគ្នានៃសមត្ថកិច្ច ការសំរបសំរួលមិនបានពេញលេញ ឬមិនគ្រប់គ្រាន់ ។ ការទទួលខុសត្រូវស្ថាប័នរវាងក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពាក់ព័ន្ធនឹងការអភិរក្សជីវៈចំរុះ និងការគ្រប់គ្រងធនធានធម្មជាតិ នៅមានភាពមិនច្បាស់លាស់នៅឡើយ ។ កង្វះខាតកិច្ចសម្របសម្រួលអន្តរក្រសួង គឺជាឧបសគ្គចំបង ក្នុងការរៀបចំផែនការសមាហរណកម្មការប្រើប្រាស់ដី និងកិច្ចការផ្សេងទៀត ដែលត្រូវការឱ្យមានកិច្ចប្រឹងប្រែងរួមគ្នា ។ ប៉ុន្តែ នៅខែ មេសា ឆ្នាំ ២០០១ គណៈកម្មាធិការដឹកនាំការងារជីវៈចំរុះជាតិត្រូវបានបង្កើត ដើម្បីជំរុញកិច្ចសហប្រតិបត្តិការ និងការសំរបសំរួល រវាងស្ថាប័នពាក់ព័ន្ធនឹងបញ្ហាជីវៈចំរុះ ។

បច្ចុប្បន្ន បណ្តាច្បាប់នានាក្នុងប្រទេសកម្ពុជា ដែលពាក់ព័ន្ធនឹងជីវៈចំរុះ កំពុងស្ថិតនៅក្រោមការពិនិត្យសើរើឡើងវិញ ឧទាហរណ៍ អនុក្រឹត្យ និងសារាចរផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ ១៩៩៦ កំពុងត្រូវបានគេរៀបចំជាសេចក្តីព្រាង ។ ការសើរើពិនិត្យឡើងវិញនេះ នឹងត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម :

- បញ្ជាក់ឱ្យច្បាស់លាស់អំពីសមត្ថកិច្ចរបស់ក្រសួង និងបញ្ចៀសភាពត្រួតភារកិច្ចគ្នា ។
- ផ្តល់ការគាំទ្រស្របច្បាប់ចំពោះផ្នែកពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ដែលមិនទាន់ទទួលការការពារគ្រប់គ្រាន់ ជាតំបន់ការពារធម្មជាតិ ឧទាហរណ៍ សិទ្ធិលើអចលនទ្រព្យ តំបន់ការពារធម្មជាតិ ប្រភេទប្រឈមគ្រោះថ្នាក់ ជីវសុវត្ថិភាព ទ្រព្យខាងបញ្ញា ។ល។
- ពង្រឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។
- អនុញ្ញាតឱ្យមានការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍មូលដ្ឋាន នៅក្នុងគ្រប់ផ្នែក ។
- បង្កលក្ខណៈងាយស្រួលដល់ការអនុវត្តន៍ច្បាប់ តាមរយៈវិធានការលើកទឹកចិត្ត ។

ប៉ុន្តែ បណ្តាច្បាប់ពាក់ព័ន្ធនឹងបរិស្ថាននៅពុំទាន់សុក្រឹត្យនៅឡើយ ហើយក៏នៅមិនទាន់បានផ្សព្វផ្សាយឱ្យបានជ្រួតជ្រាបក្នុងចំណោមសាធារណជនផងដែរ ជាពិសេសនៅតំបន់ជនបទ ។ ប្រការនេះតំរូវឱ្យមានការផ្សព្វផ្សាយបន្ថែមទៀតដល់ប្រជាជនអំពីការទទួលខុសត្រូវរបស់ពួកគេ ក្នុងការការអនុវត្តន៍ច្បាប់ និងសារាចរ ដែលពាក់ព័ន្ធនឹងជីវៈចំរុះ ។

ម្យ៉ាងទៀត ការអនុវត្តន៍ច្បាប់បច្ចុប្បន្ននៅមានភាពទន់ខ្សោយនៅឡើយនៅក្នុងប្រទេសកម្ពុជា ដោយសារតែការ[illegible] កិរិយាមិនអាចទទួលយកបាន និងកង្វះការទទួលខុសត្រូវពីសំណាក់មន្ត្រីរាជការមួយចំនួន ។ ប៉ុន្តែ រាជរដ្ឋា[illegible] ជំរុញឱ្យមានការប្រកាន់ឥរិយាបទប្រកបដោយការទទួលខុសត្រូវនៅក្នុងប្រព័ន្ធរដ្ឋបាលផងដែរ ។

## យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិស្តីពីជីវៈចំរុះ

នៅថ្នាក់តំបន់ ព្រះរាជាណាចក្រកម្ពុជាគឺជាសមាជិកដ៏សកម្មនៃកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសំរាប់ការអភិវឌ្ឍន៍ដោយចីរភាពក្នុងអាងទន្លេមេគង្គ ។ រាជរដ្ឋាភិបាលនឹងបន្តកិច្ចសហប្រតិបត្តិការយ៉ាងពេញទំហឹងជាមួយប្រទេសជិតខាង ដើម្បីសំរេចគោលដៅបរិស្ថានរួម តាមទស្សនៈនៃការអភិវឌ្ឍន៍ដោយចីរភាព ។ លើឆាកអន្តរជាតិ ព្រះរាជាណាចក្រកម្ពុជាគឺជាភាគីហត្ថលេខីនៃអនុសញ្ញាជាច្រើនពាក់ព័ន្ធនឹងជីវៈចំរុះ ។ រាជរដ្ឋាភិបាលកម្ពុជាសន្យាថា នឹងបន្តដើរតួនាទីយ៉ាងសកម្មក្នុងការបំពេញការតព្វកិច្ចរបស់ខ្លួន ។

### បញ្ហាចំបង

- កង្វះខាតស្តង់ដាគ្រប់គ្រងនៅក្នុងវិស័យនៃសកម្មភាពផ្សេងៗ ។
- ភាពត្រួតគ្នា ការសម្របសម្រួលមិនបានពេញលេញ និងមិនគ្រាប់គ្រាន់ ជាមួយអាជ្ញាធរទទួលបន្ទុកការពារ អភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិ ។
- ច្បាប់នានានៅពុំទាន់ចែងបានគ្រប់ជ្រុងជ្រោយអំពីបញ្ហាពាក់ព័ន្ធនឹងជីវៈចំរុះ ។
- កង្វះការយល់ដឹងជាសាធារណៈអំពីច្បាប់ពាក់ព័ន្ធនឹងបរិស្ថាន ។

### គោលដៅ

- ធានាការពារ និងប្រើប្រាស់ជីវៈចំរុះ និងធនធានធម្មជាតិផ្សេងៗទៀត ដោយនិរន្តរភាព តាមរយៈការកសាងច្បាប់ឱ្យបានគ្រប់គ្រាន់ និងមានប្រសិទ្ធិភាព និងការរៀបចំស្តង់ដាគ្រប់គ្រង ។
- បង្កើនកិច្ចសម្របសម្រួលអន្តររដ្ឋាភិបាល និងអន្តរស្ថាប័ន ដើម្បីការពារ អភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិ ។
- អះអាងបញ្ជាក់ និងពង្រឹងការសន្យារបស់រាជរដ្ឋាភិបាល ចំពោះសិទ្ធិ តួនាទី និងកាតព្វកិច្ចរបស់ខ្លួនដើម្បីអភិរក្សជីវៈចំរុះក្នុងតំបន់ និងលើឆាកអន្តរជាតិ ។
- ពង្រឹងដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន កិច្ចពិគ្រោះយោបល់បរិស្ថាន ការពិនិត្យគំរោង ដោយរួមទាំងការអនុវត្តន៍តាមលក្ខខណ្ឌក្នុងលិខិតអនុញ្ញាតសំរាប់គំរោងអភិវឌ្ឍន៍ថ្មីៗ ។

### គោលបំណងជាយុទ្ធសាស្ត្រ (*សន្ទស្សន៍បង្ហាញ*)

១៦.១ អនុម័តអនុក្រឹត្យ ចេញសេចក្តីសំរេច និងសារាចរពាក់ព័ន្ធនឹងបញ្ហាជីវៈចំរុះ ដូចជា តំបន់ការពារធម្មជាតិ ប្រភេទប្រឈមនឹងគ្រោះថ្នាក់ ជីវសុវត្ថិភាព កិច្ចការពារទឹក ការត្រួតពិនិត្យថ្នាំកំចាត់សត្វចង្រៃ កម្មសិទ្ធិបញ្ញា ការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ ការកសាងផែនការប្រើប្រាស់ដីធ្លី ។ល។ ( *បញ្ជីអនុក្រឹត្យដែលបានអនុម័ត* ) ។

១៦.២ គណៈកម្មាធិការសំរបសំរួលជីវៈចំរុះជាតិ និងលេខាធិការដ្ឋាន ក្នុងនាទីជាអ្នកសម្របសម្រួលការអនុវត្តន៍យុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះជាតិ ( *មានធនធានគ្រប់គ្រាន់* ) ។

១៦.៣ អនុវត្តគោលការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន (*ចំនួនគំរោងដាក់សំរាប់ធ្វើការត្រួតពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន*) ។

ជំរើសនានា

- បង្កើតយន្តការគ្រប់គ្រងជីវៈចំរុះជាតិ ។
- បង្កើតមូលនិធិទាយជ្ជទាន សំរាប់ផ្តល់ហិរញ្ញប្បទានរយៈពេល វែងដើម្បីកម្មវិធីអភិរក្ស ។
- បង្កើតអនុគណៈកម្មាធិការស្រាវជ្រាវជីវៈចំរុះ និងពង្រឹងការអនុវត្តន៍ច្បាប់ (ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីជូនដំណឹង និងឯកសារបទដ្ឋានផ្សេងៗ) ។
- អនុគណៈកម្មាធិការត្រូវវាយការណ៍ពីការអនុវត្តន៍ច្បាប់ និងស្ថានភាពជីវៈចំរុះ ។
- អភិវឌ្ឍន៍ និងជំរុញឯកសារទស្សនៈវិស័យរយៈពេលវែង ជាមូលដ្ឋានសំរាប់កសាងច្បាប់ជីវៈចំរុះ ។
- បង្កើតនគរបាលបរិស្ថាន (ក្រសួងបរិស្ថាន) ដោយសហការជាមួយក្រសួងមហាផ្ទៃ ។
- ដាក់ទណ្ឌកម្ម និងពិន័យជនល្មើស (ជូនដំណឹងស្ថាប័នមានសមត្ថកិច្ចដើម្បីចាត់វិធានការចំពោះជនល្មើស) ។
- បើកសិក្ខាសាលាថ្នាក់ជាតិ និងថ្នាក់ខេត្ត ស្តីពីជីវៈចំរុះ ។
- ហ្វឹកហ្វឺនមន្ត្រីរាជការថ្នាក់ខេត្ត និងថ្នាក់ជាតិអំពីជីវៈចំរុះ ។
- ទស្សនកិច្ចសិក្សាក្នុងប្រទេស និងក្រៅប្រទេសសំរាប់មន្ត្រីរាជការ ។
- ផ្តល់ការលើកទឹកចិត្តដល់ប្រជាពលរដ្ឋដែលគ្រប់គ្រង និងការពារជីវៈចំរុះបានល្អ ។
- យុទ្ធនាការបង្កើនការយល់ដឹងអំពីច្បាប់បរិស្ថាន ។
- ត្រួតពិនិត្យឡើងវិញ និងបំពេញបន្ថែមអំពីតម្រូវការវាយតំលៃហេតុប៉ះពាល់បរិស្ថាននៅក្នុងក្រសួងបរិស្ថាន ដើម្បីធានានូវភាពពេញលេញ និងភាពជាក់លាក់ សំរាប់ពិចារណាអនុវត្តជំរើសបច្ចេកវិទ្យា និងវិធីសាស្ត្រសមស្របនឹងគោលការណ៍បរិស្ថាន (សំរាប់គំរោងថ្មីៗ ត្រូវបញ្ជាក់ឱ្យច្បាស់លាស់តាមលក្ខណៈបច្ចេកទេស និងវិទ្យាសាស្ត្រអំពីប្រភេទបច្ចេកវិទ្យាប្រើប្រាស់ វត្ថុធាតុដើមជាក់លាក់ដែលត្រូវប្រើប្រាស់ ប្រភេទ និងបរិមាណថាមពល ព្រមទាំងបរិមាណ និងសមាសភាពសំណល់ និងឧស្ម័នបញ្ចេញចោល) ។
- ពង្រឹងតំរូវការឱ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានជាមុន និងក្នុងពេលនៃការបង្កើត និងការប្រតិបត្តិគំរោង ឬសេវាកម្ម ។
- តាក់តែងគោលការណ៍ណែនាំបរិស្ថានតាមផ្នែកនីមួយៗ សំរាប់គំរោងអភិវឌ្ឍន៍ ជាពិសេសនៅក្នុងតំបន់ការពារធម្មជាតិ និងតំបន់ជនបទទូទៅ ។

សកម្មភាពជាអាទិភាព (ស្ថាប័នសំរបសំរួល និងចូលរួមអនុវត្ត)

១៦.១ កសាង ឬធ្វើវិសោធនកម្មច្បាប់ អនុក្រឹត្យ និងបទបញ្ញត្តិ ពាក់ព័ន្ធនឹងជីវៈចំរុះ (ដើម្បីឆ្លើយតបនឹងការគំរាមគំហែងដែលបានកំនត់ឃើញថ្មីៗចំពោះជីវៈចំរុះ ជាពិសេសជីវសុវត្ថិភាព ប្រភេទប្រឈមគ្រោះថ្នាក់ កម្មសិទ្ធិខាងបញ្ញា និងបញ្ជាក់ច្បាស់លាស់ពីតួនាទី និងការទទួលខុសត្រូវរបស់ក្រសួង និងស្ថាប័ន ។ល។ (ក្រ.បស្ថ កសក និង ពណក) ។

១៦.២ គំរោងកសាងសមត្ថភាពស្ថាប័ន ស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន (ក្រ.បស្ថ និង កសក) ។

១៦.៣ យុទ្ធនាការជាតិបង្កើនការយល់ដឹងអំពីច្បាប់បរិស្ថាន (ក្រ.បស្ថ និង កសក) ។

១៦.៤ ការអនុវត្តន៍បន្តនូវកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជិតខាង ក្នុងគំរោង ឬកម្មវិធីរួម សំដៅការពារបរិស្ថាន និង អភិរក្សធនធានធម្មជាតិរួម (ក្រ.បស្ថ និង កសក) ។

# ប្រធានបទទី ១៧ : គុណភាពនៃការរស់នៅ និងការកាត់បន្ថយភាពក្រីក្រ

## បរិបទ

ការសិក្សាអង្កេតសេដ្ឋកិច្ចសង្គមក្នុងប្រទេសកម្ពុជានៅឆ្នាំ ១៩៩៧ បានបញ្ជាក់ថា ៣៦% នៃចំនួនប្រជាជនកម្ពុជា រស់នៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រ ដែលផ្អែកលើមូលដ្ឋាននៃតំរូវការអាហារអប្បបរមា ២.១០០ កាឡូរីសំរាប់មនុស្សម្នាក់ៗ ក្នុង ១ ថ្ងៃ ។ ការសិក្សាអង្កេតនេះក៏បានបញ្ជាក់ដែរថា សន្ទស្សន៍ភាពក្រីក្រមាន ១១% នៅទីក្រុងភ្នំពេញ ៣០% នៅទីប្រជុំជនផ្សេងៗទៀត និង ៤០% នៅតាមជនបទ ។ ជិត ៩០% នៃប្រជាជនក្រីក្រ គឺជាកសិករដែលរស់នៅតំបន់ជនបទ ។ រាជរដ្ឋាភិបាលបានយល់យ៉ាងច្បាស់អំពីភាពក្រីក្រធ្ងន់ធ្ងរ ដែលមានជាទូទៅនៅក្នុងប្រទេស ហើយបានចាត់ទុកការកាត់បន្ថយភាពក្រីក្រ និងការលើកកំពស់ជីវភាពប្រជាជន ថាជាអាទិភាពចំបង ។

នៅក្នុងប្រទេសកម្ពុជា ប្រជាជនភាគច្រើនពឹងពាក់អាស្រ័យលើផលិតផលកសិកម្ម ជលផល និងព្រៃឈើ ជាប្រភពចំបងសំរាប់ជីវភាព ដោយមានកសិករភាគច្រើននៅមូលដ្ឋានពឹងផ្អែកលើរបរកសិកម្មតូចតាច និងការរកផលពីព្រៃ ដើម្បីចិញ្ចឹមជីវិត ។ ជាមធ្យម គ្រួសារនៅជនបទទទួលម្ហូបអាហារ និងរកប្រាក់ចំណូល តាមរយៈសកម្មភាពចំរុះ ដូចជា ការដាំដុះ ការបរបាញ់សត្វ ការនេសាទត្រី ការកាប់ឈើធ្វើជាអុស ធ្យូង និងអនុផលព្រៃឈើផ្សេងៗទៀត ។ ប្រភពចំណូល ផ្សេងទៀតសំរាប់បង្គ្រប់ក្នុងជីវភាព គឺការចិញ្ចឹមសត្វ ការកែច្នៃបឋមនូវផលិតផលកសិកម្ម វុក្ខកម្ម និងជលផល របរមិនទៀងទាត់ផ្សេងៗ និងការលក់ដូរ ។ គេបានប៉ាន់ប្រមាណថា នៅឆ្នាំ ១៩៩៩ ផលិតកម្មដំណាំ បសុសត្វ ជលផល និងវុក្ខកម្ម មានសរុបប្រមាណ ៤៤.១% នៃផលិតផលក្នុងស្រុកសរុបរបស់ប្រទេសកម្ពុជា ។

ទោះបីជាមានការប្រឹងប្រែងជាបន្តបន្ទាប់របស់រាជរដ្ឋាភិបាល ក្នុងការអភិរក្ស និងកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិក្តី ក៏ធនធានធម្មជាតិនៅតែរងការបំផ្លិចបំផ្លាញ និងខូចខាតយ៉ាងធ្ងន់ធ្ងរ ។ ការកាប់បំផ្លាញព្រៃឈើទ្រង់ទ្រាយធំ និងការដកហូតយកផលពីព្រៃដោយខុសច្បាប់ នៅក្នុងអំឡុងពេល ៣០ ឆ្នាំកន្លងមក បានធ្វើឱ្យគំរបព្រៃឈើ ថយចុះពីប្រមាណ ៧០% មកតិចជាង ៥០% នៃផ្ទៃដីប្រទេស ។ ការបាត់បង់ព្រៃឈើដ៏ខ្លាំងក្លានេះបានបង្កឱ្យមានបញ្ហាសំណឹកដី និងគ្រោះទឹកជំនន់ញឹកញាប់ដែល នាំឱ្យដីបាត់បង់ជីជាតិ និងខូចផលដំណាំ ។ ក្នុងវិស័យកសិកម្ម ការប្រើប្រាស់មិនសមស្របនៃថ្នាំកំចាត់សត្វចង្រៃធ្វើឱ្យមានការបំពុលទឹក និងទីជំរកត្រី ព្រមទាំងរេចរឹលធនធានក្នុងទឹកផ្សេងទៀត ។ ការធ្វើអាជីវកម្មសត្វព្រៃហួសកំរិត ធ្វើឱ្យប្រភពម្ហូបអាហារដ៏មានតំលៃស្ទើរតែផុតពូជ រួមទាំង សត្វព្រៃ និងរុក្ខជាតិជាច្រើនប្រភេទ ។ ការសាងសង់ទំនប់ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតសំរាប់គ្រប់គ្រងទឹក គឺជាការគំរាមកំហែងជាប្រចាំចំពោះភាពគង់វង្សនៃជំរកមច្ឆាជាតិ ។ ការបំពុលបរិស្ថានពីឧស្សាហកម្ម និងទីក្រុង កំពុងគំរាមកំហែងដល់គុណភាពនៃការរស់នៅរបស់ប្រជាជន ។

ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះជាតិនេះ បង្ហាញយ៉ាងច្បាស់អំពីតំរូវការនៃការធ្វើផែនការ និងការគ្រប់គ្រងធនធានជីវៈចំរុះឱ្យបានប្រសើរជាងបច្ចុប្បន្ន ដើម្បីកែលំអលក្ខខណ្ឌនៃការរស់នៅ និងចូលរួមកាត់បន្ថយភាពក្រីក្រ ។ គេត្រូវចាត់ទុកសកម្មភាពជាអាទិភាពសំដៅបង្កើនសមត្ថភាពប្រជាជននៅជនបទ ក្នុងកិច្ចការពារ និងការប្រើប្រាស់ធនធានធម្មជាតិ ដោយនិរន្តរភាព ថាជាការរួមវិភាគទានដ៏សំខាន់ ក្នុងការកាត់បន្ថយភាពក្រីក្រ ។

### បញ្ហាចំបង

- ភាពក្រីក្រ និងការគាំទ្រនៅមានកំរិតទាបដល់ជំរើសផ្សេងទៀតសំរាប់មុខរបរប្រជាជនតាមជនបទ ។
- ការប្រមូលផលធនធានចំបងៗសំរាប់ទ្រទ្រង់ជីវភាពគ្រួសារមិនបានអនុវត្តតាមគោលការណ៍និរន្តរភាព ។
- ការបំផ្លាញទីជំរក ដែលជាប្រភពម្ហូបអាហារ និងសំភារៈប្រើប្រាស់ ។

### គោលដៅ

ធានាឱ្យមានការចែករំលែកដោយសមធម៌នូវផលប្រយោជន៍បានពីកិច្ចការពារ និងការប្រើប្រាស់ធនធានជីវៈចំរុះដោយនិរន្តរភាព ។

### គោលបំណងជាយុទ្ធសាស្ត្រ (*សន្ទស្សន៍បង្ហាញ*)

១៧.១ កាត់បន្ថយភាពក្រីក្រក្នុងសហគមន៍ជនបទ តាមរយៈកម្មវិធីពង្រឹងសមត្ថភាពសហគមន៍សមស្រប ( *អត្រាភាពក្រីក្រក្នុងសហគមន៍ជនបទ*) ។

១៧.២ លើកកំពស់លក្ខខណ្ឌជីវភាព តាមរយៈកម្មវិធីបង្កើនការយល់ដឹងពីបរិស្ថាន ( *ចំនួនកម្មវិធី* ) ។

១៧.៣ បង្កើនប្រាក់ចំណូលគ្រួសារ តាមរយៈការផ្តល់មធ្យោបាយដល់កសិករ សំរាប់បង្កើនផលិតភាពកសិកម្ម ( *ទិន្នផល ពូជ ជី ថ្នាំសម្លាប់សត្វល្អិត កសិកម្មអតិផល ការពង្រីកផ្ទៃដីដាំដុះ*) ។

១៧.៤ លើកកំពស់លក្ខខណ្ឌជីវភាព តាមរយៈកម្មវិធីថែទាំសុខភាព អនាម័យ ទឹកស្អាត និងអនាម័យផ្ទះសំបែង ( *អត្រាមរណៈនៃទារក ឬកុមារអាយុក្រោមអាយុ ៥ ឆ្នាំ អត្រាមរណភាពនៃមាតា អាយុកាល ករណីជំងឺអេដស៍ ផែនការគ្រួសារ*) ។

១៧.៥ ផ្តល់ឱកាសសំរាប់ប្រជាជនក្រីក្រឱ្យមានលទ្ធភាពទទួលការអប់រំជាមូលដ្ឋាន ការអប់រំមនុស្សពេញវ័យ ការអប់រំក្រៅប្រព័ន្ធ ( *ចំនួនសិស្សក្នុងកម្មវិធី* ) ។

១៧.៦ ផ្តល់មធ្យោបាយសេដ្ឋកិច្ច តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធ និងកម្មវិធីឥណទានខ្នាតតូច ( *ប្រវែងផ្លូវដែលបានជួសជុល និងសាងសង់រួច ចំនួនកម្មវិធីឥណទានខ្នាតតូច*) ។

### ជំរើសនានា

- បង្កើនប្រសិទ្ធិភាពក្នុងផលិតកម្មកសិកម្ម ។
- បង្កើនសមត្ថភាពស្ត្រីនៅជនបទ ផ្នែកបច្ចេកវិទ្យាសមស្រប សំរាប់ធានាសន្តិសុខស្បៀង (កម្មវិធីចំរុះគ្រប់គ្រងជំនាំចង្ក្រានសំចៃអុស ការផលិតជីកំប៉ុស ការគ្រប់គ្រងសួនច្បារ និងសត្វពាហនៈ ។ល។) ។
- បង្កើនលទ្ធភាពប្រើប្រាស់ឥណទានខ្នាតតូចនៅជនបទ ជំរុញស្ថាប័នមីក្រូហិរញ្ញវត្ថុ ដើម្បីឱ្យផ្តល់ឥណទានដល់ជនបទសំរាប់កសិកម្ម និងសហគ្រាសខ្នាតតូច ។
- កាត់បន្ថយ និងលុបបំបាត់ជាបណ្តើរៗ នូវការធ្វើអាជីវកម្មព្រៃសម្បទាន ។

- យុទ្ធនាការបង្កើនការយល់ដឹងអំពីបញ្ហាបរិស្ថានក្នុងសហគមន៍ជនបទ ។
- បង្កើតតំបន់គំរោងបង្ហាញសំរាប់ការពារ គ្រប់គ្រង និងប្រើប្រាស់ជីវៈចំរុះដោយនិរន្តរភាព ។
- កម្មវិធីអប់រំ និងបង្រៀនមនុស្សពេញវ័យ ។
- កម្មវិធីអប់រំសុខភាព ( ផែនការគ្រួសារ ជំងឺអេដស៍ ។ល។) ។
- ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន ។
- ធ្វើអត្តសញ្ញាណ និងជំរុញការប្រើប្រាស់បទពិសោធន៍ល្អៗ ។

សកម្មភាពជាអាទិភាព (ស្ថាប័នសំរបសំរួល និងចូលរួមអនុវត្ត )

១៧.១ កម្មវិធីគ្រប់គ្រងធនធានធម្មជាតិដោយផ្អែកលើសហគមន៍ (ក្នុងផ្នែកកសិកម្ម រុក្ខកម្ម ជលផល តំបន់ការពារធម្មជាតិ ការប្រើប្រាស់ដី ។ល។) (ក្រ.កសក បស្ថ អជប រជនស និង កនអយ) (ដោយរួមទាំងការបង្កើនសមត្ថភាពស្ត្រី និង កុមារ) ។

១៧.២ កម្មវិធីបង្កើនការយល់ដឹងបរិស្ថាននៅជនបទ ( ក្រ.បស្ថ កសក អជប រជនស) ។

១៧.៣ កម្មវិធីសិក្សាតាមដាន និងវិភាគភាពក្រីក្រ ( កអសក និង ក្រ.ផក) ។

១៧.៤ ការកសាងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ( កអសក និង ក្រ.សកហ) ។

១៧.៥ ការវាយតំលៃភាពក្រីក្រដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ ( កអសក និង ក្រ.ផក) ។